ណាវ៉ាន់ី



ប្រែសំរួលដោយ

ចន្ទ បូផល

(អតីតកំពង់ចក្លងចាំងស្ពៃខ្ពស់)

បណ្ណាគារឆ្នាំ



ក្រុងភ្នំពេញ៖ តួសំណប់ព្រះករុណាព្រះស៊ីសុវត្ថិព្រះចៅក្រុងកម្ពុជា

រឿង **«សារ៉ាម៉ានី»** និពន្ធដោយជនជាតិបារាំង ឈ្មោះ "រ៉ឺឡង់ ម៉ីយែរ" ចាងហ្វាងវិចិត្រសិល្បៈប្រចាំប្រទេសកម្ពុជា កាលជំនាន់ប្រទេសយើង ស្ថិតនៅក្រោមអាណាព្យាបាលបារាំងនៅឡើយ ដោយដាក់ចំណងជើងថា «SARAMANI, DANSEUSE KHMERE» បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩១៩។ "រ៉ឺឡង់ ម៉ីយែរ" ធ្លាប់រស់នៅក្នុងប្រទេសយើងអស់ពេលដ៏យូរ ធ្លាប់ចេញ-ចូលវាំងស្តេចខ្មែរជាញឹកញាប់ ទើបអាច ស្គាល់ និង ដឹង ជីវភាពស្តេចបានជាក់លាក់ល្អយ៉ាងនេះ។ សោតឯដំណើររឿង ខ្ញុំបានសាកសួរចាស់ទុំច្រើននាក់ ដែលធ្លាប់រស់នៅក្នុងវាំង ឃើញថា សុទ្ធសឹងជារឿងពិត រហូតដល់តួអង្គក្នុងរឿង ក៏សុទ្ធជាមនុស្សដែលធ្លាប់បានរស់នៅកាលជំនាន់នោះមែន។ ...។

ការផ្សាយរបស់ទស្សនាវដ្តីអង្គរវត្ត ◆ បោះពុម្ពផ្សាយដោយបណ្ណាគារអង្គរ
ដំកល់ទុកនៅបណ្ណាល័យជាតិបារាំងក្រុងប៉ារីស និង នៅបណ្ណាល័យខ្មែរក្រុងភ្នំពេញ

ISBN 10 : 99950-59-03-7
ISBN 13 : 978-99950-59-03-3

និពន្ធដោយ
រ៉ូឡង់ ម៉ាយរ

គ.ស. ១៩៧១
ព.ស. ២៥១៥
រក្សាសិទ្ធិ

ប្រែសម្រួលដោយ
ចន្ទ ប្ញវណ



រឿង តាយ៉ាង

ក្បួនតាំងផ្នែ

កំណត់ ការបោះពុម្ព

សារ៉ាម៉ានី ជាប្រលោមលោកនិពន្ធដោយ *Roland MEYER* ជាភាសាបារាំង *"SARAMANI, DANSEUSE KHMÈRE"* បោះពុម្ពផ្សាយនៅ ភ្នំពេញ នាឆ្នាំ ១៩១៩ ។ **លោក រ៉ូឡង់ ម៉ីយែរ** ជាចាងហ្វាងវិចិត្រសិល្បៈ ប្រចាំប្រទេសកម្ពុជា ធ្វើការនៅស្រុកខ្មែរ ឆ្នាប់ ចេញ ចូល រាំងស្តេចខ្មែរ និង បានរស់នៅយ៉ាងយូរ នៅស្រុកខ្មែរ ។ នេះជាកត្តាដ៏សំខាន់ អនុញ្ញាតឲ្យលោកនិពន្ធសៀវភៅនេះឡើង ប្រកបដោយខ្លឹមសារដ៏ល្អ រៀបរាប់ពីជីវភាពព្រះរាជវង្ស នៃ ព្រះមហាក្សត្រខ្មែរ នៅក្នុងរាំង ពីជីវភាពរាស្ត្រខ្មែរ ពីសង្គមខ្មែរនៅសម័យនោះ ពីចំណាប់អារម្មណ៍ នៃ **សារ៉ាម៉ានី** នារីខ្មែរសាមញ្ញម្នាក់ ដែលបានធ្វើដំណើរតាមកប៉ាល់ទឹក ឆ្លងកាត់មហាសាគរ ច្រើនថ្ងៃ ច្រើនយប់ មុននឹងបានមកដល់ និង ស្នាក់អាស្រ័យមួយរយៈពេលដ៏ខ្លី នៅស្រុកបារាំង ។

សៀវភៅនេះ ជាកញ្ចក់មួយ ដែលជនជាតិបារាំងម្នាក់ ហ៊ាននិយាយពីសង្គមខ្មែរ ក្នុងរជ្ជកាល **ព្រះបាទ សីសុវត្ថិ** (១៩០៤ - ១៩២៧) ក្នុងរយៈពេលដែលប្រទេសខ្មែរយើង កំពុងស្ថិតនៅក្រោមអាណាព្យាបាលបារាំង នៅឡើយ ។

ដើម្បីសង្កត់ន័យទៅលើខ្លឹមសារ នៃ សៀវភៅនេះ ដែល **អ្នកស្រី ចន្ទ បូផល** បានបកប្រែជាភាសាខ្មែរដ៏ល្អ និង បានបោះពុម្ពផ្សាយនៅ ភ្នំពេញ ពីឆ្នាំ ១៩៧១ **ឧស្សាហដ្ឋី អង្គរវត្ត** បានផ្សាយឡើងវិញនៅ ប៉ារីស នៅឆ្នាំ ១៩៩៦ និង រៀបចំបោះពុម្ពជាសៀវភៅផ្សាយនៅឆ្នាំនេះ ដោយមានដាក់បញ្ចូលរូបថតស្រុកខ្មែរមួយចំនួន ថតនៅរជ្ជកាល នៃ ព្រះមហាក្សត្រខ្មែរ **ព្រះបាទ នរោត្តម** និង **ព្រះបាទ សីសុវត្ថិ** ។ គឺ សៀវភៅនេះតែមួយគត់ ដែល **សម្តេច នរោត្តម សីហនុ** បានយកទៅតាមព្រះអង្គ ពេលដែល ព្រះអង្គ បានការអនុញ្ញាត ពី **ប៉ុល ពត** ឲ្យ ព្រះអង្គ យាងចេញ ពីក្រុងភ្នំពេញ ទៅក្រុងប៉េកាំង នៅ ថ្ងៃទី ៦ មករា ១៩៧៩ ដើម្បីទៅការពារ អាសនៈ **"កម្ពុជា ប្រជាធិបតេយ្យ"** នៅ អង្គការសហប្រជាជាតិ ពេលដែលទ័ពយួនវាយលុក និង កាន់កាប់ កម្ពុជា មួយរយៈពេលនោះ ។ ការបោះពុម្ពនៅប៉ារីសនេះ កើតឡើងបានដោយការខ្នះខ្នែងរបស់ **លោក ជិន ប៊ុន ហោច** ជាអ្នកបង្កើតតួអក្សរខ្មែរផ្ចាល់តែម្តង ព្រមជាមួយការ រៀបចំទំព័រ ខំសំអិតសំអាង ផ្តល់គុណភាពដ៏ល្អដល់សៀវភៅនេះឡើង ។

បោះពុម្ពផ្សាយនៅ ខែ កក្កដា គ.ស. ២០០០ ព.ស. ២៥៤៤ ដោយ **ឧស្សាហដ្ឋី អង្គរវត្ត**

ANGKOR BOOK SHOP
#143Eo, rue Khémarak Phoumin (St.130), Phsar Chas, Phnom Penh
Angkor Vat, angkorvat1@aol.com
ISBN: 2-9524557-9-1 ISSN : 1162-1660

3 3090 02120 2165



ព្រះបាទនរោត្តម ថតនៅឆ្នាំ១៨៦៣



ព្រះបាទនរោត្តមនិងព្រះរាជបុត្រច័ន្ទលេខា



ព្រះបាទស៊ីសុវត្ថិពេលអភិសេកត្រងរាជ្យនៅឆ្នាំ១៩០៦



បូជនីយដ្ឋាននៅវត្តភ្នំក្រុងភ្នំពេញ

ការរំលឹកសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៧




ព្រះបាទស៊ីសុវត្ថិទ្រង់ត្រៀងជាយោធា



ព្រះបាទស៊ីសុវត្ថិ ថតនៅប៉ារីសខែមិថុនាឆ្នាំ១៩០៦





ព្រះអង្គម្ចាស់មុនីវង្សយាងមកប៉ារីសបានជួបព្រឹទ្ធសាលាយោធា Saint Maixen

អ្នកទី២ខាងស្តាំគឺព្រះអង្គម្ចាស់សុភាម្រឹត



ស្ដេច្រះបាទនរោត្តម



អ្នកបកប្រែភាសាខ្មែរ-បារាំង



ស្ត្រីខ្មែរមកលេងបុណ្យអុំទូក



ស្ត្រីស្ដេច្រះបាទស៊ីសុវត្ថិ៦នាក់

សាលារៀន...ឆាំង
ព្រះវិហារស្ថិតនៅផ្នែកខាងក្រោយគឺព្រះវិហារ ព្រះកែវមរកត



Ecole Franco - Khmère
au fond, la Pagode d'Argent

កំពង់ផែភ្នំពេញ




Port de Phnom Penh

បន្ទប់គេយ និង ផ្ទះគេ
ដ៏តាំងបង្ហូរ ខាងកើតទន្លេភ្នំ



បន្ទប់គេយ និង ផ្ទះគេ





Hôtel du Résident Supérieur et les musiciens

សួនច្បារនៅទន្លេភ្នំ



Jardin du Phnom

ទន្លេភ្នំ (មើលពីស្ពាននាគ)




Le Phnom, vu du pont des Nagas

ស្ពាន FABRE ឆ្លងកាត់ព្រែកកោងកាយ...មើលពីខ្លោងទ្វារ
ផ្ទៃរដៀវក្រោយមានគុម្ព និងប្រាំមួយកោតុលិក




Pont Fabre, sur prék Pongpeay, vu du bored du Mékong
au fond, village catholique et son égglise

គីឡែ VERNEBILLE
នៅផ្នែកបន្តិចគឺស្ពាននាគ



ស្ពានដែលឆ្លងនៅផ្ទៃរមាស់ លើផ្នែកទន្លេកញ្ជ្រុង
នៅឯខាង គឺស្ពាននាគ និងដំបារគោតុលិក



tral (actuel Phsar Chas)
Nagas et la maison des mines

ស្ពាន FABRE
នៅផ្នែកបន្តិចមានប្រាំមួយកោតុលិក



Pont Fabre
au loin. Péglise catholique

បុព្វកថា

ក្រោយពីបានចុះផ្សាយ ចប់សព្វគ្រប់តាមទំព័រ នៃ សារពត៌មានរដ្ឋ *«ប្រយោជន៍ខ្មែរ»* រៀងរាល់ថ្ងៃ ចាប់តាំងពីលេខ ១៥៩ ចេញថ្ងៃទី ១៥ តុលា ១៩៧០ រហូតដល់លេខ ២៥១ ចេញថ្ងៃទី ២២ មករា ១៩៧១ ខ្ញុំក៏បានរៀបចំចងក្រងរឿង **«សារ៉ាម៉ានី»** នេះ ជាសៀវភៅឡើង ដើម្បីជាកិច្ចគោរពតាមសំណូមពរ នៃ អស់លោក-មិត្តអ្នកអាន ជាច្រើន ដែលបានយកចិត្តទុកដាក់អានរឿងនេះជាប់រហូតមក ហើយបានផ្ញើលិខិតមកសុំឲ្យខ្ញុំរៀបចំបោះពុម្ពផ្សាយជាសៀវភៅ ដើម្បីស្រួលរក្សាទុក ។

រឿង **«សារ៉ាម៉ានី»** និពន្ធដោយជនជាតិបារាំង ឈ្មោះ "រ៉ូឡង់ ម៉ីយែរ" ចាងហ្វាងវិចិត្រសិល្បៈប្រចាំប្រទេសកម្ពុជា កាលជំនាន់ប្រទេសយើង ស្ថិតនៅក្រោមអាណាព្យាបាលបារាំងនៅឡើយ ដោយដាក់ចំណងជើងថា «SARAMANI, DANSEUSE KHMERE» បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩១៩ ។ "រ៉ូឡង់ ម៉ីយែរ" ធ្លាប់រស់នៅក្នុងប្រទេសយើងអស់ពេលដ៏យូរ ធ្លាប់ចេញ-ចូលវាំងស្តេចខ្មែរជាញឹកញាប់ ទើបអាច ស្គាល់ និង ដឹង ជីវភាពស្តេចបានជាក់លាក់ល្អយ៉ាងនេះ ។ សោតងដំណើររឿង ខ្ញុំបានសាកសួរចាស់ទុំច្រើននាក់ ដែលធ្លាប់រស់នៅក្នុងវាំង ឃើញថា សុទ្ធសឹងជារឿងពិត រហូតដល់តួអង្គក្នុងរឿង ក៏សុទ្ធជាមនុស្សដែលធ្លាប់បានរស់នៅកាលជំនាន់នោះមែន ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមជំរាបបញ្ជាក់ជាថ្មីម្តងទៀតថា ក្នុងការប្រែសំរួលពីភាសាបារាំងមកជាភាសាជាតិយើង តែងតែមានការឆ្នៃ ពាក្យ-ពេចន៍ ឃ្លា ប្រយោគ ខ្លះជាធម្មតា ប៉ុន្តែទោះជាយ៉ាងណា ក៏ខ្ញុំឥតមានថែមថយសាច់រឿង ឬ ពន្លើសពាក្យសំដី ដើម្បីញុំាងសាច់រឿងឲ្យឃើញសម្បើមនោះដែរ ។

ចន្ទ ឫដ្ឋលី

ភ្លាមពីអន្ទងលាន់ឮឡើង ដោយមានស្នូរពីអន្ទងទៀតឮខ្លាំងជាងមុនបន្តិច បន្តិតាមក្រោយ... ស្ងាត់មួយរយៈ ហើយបន្ទាប់មកសម្លេងភ្លេងពិណពាទ្យដ៏សែនលន្ទង់លន្ទោច ប្រៀបបាន សម្លេងទិព្វ រសាត់ចេញពីភ្នំឯតុមុខមកបបោសអង្អែលសង្កាត់កំពង់ផែទាំងមូល ឲ្យដេកលង់លក់ស្ងាត់ឈឹង កណ្តាលរាត្រីដ៏ភ្លឺត្រចះត្រចង់ ។

សារ៉ាម៉ានីអង្គុយលើត្រែងាងនួន កំពុងចាក់ជីវអារម្មណ៍យ៉ាងស្ទៀមស្ងាត់ក្បែរចង្កៀងប្រេងកាត ។ ទាងងើបមុខឡើង ត្រចៀកប្រុងស្តាប់ ទឹកមុខញញឹម ហើយទាងម្លោះដៃទាំងពីរដែលកាន់ប្រដាប់ចាក់នោះទៅលើជង្គង់ ។ នៅពេលឮសម្លេងភ្លេងពិណពាទ្យ អនុស្សាវរីយ៍ នៃ ជីវិតរ៉ាវពីអតីតកាលទាំងប៉ុន្មាន ក៏លេចឡើងយ៉ាងច្បាស់នៅចំពោះមុខទាង ញុាំងចិត្តទាងឲ្យប្រែជាស្រពោនភ្នាមមួយរំពេច ។ ទាងពោលឡើងដោយសម្លេងញ័រៗ :

~ ពួកណ្តោនមកប្រជុំគ្នានៅលើចាកហើយ... ខ្ញុំស្រណោះកាលខ្ញុំនៅភំណាស់ !

កម្លោះ ក៏ដូចជាភ្ញាក់បន្តិចដែរ នៅពេលតន្ត្រីចាប់ប្រគុំឡើង ។ គេដាក់ស្លាបប៉ាកកាចុះ តៀសសៀវភៅដាក់នៅលើតុ ដែលដាកន្លែងធ្វើការ និង ដាកន្លែង នៃ ពន្ធីក្តីសង្ឃឹមតែមួយគត់របស់គេចេញពីមុខបន្តិច... ហើយចោលក្រសែភ្នែកសំលេងក្បាលកិរិយា បាញ់ឆ្ពោះទៅក្បែរថតព្យួរជាប់នឹងជញ្ជាំងស្លឹក ដែលជារូបសារ៉ាម៉ានី កាលទាងទើបនឹងមានវ័យដប់ប្លន់ឆ្នាំនៅឡើយ ស្លៀកពាក់ជាអ្នករាំណ្តោនហួង ពាក់មកុដមាសស្អាតប្រិមប្រិយ៍ ដូចពេលអប្សរក្នុងរឿងព្រេងនិទាន ។

៨ឆ្នាំកន្លងផុតមកហើយ ចាប់តាំងពីពេលដែលសារ៉ាម៉ានី ចាកចេញពីវាំងមក បន្ទុកជាស្ត្រីមេផ្ទះបានធ្វើឲ្យចរិតទាងប្រែប្រួលប្លែកពីមុនស្ទើរតែទាំងអស់ ។

កម្លោះ និង សារ៉ាម៉ានី *ភូស្វាមី-ភរិយាវ័យក្មេងនេះ* បានមកសង់ផ្ទះនៅជិតវាំងហួង ក្នុងសង្កាត់កំពង់ផែ ដែលជាក្តីដឹណែលដ៏មានតម្លៃ រកអ្វីមកប្រៀបឲ្យស្មើពុំបាន នៃ ភូមិខ្មែរបុរាណ ហើយគេទាំងពីរទាក់ អង្គុយធ្វើការទល់មុខគ្នាក្បែរចង្កៀងប្រេងកាតនៅក្នុងផ្ទះស្លឹកតូចច្រឡឹងនេះ ដោយមានលាក់ទុកក្នុងផ្ទះគំនិត នូវរឿងដ៏មានតម្លៃបំផុត ពុំងាយនឹងមានទណាបានដឹងឡើយ គឺរឿងពិត នៃ បុគ្គលម្នាក់មានហ៊ានៈជាស្តេចគ្រប់គ្រងប្រទេសជាតិ ហើយដែលត្រូវបានអ្នកដទៃគោរពស្មើព្រះអាទិទេព ។

ពេលនេះ ជាខែភទ្របទ... ពិធីបុណ្យចំរើនព្រះជន្មស្តេច បានទាក់ទាញទាម៉ឺនយ៉ាងច្រើនកុះករ មកពីគ្រប់ ខេត្ត-ខ័ណ្ឌ ឲ្យមកជួបជុំគ្នាក្នុងរាជធានី ដើម្បីធីកទឹកសម្បថ និង ចូលរួមក្នុងពិធីបុណ្យតាំងតុ ។

ល្ងាចនេះ មានរាំណ្តោនហួងនៅខាងក្រៅវាំង ជូនសាធារណជនទស្សនាកំសាន្តផង ។

កម្លោះ បើកចំហសៀវភៅត្រង់ទំព័រមួយ ដែលសរសេរមិនទាន់ចប់នៅឡើយ ហើយបណ្តែតអារម្មណ៍ឲ្យសាត់អណ្តែតទៅឆ្ងាយ... ឆ្ងាយឥតព្រំដែនក្នុងពិភព នៃ ក្តីស្រមៃដ៏ធំល្វឹងល្វើយ។

~ លោក! (សាវ៉ាម៉ាឌី ខុទាន់តិចៗ ខម្លាយបរិយាកាសស្ងប់ស្ងាត់ ដោយសណ្ឋកដៃទង់លួនទៅលើតុ) លោកគិតពីរឿងអីហ្នឹង? លោកនឹកទៅដល់រឿងរ៉ាវចាស់ដូចខ្ញុំដែរឬអ្វី? លោកញញឹមស្តួតអញ្ចឹង បានសេចក្តីថា លោកស្រឡាញ់ខ្ញុំមែនទែន ឬមួយក៏ លោករឭកទៅស្រុកកំណើតរបស់លោក? ខ្ញុំឃើញតែលោកគិត, ឃើញតែលោកសរសេរ! លោកគួសក្រវ៉ែមក្រវាំមដូចជើងក្តាម ក្នុងសៀវភៅធំនេះរាប់ឆ្នាំហើយ តើលោកធ្វើការដើម្បីនរណា? លោកសម្លឹងមើលទៅឆ្ងាយលន្លង់លន្លោចអញ្ចឹង ខ្ញុំអត់យល់អីសោះទេ... យីអើ! កាលណាទើបលោកបង្រៀនឲ្យខ្ញុំចេះភាសាលោក គ្រាន់តែនឹងខ្ញុំអាចអង្គុយកំដរមើលលោកធ្វើការពេលយប់បានផង?

សាវ៉ាម៉ាឌីអង្គិលខ្លួនទៅចុងព្រែ ទាងយកដៃគាញស្បែរស្តើងដែលគ្របដណ្តប់លើខ្លួនចេញ បង្ហាញទូរគល់សុដនសរលោងផ្លូចម្នាងសិលា ប្រកបទៅដោយសរសៃខៀវលេចឡើងយ៉ាងច្បាស់។ ក្រសែភ្នែកកម្លោះ ប៉ះទង្គិចគ្នានឹងក្រសែភ្នែកទាង ដែលបញ្ចេញរស្មីស្រទន់ជាតំណាង នៃ ទឹកចិត្តស្អាតបរិសុទ្ធ និងសេចក្តីស្នេហាស្មោះត្រង់។ កម្លោះ ដាក់ដៃចុះទៅលើគំនរក្រដាសដោយកាយវិការខ្ជិលច្រអូស ហើយពោលឡើង:

~ ទាង! ទាងមិនចាំបាច់ដឹងថាខ្ញុំសរសេរពីអ្វី, មិនចាំបាច់ជឿភាសាបារាំងទេ។ ភាសានេះជាថ្នាំពុលដ៏សាហាវបំផុតចំពោះស្ត្រីខ្មែរ វានឹងនាំឲ្យទាងស្គាល់ កាយវិការ និង អាកប្បកិរិយាច្រេងច្រេងច្រាំង ដែលទាងមិនធ្លាប់ដឹង វានឹងនាំឲ្យទាងកើតគំនិត និង ពុតត្បុតអាក្រក់ ដែលភាសាទាងពុំអាចថ្លែងចេញជាពាក្យសំដីបានទេ។ កម្រមានស្ត្រីខ្មែរណាដែលអាចទប់ទល់នឹងថ្នាំពុលនេះបានណាស់!... ខ្ញុំសរសេរដើម្បីអ្វី? ទាង! ខ្ញុំគិតដើម្បីអ្វី? ខ្ញុំបានន័យយប្រាប់ទាងច្រើនដងហើយតើ! ខ្ញុំបានន័យយប្រាប់ទាងថា ខ្ញុំចង់សរសេរបៀបាប់ ពីសម្រស់, ពីសីលធម៌ នៃ ព្រួជសាសន៍របស់ទាង ដើម្បីបង្ហាញឲ្យពិភពលោកឃើញច្បាស់នូវតម្លៃព្រួជខ្មែរដ៏ចាស់ឡូរអង្វែងណាស់មកហើយ, ហើយនរណាអាចដឹងបានទាង? ថ្ងៃណាមួយ ក្រែងលោវេតាលោកប្រទានរង្វាន់ចំពោះការខំប្រឹងប្រែងរបស់យើង ដោយផ្តល់ជាកិត្តិយស និង ជាទ្រព្យសម្បត្តិ ហើយដល់ពេលនោះ យើងនឹងចាកចេញពីខ្ទមស្លឹក ដើម្បីទៅសង់ផ្ទះក្បឿង សសរឆ្នឹកមួយ នៅមាត់ទន្លេ ដោយមានដាំដើមស្វា និង ដើមឈើដទៃទៀត សម្រាប់ជាម្លប់ត្រជាក់ដល់ពីភូមិយើងផង។

~ ណ្ហើយ! (សាវ៉ាម៉ាឌី ខុទមុខចុះ ដកដង្ហើមធំ) ខ្ញុំមិនចង់បាទ្រព្យសម្បត្តិដែលទាំឲ្យលោកត្រឡប់ទៅស្រុកបារាំងវិញទេ។ ខ្ញុំចង់ឲ្យលោកក្រឡូចសព្វថ្ងៃអញ្ចឹងរហូតទៅ ដើម្បីឲ្យលោកនៅតែស្មោះត្រង់នឹងខ្ញុំ។ ខ្ញុំមិនចង់ឃើញទ្រព្យសម្បត្តិដែលមកធ្វើឲ្យលោកល្អក់ចិត្ត មកបណ្តាច់លោកពីជីវភាពដ៏សុខសាន្តដូចយើងរស់នៅសព្វថ្ងៃ ហើយបែរទៅស្រឡាញ់ស្រីសស្តុសដូចសំប៉ី ទៅរស់នៅក្នុងវិមានដ៏ល្អឆើតឆាយក្នុងប្រទេសរបស់លោកវិញនោះទេ... លោកស្តាប់ខ្ញុំណា! ខ្ញុំចង់និយាយប្រាប់លោកពីទុក្ខវេទនារបស់ខ្ញុំមុនពេលបានមកជួបការជាមួយលោក។ ខ្ញុំចូលចិត្តចង់ឲ្យប្រវត្តិដ៏ខ្លោចផ្សារបស់ខ្ញុំ ស្ថិតនៅគង់វង្សជាទិច្ចសម្រាប់ជាអនុស្សាវរីយ៍ចំពោះខ្លួបលោក កាលណាខ្ញុំស្លាប់ទៅ...។

សាវ៉ាម៉ាឌីឈប់ស្ងៀមមួយសន្ទុះ... សម្លេងតន្ត្រីរសាត់មកតាមកម្លាំងជំនោរពេលរាត្រី បបោសអង្អែលសង្កាត់កំពង់ផែ ឲ្យស្រងេះស្រងោចលន្លង់លន្លោច ប្រៀបបានសម្លេងទិព្វ ហើយអតីតអ្នករបាំយើង យកចិត្តទុកដាក់ស្តាប់បទភ្លេងសម្លេងស្រួយស្រិបនេះ ដែលពីដើមវាជាមេដែកអាចទាញកាយវិការទាង ឲ្យ

ពត់ពេនទន់ភ្លន់ ទៅតាមចង្វាក់ដំណើរទេពអប្សរ ដោយចិត្តរំជើបរំជួលស្ទើរតែទប់ខ្លួនពុំជាប់។

~ លោក! (សាវ៉ាម៉ាឌី ពោលបន្តទៅទៀត) ពេលនេះហាក់ដូចជាមានប្រផ្នូលអ្វីធ្វើឲ្យដឹងថា យើងនឹងព្រាត់គ្នានៅពេលឆាប់ៗខាងមុខនេះហើយ ទើបខ្ញុំចង់និយាយរឿងរ៉ាវទាំងអស់ប្រាប់លោក ដែលជាអ្នកគ្រប់គ្រងតែមួយគត់លើជីវិតខ្ញុំ ជាស្ត្រីកំព្រា ចង់ផឹកកាយបង្ហាញលោកនូវកំណប់អនុស្សាវរីយ៍ នៃ ជីវិតខ្ញុំ ដែលលោកពុំទាន់ដឹងនៅឡើយ...។

ពេលស្តាប់ឮសំដីនេះ កម្លោះភ្ញាក់ព្រើត ហើយស្រមោល នៃ គំនិតរជើរវាយមិនល្អ ក៏ចាប់ត្របសង្កត់លើបេះដូងគេឲ្យតឹងស្ទើរប្រេះភ្លាមមួយរំពេច។ ប៉ុន្តែ សម្លេងភ្លេងពិណពាទ្យលាន់ឡើងយ៉ាងច្បាស់ ក្នុងសភាពស្ងាត់ជ្រងំ នៃ រាត្រីកាល គឺជាសម្លេងទិព្វ អាចរម្ងាប់អស់នូវអារម្មណ៍តានតឹងគ្រប់បែបយ៉ាង ហើយកម្លោះ ប្រមូលបានសេចក្តីក្លាហានបន្តិចឡើងវិញ ខំរក្សាសម្លេងឲ្យនឹងន និយាយតបទៅកិរិយាវិញថា!:

~ អូន និយាយចុះ ខ្ញុំចាំស្តាប់ហើយ!...

សាវ៉ាម៉ាឌី ផ្អែកខ្នងទៅនឹងជញ្ជាំង ហើយចាប់ផ្តើមនិទានរឿងទាង ដូចតទៅនេះ៖

ឧបករណ៍ឯកទេស



Danseuse étoile

កាលនោះ ស្តេចសុវណ្ណកោដ្ឋ[1] ឡើងសោយរាជ្យលើប្រទេសកម្ពុជា បានសែសិបប្តាយឆ្នាំហើយ។

មុនមកនៅភ្នំពេញ ខ្ញុំចាំថា ខ្ញុំធ្លាប់បានរស់នៅលើទូកអស់រយៈពេលដ៏យូរ។ ពុកម៉ែ ហើយនិង ខ្ញុំ យើងធ្វើដំណើរតាមផ្លូវទឹកពីតំបន់មួយទៅតំបន់មួយ គ្មានទីដៅជាក់លាក់ឡើយ។ ពូប៉ុល, ពូម៉ែន, ពូកៅ បងប្អូនជីដូនមួយខ្ញុំពីរនាក់ឈ្មោះ មីប៊ុន និង មីហ៊ុន និង ម្តាយវាឈ្មោះ មីងអ៊ិច ខ្សាហ៍ព្រមដំណើរជាមួយយើងណាស់ ជួនកាលជិះទូកតែមួយ ជាមួយគ្នាទាំងអស់ ជួនកាលគេជិះលើទូកមួយផ្សេងទៀត។

កាលនោះ ខ្ញុំនៅតូចពេក ពុំអាចចាំរឿងរ៉ាវសព្វគ្រប់ទាំងអស់ទេ... ខ្ញុំប្រហែលជាមានអាយុប្រាំពីរឆ្នាំ ដំណាលគ្នានឹងបងប្អូនជីដូនមួយខ្ញុំឈ្មោះ ប៊ុន នោះហើយមើលទៅ។ យើងទាំងពីរនាក់ អង្គុយលេងជាមួយគ្នាលើភ្នាក់ម្រាលទូក ហើយឲ្យតែកើតមានរឿងទាស់ចិត្តបន្តិច ខ្ញុំស្អុះទៅក្រញៀវ ដាច់មុខ ដាច់មាត់ភ្លាមមួយរំពេច ព្រោះខ្ញុំនេះឆ្នាស់រកលេខដាក់គ្មាន តាំងពីតូចមក។

ពុកចែវខាងមុខ ទុកឲ្យម៉ែ ចែវខាងក្រោយ យើងធ្វើដំណើរលក់ផ្លែ ផ្លែឈើស្រស់ និង ថ្នាំជក់ តាមបណ្តោយមាត់ទន្លេ ហើយយើងទិញមកវិញនូវ អង្ករ និង ត្រីងៀត សម្រាប់ទុកជាស្បៀងបរិភោគ...។

ពីមួយឆ្នាំទៅមួយឆ្នាំ ដីច្រាំងភូមិព្រែកថ្មីរបស់យើង បាក់ធ្លាក់ចុះទៅបាតទន្លេទាំងផ្ទាំងៗ ដើមស្វាយដែលខ្ញុំបានដាំផ្ទាល់ដៃ និង ផ្ទះដែលខ្ញុំធ្លាប់រស់នៅជួបជុំគ្រួសារទាំងអស់គ្នា ក៏ទាសសាបសូន្យអស់ទៅសល់នៅតែអនុស្សាវរីយ៍ដ៏មានតម្លៃកាត់ថ្លៃមិនបាន ដែលស្ថិតជាប់ក្នុងអារម្មណ៍ខ្ញុំរហូតទល់ថ្ងៃស្លាប់។

លើផ្ទៃដីដែលជីតាខ្ញុំបោសជ្រះសំអាតរាល់ថ្ងៃ ខ្ញុំលួសមែកឈើតូចៗមកសង់ធ្វើជាងរបាំ សម្រាប់រាំលេងជាមួយពួកម៉ាក ពីព្រោះនេះជាល្បែងដែលខ្ញុំចូលចិត្តជាងគេ។ ក្មេងស្រីៗខ្លះទៀត ចូលចិត្តលេងធ្វើការប្តី-ប្រពន្ធ, លេងបិទពួន ឬ កាត់ធាងចេកមកធ្វើជាសេះរត់បំផាយហុយដីទ្រលោម។ មានតែខ្ញុំម្នាក់ឯងគត់ ដែលស្រឡាញ់របាំ ចូលចិត្តឲ្យមីងខ្ញុំជាត់ម្សៅឲ្យ ហើយរាំឲ្យអ៊ុកពុកម្តាយខ្ញុំមើល។ ពុកញញឹមសម្លឹងមើលខ្ញុំ ហើយនិយាយថា:

~ ចាំពុកយកកូនឯងទៅឲ្យនៅហាត់រាំក្នុងភាំង ក្រែងលោបានធ្វើ លោកឃុន នឹងគេ។

ឮពុកនិយាយអញ្ចឹង ពូម៉ែន និយាយចំអកថា គាត់ទុកឲ្យកូនស្រីគាត់នៅធ្វើការផ្ទះ ត្រាន់តែបានបំរើទឹកក្តៅ ទឹកត្រជាក់ នៅពេលគាត់ចាស់ជរា ប៉ុន្តែពុកបែរជាស្តីឲ្យ ពូម៉ែន ថាជាមនុស្សអាត្មានិយម ហើយថែមទាំងទាយទុកថា ថ្ងៃណាមួយ កូនគាត់នឹងភ្លាយមកជាអ្នកបំរើខ្ញុំមិនខាន។ ឥទៅថ្ងៃក្រោយ ប្អឹងនេះ

[1] សុវណ្ណកោដ្ឋ ជាមរណនាម នៃ ព្រះបាទ អង្គតួម។

មានដំណើរសើងតែដូចពាក្យទំនាយពុកទាំងអស់។

ក្រោយបន្តិចមក យើងចាកចេញពីព្រែកថ្មី ដើម្បីចេញដើរលក់ផ្លែអ៊ីវ៉ាន់ជាថ្មីម្តងទៀតទៅម្តុំទន្លេសាប។ ទូកយើងមានដីក ចេក និង ភោគ ហើយជួលសណ្តោងទៅនឹងកប៉ាល់ចិន ធ្វើដំណើរឆ្ពោះទៅខែត្រកំពង់ឆ្នាំង។ នៅនឹងផែកំពង់ឆ្នាំងនេះ យើងយក ចេក, ភោគ, ផ្លែជាមួយឆ្នាំងដី ដែលពុកគិតថា នឹងយកមកលក់បន្តទៀតបានចំណេញច្រើនណាស់។

ពេលត្រឡប់មកវិញ ខ្យល់ហើយបក់បោកឥតឈប់ឈរ ហើយទៅកន្លែងខ្លះដែលផ្តៃទន្លេរកធំ ទូលាយ ផ្ទួចដៃសមុទ្រនោះ រលកធ្យាចាប់ផ្តើមបោក រុញច្រានទូកទាំងគ្មាយឲ្យរេចុះរេឡើង ប៉ះទង្គិចគ្នាពេញទន្លេ។ ទូកយើងក៏សាត់ចង់ទៅប៉ះនឹងទូកប៉ុកចាយដីកទំនិញមួយដែរ ប៉ុន្តែសំណាងល្អបានម្ចាស់ ទូកធំនោះហៅយើងឲ្យឡើងជិះជាមួយគាត់ទម្រាំស្ងប់ខ្យល់។

ម្ចាស់ទូក ជាអ្នកជំនួញខ្មែរឈ្មោះ ដង្កៅរស់ រកស៊ីជួញឈើដឹកតាមក្បូន ពីស្រុកបរិបូណ៌ និង លង្វែក ទៅលក់ ប៉ុន្តែគាត់មានផ្ទះសម្បែងនៅភៀនស្វាយឯណោះទេ។ គាត់មានភ្ញៀវប្រុសជំទង់មួយ ទើបនឹងបំបួសនេះ ដើម្បីសងគុណនាគពុកម្តាយ។ ដង្កៅរស់ អួតសរសើរពីកូនប្រុសតែមួយរបស់គាត់ខ្លាំងណាស់ ហើយគាត់បានទាំងនិយាយស្តើរលេងស្តើរមែន ស្មើចង់ធ្វើជំនួងជាមួយពុកទៀតផង។

មកដល់ភ្នំពេញ ទូកបែកខ្ញែកគ្នាអស់ យើងក៏លាដង្កៅរស់ បត់ក្បាលទូកទៅឈប់ត្រង់កំពង់វត្តស្វាយពពែ ដើម្បីចូលលេងផ្ទះនាគពុកធំខ្ញុំម្នាក់ឈ្មោះ អ៊ុម ដែលធ្វើជាទាហ៊ីនធំក្នុងភាំង មានងារជាអគ្គមហាសេនា។ ពុកប្រាប់ឲ្យ ម៉ែ និង ខ្ញុំ នៅចាំក្នុងទូក គាត់ឡើងទៅតែម្នាក់ឯង មានយួរកន្ត្រកដាក់ផ្លែឈើពេញទៅជាមួយផង សម្រាប់ជាបណ្ណើ។ ប៉ុន្តែ ខ្ញុំមានគំនិតខ្លួច លួចរត់តាមពីក្រោយគាត់ជាប់ហួត មិនឲ្យគាត់ដឹងខ្លួនឡើយ។

ផ្ទះលោកអគ្គមហាសេនា អ៊ុម ស្ថិតនៅមិនឆ្ងាយប៉ុន្មានពីមាត់ទន្លេ មានរបងថ្មព័ទ្ធជុំវិញ និង សួនច្បារពីមុខផង។ ផ្ទះនោះធ្វើពីឈើ មានឥណ្ឌូចិន មានឥសំយាកចេញជារោងតូចៗច្រើនទៀត និង រោងធំមួយជាបន្ថែមពិសេសសម្រាប់ក្រុមលោនរបស់គាត់ភាំ។ បន្ទាប់ពីក្រុមលោនហួង មានតែក្រុមលោនលោកអគ្គមហាសេនាអ៊ុមនេះហើយ ដែលល្បីល្បាញជាងគេក្នុងស្រុកខ្មែរ។

ពុកដើរឡើងជណ្តើរ ឆ្លងកាត់រនាលទៅអង្គុយចាំត្រង់មាត់ទ្វារបន្ទប់ទទួលភ្ញៀវ។ ខ្ញុំអង្គុយចុះពីក្រោយខ្នងគាត់ ប៉ុន្តែពុកនៅតែមិនដឹងថា ខ្ញុំមកតាមគាត់ដដែល។ លោកអគ្គមហាសេនា អង្គុយលើកៅអីលាបពណ៌មាស មានសាច់ញាតិអ្នកមកពឹងបុណ្យមួយហ្វូងធំ អង្គុយបត់ជើងលើកន្ទេលត្បៀបត្រាពីក្រោយខ្នង។ គ្រាន់តែឃើញផ្ទះធំទូលាយ របៀបរៀបរយ សួនច្បារអ៊ីប៉ុណ្ណឹង ខ្ញុំសប្បាយចិត្តចង់រស់នៅក្នុងទីនេះស្រេចទៅហើយ។ ខ្ញុំអង្គុយបត់ជើងបួនក្រវៀនក្រោយខ្នងពុក លួចសម្លឹងមើលមុខលោកអគ្គមហាសេនាភ្លឹកៗ... គាត់ចាស់កោងខ្នង សក់ស្កូវសក្បុសកាត់ជ្រងខ្លី ស្បែកមុខជ្រីវជ្រួញ ពាក់អាវបំពង់សដៃខ្លី ស្លៀកសារុងសូត្រ។ គាត់និយាយរាក់ទាក់មកកាន់ពុកថា:

~ យីនឯង យកផ្លែឈើអស់ហ្នឹងមកធ្វើអញ្ចឹងហ្អែ? ប្រពន្ធ-កូនឯង សុខសប្បាយជាទេ?... អើ, ហ្នឹងឯងយកកូនមកឲ្យនៅហាត់រាំជាមួយអញឬអី?

- ប្រចាទម្ចាស់, (ពុកឆ្លើយ) កូនខ្ញុំនៅចាំក្នុងទូកឯណោះ... ខ្ញុំមកពិលក់អ៊ីវ៉ាន់ ត្រឡប់ទៅព្រែកថ្មីវិញ ត្រាន់តែធ្វើងចូលមកលេងនឹងព្រះគុណម្ចាស់មួយភ្លែតប៉ុណ្ណឹងទេ។

- ម៉េចអញ្ចឹង? កូនឯងវានៅក្រោយខ្នងនេះឆែ, ឯងមើលទៅមើល៍! (លោកអគ្គមហាសេនា

និយាយខ្លាំងៗ ព្រមទាំងផ្តុំះសំណើចកាច់កកាច់សុរង) ។

ពុកបែរមកក្រោយឃើញខ្ញុំអង្គុយច្រងុក ស្រាប់តែបើកភ្នែកធំៗសម្លក់ត្បែរ ឥតចេញស្តីថាម៉េចទាំងអស់។ សើចអស់ចិត្ត ទើបលោកអគ្គមហាសេនា សួរខ្ញុំ :

~ អើតែ, មេនាងឯងចង់ត្រឡប់ទៅព្រែកថ្មីវិញ ឬក៏ ចង់នៅជាមួយអ៊ុំ, ហ្នាមេនាង ?

~ ខ្ញុំចង់... នៅ... (ខ្ញុំឆ្លើយទាំងអឺមអៀម)

ដើម្បីកុំឲ្យបែក ង៉ុពុក-ម្តាយ លោកអ៊ុំបានឲ្យពុកសង់ផ្ទះតូចមួយនៅបណ្តោះអាសន្ន ក្បែរសួនច្បារ គាត់ ។

លោកអគ្គមហាសេនា គាប់ចិត្តនឹងខ្ញុំជាងគេ គាត់ស្រឡាញ់ខ្ញុំជ្រួចក្បួនបង្កើតអញ្ចឹង ។ គាត់ទិញ សំពត់ខៀន កាត់អាវវៀលភ្លៀកកំណាត់សូត្រ សម្រាប់ឲ្យខ្ញុំស្លៀកពាក់ហាត់រាំរាល់ថ្ងៃ មួយគំនរធំ ។ លោកអ៊ុំ រកឈ្មោះដាក់ឲ្យខ្ញុំ នេះមិនពិរោះ នោះមិនពិរោះ ទីបំផុតក៏ហៅខ្ញុំថា យ៉ែមៗ ជាប់រហូតមក ។ ប៉ុន្តែខ្ញុំ មិនវេរនឹងរឿងរ៉ាវកំប៉ិកកំប៉ុកអស់នេះទេ មួយថ្ងៃៗខ្ញុំគិតតែពីរបេះបោចដំណាំក្នុងសួនច្បារ ឬ សម្ងំពួនទៅ ក្រោមផ្ទះ ទុកឲ្យគេដើរកវិរវ៉ក់ ។ ម្តងនោះ ខ្ញុំធ្វើឲ្យជ្រុះបែកកញ្ចក់ដែលគេតាំងលំអនៅក្នុង បន្ទប់ទទួលភ្ញៀវ ប៉ុន្តែលោកអ៊ុំឥតមានស្តីបន្ទោស ឬ វាយខ្ញុំទេ ។ ខ្ញុំឥតខ្លាចលោកអ៊ុំទាល់តែសោះ គឺខ្ញុំស្រឡាញ់គាត់ទុក ស្មើង៉ុពុក ។ ខ្ញុំសប្បាយចិត្តណាស់ ដែលបានធ្វើជាភ្ងូអ្នកធំ បានស្គាល់ភាពថ្លៃថ្នូរ នៃ ការរស់នៅក្នុងទីក្រុង បានស្លៀកពាក់ សំពត់-អាវល្អៗ បានពាក់មាសពេជ្រស្រោចខ្លួន និង ជាពិសេស បានហាត់រាំយ៉ាងនេះ ។ ខ្ញុំចង់ក្លាយទៅជាលោកឃុន មានរូបសម្បត្តិស្អាតដូចពេកញ្ញា ធ្វើឲ្យប្រុសៗមើលឃើញតែពីចម្ងាយ ហើយចាប់ចិត្តលួចស្រឡាញ់វង្វេងហួចស្មារតីគ្រប់គ្នា ។ គំនិតរវើរវាយបែបនេះ ធ្វើឲ្យខ្ញុំញញឹមខឹកឃើញ សប្បាយតែម្នាក់ឯងដូចមនុស្សឆ្កួត ។

ក្រុមលោកអគ្គមហាសេនា មានគ្រូសៀមបីនាក់ ជាអ្នកបង្ហាត់ និង ជាប្រពន្ធគាត់ទាំងបីនាក់តែម្តង គឺ អ្នកគ្រូជាម, អ្នកគ្រូម៉ាំខ្មៃ និង អ្នកគ្រូយឹម ។ បន្ទាប់មកមាន អ្នកហ្គង, អ្នកចម្រៀង និង ភ្ងូនស្នេង ទាំងក្មេង ទាំងចាស់ សុទ្ធតែស្គាត់ជំនាញដូចៗគ្នាទាំងអស់ ។ ប្លកួមទាំងអស់ ក្រុមនេះមានគ្នាដល់ទៅជាង មួយរយនាក់ ។

អ្នកគ្រូយឹម ជាអ្នកទទួលការៈបង្ហាត់ខ្ញុំ ។ រាល់ព្រឹក ខ្ញុំស្លៀកសំពត់ចងក្បិន ពាក់អាវវៀលភ្លៀក មាន សៀតផ្កាកុលាបមួយទងនៅនឹងត្រចៀក ពាក់កងជើងមាសធំៗ ដើម្បីហាត់រាំតាមបញ្ជាអ្នកគ្រូ ។ អ្នកគ្រូ ពេញចិត្តនឹងខ្ញុំជាភ្ងូសិស្សពេកណាស់ សមបាននឹងថា លោកអ៊ុំស្រឡាញ់ខ្ញុំថ្លូចក្បួនបង្កើតផង គាត់រឹតតែ យកចិត្តទុកដាក់បង្ហាត់ខ្ញុំជាងនរណាទាំងអស់ ។ ប៉ុន្តែ កាលណាខ្ញុំមិនសូវប្រុងប្រយ័ត្នធ្វើតាមគាត់ ឬ ពត់ ដៃជើងមិនបានទន់ភ្ងន់ដូចគាត់ គាត់យកក្រចកចុច ឬ ក្តិចខាល់តែខ្ញុំស្រក់ទឹកភ្នែក យំអណ្តឺតអណ្តក់ភ្លាម មួយរំពេច ។ ជាងប្លង ខ្ញុំត្រូវហាត់ធ្វើឲ្យទន់ ក, ស្មា, សន្លាក់ដៃ, ចង្កេះ, ជង្គង់ និង កជើង ។ ជង្គង់ត្រូវ ពត់ អែនចុះ អែនឡើង ទាល់តែទន់ដូចវល្លិ៍ បណ្តាលឲ្យខ្ញុំអស់កម្លាំងស្ទើរខ្ជប់ខ្ជួលឈរមិនឡើង ។ ជួនកាលខ្ញុំ ត្រូវឈរជើងមួយបន្ទន់ជង្គង់ទៅមុខបន្តិច ជើងមួយទៀតបត់ទៅក្រោយលើកខ្ពស់ ដៃលើកខ្ពស់ហួសដងខ្លួន ថែមទាំងមាន កាន់ដាវ ឬ ផ្កា ដោយពត់កដៃមកក្រោយទាល់តែចុងក្រចកប៉ះនឹងសាច់កំភួនដៃទៀតផង ។ ខ្ញុំសំគាល់ឃើញថា ពីគ្រូមួយ ទៅគ្រូមួយ ក្បាច់របាំតែងមានការខុសគ្នាបន្តិចៗជាទិច្ច គឺម្នាក់ៗចេះតែ ឆ្នៃបន្តែមបន្តយទៅតាមការគិតឃើញរបស់ខ្លួន ។ ខ្ញុំបណ្តោយឲ្យអ្នកគ្រូយឹម កាច់, ពត់ ដៃជើងតាមចិត្ត ប៉ុន្តែ កាលណាគាត់កាច់ឈីខ្លាំងពេកគ្រាំមិនបាន ខ្ញុំក៏ទ្រហោយំងោងឡើង ។ កាលណាហាត់ចប់ម្តងៗ អ្នកគ្រូ ឬ

ម៉ែ តក់ច្របាច់រឹតឲ្យខ្ញុំសព្វដៃជើងខ្លួនប្រាណ ដើម្បីស្ទុះលសាច់ដុំ ។

ពួកយើងជាអស់លោកឃុន ដែលបានហាត់រាំតាំងពីក្មេងអញ្ចឹង យើងពុំបានទុកដាក់ខ្លួនថ្លូចជាស្ត្រី សាមញ្ញធម្មតាទេ ។ ការរស់នៅក្នុងវាំង ហ្វាតជាច់ស្រឡះពីភពខាងក្រៅ បានធ្វើឲ្យយើងផ្ទាស់ប្តូរ ចិត្តគំនិត តាំងខ្លួនជាវត្ថុមានតម្លៃ ទម្រន់ខ្ជិលធ្វើការ សូម្បីយួរកន្ត្រកទៅផ្សារក៏មិនសូចផង មួយថ្ងៃៗគិតតែសប្បាយ រាំច្រៀង និង សំអិតសំអាងតែងខ្លួនតែប៉ុណ្ណោះ ។

ប៉ុន្មានអាទិត្យសោះ ខ្ញុំអាចរៀនចប់ក្បាច់ឆាបបញ្ចុះ និង អាចរាំចូលជាមួយហ្វូងត្រូវឥតខ្ចោះ ។ អ្នកគ្រូ សៀម ញញឹមបិទមាត់មិនជិត ដើរអួតសរសើរពីខ្ញុំប្រាប់គេប្រាប់ឯងគ្រប់គ្នា ។ មកដល់អាយុប្រាំបីឆ្នាំ ខ្ញុំហាត់ ដើរតួបានពីរ គឺមួយជាតួឆ្នា និង មួយទៀតធ្វើជាស្តេចដោះពាក់មុខអាក្រក់អាក្រីក្រខ្លាច ។ ខ្ញុំអាចគ្រវីដងបង វិលខ្ទាល់ដូចកង្ហារយ៉ាងស្អាត់ជំនាញ ពុំដែលរបួតចេញពីដែនដល់ម្តងណាឡើយ ។

ល្ងាចមួយនោះ លោកអគ្គមហាសេនា អនុញ្ញាតឲ្យអ្នកភូមិចូលមើលរបាំដល់ក្នុងបរិវេណផ្ទះគាត់ជា សាធារណៈ។ មនុស្សច្រើនកុះករប្រជ្រៀតគ្នាពេញសួនច្បារ ហៀរទៅដល់ក្រៅរបង, ពុក និង ម៉ែ ក៏បាន នាំយាយកែម ពីព្រែកថ្មី ឲ្យមកមើលខ្ញុំរាំនឹងគេដែរ ។ លើសពីនេះទៅទៀត លោកអ៊ុំបានអញ្ជើញអ្នករបាំ ក្នុងវាំង ឲ្យមកមើលក្រុមល្ខោនគាត់រាំទៀតផង ។ គេទាំងអស់គ្នារវក្រសែភ្នែកតាមសម្លឹងមើលខ្ញុំគ្រប់ កាយវិការ ព្រមទាំងជញ្ជក់មាត់សរសើរគ្រប់គ្នា ។ នេះជាជោគជ័យលើកទីមួយរបស់ខ្ញុំ!... ចាប់តាំងពី ពេលនោះមក លោកអ៊ុំរឹតតែស្រឡាញ់ខ្ញុំលើសដើម ទៅណាមួយជំហាន ក៏យកខ្ញុំទៅតាមជាប់ជាទិច្ច ហើយ គាត់ហាមថា តទៅថ្ងៃក្រោយមិនឲ្យខ្ញុំទៅណាចោលគាត់ជាដាច់ខាត ។ គាត់ឧស្សាហ៍ទាំខ្ញុំទៅលេងនឹង សម្តេចនុបរាជ[2] ដែលគង់នៅឯវាំងខាងជើងជាប្រចាំៗ ។ ហើយគាត់និយាយប្រាប់ខ្ញុំថា សព្វថ្ងៃ សម្តេចនុបរាជ ចង់សោយរាជ្យខ្លាំងណាស់ ។

ថ្ងៃមួយ ពុកម៉ែ និង ខ្ញុំ ទាំគ្នាមកសំណាក់លេងនៅព្រែកថ្មីបាន ពីរ-បីថ្ងៃ ទើបនាំគ្នាត្រឡប់មកវិញ ដោយមានបេះផ្លែស្វាយល្អៗជាក់កន្ទុះទុក ទុកសម្រាប់យកមកថ្វើលោកអ៊ុំ ។ ប៉ុន្តែមកដល់ត្រើមភ្នំពេញ មាន នរណាម្នាក់ស្រែកហៅពុកឲ្យឈប់ ហើយប្រាប់ថា លោកអគ្គមហាសេនា ស្លាប់ទៅហើយ!... មរណភាព នៃ លោកអគ្គមហាសេនា ប្រៀបបានទៅនឹងការលំរាយ នៃ បង្គោលដែលជាទីពឹងពាក់អាស្រ័យដ៏កក់ក្តៅ សម្រាប់គ្រួសារខ្ញុំយ៉ាងនោះដែរ... ។

♥ ♥

♥

(២) សម្តេចនុបរាជ គឺជាងារ ស្តេចស៊ីសុវត្ថិ មុនពេលបានឡើងសោយរាជ្យ ។

ប្រែជា ខែកន្លងទៅ... យើងចាកចេញពីផ្ទះនៅក្បែរវត្តស្វាយពពែ មកទិញផ្ទះស្អីកតួចមួយ នៅម្តុំកំពង់ផែវិញ។ រាល់ថ្ងៃ ពុកបោសសំអាតតុបតែងផ្ទះ និង ដីភូមិ មិនឲ្យខ្ញុំខ្មាសភ្ញៀវអ្នកជិតខាង ដែលគេមានសុទ្ធតែផ្ទះក្បឿងសសរឆ្នឹកនោះទេ។

ដោយសារខ្មោចលោកអុំមានឆ្នាំធ្វើទុកនឹងគេ ពុកក៏បានចូលធ្វើការនៅក្នុងភឹង ហើយឆ្លៀតពេលទំនេរគាត់តែងជួយធ្វើការជួនអស់លោកទាំមីនក្នុងភឹង ដែលជាហេតុអាចឲ្យគាត់រកប្រាក់បានច្រើនគួរសម បន្ថែមលើប្រាក់ខែបន្តិចបន្តួចនោះ សម្រាប់យកមកផ្គត់ផ្គង់គ្រួសារ។

ខ្ញុំមានអាយុមិនទាន់គាំងគ្រប់ដប់ឆ្នាំស្រួលបួលផង។ ខ្ញុំមិនដឹងថា ជីវភាពនៅក្នុងភឹង សប្បាយ ឬ លំបាកជាយ៉ាងណាទេ ប៉ុន្តែខ្ញុំចេះតែចង់នៅក្នុងភឹង ព្រោះខ្ញុំចង់ហ៊ីហាស្មៀកសំពត់អាវរបាំតែប៉ុណ្ណោះ។ ខ្ញុំនៅជាធុញទ្រាន់ លែងចង់រស់នៅក្នុងខួមស្អីក លែងចង់រស់នៅជាមួយ ឪពុក-ម្តាយ ទោះបីពុកផ្គត់ផ្គង់ខ្ញុំគ្រប់សព្វ មិនដែលឲ្យខ្វះខាតយ៉ាងណាក៏ដោយ។

ប៊ុន និង ហ៊ុន ឱស្សាហ៍មកពីព្រែកថ្មី មកលេងនឹងយើងខ្ញុំណាស់ ជួនកាលមកនៅ ពីរ-បីអាទិត្យ ទើបត្រឡប់នៅវិញក៏មាន។ ឮប៉ុល និង ឮម៉ែន ជាអ្នកបញ្ជិះទូកនាំវាមក ព្រមទាំងនាំយកដំណឹងផ្សេងៗពីស្រុកមកប្រាប់ ពុក-ម៉ែ ផង។ ប៉ុន្តែ ពុកមិនចូលចិត្តឲ្យ ឮប៉ុល និង ឮម៉ែន នៅយូរទេ ពីព្រោះណាមួយផ្ទះក៏ចង្អៀត ណាមួយពុកស្អប់ត្រង់គាត់ចូលចិត្តស្មៀកពាក់ខោអាវច្រឡូកច្រឡំ ឲ្យតែពុកមិននៅ គាត់យកអាវពុកព្យួរនៅនឹងស្នែងក្តាន់ពាក់ដើរលេងផ្សារមួយរំពេច។ ចំណែកម៉ែវិញ គាត់ស្រឡាញ់ បង-ប្អូន ជាងប្តី ទៅទៀត សុខចិត្តលក់បញ្ជាំរបស់ទ្រព្យឯងយកលុយឲ្យគេខ្ចី ហើយអ្នកខ្ចីនោះ ក៏ខ្ចីរហូត មិនដែលឃើញសង់វិញឡើយ។

ពេលថ្ងៃទំនេរ មិនដឹងធ្វើអី ខ្ញុំជួយដាំបាយម៉ែ ខ្ញុំងូតទឹកដុះសាប៊ូលាបរមៀតមួយថ្ងៃ ដប់-ម្តែងទាល់តែពុករកលុយទិញសាប៊ូឲ្យសឹងតែមិនទាន់។ មនុស្សដើរទៅមកតាមផ្លូវកំពង់ផែ តែងត្រូវខ្ញុំចំអកឡកឡឺយឲ្យ ឬ ជួនកាលខ្ញុំហ៊ានដល់ទៅដេរច្រាស់ឆ្នេះឲ្យគេទៀតផង។ ម្ល៉ោះហើយ ខ្លះណា ក៏ខ្លាចរអាក៏ស្អប់ខ្ញុំដែរ គេចាត់ពុកខ្ញុំថ្លង់ជាខ្មោចបិសាចនៅក្នុងភូមិអញ្ចឹង។

មានរឿងរ៉ាវខ្លះក្នុងជីវិតដែលគេពុំអាចបំភ្លេចបានឡើយ... ថ្ងៃដែលខ្ញុំចាកចេញពីគ្រួសារ ចាកចេញពីខួមកំសត់ដែលខ្ញុំធ្លាប់រស់នៅបានទទួលក្តីស្នេហាពី ឪពុក-ម្តាយ បានទទួលក្តីសប្បាយរីករាយ នៃ ភាពកុមារ ថ្ងៃនោះឆ្កិតជាប់ច្បាស់ក្រែឡែតក្នុងអារម្មណ៍ខ្ញុំ ហាក់ដូចជានៅថ្មីៗនៅឡើយ។

ម៉ែបានទៅពឹង ទាងរឿក ជាអ្នករបាំនៅក្នុងភឹង អាយុបងខ្ញុំដប់ឆ្នាំ ឲ្យមកជួយចាត់ចែងនាំខ្ញុំទៅគាល់

ហ្លួង។ ទាងរឿកនាំយកមកឲ្យ សំពត់ម៉ដ្ឋពណ៌ស្វាយ អាវរៀលក ដៃខ្លីពណ៌ខ្មៅ ប៉ាក់ជរផង ជាសម្លៀកបំពាក់សម្រាប់ហាត់រាំ ជាហ៊ឺពណ៌ល្មើង ពាទាព័ទ្ធធៀង ខម្លាក់ជាយម្ខាងមកត្រឹមចង្កេះ រយ៉ាមួយឫចិញ្ចៀនជើង និង កងជើងមាសធ្ងន់ដូចគេដាក់ខ្មោះជើង។

ស្មៀកពាក់អញ្ចឹងទៅ ខ្ញុំដូចជាហ៊ីហាក្នុងចិត្ត ចុះជណ្តើរយឺតៗយ៉ាងប្រយ័ត្នប្រយែង ខំធ្វើឫកឲ្យដូចជាអស់អ្នកក្នុងភឹងមែនទែន។ ខ្ញុំដើរចន្លោះកណ្តាល ម៉ែ និង បងរឿក បំពង់កស្ងួតចែសរកទឹកមាត់លេបគ្មានដោយក្តីរំជួលចិត្ត, អារម្មណ៍អណ្តែតត្រសែតចេញពីរាងកាយទៅកាន់ពិភព នៃ ក្តីស្រមៃមើលឃើញតែភាពរុងរឿងថ្ងៃថ្នូរ។ បន្តិចទៀតខ្ញុំនឹងក្លាយខ្លួនជាអ្នករបាំរបស់ហ្លួង រាស្ត្រសាមញ្ញលែងហ៊ានហៅខ្ញុំ "មី" គេនឹងហៅខ្ញុំថា អ្នក ឬ ទាង មិនខាន។ ខ្ញុំនឹងមាន មាសពេជ្រ, សំពត់អាវសម្បុរណ៌ហូរហៀរ មានខ្ញុំបំរើសម្រាប់យួរកន្ត្រកដើរតាមក្រោយ, មានរនេះ, មានដីរ, មានទូកបិទដំបូលសម្រាប់ជិះដើរលេងកំសាន្ត, មានអ្វីៗទាំងអស់ សម្រាប់បំពេញសេចក្តីត្រូវការ។

ទាំប៊ីការប៉ោលធ្យូនៅក្នុងទីតាំងស្តេច បន្ទីស្នូរប្រាំមួយអន្ធង់យ៉ាងយឺតៗរបៀបខ្វិលច្រអូស ហាក់ធុញទ្រាន់នឹងបំពេញមុខការដដែលៗនេះតាំងពីច្រើនឆ្នាំមកហើយ។ មកដល់ត្រង់ក្លោងទ្វារ ងងឹតព្រាលៗ នរណាម្នាក់លាន់មាត់និយាយមកកាន់យើង :

~ យើ! កូនអ្នកណាហ្នឹង ស្អាតមើលតែទៅតាំ?

~ កូនខ្ញុំណា! (ម៉ែប្រញាប់ឆ្លើយទៅវិញយ៉ាងពេញចិត្ត) ខ្ញុំទាំវាទៅថ្វាយហ្លួង។

ខ្ញុំមិនដឹងថា ពាក្យទាំងនេះមានន័យសរសើរមែនទែន ឬ ជាពាក្យចំអកទេ ប៉ុន្តែគ្រាន់តែឮគេនិយាយអ៊ីចឹង ខ្ញុំទៅជាចេញទឹកមាត់។

ខ្ញុំទំលេបវាទៅវិញកុំឲ្យហៀរមកប៉ះម្សៅលាបមុខ ហើយធ្វើមិនឮដើរតាមចន្លោះទៅវិនិច្ឆ័យ ដែលជាកន្លែងដំកល់បល្ល័ង្កស្តេច និង ទាងរបាំ ឆ្ពោះទៅកាន់កន្លែងយាម ត្រង់មាត់ទ្វារព្រលប់។

ពីដើម, កាលនៅក្នុងវាដ្យាស្តេច សុវណ្ណកោដ្ឋ តែពេលព្រលប់ភ្លាម គេលែងឲ្យចេញចូលតាមទ្វារនេះហើយ។ ប៉ុន្តែសព្វថ្ងៃនេះ ទាល់តែបាញ់កាំភ្លើងម៉ោងប្រាំបីយប់[៣] ទើបគេលែងឲ្យ ចេញ-ចូល ហើយគេក៏មិនស្ទុះពឹងតែងប្រយ័ត្នណាស់ណាដែរ។

ក្រុមភឹងចាស់ៗដែលនៅយាមទ្វារ ទាំគ្នាស្គុះងើបឡើង នៅពេលឃើញយើងទៅដល់ ហើយបន្តន់ខ្លួនត្រួទ្យគោរពម៉ែ ដោយឃើញគាត់ដើរជាមួយបងរឿក ដែលជាកូនលោងយុនព្រះញាតិ។ គេប្រញាប់បើកទ្វារឲ្យយើងចូល ដោយឥតហ៊ានសួរនាំអ្វីឡើយ។

ខ្ញុំចុះជណ្តើរថ្ម ពីរ-បីកាំ ហើយឈប់មើងមាំង ភ្នែកសម្លឹងមើលផ្លូវដ៏ស្ងាត់ជ្រងំក្រាលថ្មយ៉ាងស្អាត អមសង្ខាងទៅដោយរបងដែក សួនច្បារ អាងទឹក និង ដើមឈើល្អត្រកាល ប្លែកភ្នែកគួរឲ្យចង់តយតន់។ ស្ត្រីចាស់កោងខ្នងម្នាក់ ចោះជំហានយឺតៗតម្រង់ទៅរកទ្វារចេញ មានអ្នកបំរើមួយហ្វូងធំកាន់ថាសជាក់ចង្ហាន់យកទៅប្រគេនព្រះសង្ឃវត្តព្រះកែវ ដើរតាមហ្វូរហែពីក្រោយ។ បងរឿក កេះម៉ែឱ្យបង្ហាប់ថា ស្ត្រីចាស់ដើរមុខគេនេះជាស្តេច ហើយម៉ែក៏លើកដៃសំពះយ៉ាងគួរសមក្រៃលែង។ ឆ្ងាយពីនេះទៅទៀត ទៅខាងមុខផ្លូវ ដើមតគីរធំខ្ពស់ដុះតម្រៀបគ្នាជាជួរ មើលពីក្រៅមកឃើញតែស្លឹកស៊ុបខ្ចីបត្របច្របលើភឹងទាំងមួល។

អស់អ្នក អស់ទាង ឬ អ្នករបាំ ឥតពាក់អាវទេ មានតែស្បែស្តើងជណ្តប់ខ្លួន ដើរលេងប្រសេចប្រសាចពេញសួនច្បារ។ ខ្លះទៀតប្រជុំគ្នាជាក្រុមៗ ជក់ចាំរីជដែកគ្នាអែប្រមែ និង ខ្លះទៀតដើរទៅដើរមក ញាប់ជើង

(៣) កាំភ្លើងបាញ់ម៉ោងប្រាំបីយប់នេះ ជាសញ្ញាប្រាប់ម៉ោងពេល ដូចជាស៊ីជីនម៉ោង ១២ថ្ងៃត្រង់។

ទំនងជាមានការអីសំខាន់ហើយមើលទៅ។

ដំណាក់ឈើមួយសង់ខាបទីងដី ប្រកបដោយរាងហាលព័ទ្ធជុំវិញ ក៏ស្ថិតនៅជិតដំណាក់ហួង ផ្ទះមហាមន្ត្រីវែរ គឺស្ថិតនៅត្រង់កែងផ្លូវធំ និង ផ្លូវក្រាលថ្មមួយទៀត។ កន្លែងនេះ ពិតជាកន្លែងសំខាន់ជាងគេនៅក្នុងភូមិ ព្រោះមនុស្សមានមកប្រជុំគ្នាអ៊ីអរ សោតដំណាក់ខាខាជាច្រើនទៀត ក៏សុទ្ធតែសង់នៅក្បែរនេះដែរ។

ក្រមុំតិងដើរក្រឡឹងជុំវិញដំណាក់ហួង ដៃកាន់ឈើច្រត់ក្រាក់ ជួនកាលវត់ធ្លាធ្លាក់នេះបន្តិច ទៅនោះបន្តិច ដើម្បីបញ្ជូនបន្តទៅកន្លែងផ្សេងៗ ទ្វារពាក្យបញ្ហាដែលស្ត្រីភ្លេងៗអង្គុយរង់ណែលនៅត្រង់មាត់ទ្វារបន្ទប់ហួងនោះ នាំយកមកប្រាប់។ នៅកន្លែងនេះ គេនិយាយគ្នាតិចៗ បញ្ចេញឫកថ្លៃថ្នូរបែបចម្លែក គួរឲ្យខ្ញុំតឹកន្ទាសខ្លួនឯងណាស់ ដែលមានឫកពារជាអ្នកស្រែសុទ្ធសាធ។ មិនអីទេ! ខ្ញុំនឹងខំរៀនឲ្យចាស់តែចេះរបៀបថ្លៃថ្នូរផ្ទួចគេមិនខាន។

ឆ្ងាយបន្តិចទៅទៀត នៅពីក្រោយប្រាសាទបាញ់យ៉ាង ខ្ញុំឃើញផ្ទះឈើធំៗសង់យ៉ាងខ្ជីខ្ជាបំផុត ទុកសម្រាប់ឲ្យពួកកូនស្នងរបស់ឃុនព្រះញាតិ សំណាក់នៅ។ គ្រាន់តែឃើញនៅជិតនោះ មានដើម ស្វាយ, ដើមល្មុត ខ្ញុំលួចញញឹមក្នុងពោះ ក្របួចមាត់ទុកមុឈួចស្រេចទៅហើយ។ ក្រមៀតទៅខាងណាក៏ឃើញតែបុប្ផាវ័កស្គុសស្គាយ ឃើញតែម្លប់ត្រជាក់ នៃ ដើមក្អមជាតិធំៗ ឃើញតែក្បាលម៉ាស៊ីនទឹក ដែលបញ្ចេញមកនូវទឹកថ្នាំឆ្ងង់ផ្ទួចកញ្ជក់ ឃើញតែផ្លូវធ្លាស្អាតរលើងឆេងគ្មានសំរាមមួយទង ផ្ទុយស្រឡះពីវាលចំការដែលខ្ញុំធ្លាប់ឥតលេងរាល់ថ្ងៃ។

គេទាំយើងចូលដល់ក្នុងដំណាក់ ឃុនព្រះញាតិ ដែលមានហៅៈជាចាងហ្វាងទីពីរ នៃ ក្រុមល្ខោនហួង។ ដំណាក់របស់ឃុនធ្វើអំពីឈើប្រក់ក្បឿង ហើយទូលាយណាស់។ ឃុនចាស់ជ្រួលបន្តិចទៅហើយ បើសន្និដ្ឋានទៅតាមការដែលអ្នកផងនុនលំទោនគោរពគាត់ស្រប់គ្នានេះ ឃើញថា ឃុនព្រះញាតិ ជាមនុស្សមានមុខមានមាត់សម្បើមណាស់។ យើងសំពះសួរឃុន រួចថយដើរនុនៗទៅអង្គុយលើកន្ទេល ឆ្ងាយពីកន្លែងឃុន អ្នកបំរើយក កន្ទោរស្ពោះទឹកមាត់ និង ហិបស្លាន់មានតម្លៃ មកដាក់ផ្ទួចៅហ្វាយ ហើយថយទៅវិញសុទ្ធតែប្រើអាកប្បកិរិយាត្រួៗបែបនេះផ្ទួចគ្នាទាំងអស់។ ខ្ញុំវល់តែជក់ក្អែកគយគន់មើលរបៀបរៀបចំក្នុងផ្ទះ ពុំបានស្តាប់ម៉ែនិយាយថាអ្វីខ្លះជាមួយឃុនទេ...។

គេយកជើងពានមាសដាក់ ចាប់ផ្តាំ និង កម្រងផ្តាំ មកឲ្យខ្ញុំ ហើយតាញដៃខ្ញុំចេញទៅក្រៅ និយាយពន្យល់ថា កាលណាគេកេះឲ្យសញ្ជា ខ្ញុំត្រូវយកជង្វាយនេះទៅដាក់ក្បែរព្រះបាទហួង ដោយលត់ជង្គង់ចុះទៅលើកន្ទេល។ ម៉ែ និង បងប្រឹក ខ្សិបប្រាប់ខ្ញុំថា កាលណាហួងសួរខ្ញុំជាភាសាសៀម ខ្ញុំត្រូវឆ្លើយថា៖ "ព្រះពរម្ចាស់ ខ្ញុំចេះនិយាយតែខ្មែរទេ" ហើយគាត់ឲ្យខ្ញុំអង្គុយលើកាំជណ្តើរទីតាំងមេឧលា ចាំទម្រាំហួងចេញពីសោយអាហារក្នុងបន្ទប់នេះមកវិញ។ ខ្ញុំអង្គុយលុតជង្គង់ ងាកមើលទៅក្រោយឥតឃើញម៉ែ ផ្ទួចជាភ័យស្រាលខ្លួន ទំនងអស់សង្ឃឹមបន្តិចផង។ បងប្រឹកក្តិចក្តៅខ្ញុំ ហើយខ្សិបថា:

- ងើបឡើងមេនាង! ទៅថ្វាយបង្គំហួងភ្លាមទៅ!

សភាពអ៊ីអរសិបរសៀវភ័ក៌កើតមានឡើងក្នុងចំណោម ទាម៉ីន និង ស្រីៗ ដែលប្រមូលផ្តុំគ្នាត្រៀបត្រាទៅមុខទីតាំងមេឧលា អង្គុយបត់ជើង កាច់ចង្កេះរៀចក្រងេវមកម្ខាង ដៃលើកសំពះ។ អ្នកដែលអង្គុយលើកាំជណ្តើរ និង នៅក្នុងបន្ទប់នោះ ក៏ធ្វើការយ៉ាងការផ្ទួចគ្នានេះដែរ។

ហួងសុវណ្ណកោដ្ឋ យាងមកដល់មាត់ទ្វារបន្ទប់ដែលមានពន្លឺព្រិលៗ ហើយក្រសែភ្នែកមើលហួង "កូនចៅ" មួយក្រុស។ ហួងចាស់ចំណាស់ទៅហើយ រាងស្គមកំព្រឹង ខ្លួងកោងបន្តិច ត្រចៀបខ្លួនទៅលើឈើច្រត់ស្រោបមាស ខ្លួនទេមានពាខាជាហ៊ីព័ទ្ធធ្វើងពីស្មាឆ្វេង ទម្លាក់ជាយមកចង្កេះខាងស្តាំ ចង្កេះរៀវសួច ស្លៀកសំពត់សូត្រសម្បុរស្រអាប់ សក់កាត់ជ្រុងខ្លី។

ខ្ញុំខាំមាត់ប្រមូលសេចក្តីក្លាហានងើបឈរឡើង ហើយដើរនុនៗទៅលុតជង្គង់ដាក់ជើងពានផ្តាំក្បែរជើងព្រះអង្គ... ខ្ញុំហាក់ដូចជាដឹងថា ហួងនុនមុខឈ្មោកសម្លឹងខ្ញុំ។ នៅពេលដែលព្រះអង្គនិយាយពាក្យអ្វីញ៉ាំៗពីរ-បីមាត់ រកតែខ្ញុំស្តាប់មិនបាន ខ្ញុំក៏ឆ្លើយតបទៅវិញថា:

- ព្រះពរម្ចាស់ ខ្ញុំម្ចាស់ចេះនិយាយតែភាសាខ្មែរទេ។

- ហាំ ! ហាំ ! (ហួងសើចតិចៗ) វាកូនអ្នកណាហ្នឹង, ឫចវាចង់បានអី?

បងប្រឹក ឆ្លើយជំនួសខ្ញុំភ្លាម ដោយខ្លាចក្រែងខ្ញុំនិយាយមិនបានសមម្យ:

- ក្រាបទូល! នាងហ្នឹងកូន នាយយិន ធ្វើការហានហួង និង នាងឯម, នាងមកសុំចូលភាំណោនព្រះករុណា។

- ហាំ! ហាំ! ឲ្យវាចូលជិតបន្តិចមក អញមើលឲ្យច្បាស់បន្តិច។

ខ្ញុំងើបឈរឡើង ហួងតាញសក់អួសខ្ញុំឲ្យទៅឈរពីមុខកញ្ជក់ ដែលអាចឲ្យខ្ញុំមើលឃើញរូបហួងភ្លាប់សក់ដួងជុករបស់ខ្ញុំជាប់ ។ ហួងសើចរលាក់ញ៉ីរអស់ដងខ្លួន ហើយសួរខ្ញុំថា:

- ឯងស្រឡាញ់អញទេហាំ?

នាងស្រឡាញ់ព្រះអង្គណាស់ក្រាបទូល (បងប្រឹក ឆ្លើយកាត់ម្តងទៀត ជារបៀបសរសើរលើកដំកើង)។

បងប្រឹកភរទេ! តាមពិតខ្ញុំខ្លាចហួងស្ទើរភតនោមទៅហើយ ខ្ញុំចង់ឲ្យតែឆាកនេះឆាប់ចប់ស្រឡះទៅ ប៉ុន្តែខ្ញុំក៏មិនហ៊ានបម្រះដែរ បណ្តោយឲ្យហួងផ្តៀងភ្នែងមើលតាមចិត្ត។ លោកបង្គាប់ថា:

- ហ៎! ឲ្យគេយកប្រាក់បួនណែនមកឲ្យក្មេងនេះ ហើយឲ្យគេចុះឈ្មោះវាក្នុងបញ្ជីកូនល្ខោនរបស់ឃុនថាន់ផង។ អើនែ៎! ជាក់ឈ្មោះវាថា "ឯកណាមយ៉ែម" ណា!។

ស្រីម្នាក់ ជាអ្នកកាន់កូនសោ ហើយដែលក្រោយមកខ្ញុំដឹងថាឈ្មោះ ម៉ែមឲ្យ ជាអ្នកគាប់ខឹងហួងជាងគេ ប្រញាប់ទូលគាត់ភ្លាម:

- ក្រាបទូល! ឲ្យតែបីណែនគ្រាន់ហើយ ព្រោះវានៅក្មេងណាស់។

ឃើញថា ហួងនៅស្ងៀមសម្តែងការយល់ស្រប គាត់ក៏ងើបដើរចេញទៅក្រៅមួយភ្លែត ហើយត្រឡប់មកវិញ ព្រមទាំងពោលមកកាន់ខ្ញុំថា:

- អាយុប៉ុនឯង គេឲ្យតែពីរណែនទេ ប៉ុន្តែហួងគាប់ព្រះទ័យនឹងឯងហើយ បានជាប្រទានបីណែនអញ្ចឹង, ម៉េចក៏មិនលុតជង្គង់ថ្វាយបង្គំអរព្រះគុណព្រះអង្គភ្លាមទៅ!។

ទោះបីខ្ញុំត្រូវខាតបង់មួយណែន ដោយសារមានអ្នកទូលទាស់យ៉ាងនេះក៏ដោយ ក៏ខ្ញុំនៅតែយល់ថាប្រាក់បីណែននេះ ជាព្រះរាជអំណោយមានតម្លៃច្រើនពេកណាស់។ ខ្ញុំលុតជង្គង់ចុះប្រុងថ្វាយបង្គំ ប៉ុន្តែហួងយាងចេញទៅដោយបញ្ជាក់ម្តងទៀត:

- យកវាទៅឲ្យនៅជាមួយនួនណា! ព្រោះគេធ្វើការម៉ឺងម៉ាត់ជាង ញ៊ឹក។

នួនជាឈ្មោះរបស់ឃុនថាន់ ក្រុមល្ខោនក្រុមទីមួយ ចំណែកឯញ៊ឹក ជាឈ្មោះឃុនព្រះញាតិ។ សំដីបង្ហាញឲ្យឃើញថា ហួងមិនសូវទុកចិត្តលើអ្នកដែលបានជួយជ្រោមជ្រែងខ្ញុំប៉ុន្មានទេ។ បងប្រឹក តាញដៃខ្ញុំទៅក្រៅ លួងលោមពន្យល់ថា:

~ កុំទៅនៅជាមួយយុនថាន់អី នៅជាមួយយុនព្រះញាតិ ហ្នឹងហើយ, ឯងកុំភ្លេចណា! គាត់ជាអ្នកទាំងឯងមកថ្វាយហ្លួង ។

ពួកណ្តែនទាំគ្នាមកចោមរោមខ្ញុំដោយចិត្តច្រណែនឈ្នានិស ចំណែកឯចាស់ៗធ្មេញក្រហុបវិញ ខំសរសើរខ្ញុំ ក្រែងបានមួស្ករ ។ ពួកម៉ាកស្រីរបស់ខ្ញុំម្នាក់ឈ្មោះ ស៊ុន មានផ្ទះនៅជិតគ្នាឯកំពង់ផៃ វាចូលមកនៅវាំងមុនខ្ញុំមួយឆ្នាំ, វាសំដែងទឹកមុខមិនពេញចិត្តខ្លាំងណាស់ ដែលឃើញហ្លួងប្រទានលុយខ្ញុំលើសវាមួយណែន ។

ម៉ែចេញមកពីកន្លៀតណាមក មុខញញឹមពព្រាយ ស្រវាយកលុយទុក អរគុណបងប្អូនទាំងអស់ខ្ញុំទៅជម្រាបលាយុនព្រះញាតិ ។ យុនផ្តាំថា ស្អែកព្រឹកឲ្យម៉ែទាំខ្ញុំមកម្តងទៀត ។

នៅពេលដែល ម៉ែ និង ខ្ញុំ ឆ្ងងផុតក្លោងទ្វារ នៃ កំផែងសីមា ទីលានកំពង់ផែដ៏ធំទូលាយ លេចឡើងនៅចំពោះមុខខ្ញុំ កណ្តាលថ្ងៃអន្ធការ នៃ រាត្រីកាល ។

ហាក់ដូចជាទម្ងន់អ្វីមួយរបួតខ្សាកចេញពីទ្រូង បណ្តាលឲ្យខ្លួនខ្ញុំប្រែជាស្រាលស្ទើរតែដួចជាន់ខុសដី ។ បន្តិចទៀតខ្ញុំនឹងបានឡើងឋានៈជា លោកយុន ខ្ញុំនឹងក្លាយទៅជាមនុស្សម្នាក់ផ្សេងទៀត ពុំមែនដូចខ្ញុំសព្វថ្ងៃនេះទេ ។ ហ្លួងចិត្តទូលាយប្រទានប្រាក់ច្រើនម្ល៉ឹងៗ មិនយូរមិនឆាប់ ឪពុកម្តាយខ្ញុំតង់នឹងបានខ្ពស់មុខខ្ពស់មាត់ ពុកអាចនឹងមានលុយទិញអាវ កត្រង់ ឡេវប្រាក់ ពាក់ដូចគេមិនខាន ។

សម្រាប់ប្អូនខ្ញុំ ខ្ញុំឥតត្រូវការចង់បានអ្វីទាំងអស់ ខ្ញុំចង់តែម្យ៉ាង គឺថ្ងៃណាមួយខ្ញុំនឹងបានឡើងធ្វើជាតួឯកណ្តែនហ្លួង រាំនៅចំពោះមុខខេស្សូនិកជនតែប៉ុណ្ណោះ ។ ខ្ញុំស្រមៃឃើញអនាគតភ្លឺស្វាង ប្រកបទៅដោយកិត្តិយស និង ជោគជ័យ ហើយខ្ញុំហួចអស់រលីងនូវរឿងរ៉ាវអតីតកាល ដែលខ្ញុំធ្លាប់ជួបប្រទះកាលរស់នៅឯព្រែកថ្មី ។

នៅលើចុងសសរដងកើ ទង់ក្រហមបក់រាំចៅតាមកម្លាំងវាយោ ។ ហ្លួងក្អែកហើរត្រឡប់មកកាន់ទ្រនំវិញ បញ្ចេញសំឡេងកោកកាកគ្រហឹងអឹងអាប់... ។

♥ ♥

♥

ស្អែក ខ្ញុំចូលមកនៅជាមួយនឹងយុនព្រះញាតិ ដែលទំនុះខ្នែងខ្លាំងណាស់ ពុំព្រមឲ្យយុនថាន់ ជាគូប្រជែង កេងយកចំណេញក្នុងការបង្ហាត់ខ្ញុំទេ ខ្ញុំ សាកសួរគេខ្លះ លួចមើលគេខ្លះ រហ័ទីដល់អាចចេះដឹង ស្គាល់វិន័យ និង របៀបរៀបរយ ក្នុងវាំង បានយ៉ាងចាប់ហើស ។

ដូចខ្ញុំស្មានមិនខុសមែន សកម្មភាពអ្វីអាជាងគេ គឺនៅត្រង់ក្រោយប្រាសាទតាំងជ្រាំ ដែលបញ្ចេញតែផ្លែកខាងមុខឲ្យគេឃើញនេះឯង ។ ផ្លូវតែមួយគត់ដែលនាំឆ្ពោះទៅទ្វារព្រលប់ ដោយកាត់តាមចន្លោះទេវាវិនិច្ឆ័យ និង ឆាងរបាំនោះ បន្តចូលមកក្នុង កាត់តាមចន្លោះប្រាសាទបាញ់យ៉ឹង ទីតាំងទក្សិណ និង មហាមន្ត្រី ដែលជាដំណាក់ហ្លួងតង់នៅរាល់ថ្ងៃ ហើយបន្តរហូតដល់កាត់ខ្វែងគ្នាជាមួយផ្លូវធំមួយទៀត ។ កន្លែងផ្លូវកែងនេះ ជាទីសម្បាយអ្វីអាជាងគេ មនុស្សមកជួបជុំគ្នាកុះករ ស្រីៗលក់ទំចំណីនៅខាងក្រៅ ក៏អនុញ្ញាតឲ្យចូលមកលក់ដល់ទីនេះបានដែរ ។ ផ្លូវតូចៗច្រើនទៀត បន្តចេញពីផ្លូវធំ ឆ្ពោះទៅផ្ទះព្រះអង្គម្ចាស់អស់អ្នកអស់ទាង សាវ៉ាក់សាវ៉ាឡយ ដែលម្ចាក់ៗមានកិត្តិយស ឬ ទ្រព្យសម្បត្តិ តិចច្រើន ទៅតាមឋានៈខ្លួនជាឃុន ជាម៉ម... ។ យុនថាន់ អ្នកតាប់ចិត្តហ្លួងជាងគេ បានទៅក្នុងប្រាសាទមេខ្លា ។ ចំណែក យុនព្រះញាតិ ចៅហ្វាយខ្ញុំ និង ម៉មសួន ជាចាងហ្វាងក្រុមណ្តែនទីបីនោះ នៅក្នុងបន្ទប់ថែវែងណោះទេ ។

យុន ម៉ម អស់អ្នកអស់ទាង ទាំងនេះ ម្នាក់ៗមានខ្ទុំបំរើផ្ទាល់ខ្លួនមួយហ្លួង ថែមទាំងដឹកជញ្ជូន ឪពុកម្តាយទាំងសាច់ញាតិប្រាំពីរសន្តាន មកឲ្យដេកស៊ីលុយហ្លួង ដោយពុំចាំបាច់ធ្វើការអ្វីទៀតផង ។

នរណាមានវ័យចាស់ និង មានឋានៈធំ អាចមានសេរីភាព ចេញ-ចូលក្នុងវាំង ដើរទៅលេងផ្សារ ឬទៅសុំសីលនៅវត្តជិតៗបាន ។ ប៉ុន្តែ ហ្លួងដូចជាមិនសូវវល់នឹងអ្នកនេះទៅ អ្នកនោះមិនទៅ អីប៉ុន្មានទេ ឃ្លាៗជួបគ្នាម្តង ហ្លួងគ្រាន់តែសួរសុខទុក្ខពីក្លូនពីចៅតែប៉ុណ្ណោះ ។ ឯការជួបគ្នានេះទៀតសោត ទាល់តែត្រូវការសុំនេះសុំនោះ ទើបគេទៅគាល់ហ្លួង ហើយខ្ញុំកម្រឃើញហ្លួងប្រកែកថាមិនឲ្យណាស់ ។ ឋានៈអ្នកនៅក្នុងវាំង មានច្រើនពេក សាំញ៉ាំមិនដឹងជាស្លឹខ្លះទេ ប៉ុន្តែបើនិយាយពីអំណាចត្រួតត្រាលើគេវិញ ស្ថិតនៅក្នុងកណ្តាប់ដៃមនុស្សបីទាក់ ។ មុនគេបង្អស់គឺ យុនថាន់ ចាងហ្វាងណ្តែន មានអំណាចខ្លាំងជាងគេ និងបន្ទាប់មកគឺ យុនព្រះញាតិ ។ អ្នកទាំងពីរត្រូវចំណាយប្រាក់ច្រើនឥតគណនា ដើម្បីបើសក្លូនណ្តែនសម្រាប់ក្រុមផ្ទាល់ខ្លួនម្នាក់ៗ ក្នុងចំណោមគ្រួសារអ្នកទីក្រែង ដែលភាគច្រើនមានសុទ្ធតែខ្មែរ និង សៀម ចំណែកឯក្លូនណ្តែនរបស់ម៉មសួនអ្នកតាប់ចិត្តហ្លួងជាទីបីនោះវិញ មានសុទ្ធតែក្មេងស្រីក្លូនកាត់ចិនយួន សម្បុរសស្គុស ដែលគេយកមកកាត់សក់រៀបសៀម និង ឲ្យស្លៀកពាក់ដូចយើងដែរ ។

យុនថាន់ អាយុចាស់បន្តិចមែន ប៉ុន្តែហ្លួងនៅតែតាប់ចិត្តនឹងគាត់ជាងគេជានិច្ច ព្រោះគាត់ជាមនុស្ស

ស្និតស្នាញក្នុងការងារ ព្រមទាំងមានចិត្តទូលាយ ប្រឹងប្រែងបង្ហាត់សិស្សឥតគិតឈឿយហត់ និង ចេះធ្វើឲ្យសិស្សគ្រប់គ្នាគោរពស្រឡាញ់។ នេះជាកំហុសធំរបស់ខ្ញុំ ដែលពុំព្រមទៅនៅជាមួយគាត់តាមព្រះរាជបញ្ជា ហើយក្រាញនៅជាមួយឃុនព្រះញាតិ ដែលជាហេតុទាំឲ្យខ្ញុំជួបប្រទះនឹងរឿងរ៉ាវល្អឹងផ្ទរចត់ ហើយសេចក្តីសង្ឃឹមថា នឹងបានស្គាល់អនាគតភ្លឺស្វាងនោះ ក៏រលត់រលាយអស់ទៅវិញដែរ។

ឃុនព្រះញាតិនេះ ប្រសប់អស្ចារ្យខាងនិយាយលើកជើង ន៉ពុក-ម្តាយនៃក្មេងស្រីៗ ដែលគាត់ចង់ទាញបញ្ចូលមកក្នុងក្រុមគាត់ ដើម្បីឃាត់ឃាំងកុំឲ្យអ្នកទាំងនោះ យកកូនខ្លួនទៅថ្វាយហួងដោយផ្ទាល់។ ធ្វើយ៉ាងនេះ គាត់អាចកេងយកចំណេញជាប្រយោជន៍ផ្ទាល់ខ្លួន លើប្រាក់រង្វាន់សម្រាប់សិស្សម្នាក់ៗបានយ៉ាងស្រួល, នៅសល់ប៉ុន្មាន គាត់ថែមទាំងយកទៅចងការឲ្យន៉ពុកម្តាយ ដែលគ្មានមិនដឹងអីសោះទៀតផង។ ប៉ុន្តែ ម្រាំនឹងខ្ញុំបានដឹងរឿងរ៉ាវអស់ទាំងនេះ វាហួសពេលអស់ទៅហើយ។ ក្មេងស្រីមួយចំនួនដែលគ្រប់អាយុល្មមទៅគាល់ហួងបាន គេបានអំណាចហួងការពារ មិនចាំបាច់វល់មកហាត់រាំ ក៏អត់មានអ្នកណាហ៊ានថាអីឲ្យដែរ រហូតដល់អ្នកខ្លះឈប់មករាំសោះតែម្តង ដើម្បីចូលកាន់តំណែងថ្មី ជាអង្គរក្ស និង ជាអ្នកតាំបញ្ជាពីហួង បន្តទៅប្រាប់អ្នកបំរើប្រុសៗទៅខាងក្រៅ។ ខ្ញុំយល់ថា នៅក្នុងរឹងមានតែស្រីអ្នកបំរើហួងនេះទេ ដែលជាមនុស្សមានសំណាងជាងគេ ព្រោះកិច្ចការនេះគ្មានឈឿយហត់អីសោះ ឲ្យតែពូកែរណោបរណើបធ្វើការឲ្យហួងឃើញបន្តិច ច្បាស់ជាបានរង្វាន់ញឹកញាប់ណាស់។

នៅពេលហាត់រាំលើកទីមួយ ខ្ញុំប្រឹងប្រែងយកចិត្តទុកដាក់ជាទីបំផុត។ អ្វីៗដែលខ្ញុំធ្លាប់ហាត់រៀនកាលនៅផ្ទះលោកអុំអគ្គមហាសេនា ខ្ញុំនៅចាំទាំងអស់ ឥតមានភ្លេចចន្លោះត្រង់ណាឡើយ ជាហេតុធ្វើឲ្យអ្នកគ្រូចាស់ៗថ្នាក់ឆ្ពើលឆ្ពល់ស្រប់គ្នា។ អ្នកគ្រូសៀមឈ្មោះសិរតនោះ ឆ្លាស់លេខមួយ ឲ្យតែខុសបន្តិច គាត់ក្តិចភ្លៅ លើកំពាត់ផ្តៅកំញើញមួយរំពេច។ ក្មួយសិស្សក្មេងៗ ស្រឡាញ់អ្នកគ្រូត្រឹបនិងអ្នកគ្រូលុតជាង ប៉ុន្តែមិនស្វះខ្លាច ហើយក៏មិនស្វះស្តាប់បង្គាប់គាត់ដែរ។ ដើម្បីបំភ័យយើង អ្នកគ្រូចាស់ៗទាំងនេះ សម្លុតចង់វាយធ្វើបាបយើង តាមរបៀបដែលគេធ្លាប់ប្រើកាលពីដើម សម្រាប់បង្ហាត់ពួកល្ខោន។

ព្រលឹមស្រាងៗឡើង គេនាំគ្នាចុះប្រសាចទៅក្នុងសួនច្បារ ដើម្បីស្រស់ស្រួបបបរ ឬ ទិញនំផ្សេងៗទៀតដែលអ្នកលក់ខាងក្រៅនាំយកចូលមក។ បន្ទាប់មក គេពាក់អាវវៀលភ្លៀកពណ៌ប្លែកៗគ្នា ស្លៀកសំពត់ រៀនជាត់ម្សៅ រួចហើយរត់ប្រញាយសំដៅហែងរបាំខាងក្នុង ដើម្បីប្រជុំគ្នាសមប្រឹង ឯណាវប្រឹង ស្តេចដោះទុកសម្រាប់ភ្ញាយហួងទតក្នុងឧកាសបុណ្យខាងមុខនេះ។

កាលណាឃើញអ្នកគ្រូចាប់កាច់ដៃកាច់ជើងពួកម៉ាកណាម្នាក់ ដែលពត់ពេនពុំត្រូវតាមចង្វាក់ហ្លួង ខ្ញុំសប្បាយចិត្តសើចហើកញ្ជ្រៀវចំអកឲ្យគេ។ រាល់ព្រឹក មានស្ត្រីទាំងហ្វូងៗ ចូលមកមើលយើងសមរបាំដែលជាហេតុធ្វើឲ្យខ្ញុំបារម្ភក្នុងចិត្តក្រៃលែង ខ្លាចតែត្រូវវាពាត់ខ្មាសគេ។

វេលាប្រហែលម៉ោង ១០ យើងឈប់ហាត់ អស់កម្លាំងរមួលពោះស្ទើរចោចពោះរៀន។ យើងប្រញាប់ផ្ទាស់សំលៀកបំពាក់ ប្រមូលគ្នាតាមក្រុមទៅងូតទឹកម៉ាស៊ីន ហើយត្រឡប់មកបរិភោគបាយថ្ងៃត្រង់ នៅផ្ទះចៅហ្វាយខាយរឿងខ្លះ ឬ នៅក្នុងបន្ទប់ដេកផ្ទាល់ខ្លួន កាលណាន៉ពុកម្តាយយើងយកបាយពីខាងក្រៅមកឲ្យ។

តាំងពីទើបនឹងមកដល់ដំបូង ខ្ញុំរអៀសខ្លួនពុំចង់រស់នៅដោយសារបាយចៅហ្វាយខាយទេ។ រាល់ព្រឹកម៉ែតែងយកបាយមកធ្វើខ្ញុំឥតដែលខានឡើយ។ ថ្ងៃមួយ ម៉ែយកបាយមកមិនទាន់ពេល ហើយខ្ញុំរមួលពោះខ្លាំងពេកទ្រាំមិនបាន ក៏បង្ខំចិត្តធ្វេចហ្នឹកលេបបាយជាមួយគេជាមួយឯងទៅ។ មួយម៉ោងក្រោយមក ត្រាន់តែ

យើញម៉ែយួរចានស្រាក់មកដល់ ខ្ញុំមួម៉ៅស្ទុះទៅទាត់ចានស្រាក់ កំពប់បាយសម្លពេញផ្លូវ។

ខ្ញុំឆ្ងាស់សម្បើមណាស់! នៅក្នុងភាំង នរណាក៏ឮល្បីឈ្មោះខ្ញុំដែរ។ ក្មេងតូចៗដូចគ្នា ឲ្យតែហ៊ានធ្វើអ្វីប៉ះពាល់ខ្ញុំបន្តិច ខ្ញុំវាយភ្លាម ទាល់តែឃុនព្រះញាតិឬឃុនថាន់ មកឃាត់ទើបឈប់។ ម៉ែនុស្សហ៊ាវាយខ្ញុំណាស់ដែរ កាលណាមានគេនិយាយប្រាប់គាត់ថា ខ្ញុំប៉ិនដើរកម្ចីឈ្មោះប្រកែក ប៉ុន្តែវាយឯណាខាន់, គាត់គ្រាន់តែយារំពាត់ ខ្ញុំរត់ប្រួចពួនចាត់ត្រង់កន្លៀតណាមួយ ពុំងាយរកយើញឡើយ។

ស៊ុនជាពួកម៉ាកស្រីម្នាក់ ដែលន៉ពុក-ម្តាយវា មានផ្ទះនៅក្នុងសង្កាត់កំពង់ផែ ក្បែរផ្ទះខ្ញុំដែរ។ ម៉ែនុស្សហ៊ាមកសុំយកយើងទាំងពីរទៅក់ ទៅលេងផ្ទះណាស់។ បានទំនេរទៅផ្ទះ យើងគិតតែសប្បាយមុជទឹកទន្លេមួយថ្ងៃវាល់ល្ងាច។

កាលនោះ ដីច្រាំងកំពង់ផែពុំទាន់បាក់នៅឡើយទេ ហើយមានឆ្នេរខ្សាច់មួយដែលជាកន្លែងប្រជុំក្មេងៗក្នុងភូមិ មកប្រឡែង ឬ មុជទឹកហ៊ោកញ្ជ្រៀវយ៉ាងសប្បាយរីករាយ។ នរណាហ៊ានមកធ្វើឲ្យល្អក់ទឹកក្បែរកន្លែងយើងមុជ យើងជេរគេឥតឮញញើតមាត់, នរណាហ៊ានមកឡេមឡឺមក្បែរទីតាំងផែ យើងផ្ទេរម្ខាក់ទឹកភ្លាម។ ស៊ុនមានបងប្រុសម្នាក់ស្លូតណាស់, យើងបានចិត្ត តាំគ្នាធ្វើបាបវាឲ្យយំជាច្រើនៗ។ ពេល ស៊ីបាយ យើងផ្តាប់ចានចាក់បាយវាចោល យើងប្រមូសប្រទាញប្រទាស់ទម្លាក់ទឹក ឬក៏ ចាក់រុកវាឲ្យឈ្លោះវាយតប់ជាមួយពួនគេនៅជិតខាង ដែលមកឆាចៅយើង។ យើងស្លៀកសារុងចងក្បិនកប់ក្រលៀន ខ្លួនទេ ជ្រៀបបានឆឹងបិសាចមែនទែន សូម្បីតែក្មេងប្រុសៗក៏ខ្លាចយើងដែរ។

ជួនកាល យើងប្រមូលគ្នាបានមួយក្រុម ច្រឡឹមផ្ងួចយួភ្លុង រត់ចេញប្រសេចប្រសាចពីភាំង ទៅមើលរូបចម្លាក់ប្រឹងរាមស្ក្តើ ឆ្លាក់ជាប់នឹងជញ្ជាំងវិហារវត្តព្រះកែវ ឬក៏ ដើរសម្លុតផ្ទះអ្នកដែលមានឪពុកាថា ហួងប្រើយើងឲ្យមកសុំបេះផ្កា ហើយមិនចាំបាច់ម្ចាស់គេថា ឲ្យឬមិនឲ្យទេ យើងប្រញាយគ្នាបេះបង្ហិនបង្ហោចរបស់គេភ្លាមមួយរំពេច។ កាលណាយើងជួបនឹងពួកក្មេងប្រុស ស្លៀកពាក់ស ពាក់មួកកន្ទេល និង ពាក់ស្បែកជើងឃ្លុប ដើរចេញពីសាលាទៅឯសង្កាត់ខាងជើងនោះមក យើងនាំគ្នាស្រែកជេរគេថា អាក្បត់ជាតិអាខ្ញុំបាវាំង ដែលជាហេតុធ្វើឲ្យគេខឹង រត់ដេញតាមប្រជាប់ចាប់ប្រកឹង រហូតទាល់តែដល់ក្លោងទ្វារភាំង។

ពីរ-បីខែ កន្លងផុតទៅ យើងនៅតែសមរបាំរាល់ថ្ងៃ រហូតដល់ពេលធ្វើបុណ្យតាំងពុ ដែលឆ្នាំនេះក៏ផ្ទួចជាឆ្នាំមុខ្យៃដែរ គឺប្រជាពលរដ្ឋក្នុងទីក្រុងសឹងតែទាំងអស់ និង ឥស្សរជនមុខមន្ត្រី មកពីគ្រប់ខេត្តទីណូមកប្រជុំគ្នាត្រៀបត្រាក់ករជុំវិញបន្ទប់ខាងក្រៅ។ នេះជាពិធីបុណ្យចំបើរបស់ព្រះជន្មចុងក្រោយបំផុតរបស់ ស្តេចសុវណ្ណកោដ្ឋ ហើយគ្មានអ្នកណាចាប់ភ្លឹកគិតថា មរណាភាពនៃព្រះអង្គ ជិតធ្វើដំណើរមកដល់នោះទេ។

ក្នុងឧកាសបុណ្យនេះ ខ្ញុំត្រូវចេញរាំនៅចំពោះមុខសាធារណជនជាលើកដំបូងបំផុត ដោយគ្រាន់តែធ្វើជាតួរាយរេងប៉ុណ្ណោះ។ សម្លៀកបំពាក់តែងខ្លួនរបស់ខ្ញុំ ពុំអាចយកទៅប្តីមនឹងពួកអ្នកល្បីឈ្មោះចាស់ៗដែលគេដើរជាតួឯកនោះបានទេ។

ពួកអ្នកគ្រូលុតដង្កង់ក្បែរយើង រៀបចំស្លៀកពាក់ឲ្យ ទាញខ្នើបត្រង់ណោះបន្តិច ត្រង់ណោះបន្តិច យកម្ខាលមកចាក់ខ្ទាស់ ឥតវល់ប្រឹងមុតដល់សាច ឬ នរណាស្រែកឈឺអ្វីទាំងអស់។ យើងត្រូវឈរស្លៀកពាក់របៀបនេះពេញមួយល្ងាច បណ្តាលឲ្យជាយជើងឈរមិនឡើង។ ជាពិសេសទៅទៀត យើងត្រូវឈ្លោះប្រកាប់ប្រចាក់គ្នា ដណ្តើមគ្រឿងអលង្ការក្រៃលែ និង អង្ករអ្នកគ្រូ ដើម្បីឲ្យបានស្លៀកខោអាវល្មមខ្លួន។

ពុទ្ធោអើយ! តែងខ្លួនរៀបហ្នឹងមួយថ្ងៃ ខ្ញុំសឹងតែត្រាំមិនបាន។ ណាមួយម្ខាមែនឹងអ្នកតែងខ្លួន ដែលវល់ប្រចុបប្រចៀងតែជាមួយអ្នករបាំណា ដែលត្រូធ្យូពេញចិត្តប៉ុណ្ណោះ ចំណែកយើងវិញ គេយកម្ខាលខ្ទាស់

មកចាក់មុតដល់សាច់ ក៏មិនខ្លីឈឺក្បាលគេផង។ ពួកស្រីធំៗដែលមានដើមទ្រូងពេញ រឹតតែជួនណាស់ ទៅទៀត ព្រោះគេយកអាវចង្កៀតណែនក្តៅខ្លាំងមកឲ្យពាក់រឹតរួតដោះស្ទើរបែក ដើម្បីតែងខ្លួនធ្វើឲ្យប្រុស គេឲ្យស្លៀកខោខ្លីប៉ាក់អង្កាំ សុទ្ធតែក្អែលក្រខ្វក់បន្តគ្នាពីមួយទៅមួយ ពុំដឹងជាប៉ុន្មានដំណមកហើយ ហើយពុំដែលឃើញបោកគក់ម្តងណាសោះ។ ថ្ងៃណាមួយខ្ញុំតង់ឌឹងបានជួបប្រទះ ទុក្ខវេទនារបៀបដូចគ្នានេះមិនខាន ដើម្បីតែងខ្លួនឲ្យបានល្អប្រិមប្រិយ៍។

ជួនកាល ស្លៀកពាក់ចូចស្រេចបាច់អស់ទៅហើយ សល់តែលាបម្សៅ ភ្លូចិញ្ចើមរោមភ្នែក លាបបបូរមាត់ បន្តិចបន្តួចប៉ុណ្ណោះ ស្រាប់តែឈឺ បត់ជើងតូច បត់ជើងធំ ខ្លាំងមែនទែន ត្រាំអត់មិនបាន ភ្លេងៗក៏ទ្រហោរយំដោងឡើង, នរណាធំប្រកែកតមាត់ជាមួយអ្នកតែងខ្លួន ទាល់តែគេដោះសម្លៀកបំពាក់ចេញស្ទើរតែទាំងអស់ ហើយរត់ច្រាសច្រាលទៅដោះទាល់ទៅត្រង់កន្លៀតណាមួយសិន ពីព្រោះបង្គន់នៅឆ្ងាយពេក ពុំអាចទៅមកបានរហ័សទាន់ចិត្តឡើយ... ។

ក្មួនសិស្សខ្លះដែលហាត់ពុំបានស្ទាត់ល្អ ដល់ឮស្គរឮហ្លួង ឃើញភ្លើងព្រោងព្រាត ឃើញមនុស្សឈរមើលត្រឿបត្រា វាទៅជាភ័យស្លន់ឈឺនោមបន្តិចឈឺជុះបន្តិចអញ្ចឹង តើត្រូវធ្វើម៉េចហ្ន៎ បើជិតដល់ពេលចេញរាំណាស់ទៅហើយ? ដល់រាន់ខ្លាំងមែនទែន ក្មួនសិស្សហ៊ានជជែកមាត់ប៊ីប៊ែសជាមួយគ្រូ លែងកោតខ្លាចអ្វីទាំងអស់។ ហួសពេលទៅហើយ ទម្រាំតែដោះសម្លៀកបំពាក់ និង ស្លៀកមកវិញនោះ ពុំដឹងជាកាលណាទើបបានចេញរាំទេ។ ម្ល៉ោះហើយបញ្ហានេះ ត្រូវតែរកផ្លូវដោះស្រាយដោយខ្លួនឯង គឺនរណាត្រាំទប់ពុំជាប់ ក៏ធ្វាយនោមទទឹកខោពណ៌បៃតងខ្ចី ឬ ក្រហមនោះជោក ហៀរដល់កន្ទេល ប្រឡាក់ដល់ជើងអ្នកគ្រូ ដែលអង្គុយបើកភ្នែកធំៗហួសចិត្តរកស្តីមិនចេញ។ ទឹកឃើញអញ្ចឹង ខ្ញុំព្រឺខ្លួនខ្លាចចំលើថ្ងៃស៊ីយ ប្រឹងរាំវានេះវាកើតចំពោះខ្ញុំតែម្តង។

ពេលចេញរាំជិតមកដល់ ខ្ញុំរឹតតែភ័យខ្លាំងឡើងៗ។ ដូចកាលយប់រាំសមជើងនៅក្នុងភាំងនោះដែរ ខ្ញុំយកធួបមកអុជដាក់ពីមុខមុកដមុខស្វាមុខយក្ស សុំឲ្យព្រាយសោធជួយកុំឲ្យទន់ដៃទន់ជើង។ អ្នកគ្រូសិតលើកមកដល់ខ្ញុំឡើង ជាក់កស្តែងយ័ឌមានចារគាថាលើនោះផងពីខាងក្នុង ទើបចំពាក់ឲ្យខ្ញុំ សម្រាប់ការពារកុំឲ្យហួចក្បាច់ណាមួយនៅកណ្តាលឆាក។

ដល់ជនខ្ញុំត្រូវចេញ គេចែកគ្នាតាមរបៀប គឺឲ្យខ្ញុំចេញមុនគេ ហើយបន្តគ្នារហូតដល់អ្នកណាអាយុច្រើនជាងគេ ឲ្យនៅក្រោយបង្អស់។ កាលនៅផ្ទះលោកអ៊ុំអគ្គមហាសេនា ខ្ញុំធ្លាប់រាំដើរជាតួសំខាន់ៗតែម្នាក់ឯងរួចអស់ទៅហើយ, ម្ល៉ោះហើយ ត្រាន់តែភ្លេងចាប់ប្រគុំភ្លាម ខ្ញុំក៏ស្ទុះភ្លែតចេញទៅ ដោយទំពត់ពេទ ចលនាជាងខ្លួនទៀង អាយវៈ: ឲ្យត្រូវឥតខ្ចោះតាមចង្វាក់ភ្លេង។ យាយចាស់ៗដែលអង្គុយបត់ជើងព័ទ្ធជុំវិញឆាក ជជែកគ្នារអ៊ូរអ៊ើរ ហើយហួងក៏ស្រែកប្រាប់ជាភាសាសៀមទៅកាន់នាម៉ឺនម្នាក់ដែលលុតជង្គង់ក្បែរនោះដែរ។ ខ្ញុំមិនខ្លីស្តាប់នរណានិយាយថាអ្វីទាំងអស់ រាំទាល់តែគ្រប់មួយជុំឆាក ទើបខ្ញុំត្រឡប់ចូលមកក្នុងវិញក្នុងចិត្តគិតស្មានថាខ្លីឯងបានទទួលពាក្យកោតសរសើរមិនខាន។ ប៉ុន្តែខ្ញុំបែរជាបានទទួលសំណើចចំអកឡកឡឺយពីអ្នករាំផ្ទួចគ្នា និង រំពាត់ផ្តៅពីអ្នកគ្រូ ជារង្វាន់ទៅវិញ។ ម៉េចក៏ខ្ញុំហ៊ានចេញទៅមុនពេលគេឲ្យសញ្ញា? ម៉េចក៏ខ្ញុំចេញទៅតែម្នាក់ឯង ពុំព្រមចាំអ្នកឯទៀតផង? ខ្ញុំចង់យកមុខយកមាត់តែម្នាក់ឯង ដើម្បីបំបាក់មុខធ្វើឲ្យហួងខ្មាសភ្លៀវបារាំងឬអ្វី? គេក្តិចមួលភ្លៅខ្ញុំចេញឈាមទាល់តែខ្ញុំយំ។ ពេលនោះ ឃុនថាន់ចូលមកជិតនិយាយលួងលោមខ្ញុំថា ខ្ញុំធ្លាប់តែរាំម្នាក់ឯង បានជាថ្ងោះធ្លោយអញ្ចឹង, ចាប់តាំងពីពេលនេះតទៅ ខ្ញុំត្រូវប្រយ័ត្នមើលគេមើលឯងឲ្យមែនទែន។

ម្តងនេះ ខ្ញុំប្រែងប្រៀបខ្លួនស្រួលបួលចេញរាំជាថ្មីម្តងទៀត ដោយមានគេឯងចេញមកហូរហែតាម ក្រោយហើយចាំបាន់ប្រព្រឹត្តទៅរហូតដល់ចប់ គ្មានការច្រដេងច្រដាងផ្សេងទៀតឡើយ។ ប៉ុន្តែ ខ្ញុំចងគំនុំឌឹងអ្នកគ្រូសិតជ័ន្ធាស់នោះជាប់រហូត ទើបខ្ញុំប្រកែកលែងព្រមហាត់ជាមួយគាត់។

ខ្ញុំសំណាក់ទៅក្នុងរោងក្បែរផ្ទះ ឃុនព្រះញាតិ។ ស្ងាចនោះ គេយកឰពុកមកក្រាលលើភ្លារ និង ចងមុងធំជើង ដើម្បីឲ្យពួកល្ខោនទទួលទានដំណេកជាមួយគ្នាទាំងអស់តែម្តង។ ខ្ញុំចូលចិត្តរស់នៅជាមួយគ្នាច្រើនថ្ងៃទេ ជាងរស់នៅម្នាក់ឯង ព្រោះខ្ញុំខ្លាចខ្មោចណាស់។

យប់ឡើង នរណាអស់កម្លាំងក្ស័សារាន់ចូលមុងមុនគេទៅ អ្នកខ្លះទៀតនៅលេងបៀឬជក់ចាំរីឯជជែកគ្នាអែ រហូតដល់យប់ជ្រៅ។

អ្នកផេកជិតខ្ញុំឈ្មោះរុន។ គាត់មានអាយុបងខ្ញុំជាងដប់ឆ្នាំ ហើយបានលះបង់ការរាំរ៉ែកជ្រះស្រឡះដើម្បីទៅបំរើហ្លួងវិញ។ មិនយូរប៉ុន្មាន គាត់ក៏ចាប់ចិត្តរាប់អានខ្ញុំ ហើយខ្ញុំក៏ស្រឡាញ់គាត់ដូចជាបងស្រីបង្កើតម្នាក់ដែរ គ្រាន់តែបានពឹងពាក់គ្នាទៅវិញទៅមកពេលឈឺថ្កាត់យប់ព្រលប់។ ខ្ញុំផេក អោបឬគងគាត់ បានតាមចិត្ត ព្រោះគាត់ទ្រមក់ផេកណាស់ ទាល់តែកាលណាក្តៅស្អុះ ទើបច្រានខ្ញុំចេញ។ រាល់យប់មុនពេលផេក យើងជជែកគ្នារអ៊ូរ៉ា ពីរឿងរ៉ាវកំប៉ិកកំប៉ុកក្នុងភាំង ពីកិច្ចការប្រចាំថ្ងៃ និង ពីកិច្ចការសម្រាប់ថ្ងៃស្អែករហូតដល់ផេកលក់ម្យ៉ាងខ្លួន។

ព្រឹកមួយនោះ ខ្ញុំភ្ញាក់ពីផេកតាំងពីព្រលឹមខុសធម្មតា។ ដោយធាតុអាកាសរងាធ្វើឲ្យក្តុកខ្លាំងពេក ខ្ញុំក៏ទាញភួយពី បងរុន មកដណ្តប់ម្នាក់ឯង ស្រាប់តែឃើញមានឈាមប្រឡាក់ភួយមួយដុំ។ ខ្ញុំភ័យស្លន់ ស្មានថាបងរុនស្លាប់ឬត្រូវរបួស ក៏តាំងស្រែកឆោឡោ ដើម្បីបង្ហើលដាស់អ្នកជិតខាង។ បងរុនស្ទុះងើបឡើង, ដល់ឮខ្ញុំនិយាយរឿងនេះប្រាប់ គាត់យកដៃខ្ចប់មាត់កុំឲ្យខ្ញុំនិយាយតទៅទៀត ហើយងើបទៅផ្ទាស់សំពត់ចេញភ្លាមមួយរំពេច។ គាត់បបួលខ្ញុំផេកទៅវិញ តាំបន្ទប់និយាយពីរឿងស្រីទៅបំរើហ្លួង ដែលត្រូវបក់ធ្មិតគក់ច្រចាច់ តាំងយប់តាំងថ្ងៃ ព្រមតាំងឲ្យដំបូន្មានថា ថ្ងៃណាមួយខ្ញុំត្រូវរកផ្កាឬផ្លែឈើ ទៅថ្វាយហ្លួង ដើម្បីបានរង្វាន់ខ្លះផង។ គាត់និយាយទាល់តែខ្ញុំផេកលក់ទៅវិញ។

កន្លងមក ពីរ-បីថ្ងៃ ស៊ុនឌឹងខ្ញុំ បានច្បាប់ទៅលេងផ្ទះមួយថ្ងៃ, ពុកក៏បានឈប់ធ្វើការ ប្រុងប្រៀបចេញទៅផ្ទះដែរ។ ខ្ញុំគ្មានលុយមួយសេនជាប់ឌឹងខ្លួនសោះ ប៉ុន្តែខ្ញុំប្រាប់ពុកឲ្យទៅផ្សារទិញផ្លែឈើល្អៗ សម្រាប់យកទៅថ្វាយហ្លួង។ ពុកប្រញាប់រត់ទៅផ្សារ ទិញបានផ្លែទទឹមទុំ ព្រមតាំងខ្លីថាសប្រាក់របស់ ឪពុកម្តាយស៊ុន មកវៀបចំដាក់យ៉ាងត្រឹមត្រូវទៀតផង។ ត្រឡប់មកភាំងវិញ ខ្ញុំប្រថុយចូលទៅក្នុងប្រាសាទមេខលាដែលទៅក្នុងនោះ ហួងកំពុងផ្តុំសោយអាហារលើតែ្រប្រកបទៅដោយចម្លាក់ក្បាច់ក្បូរល្អប្រណីត។ ហួងមើលមកឃើញខ្ញុំអង្គុយត្រង់កន្លៀតក្បែរកញ្ចក់ ក៏សួរទៅពួកស្រីអ្នកវៀបចំខ្សៀវអាហារ:

~ មីតួចហ្នឹង វាមករកអី?

បងរុន ដែលកំពុងអង្គុយបក់ផ្ទិតទៅចុងជើងតែ្រនោះ ទូលហួងភ្លាម:

~ ក្រាបទូល, នាងយ៉ែម ចង់យកផ្លែឈើមកថ្វាយព្រះអង្គ។

~ អើ! ឲ្យវាចូលមក ហើយឲ្យគេយកប្រាក់មួយណែនមកឲ្យវាផង។

ស្រីម្នាក់ដែលទទួលវេទកាន់ភួងសោក្នុងថ្ងៃនោះ នាំយកប្រាក់ត្រប់ចំនួនមកឲ្យខ្ញុំ, ខ្ញុំថ្វាយបង្គំហួងសំដែងទឹកចិត្តត្រេកអរឥតឧបមា។ លោកសម្លឹងមើលខ្ញុំយ៉ាងយូរ ញញឹមបន្តិចព្រមតាំងមានបន្ទូលថា:

~ ម៉េចក៏គេមិនចុះឈ្មោះវាក្នុងបញ្ជីអ្នកមកបម្រើអញ? ក្មេងហ្នឹងវាឧស្សាហ៍ណាស់ណា!

~ វានៅក្មេងពេកក្រាបទូល (បងអូន ធ្លើយ) អាយុមិនទាន់ត្រប់ដប់បួនឆ្នាំស្រួលបួលផង ។

~ បើអញ្ចឹង មីតួចឯងទៅវិញចុះ ហើយថែ !... ខំស៊ីបាយឲ្យឆាប់ធំឡើង ! ។

ខ្ញុំជាយមកកន្លែងដេកវិញ យកលុយលាក់ក្នុងហិបនៅក្បាលដំណេក ដើម្បីទុកឲ្យម៉ែ ។ នៅពេលជួបហួងលើកទីពីរនេះ ខ្ញុំមិនស្ទុះភ័យដួចកាលមុនពេកទេ ។ ខ្ញុំចាប់ផ្តើមនឹកថា មុខការរបស់ហួង មានត្រឹមតែចែកលុយមាសពេជ្រ ឲ្យស្រី និង ក្មេងបំរើព្រះអង្គ ប៉ុណ្ណោះ... ខ្ញុំឧស្សាហ៍ហ៊ានប្រថុយដើរទៅឡេមឡឺមក្បែរប្រាសាទមេខលា ដែលឃើញមានអុជភ្លើងភ្លឺ សប្បាយរីករាយអ្វីអាជាទិច្ចតាំងយប់ទាំងថ្ងៃ ហើយដែលនៅក្នុងនោះ ហួងរស់នៅប្រកបដោយក្តីសុខកាយសប្បាយចិត្តជាអតិបរមា កណ្តាលចំណោមស្រីបម្រើស្អាតៗ ដែលត្រូវគេផ្គាស់ប្តូរយកអ្នកថ្មីមកជំនួសជារឿយៗ ។

ស៊ុន និង ខ្ញុំ មានទម្លាប់ទៅលបមើលកិច្ចការក្នុងប្រាសាទមេខលា ឥតមានខានមួយយប់ណាឡើយ ដោយទាំងពួនក្បែរភាលខាងក្រោយ ដែលលយចូលទៅដល់ក្នុងសួនច្បារ ងងឹតចាក់ភ្នែកមិនយល់ ។ ខ្ញុំចំអើតមើល ក្បាលស៊ីងតែមិនដល់ក្តារក្រាលនៃភេនហាលនោះផង ប៉ុន្តែបានស្បែងងឹត ជួយបិទបាំងមិនឲ្យអ្នកដើរទៅមកកាត់តាមនេះ មើលយើងឃើញឡើយ ។

ហួងសោយបាយតិចណាស់ រវល់តែយកស្លាបព្រាចូកបាយដុះចោលទៅលើក្តារ ជាទិម្ឌលដើម្បីធ្វើឲ្យរាស្ត្រសម្បូរណ៍ស្រួវ-អង្ករបរិភោគ ។ មួយថ្ងៃៗ ហួងសោយអាហ៊ែនទិង ផ្តុំវាល់ល្ងាច ដល់ព្រលប់ធំ ទើបតើនឡើងដើម្បីសោយព្រះស្ងោយតែម្តង ។ ព្រះអង្គ ទ្រង់សោយលើតុ ជួនកាលម្ហាក់ឯង ជួនកាលមានឃុនឬ ម៉មដែលគាប់ចិត្ត មកអង្គុយកំដរផង ។ ស្ត្រីភ្លុនកាត់ ចិនយួន និង ហ្វីលីពីន ក្រងសក់ម្ខាក់ទៅក្រោយ និង ស្លៀកពាក់តាមរបៀបអ៊ីរ៉ុប ជាអ្នកទទួលថាសប្រាក់ជាក់ម្តួបពីអ្នកបើរើ យកមកជូនថ្វាយហួង ។ ខ្ញុំសង្កេតមើលឃើញម្តួបទាំងនោះ ជួនកាលធ្វើតាមរបៀបសៀម ជួនកាលតាមរបៀបចិនឬរបៀបយួន របៀបបារាំងក៏មានដែរ ។ ប្រពន្ធហួងដទៃទៀត អង្គុយបត់ជើងលើកន្ទេលក្រាបផ្គាល់ទិងក្តារ បរិភោគបាយយ៉ាងស្ងៀមស្ងាត់ ។

ដល់ពេលយប់ជ្រៅ ហួងស្ងៀកសារុង និង ដណ្តប់ជាហ៊ុំ ចូលទៅអង្គុយកណ្តាលចំណោមស្រីៗ ស្រែកច្រៀងសក្តវិទីលេងជាមួយគ្នាយ៉ាងសប្បាយរីករាយ ប៉ុន្តែសម្លេងហួងធំគ្រប ឮខ្លាំងលុបអស់សម្លេងស្រី ។ ចំណែក ទាម៉ុន និង ស្រីអ្នករបាំ ដែលអង្គុយជុំនៅខាងក្រៅនោះវិញ គេទាំងគ្នាស្តាប់ចម្រៀងនេះធ្វើក្អែកមមើរ ។

យប់ទីមួយៗកន្លងទៅដោយក្តីរីករាយ ក្នុងការច្រៀងរាំ ក្នុងការជក់អាភៀន ឬបារី ដែលហួងចែកឲ្យគ្រប់គ្នា គ្មានសំណាងកខ្វាយខ្វល់ព្រួយបារម្ភពីរឿងអ្វីឡើយ ។

យប់មួយនោះ ខ្ញុំអើតឡេមឡឺមតាមមើលបងអូន ឃើញគាត់លួចបានទំពីរនៅក្តៅគគុកហុចមកឲ្យខ្ញុំ ។ ឆ្ងាញ់ទាំងមាត់, ឆ្ងាញ់ទាំងក្អែក, ខ្ញុំឈរសេប្បាយភ្លើតភ្លើនភ្លេចខ្លួន ស្រាប់តែលេចជើងពីរនៅលើរាតហាលរិះជាន់ចំក្បាលខ្ញុំ ហើយភ្លាមនោះ ទឹកទោមក៏បាញ់ច្រួចពីលើមក ទទឹកស្មាខ្ញុំអស់មួយចំហៀង រកតែខ្ញុំគេចចេញក៏ពុំទាន់ ។ ខ្ញុំភ្ញាក់ផង ភ័យផង ស្ទុះដាយក្តីងឥតងាកក្រោយ ។ ពេលនោះ ខ្ញុំឮសម្លេងហួងស្រែកឡូឡាឡើងទាំងកណ្តាលយប់ស្ងាត់ :

~ មីច្រឡឹមអស់ហ្នឹង វាចង់ឲ្យអញទោមច្រាសក្បាលណាស់ទៅឬអី ?

សម្លេងស្រីៗសើចសប្បាយហ៊ោកញ្ជ្រៀវរសាត់មកដល់ត្រចៀកខ្ញុំ នៅពេលដែលខ្ញុំរត់មកដល់កន្លែងដេក ដើម្បីផ្លាស់សម្លៀកបំពាក់ និង យកសាប៊ូទៅមុជទឹកជុះពងួនឲ្យជ្រះចង្រៃ ។

ពេលវេលាកន្លងទៅយ៉ាងឆាប់រហ័ស... ពិធីបុណ្យមួយ ហើយមួយទៀត ចេះតែមានបន្តបន្ទាប់គ្នានៅក្នុងវាំង ហើយឲ្យតែដល់បុណ្យម្តងៗ ហួងតែងចែកប្រាក់ដល់ ស្រីបំរើ និង ពួករបាំ ឥតដែលខាន ។

ថ្ងៃមួយ ហួងទឹកក្អកចង់ធ្វើជាអធិបតីក្នុងពិធីកាត់សក់ពួកណ្តោនក្មេងខ្លះៗ នៅក្នុងប្រាសាទមេខលា ។ អ្នកដែលមានសំណាងត្រូវបានគេជ្រើសរើសមកឲ្យកាត់សក់នៅក្នុងទុកាសនោះគឺ គីញ, ម៉ាលួន, ម៉ែឡូន, ចន្ថ, ថៃ្យសេន និង ខ្ញុំ ។ ហួងមើលឃើញសក់ហួងដុះរបស់ខ្ញុំធំជាងគេ ក៏ស្រាយខ្សែម្ហាក់សំយាកទៅក្រោយខ្នង ។ ខណៈពេលនោះ ពួកព្រាហ្មណ៍ក្រុយកកាំបិតកោរមាសមកដល់ពេក ហួងក៏ទឹងតឆ្លងឡើង ទាញយកកន្ត្រៃមកកាត់ច្របសក់ខ្ញុំ ជាច់រធិញរធុញអស់រលីង ។ បន្ទាប់មក ពួកបាឆ្លមកដល់ ចាត់ការកោរសក់ខ្ញុំបង្ហើយ និង ផ្តុំសង្ខប្រសិទ្ធី ។ ហួងឡើងឈរលើតាទម៉ា យកទឹកមន្តមកច្រួចជាក់លើក្បាលយើងម្នាក់បន្តិច ។

ពុកខ្ញុំវល់ធ្វើការ ពុំបានមកមើលពិធីនេះទាន់ពេលវេលាទឹងគេទេ មានតែម៉ែម្នាក់ឯងគត់ ដែលបានមកប្រមូលសក់ខ្ញុំ យកទៅរក្សាទុកយ៉ាងម៉ត់ចត់ ។ ក្រោយមក ម៉ែប្រាប់ខ្ញុំថា គាត់យកសក់នោះទៅប្រគេនលោក ទុកសម្រាប់ចងសាស្ត្រាទៅហើយ ។

គេសរសើរសំណាងខ្ញុំស្រប់ថ្នា ព្រោះថា គីហួងខ្លួនឯង ដែលបានកាត់សក់ខ្ញុំជាសញ្ញាបង្ហាញឲ្យឃើញថា ហួងគាប់ព្រះទ័យនឹងខ្ញុំខ្លាំងណាស់ ។ បន្ទាប់ពីកាត់សក់រួចហើយ ឃុនថាន់ ឃុនព្រះញាតិ និង អ្នកឯទៀតដែលអង្គុយព័ទ្ធជុំវិញយើងនោះ តាំងាបង្វិលពពិល ហុចបន្តគ្នាពីមួយទៅមួយស្រប់ចិត្ត ទើបគេយកអំបោះឆៅមកចងរុំក្បាលយើង ព្រមទាំងហាមថា ទាល់តែស្រប់មួយរំខើបឲ្យស្រាយចេញ ។ ខាងក្រោយខ្លួនយើង មានភ្ងូនតាមីនធំៗពីរ-បីនាក់ មកសុំកោរសក់ក្នុងទុកាសជាមួយគ្នានេះដែរ ប៉ុន្តែពួកវាគ្រាន់តែបានពួកព្រាហ្មណ៍កោរឲ្យតែប៉ុណ្ណោះ ។

♥ ♥

♥

នាដ្យការី



យើង កាន់តែធំពេញវ័យពេញរាងបន្តិចហើយ... គេអនុញ្ញាតឲ្យយើងទុកសក់ជីង លែងឲ្យកោរដូចមុនទៀតហើយ... ។ យាយចាស់ៗអង្គុយជជែកគ្នាអែនៅតាមកាំជណ្តើរដំណាក់ឲ្យតែយើញខ្ញុំដើរទៅជិត គាត់និយាយចំអែចំអន់ភ្លាមថា អាយុប៉ុនខ្ញុំល្មមមានប្តីហើយ! ខ្ញុំមិនសូវរវល់យកចិត្តទុកដាក់ស្តាប់សំដីអស់នេះទេ ប៉ុន្តែខ្ញុំចាប់ផ្តើមយល់យ៉ាងច្បាស់ ទ្វារឡើងរ៉ាវដែលបណ្តាលឲ្យពួកប្រុសកម្លោះ ដើរក្រឡឹងជុំវិញភឹង ប្រឹងតាមសម្លក់ស្រីៗដូចឆ្កែតាមសម្លក់ឆ្អឹងស៊ុប ។

ពេលមួយនោះ ម៉ែនាំខ្ញុំទៅលេងនឹងពួកម៉ាកស្រីគាត់ម្នាក់ ជាអ្នកហួងនៅឯភឹងសម្តេច នុហាជ[4] ។ ចាប់តាំងពីពេលលោកអគ្គមហាសេនាអ៊ុម ជាឪពុកធំខ្ញុំស្លាប់ទៅ ខ្ញុំខានមកលេងភឹងខាងជើងនេះយូរហើយ ។

ភឹងរបស់ស្តេចទីពីរនេះ មិនដូចគ្នានឹងភឹងចតុមុខទេ មើលទៅឃើញដូចជាភឹង "អ្នកស្រែ" អញ្ចឹង ។ សួនច្បារមានស្មៅដុះត្រួបត្រួល ព្រោះគ្មានអ្នកថែទាំ ក្រឿងតុបតែងមិនហ៊ឺហា ផ្ទះនីមួយៗចង្អៀតជីខ្លួនមិនសូច របៀបរបប នៃ ពួកនាម៉ឺន និង ពួកបាំ ក៏មិនសូវត្រឹមត្រូវ ក្រខ្សែកទៅកៀកខ្ទៀតណា ក៏ឃើញតែតក្រិចស្មោកគ្រោកគួរឲ្យខ្ពើម ។

នៅទីនេះ មានក្រុមល្ខោនតែមួយគត់ ដែលដឹកនាំដោយព្រះអង្គម្ចាស់ក្សត្រីយ៍ ដ៏ល្បីល្បាញឈ្មោះ វិមធីតា ជាកូនបង្កើតរបស់សម្តេចនុហាជ ។ ក្នុងក្រុមល្ខោននេះ នរណាចង់ធ្វើអ្វីក៏ធ្វើទៅ ព្រោះមួយថ្ងៃៗម្ចាស់ក្សត្រីយ៍ចាងហ្វាងនោះ រវល់តែជក់អាភៀនបង្ខុយដូចនុំពុកដែរ ហើយបើនិយាយពីរឿងស្រាវិញ ម្ចាស់ក្សត្រីយ៍ក៏ពុំមែនអន់ប៉ុន្មានដែរ លេងសុទ្ធតែ "សិច" តែម្តង ។ ដល់មានចៅហ្វាយធំជាអ្នកឲ្យនុខាហរណ៍អញ្ចឹង កូនចៅក៏ចេះតែនាំគ្នាជក់ ផឹកឬលេងល្បែងបៀបោ៊ តាមតម្រាប់ចៅហ្វាយ ដែលជាហេតុនាំឲ្យកើតការរាយច្បាំយគ្មានសណ្តាប់ធ្នាប់យ៉ាងនេះ ។

នៅពេលដែលដឹងថា ខ្ញុំមកថ្វាយបង្គំម្ចាស់ក្សត្រីយ៍ ពួកគេស្រាប់តែនាំគ្នាឆ្ពើលឈូឆរដកកចំហមាត់មើលមុខខ្ញុំធ្វើហ្អី ព្រោះពួកគេកម្របានឃើញអ្នករបាំមែនទែន នៅឯភឹងខាងត្បូងនេះណាស់ ។ ទឹកឃើញដល់ពួកអស់ហ្នឹង ខ្ញុំថ្លងជាខ្មាសគេជួស ។ ម្ចាស់ក្សត្រីយ៍អង្គុយស្តៀចលើកន្ទេល និយាយសួរខ្ញុំថា តើខ្ញុំចង់មកនៅជាមួយលោកឬទេ ?

ខ្ញុំរកមើលមិនឃើញ សម្តេចនុហាជទេ ប៉ុន្តែកាលពីពេលមកមុនៗ ខ្ញុំធ្លាប់ឃើញ ធ្លាប់ស្គាល់លោកច្បាស់ណាស់ ។ លោកមានវ័យចាស់បន្តិចទៅហើយ ព្រមទាំងមានមារធំ និង សម្បុរណ៍សាច់ឈាមជាង

[4] នុហាជ នេះ ជាងារបស់ព្រះបាទ ស៊ីសុវត្ថិ មុនពេលបានឡើងសោយរាជ្យ ។

ស្តេចបង ដែលជាហួងសោយរាជ្យ ។ លោកជាក់ធ្មេញភ្លុកពីក្រាស់យ៉ាងល្អប្រណីត ធ្វើទិញពីអ៊ីរ៉ុបមកបម្លាមាត់ធ្នាក់ សក់សក្បុសដូចសំឡី ភ្នែកមុត ។

តាមលេចធ្លាពាក្យចចាមអារាមថា សម្តេចនុហាជ ដូចជាឆ្លួតឲ្យប់ម្តងៗផង គឺមានយប់ខ្លះ លោកស្រាតខោអាវ លបរត់ចេញទៅក្រៅភឹងតែម្នាក់ឯង ទាល់តែពួកនាម៉ឺនដេញតាមចាប់ប្រមូសប្រទាញ ទើបព្រមចូលមកវិញ ។ លោកមានវ័យចាស់បន្តិចមែន ប៉ុន្តែកម្លាំងលោកនៅមាំមួនល្អណាស់ ។ គេនិយាយច្រើនប៉ុនខ្ញុំថា ល្ងាចមួយនោះ មានបុរសម្នាក់កាន់ច្នោងធំ ចូលមកអុកឡុកក្នុងចៅលោកដល់ក្នុងថ្លៃភឹង លោកក៏ស្ទុះងើបឡើង ប្រើតែខ្សៀអាភៀនប្រយុទ្ធជាមួយជនខ្មោះ វាយវាទាល់តែសន្លប់ ហើយបង្គាប់ឲ្យគេយកទៅកាត់កចោលភ្លាមមួយរំពេច ។

គេនិយាយពីមាត់មួយទៅមាត់មួយទៀតថា ថ្ងៃណាមួយ សម្តេចនុហាជនឹងបានឡើងសោយរាជ្យទៅភឹងចតុមុខមិនខាន ហើយពួកអ្នកឡេមឡឺមរកបុណ្យសក្តិ ក៏តាំងតាំគ្នាអែបអបយកគាប់គួរតាំងពីឥឡូវ ។ នៅជុំវិញហួងចាស់ដែលធ្លាក់ខ្លួនឈឺនោះ ព្រះអង្គម្ចាស់ តាម៉ឺន មន្ត្រី ឃុន ម៉ម តាំគ្នាដណ្តើមកេរ្តិ៍ បុណ្យសក្តិ ទុកសម្រាប់ថ្ងៃស្អែកម៉ងៗខ្លួនឯងស្រេចអស់ទៅហើយ ។

ការដែលទ្វណាម ជាប្រពន្ធគាប់ចិត្តជាងគេ ដាច់ចិត្តបោះបង់ហួងចោល បានធ្វើឲ្យជម្ងឺព្រះអង្គកាន់តែដុនដាបថែមឡើងទៀតជាលំដាប់ រហូតដល់ហួងខ្លួនឯងក៏ដឹងខ្លួនថា មិនអាចរស់បានយូរតទៅមុខទៀតទេ ។

ទ្វណាម ជាកូនអ្នកស្រែសុទ្ធ ប៉ុន្តែបានមកនៅភឹងតាំងពីក្មេង ។ គាត់មិនសូវស្អាតប៉ុន្មានទេ ប៉ុន្តែទឹកមុខមានស្នេហ៍អ្វីម្យ៉ាង ល្អឲ្យអ្នកដងស្រឡាញ់រាប់អាន រហូតបានឡើងធ្វើជាតួឯកក្នុងក្រុមល្ខោន នៃ ឃុនថាន់ ។ ហួងពេញចិត្តនឹងមើលគាត់រាំឥតចេះធុញទ្រាន់ ហើយប្រទានមាសពេជ្រ លុយកាក់ បំពោរបំពោកឲ្យតែគាត់ម្នាក់ ច្រើនឥតនុបមា ។

ប៉ុន្តែ ទ្វណាមស្រឡាញ់តែខ្លួនគាត់ប៉ុណ្ណោះ ។ ដោយដឹងថា ហួងជិតអស់បុណ្យ គាត់តែងឆ្លៀតពេលចេញទៅក្រៅភឹង ដើម្បីទៅធ្វើឫកម៉ិកម៉ំក៏រឹតសម្តេចនុហាជ នៅឯភឹងខាងជើងនោះទៀត ។ សម្តេចនុហាជឈ្លក់នឹងសម្រស់ទ្វណាម ភ្លេចប្រពន្ធចាស់ឈ្មោះប្រឹម ដែលជាស្រីសៀមខ្មៅគគ្រិច ហើយបែរមកគាប់គួរជាមួយទ្វណាម រហូតដល់មានសន្យាថា នឹងលើកដំកើងគាត់ឲ្យមានអំណាចលើគេមួយភឹង កាលណាខ្លួនបានឡើងសោយរាជ្យ ទៀតផង ។

និយាយពីហួងវិញ ទោះបីឈឺដាបដើរមិនរួចយ៉ាងនេះក្តី ក៏នៅតែឆ្លៀតស៊ើបសួរពីរឿងទ្វណាមជានិច្ចគ្រាន់តែមិនចេញស្តីថាដូចម្តេច សុកចិត្តសម្ងំកើតទុក្ខតែម្នាក់ឯង ។ ថ្ងៃមួយ លោកប្រើគេឲ្យទៅហៅទ្វណាមមកគាល់ ប៉ុន្តែគាត់នោះចិត្តស្បើងប្រកែកពុំព្រមមក ដែលជាហេតុបណ្តាលឲ្យហួងខឹងច្រឡោតតួងឡើងបង្គាប់ឲ្យក្រុមភឹងបួនទាក់ទៅចាប់ទ្វណាមមកធ្វើឥរុណកម្ម ចងដាក់ឲ្យដេកផ្កាប់មុខលើដី ហើយយកកំពាត់មកវាយវាត់បែកឈាមរត្បាក់ ។ ទ្វណាមឈឺចាប់ខ្លាំងពេក ស្រែកយំជាទីឆ្អើលអស់មួយថ្ងៃភឹង គេចេញមកឈរមើលត្រឿបត្រា ។ បន្ទាប់មកគេដាក់ច្រវាក់បណ្តើគាត់យកទៅឃុំនៅក្នុងសាលាទាលីយក្ស ដែលជាកន្លែងឃុំឃាំងស្រីមានទោស ស្ថិតនៅឆ្ងាយឯចុងសួនច្បារឯណោះ ។

ឥរុណកម្មបែបនេះ នុស្សាហ៍មានញើកញាប់ណាស់ ។ អនុស្សាវរីយ៍យោរយៅជាងគេដែលខ្ញុំចាំមិនភ្លេចនោះ គឺថ្ងៃមួយគេចាប់យកស្រីរបាំម្នាក់ឈ្មោះលត្តា យកទៅធ្វើទោស ។ ទាំងនោះមានថ្ងៃពោះច្រើនខែហើយ ពុំអាចដេកផ្កាប់មុខកើត គេក៏ជីកដីឲ្យក្រហួងត្រង់ពោះហើយច្រានឲ្យដេក ដើម្បីគេធ្វើឥរុណកម្មយ៉ាងអមនុស្សធម៌ក្រៃលែង ឥតមានក្តីមេត្តាករុណាបន្តិចបន្តួចសោះ ។

ការផ្តាំផ្ញើទៅសងចំពោះទ្វណាម គឺជាអនុមាហរណ៍សម្រាប់បន្ទាចក្មេងជំនាន់ក្រោយ កុំឲ្យយកតម្រាប់តាម។ ខ្ញុំកឃើញដល់រំពាត់ផ្តៅដែងមាសនេះ ខ្ញុំខ្លាចញ័រសោច សូម្បីសព្វថ្ងៃនេះដែលខ្ញុំចេញផុតពីភឹងមកហើយក្តី ក៏ខ្ញុំនៅតែនឹកខ្លាចជានិច្ច។

ជីវភាពនៅក្នុងភឹង ប្រែជាស្រពាប់ស្រពោន លែងមានភាំច្រៀងសប្បាយហ៊ោកញ្ជ្រៀវអ្វីទាំងអស់។ គេឃើញតែព្រះសង្ឃគង់តម្រៀបជាជួរជុំវិញក្រឡាបន្ទំ លើកឆ្អឹតចាំងភ្នែក សូត្រធម៌ទាំងយប់ទាំងថ្ងៃ។ ទាល់តែដល់ពេលនេះទើបហ្លួងអាចយល់ និង ឃើញនូវសេចក្តីស្មោះត្រង់ពិតប្រាកដ នៃឃុនថាន់ និង ឃុនព្រះញាតិដែលមកចាំគាល់ទាំងយប់ទាំងថ្ងៃ ឥតគិតខ្មើយហត់។ ក្សត្រី, ក្សត្រា, អស់អ្នក, អស់ទាង ក៏នាំគ្នាមកជួបជុំក្នែកសំឡីងឆ្ពោះទៅក្រឡាបន្ទំឥតប៉ប្រិចដែរ។

ដល់ពេលស្ងួឈាមមែនទែន ហ្លួងបង្គាប់ឲ្យគេលើកលោកជាក់លើគ្រែស្នែង សែងចេញទៅក្រៅទាំងយប់អាត្រាត្រងងឹតឈឹង ដើរកាត់ស្មៅព្រៃពពីមពើមអស់ចិត្ត ទើបបង្គាប់ឲ្យត្រឡប់មករាជមន្ទីរ ហើយឲ្យគេផ្ទេរលើកជាក់ទៅលើកៅអីមានកង់ រុញទៅ រុញមក ឥតឈប់ឈរ។

សភាពស្ងប់ស្ងាត់ត្រជាក់ណាប់ពេញផ្ទៃភឹងទាំងមូល... គេឮតែសូរសម្លេងព្រះសង្ឃសូត្រកាវតា យ៉ាងលន្ឋេងលន្ឋោចគួរឲ្យស្រងេះស្រងោចក្រៃលែង និង សម្លេងមនុស្សខ្សិបខ្សៀវគ្នា។ ហ្លួងលើកដៃឡើងប្រាប់ឲ្យគេទៅស្ងៀម ហើយមានបន្ទូលខ្សាវៗថា:

~ អញអត់ភ្លេចទេ!

បន្ទាប់មក លោកហៅម៉មសួន មកប្រាប់ឲ្យទៅយកលុយប្រាំរៀលមកថ្វាយ ប៉ុន្តែ ម៉មសួន ទើបនឹងចូលទៅជិតដល់គ្រែ លើកដើងពាន់ថ្វាយ ស្រាប់តែហ្លួងទត់ដៃម្នាក់លុយទៅលើខ្នើយ ហើយមាត់និយាយថាដូចម្តេចក៏ល្អិច ងាកបត់កមកខាងឆ្វេងបន្តិច ហើយផុតដង្ហើមទៅ។

រំពេចនោះ សម្លេងទ្រហោយំក៏ផ្ទុះឡើង ទ្រហឹងអឺងអាប់រកស្តាប់ទិសតំបន់អ្វីមិនឮ។ ចំណែកឯក្មេងៗឃើញតែគែយំគ្រប់គ្នា មិនយល់ឡើងអីសោះ ក៏កើតក្តីកិតភ័យស្រែកយំជាមួយនឹងគេដែរ ព្រមទាំងស្រែករក ម៉ែ-ឪជួយ។

យើងរត់ប្រសេចប្រសាចតម្រង់ទ្វារព្រលប់ ប៉ុន្តែភ្លាមនោះទ្វារត្រូវគេបិទជិត ហាមមិនឲ្យចេញជាដាច់ខាត។ ពួកស្រីធ្យាភ័យច្រួលច្របល់ជាងគេ រត់ពីកន្លែងមួយទៅកន្លែងមួយ ស្រែកឆោឡោថា:

~ បន្តិចទៀតគេនឹងចូលប្លន់ភឹង ហើយស្ត្រី ទាំងក្មេង ទាំងចាស់ មុខជាត្រូវទាហានចាប់ប៉ោលលើរូបកាយ និង សម្លាប់ចោលទាំងអស់គ្នាមិនខាន។ ប្រហែលជាគ្មានឧរណាម្នាក់បានរួចរស់នៅជួបមុខ ម៉ែ-ឪវិញទេ ពីព្រោះស្តេចសុគតហើយ យើងអត់មានស្តេចគ្រប់គ្រងមើលខុសត្រូវដូចមុនទៀតទេ!។

♥ ♥

♥

ពុំបានចាំសព្វគ្រប់ថា ក្នុងពេលចលាចលនេះ កើតមានរឿងរ៉ាវដូចម្តេចខ្លះទេ។ តាមឮ គេនិយាយថា ពួកបាក់ឯងបានតាំគ្នាមកតំទាប់សព ស្តេចសុវណ្ណកោដ្ឋ និង យកមកុដរាជ្យពីក្នុងទីតាំងទេវាភិនិច្ឆ័យ ទៅយាង សម្តេចនុហាជ ពីភឹងខាងជើង ឲ្យមកគង់នៅភឹងចតុមុខវិញ។

គេឲ្យយើងស្ងៀកពាក់ស ព្រមទាំងកោរសក់យើងទាំងអស់គ្នា ទាំងអ្នករបាំ, ទាំងអ្នកបំរើផ្ចាល់។ បន្ទាប់មក មានធ្វើពិធីផ្សេងៗទៀត ដែលមានតែចាស់ទុំប៉ុណ្ណោះត្រូវទៅធ្វើ ហើយព្រះសង្ឃសូត្រព្រះធម្ម ទាំងយប់ទាំងថ្ងៃ នៅជុំវិញកោដ្ឋមាស ដែលនៅក្នុងនោះគេបញ្ចុះសពហ្លួង ដោយយកកាំបិតកាត់ផ្តាច់ សរសៃដៃ សរសៃជើង ដើម្បីស្រណុកទាញឲ្យអង្គុយរបៀបលុតជង្គង់សំពះ។ កោដ្ឋនេះជំកស់នៅក្នុងប្រាសាទព្រះធម្មសង្វេគ ទុកសម្រាប់ធ្វើបុណ្យបូជានៅឆ្នាំក្រោយ។

លោកមហាមន្ត្រី អ្នកខ្នួលការ:មើលរបៀបរៀបរយក្នុងភឹង បានបើកទ្វារភឹងអនុញ្ញាតឲ្យ ឪពុក-ម្តាយ ពួកណ្តែន ចូលមកមើលខុសត្រូវ និង ចាត់ចែងរឿងក្មួនចៅរៀងៗខ្លួន។ ម៉ែចូលទៅតាល់ឃុនព្រះញាតិដើម្បីនិយាយចង់យកខ្ញុំទៅនៅផ្ទះវិញ ឲ្យបានទាន់មុនពេលស្តេចថ្មីឡើងសោយរាជ្យ ពីព្រោះខ្ញុំនៅប៉ំរើហ្លួងអស់ពេលជាងមួយឆ្នាំហើយ មិនដែលឃើញបានប្រយោជន៍អ្វីចំពោះខ្លួនឯង ឬ បានប្រាក់កាសត្រាន់និងជួយទប់ប្រាក់ខែបន្តិចបន្តួចរបស់ពុកសោះ។ ប៉ុន្តែ ឃុនប្រកែកញ៉ាញ ពុំព្រមឲ្យខ្ញុំចេញពីភឹងជាដាច់ខាត សុខចិត្តចំណាយលុយហោប៉ៅឯងមួយរយរៀល ឲ្យម៉ែយកទៅជួសជុលផ្ទះ ព្រមទាំងទំលួងលោមអង្វរខ្ញុំទន់ផ្តឹង។

ហ្លួងសុគតមិនបានប៉ុន្មានផង សម្តេចនុហាជ ដោយមានក្មួនចៅទាំមុខ និង ពួកបាក់ឯងមួយហ្វូងធំ ហែរហមដួនដំណើរផង កំរើតភ័ាន់មកនៅក្នុងភឹងចតុមុខ ដែលជាលំនៅសម្រាប់ហ្លួងសោយរាជ្យនេះវិញ។ សម្តេចនុហាជ ស្រមៃចង់សោយរាជ្យយូរណាស់មកហើយ ដល់បានសំរេចផ្តួចបំណងអញ្ចឹង វាទៅជាសប្បាយចិត្ត ញញឹមស្នេញបិទមាត់មិនជិត លេចធ្មេញភ្លុកពីរក្រាសមកផ្តួចចង្គុមយក្ស។

បើតាមខ្ញុំស្មានមើលទៅ ពេលនេះប្រហែលជាចូលដល់ខែពិសាខហើយ ពីព្រោះខ្ញុំឃើញដើមស្វាយនៅក្នុងសួនច្បារភឹង ចាប់ផ្តើមមានផ្លែខ្ទុំគ្រប់តែដើម។ ប៉ុន្មានថ្ងៃក្រោយដែល ស្តេចសុវណ្ណកោដ្ឋ ចូលទីវង្គតទៅ ស្រាប់តែកើតមានខ្យល់ព្យុះសង្ឃរាដ៏ខ្លាំងក្លាអស្ចារ្យ ដែលមួយអាយុមនុស្សក្រមុំនឹងមានឧរណាបានជួបប្រទះណាស់ ដូចជាប្រផ្នូលប្រាប់ឲ្យដឹងថា នឹងកើតមានចលាចលវឹកវរក្នុងប្រទេសខ្មែរ ចាប់តាំងពីដើមរដ្ឋកាលថ្មីនេះទៅតែម្តង។

ពេលនោះ ជានុកាសដែលគេត្រូវផ្តេរទឹកវង៉ែងហូរចេញពិសពហ្លួងដាក់ក្នុងកោដ្ឋមាសនោះ បញ្ចូលទៅក្នុង

ថ្ងៃមួយបិទជិត ដើម្បីយកទៅចោលកណ្តាលទន្លេបួនមុខ ។ ក្បួនដង្ហែរវិលវង ទាំងក្បួន និង ទូកជាច្រើន ហែរអធិកអធមចេញពីកំពង់ផែទៅ តោះបីនាឬីទចាស់ទុំមើលឃើញមេឃបែបមិនស្រួល ខំទទួចយាត់មិនឲ្យ ចេញទៅយ៉ាងណា ក៏គ្មានទណាស្តាប់ដែរ ។ ពិធីម្នាក់ថ្ងៃក្នុងទីកមិនទាន់ចាំងចប់ស្រួលបួលផង ខ្យល់ព្យុះក៏ចាប់បោកបក់ឡើងពេញមួយកំណាត់ថ្ងៃ ហើយមួយយប់ទៀត បន្តហូតដល់ស្អែកឡើងទើបសូប់ទៅវិញ ។

ទីកទន្លេដែលទើបនឹងបានទទួលសាច់ឈាមស្តេចថ្មៃថ្មីៗនេះ ក៏ចាប់ផ្តើមហាក់ពណ្តើលបោកបាច បង្កើតជារលកធំៗប៉ុនរលកសមុទ្រ វាយផ្ទប់ច្រាំងបាក់ដីទាំងផ្តាំង ។ កប៉ាល់លិចលង់ ទូកត្រូវខ្យល់វាយខ្ចាត ឡើងដល់គោក ស្លាប់ជីវិតមនុស្សអស់ជាច្រើន ។ ទូកធំៗរបស់ហ្លួងដែលកំពុងតែឡើងអ្វី ក៏ត្រូវខ្យល់ព្យុះ វាយពន្លិច ជួលដេករង្គកវណែលពេញឆ្នេរខ្សាច់ដែរ ។

នៅក្នុងភំង ផ្ទៃស្វាយទៅខ្លីនៅឡើយ ព្រះបាចសាចដួចគ្រាប់ភ្លៀងមកលើស្មៅ ។ ដើមគគីរដ៏ធំសម្បើម មួយ នៅក្រោយទីតាំងទេវាវិនិច្ឆ័យ រលើងគល់រលំសង្កត់បាក់រលងប្រាសាទបាញ់យ៉ុង អស់មួយចំណែក ។ យើងទាំងអស់គ្នាយល់ថា ព្រឹត្តិការណ៍ចម្លែកបែបនេះ ពិតជាកើតឡើងដោយសារកំហឹងព្រះអាទិទេព ពិតប្រាកដណាស់ ។

ចាប់តាំងពីពេលនោះមក រៀងរាល់ឆ្នាំ ទីកទន្លេមេគង្គតែងហូរនាំយកដីច្រាំងទាំងផ្តាំងៗទៅជាមួយ ដែលជាហេតុធ្វើឲ្យចម្ងាយពីមាត់ទន្លេមកកំផែងសីមា[៨] កាន់តែញ្ជិតខ្លីជាលំដាប់ ហើយថ្ងៃណាមួយ ទន្លេមេគង្គក៏ប្រហែលជានឹងលេបត្រជាក់ភំងទាំងមូល ដែលជាជម្រកដ៏សុខសាន្ត នៃ ពពួកស្តេចខ្វិលច្រអូស និង នាឬីទទ្បើម ឱតតែប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីជាកិច្ចសងសឹកជូសទីកចិត្តក្តៅក្រហាយ នៃ រាស្ត្រខ្មែរ ដែលធ្វើវាសនាលើពួកទាំងនោះ ហើយបែរជាត្រូវពួកនោះ តាំឲ្យជួបតែនឹងទុក្ខវេទនាឥតស្រាកស្រាន្ត ។

ជាពិសេសទៅទៀត ក្នុងឆ្នាំរោងនោះ ទីកទន្លេជន់លិចអស់ដំណាំដាំដុះ ត្រូវនឹងឆ្នាំមុនដែលរីងរាំង ធ្វើស្រែមិនបានផលផង រាស្ត្រក៏តែងតែវេទនាណាស់ទៅទៀត ។ នៅជុំវិញភំងដែលពោរពេញទៅដោយមនុស្ស ខ្វះសមត្ថភាព អំពើអយុត្តិធម៌ អំពើបាប និង ការលបលួចសាហាយស្មន់នឹងគ្នានេះ រាស្ត្រត្រូវរស់នៅវេទនា អត់ឃ្លានថ្លូចសព្វធាតុ ឯការអនាថា គ្មានទណាមើលខុសត្រូវ ព្រោះហ្លួងប្រចាំថា ឲ្យបាក់ងមើលរាស្ត្រ បាក់ងថា ហ្លួងទេដែលជាអ្នកត្រូវត្រួតត្រាប់គ្រងរាស្ត្រ សម្រេចសម្រួចទៅ គ្មានទណាដឹងឮអ្វីទាំងអស់ ។

ប៉ុន្តែ មុនពេលកើតមានព្រឹត្តិការណ៍អស់នេះ គឺគ្រាន់តែហ្លួងសុគតភ្លាម លោកមហាមន្ត្រីដោយមាន បាក់ងម្នាក់ ក្បាលទំពែក ក្អែកធំមួលថ្លូចត្រើស្ងោរ ថ្លូនដំណើរផង បានចូលមកក្នុងភំង បើកបីកកាយទូរដាក់ សម្បត្តិហ្លួង ប្រមូលយកមាសពេជ្រលុយកាក់ទាំងអស់ ហើយប៉ុន្មានថ្ងៃក្រោយមក ស្រាប់តែអ្នកទាំងពីរ មានលុយដើរចងការពាសវាលពាសកាលតែម្តង ។

សម្បត្តិហ្លួងមួយចំណែក ត្រូវលោកចែកទៅឲ្យ ភូនថៅ និង អ្នកបំរើនែបនិត្យទីកក្តៅទីកត្រជាក់ ក្នុងរវាង ប៉ុន្មានខែមុនពេលសុគត ។ សំបុត្រចែកស្តើមរតកមួយ ដែលគេយកទៅថ្វាយហ្លួងស៊ីញ៉ៅទៅពេលដែល លោកកំពុងឈឺដាបលែងដឹងខ្លួនដឹងក្រាណាទៅហើយនោះ ត្រូវគេយកមកអនុវត្តតាមឥតខ្ចោះ ម្ល៉ោះហើយ ភូនស្តេចខ្លះ និង អ្នកខ្លះទៀត គ្មានជាប់ឈាមព្រះញាតិវង្សានុវង្សអ្វីនឹងគេបន្តិចបន្តួចសោះ ក៏ស្រាប់តែ បានទទួលមរតកច្រើនអស្ចារ្យ ចំណែកឯអ្នកខ្លះទៀត បែរជាវិនាសហិនហោចអស់ផ្ទះអស់សម្បែង ជាហេតុ បណ្តាលឲ្យកើតមានការច្រណែនឈ្នានីសគ្នាត្រឡប់ត្រឡិន ។ ស្រីបំពី និង ពួករបាំ ក្តៅក្រហាយណាស់ ដោយខ្លួនម្នាក់ៗបានទទួលតែប្រាក់ពីរ-បីរៀល ប៉ុណ្ណោះ ក៏តាំងនាំគ្នាទន្ទេញជាប់នឹងមាត់ថា គេចូលមក

(៨) កំផែងភំង ។

ប្លន់ភំង ។ ប៉ុន្តែរឿងចលាចលទាំងនេះ ត្រូវស្ងប់ស្ងាត់ទៅវិញ នៅពេលដែលកើតមានរឿងថ្មីមួយទៀត ។

លោកស្មៀនឌៀប កំពៀកសៀវភៅបញ្ជីបួនក្បាល ដើរកោះហៅអ្នករបាំទាំងអស់មកសួរ តើនណា ចង់ចេញពីភំង ? នណាចង់នៅតទៅទៀត ? ភាគច្រើនសម្រេចចិត្តឈប់នៅ ហើយត្រូវគេលុបឈ្មោះ ចេញពីបញ្ជីឈប់ឲ្យស៊ីប្រាក់ខែភំង ។ ចំពោះអ្នកណាព្រមនោះ ថីឌៀប សម្លឹងមើលតាំងពីក្បាលដល់ចុងជើង ទើបគាត់សំគាល់ថា ៖ មានធំ, ក្បាលទេវតា, រាងខាប, ដើមទ្រូងកិន្នរី, ស្ពឹអញ្ជើងតរហូតមក ។ ដល់ជំនុំ, ខ្ញុំឆ្លើយថាព្រមនៅ ថីឌៀបក៏និយាយថា :

~ អ្នករបាំ, ក្បាលព្រហ្ម (ហើយសរសេរពាក្យនេះចុះក្នុងបញ្ជី) ។

សំដីនេះ ធ្វើឲ្យខ្ញុំហ៊ឺហាក្នុងចិត្តមិនតិចទេ ។

♥ ♥

♥

តន្ត្រីការិនី



Musiciennes

ដំណាយពីហួងថ្មីនោះវិញ ហាក់ដូចជាមិនខាន់ស្លឹថា ខ្លួនឯងបានឡើងសោយរាជ្យជាស្តេចផែនដី មិនខាន់ស្លឹថា រាំងចតុមុខនេះជារបស់ខ្លួនផងទេ។ លោកធ្វើឫកវញ្ចាក់ញ៉ូវត្រូវឲ្យចង់សើច ឃើញបន្ទប់ម៉ៀបចំស្អាតបាត ខំឈរមើលហួចខ្លួន ឃើញកម្រាលព្រំ ឃើញខ្នើយកំណាត់ស្អាតៗ មិនហ៊ានអង្គុយលើ ខ្លាចប្រឡាក់ ព្រមទាំងចេះតែរើលខ្លួង ខ្លាចខ្មោចហួងសុវណ្ណកោដ្ឋជាបងឯងនោះ តាមលង។

បន្ទាប់មក គីកូនចៅម្ចាស់ក្បត្រីរ៉ែមធីតា មានស្រីបំរើចាស់ៗគគ្រិចស្មោកគ្រោក ពួករបាំស្លៀកពាក់រយ៉ីវយ៉ី ហួងកូនស្តេច និង អ្នកបំរើ ដែលលើកគ្នាពីរាំងខាងជើង ចូលមកលុកលុយរាំងចតុមុខ ដោយម្នាក់ៗមានដបស្តាយកន្ទេលហែក តុកៅអីកញ្ចាស់បាក់បែក និង កន្ទោរស្មោគំពិតកំពៀរមកជាមួយផង។ ពួកអស់នេះ គ្រាន់តែឃើញរបៀបតុបតែងរាំង ក៏តាំងតាំត្មាជញ្ជក់មាត់សរសើរសប្បាយចិត្តរីកថ្លើមប៉ុនចង្កេរ។ ជួនកាលខ្ញុំដើរដល់កូនស្តេច ដែលខ្ញុំស្មានថាជាពួកកូនចៅ[b] កំពុងឈរយាមនោះ ទាល់តែចង់ដួលផ្ងារក្រោយ ឬ ដើរជាន់ដៃកូនស្តេចតួចៗដែលប្រឡែងគ្នាដេកពេញកណ្តាលផ្លូវ បណ្តាលឲ្យវាយំថ្លង់រកស្តាប់ទិសតំបន់អ្វីមិនឮ។

ឃ្លាណាស់ទម្រាំនឹងពួកអស់នេះ ម្ចាស់ខ្លួនបានជាមួយជីវភាពថ្មី ដែលសម្បូរណ៍សប្បាយជាងកាលរស់នៅឯរាំង សម្តេចនុបរាជ។ ហួងថ្មីក៏កាន់តែស៊ាំជាមួយការរស់នៅក្នុងបន្ទប់ថ្មី នៃ ទីតាំងមេខលា និង ប្រាសាទបាញ់យ៉ុងវែរ។ គេអញ្ជើញ ឃុនថាន់ ឲ្យចេញពីផ្ទះនៅក្បែរទីតាំងមេខលា ដើម្បីទុកកន្លែងនេះឲ្យម្ចាស់ក្បត្រីរ៉ែមធីតា នៅម្តងវិញ។ ម្ល៉ោះហើយ ឃុនថាន់ ត្រូវប្រមូលទ្រព្យសម្បត្តិដ៏ច្រើនមហិមារបស់គាត់ចាកចេញពីរាំង ទៅសង់ផ្ទះថ្មីមួយទៀតនៅខាងត្បូងទីក្រុង ត្រង់ម្តុំក្បែរវត្តស្វាយពែ។ នៅទីនោះ គាត់បានចំណាយសម្បត្តិផ្ទាល់ខ្លួនកសាងវត្តមួយ សម្រាប់ជាកុសលទៅអនាគតជាតិ ដោយយកឈ្មោះគាត់ដាក់ជាឈ្មោះវត្ត គឺវត្តថាន់ សព្វថ្ងៃនេះឯង។

ឃុនព្រះញាតិ គ្មានសម្បត្តិសម្បូរណ៍ហួរហៀរដូចឃុនថាន់ទេ ម្ល៉ោះហើយផ្ទះគាត់ក៏មិនស្អូរហ៊ីហារគួរឲ្យនរណាចង់ដណ្តើមយកដែរ។ គាត់ប្រគល់កូនស្នេហ៍ផ្ទាល់ខ្លួនទាំងអស់ថ្វាយហួងថ្មី ដើម្បីយកចិត្តកុំឲ្យគេដេញចេញពីរាំង ហើយរស់នៅក្នុងសភាពក្រគោកយ៉ាក គ្មាននរណាទឹកនាប់ក្រហួតលើថ្ងៃស្លាប់។ ប្រឹងរ៉ាវ ស្ទើរកំសត់ ស្ទើរកំប្លែង ចេះតែកើតមានប្លែកៗគ្នារាល់ថ្ងៃនៅក្នុងរាំង។

ពួកបារាំងមាននៅត្រៀបត្រា ចាំជួយជ្រោមជ្រែងហួងឲ្យឡើងកាន់អំណាចជាស្តេចផែនដី គឺគេយកតាហានមកឲ្យយាមការពារ និង ធ្វើឫកជាគោរពកោតខ្លាចហួងខ្លាំងណាស់ ដើម្បីជាកិច្ចលើកទឹកចិត្តហួងក្នុងពេលរង់ចាំទម្រាំដល់ពេលធ្វើបុណ្យរាជាភិសេកតាមទំនៀមទម្លាប់។ គេទិតទំពន្យល់ហួងកុំឲ្យដើរលេងជើងទេ លើកម្រាលព្រំនៅក្នុងបន្ទប់ទទួលភ្ញៀវ គេទិញស្បែកជើងឃ្លប់ ស្រោមជើង អាវស ថ្វាយហួង គេពន្យល់ហួងឲ្យឈប់ភ័យពីប្រឹងជំពាក់ប្រាក់គេ និង ហាមមិនឲ្យទៅជាស់ទ្វារចៅកែចិត្តខ្ជីលុយទាំងយប់អាត្រាត្រ ដូចពីមុនទៀត។ ហួងមិនចាច់ភ័យព្រួយពីប្រឹងអ្វីទៀតទេ ចាំតែសោយរាជ្យទៅបានហើយដល់ពេលជាច់ខែ គេបើកប្រាក់ខែបួនម៉ឺនរៀល មកថ្វាយរាល់ខែ។

ឡៀតនុកាសកើតការរឹកវរនៅដើមរដូវកាលថ្មីនេះ ពួកអាណាព្យាបាលបារាំង ទាំយកសំបុត្រស្នាមជាច្រើន ដែលគេរៀបចំធ្វើតាំងពីច្រើនឆ្នាំណាស់មកហើយនោះ មកសុំឲ្យហួងស៊ីញ៉ូ ដើម្បីជាថ្នូរក្នុងការដែលគេជួយជ្រោមជ្រែងឲ្យបានឡើងសោយរាជ្យ។ សំបុត្រស្នាមទាំងនេះ ហួងស៊ីញ៉ូទាំងមិនយល់សេចក្តីគេថាម៉េចផងទេ។ មួយថ្ងៃៗ លោករវល់តែជីកកាយ ថតតុ ថតខ្នូ ស្រាប់តែថ្ងៃមួយប្រទះឃើញលិង្គកៅស៊ូមួយ នៅក្នុងថតតុ ដូចបេះបិតនឹងប្រដាប់មែនទែន រឹងគួរឲ្យខ្លាច ប្រកបដោយហេតុណាទង់ដែង មើលមួយភ្លែតស្មានថា របស់នេះត្រូវគេកាត់យកមកពីខ្មោចបារាំងណាម្នាក់ ដែលត្រូវគេសម្លាប់ចោលតាមបញ្ជាហួងចាស់។

របស់ចម្លែកអស់នេះ ធ្វើឲ្យហួងសប្បាយចិត្តរកអ្វីមកប្រៀបស្មើគ្មានទេ។ លោកទំនុរឲ្យគេពន្យល់ពីរបៀបធ្វើឲ្យដង្គាល់អគ្គីសនីវិល ពីរបៀបបើកទឹកម៉ាស៊ីន លោកស្ទាបអង្អែលខ្នើយស្បូវ និង អង្គុយទោរជើងលើកៅអីហួងទិញមកពីអ៊ឺរ៉ុប ញញឹមធ្លាក់បបូរមាត់ស្តែស ចេញធ្មេញភ្លុកទាំងពីរក្រាស។ តើមានប្រយោជន៍អ្វីនឹងមើលសេចក្តីក្នុងសំបុត្រ ដែលបារាំង "ជាន់ ជាម៉ែ" យកមកថ្វាយតនោះ? ហួងស៊ីញ៉ូខ្លាច ព្រមទាំងនិយាយថា មែរស៊ី!។

ជួនកាល ហួងដូចជាភ្ញាក់ខ្លួន ឡើយណាយនឹងពួកបារាំងដែលដណ្តើមយកអំណាចអស់លើង ធ្វើអ្វីក៏ចាំតែធ្វើតាមបញ្ជាគេ និង ជាពិសេសទៅទៀត ពួកស្បែកសនេះ ឮកែសុំមិនចេះឆ្អែតឆ្អន់សោះ។ សូម្បីតែបញ្ជីលុយកាក់ផ្ទាល់ខ្លួន ក៏គេមិនឲ្យកាន់កាប់ខ្លួនឯងដែរ ដាច់ខែ ស្មៀនបើកយកមកថ្វាយគ្រប់ចំនួន ហើយបើចង់ប្រទានវង្វាន់ឲ្យនរណា ឬ ទិញរបស់ប្រើប្រាស់បន្តិចបន្តួច ទាល់តែសុំបារាំងជាអ្នកចាំត្រួតត្រាទោះ ឲ្យគេយល់ព្រមសិន។ ដល់ឃើញអញ្ចឹង លោកទឹកស្តាយ ចង់តាមឪយកអំណាចមកវិញខ្លះដែរ ប៉ុន្តែហួសពេលទៅហើយ។

ទស្សនីយភាពក្នុងរាំងដែលធ្លាប់តែរុងរឿងនោះ ក៏ប្រែជាស្រពាប់ស្រពោនគួរឲ្យអនិច្ចា! សភាពគគ្រិចស្មោកគ្រោក រាតត្បាតសព្វទីកន្លែង ដែលកូនចៅម្ចាស់ក្បត្រីរ៉ែមធីតារស់នៅ។ គេស្ពោះទឹកមាត់ញើសសម្បោរតែពីសតែពាស យកប្រហុកមកទុកដល់ក្រោមបង្ហួចប្រាសាទបាញ់យ៉ុង ធំក្លិនស្អុយស្អើរទ្រាំពុំបាន។ ស្រីអ្នកល្អជា គេចេញពីរាំងអស់ទៅ ហើយអ្នកនៅសល់ទាំងប៉ុន្មាន បើចង់បានមុខងារថ្លៃថ្នូរនៅក្នុងក្រុមប៉ាតែមួយគត់របស់ម្ចាស់ក្បត្រីនោះ ទាល់តែចេះតម្រូវខ្លួនរស់នៅតាមរបៀបថ្មី គឺចេះសរសើរលើកជើងម្ចាស់ក្បត្រី ចេះរៀបចំខ្សៀអាកៀនថ្វាយ ដូចជាថ្វាយហួងបិតាដែរ ឬ ចេះចាក់ស្រា "សិច" បំពេញកែវ។

ម្ចាស់ក្បត្រី អង្គុយលើកន្ទេល ឬ លើត្រែ កណ្តាលរង់ពួកស្នេន និង អ្នកបំរើ ក្នុងផ្ទះឃុនថាន់ ដែលប្រែជារាយប៉ាយគ្មានសណ្តាប់ធ្នាប់ ហើយតាំត្មា ស៊ី ផឹក ជក់ លេងបៀរ ឬ ប្រឡែងគ្នារបៀបប្លែកគួរឲ្យសង្ស័យ គឺ អង្អែល ច្របាច់ដោះ ពួកក្មេងស្រីជំទង់។

[b] ពួកស្រីៗអ្នកលើកបាយទឹកបំរើហួង។

បើអង្គុយជិតម្ចាស់ក្សត្រី រឃតសារុងកុំធ្វើដឹងខ្លួន មិនបាច់ពាក់អាវទេ ដណ្តប់តែជាហ៊ីស្តើងបានហើយ ហើយគិតតែចាក់ស្រាបំពេញកែវថ្វាយទៅ នោះទើបបានគាប់ត្រូវ។ កាលណាគេផឹកស្រាស្រឹងហើយ គេដួលដេកផ្ងារណែលលើកម្រាល រឃតសារុងស្រាតទៅខ្លួនទទេ។ ប៉ុន្តែ ដូចជាស្រួលម្យ៉ាងដែរ ព្រោះថាផ្ទះហ្នឹង នរណាចង់ចេញចូលស្មើណាក៏បាន ទ្វារបើកចំហជាមិច្ច មកប្រទះឃើញអី ស៊ីហ្នឹងទៅ ហើយពួកល្មោកក៏គ្មានវេលាធ្វើអ្វី ក្រៅពីផ្តាប់ផ្តុនចៅហ្វាយថ្មីនេះដែរ។

យ៉ាន និង ខ្ញុំ យើងមិនសូវចូលចិត្តទៅរើមរវាំមក្បែរហ្នឹងទេ។ ខ្ញុំបានទាំងនិយាយប្រាប់ពុកសព្វគ្រប់ពីរឿងរ៉ាវនៅក្នុងភ្នំងផង ប៉ុន្តែពុកបង្គាប់ថា ឲ្យត្រាំបន្តិចទៅ ក្រែងលោវាបានធូរស្រាលឡើងវិញ ហើយបើយ៉ាងម៉េចៗ គាត់នឹងមកយកខ្ញុំទៅនៅផ្ទះវិញក្នុងពេលឆាប់ៗនេះ។

ចាប់តាំងពីពេលដែលស៊ុន គេបែកពីខ្ញុំទៅបំរើម្ចាស់ក្សត្រី ដើម្បីប្រាថ្នាបុណ្យសក្តិនោះមក មានតែ យ៉ាន ត្រូវចាំខ្ញុំទេ ដែលបានភ្លាយមកជាមិត្តដ៏ល្អម្នាក់។ វាជាកូនទាយាទាហានហួង ប៉ុន្តែកំព្រា ឪពុកម្តាយស្លាប់ចោលតាំងពីតូច គឺធ្លាប់ជាកូនអ្នកមានព្ងាជអំបូរថ្លៃថ្នូរនឹងគេដែរ ម្ល៉ោះហើយវាមិនសុខចិត្តទៅឡូកឡំជាមួយពួកកូនចៅម្ចាស់ក្សត្រីជាដាច់ខាត។ ធ្វើម្តេច គ្នាក្រ ភ្នាទីពឹង ចេះតែត្រាំនៅក្នុងភ្នំងទៅ។ យ៉ាន ថែមទាំងចេះសង្ស័ប្រាក់ខែដប់រៀលនោះ ទុកបានយ៉ាងច្រើនទៀតផង។ ចំណែកខ្ញុំវិញ ប្រាក់ខែប៉ុនគ្នាដែរ ប៉ុន្តែខ្ញុំទុកឲ្យមែតែបន្តិចបន្តួចប៉ុណ្ណោះ សល់ប៉ុន្មាន ខ្ញុំចំណាយទៅលើទំចំណីខ្ទេចទាំងអស់ គ្មានដែលសល់មួយរសេទេ។

តើខ្ញុំវល់ព្រួយសង្ស័ទុកជាក់ធ្វើអ្វី? សំពត់ជាហ៊ី និង កំណាត់ស្រប់បែបយ៉ាង ហួងបញ្ជាឲ្យគេចែកឲ្យយើងច្រើណាស់ ប្រើមិនអស់ សល់បានទៅដល់ ប៊ុន និង ហ៊ុន ជាបងប្អូនជីដូនមួយខ្ញុំនៅព្រែកថ្មីឯណោះផង។ វាទាំងពីរនាក់ នុស្សាហ៍មកលេងនឹងខ្ញុំជាញឹកញយក្នុងភ្នំង ហើយជួនកាលខ្ញុំឃាត់វាឲ្យនៅដេកពីរ-បីយប់ក៍មាន។ ខ្ញុំចង់តាំងវាទៅដេកឯផ្ទះម្ចាស់ក្សត្រីរ៉ៃធីតា ឬ ផ្ទះណាមួយក៍បានដែរ ព្រោះគ្មានវេលាត្រួតត្រាទេ ចង់ដេកត្រង់ណាក៍ដេកទៅ។

ថ្ងៃមួយ ស្រាប់តែកើតមានហេតុការណ៍ប្លែកគួរឲ្យខ្ញុំមានសង្ស័យថា ក្តីស្រមៃដែលថានឹងបានភ្លាយខ្លួនទៅជាតួឯករបាំនោះ គង់នឹងបានសំរេចជាមិនខាន។ ពេលនោះ ខ្ញុំត្រូវរាំសមជាមួយអ្នកឯទៀត មុនពេលចូលឆ្នាំថ្មី ដែលគេតម្រូវឲ្យយើងទៅចេញរាំនៅសួនច្បារវត្តភ្នំ។ ព្រះអង្គម្ចាស់ ដួង មធុរ កូនប្រុសរបស់ហួង និង ជាបងម្ចាស់ក្សត្រីរ៉ៃធីតា បានទាំពួកម៉ាកម្ល៉ោះៗជាច្រើន ដើម្បីមកមើលយើងរាំសមនេះ។ លោកតាមសម្លឹងមើលខ្ញុំយ៉ាងយកចិត្តទុកដាក់តាំងពីដើមដល់ចប់ ហើយហៅខ្ញុំទៅអង្អែលស្មាសរសើរ ព្រមទាំងប្រាប់ទៅម្ចាស់ក្សត្រីប្អូន ឲ្យលើកខ្ញុំធ្វើជាតួសំខាន់ឡើង ព្រោះបើតាមលោកមើលទៅឃើញថា ខ្ញុំអាចបំពេញមុខងារនេះបានប្រសើរណាស់។ ម្ចាស់ក្សត្រីទទួលធ្វើតាមបញ្ជា ហើយបញ្ជេញឫកសួតជាមួយខ្ញុំប្លែកសព្វមួយផង។ ប៉ុន្តែឫកពារស្ងួតហួតរបៀបនេះ បែរជាធ្វើឲ្យខ្ញុំខ្លាចទៅវិញ ព្រោះតែកាលណាម្ចាស់ក្សត្រីយ៉ាសើចម្តងៗ ចេញធ្មេញស៊ីស្លាទៅអ៊ីញ ធ្វើឲ្យខ្ញុំខ្លាចរត់គេចខ្លួនបាត់មួយរំពេច។

នៅក្នុងភ្នំង ម្ចាស់ក្សត្រីមានឥទ្ធិពលគ្របសង្កត់លើហួងបិតាសម្បើមណាស់។

គេខ្សឹបខ្សៀវគ្នាពីមាត់មួយទៅមាត់មួយថា តាមពួកអ្នកបំរើចាស់ៗធ្លាប់នៅភ្នំងខាងជើងនិយាយថា សម្តេចនុហាជ បានលបលាក់ស្រឡាញ់គ្នាជាមួយកូនបង្កើតឯងផង។ គេនិយាយទៀតថា នេះជាក្រយៅអាក្រក់តព្ងជ នៃ ត្រកូលស្តេចសោយរាជ្យ គឺស្តេចស្រីក្មេងៗ ស្រឡាញ់សាហាយស្មន់ជាមួយ ឪពុកមាងង, ឪពុកឯង ឬ ជីតាឯង ដូចមានរឿងម្ចាស់ក្សត្រីជិបជាដើម ហើយរឿងរ៉ាវអស់នេះ តែងលេចឮទៅដល់

ចំណោមប្រជារាស្ត្រ ដែលកំពុងរស់នៅលំបាកអត់ឃ្លាន ដែលជាហេតុធ្វើឲ្យរាស្ត្រក្តៅក្រហាយក្រៃលែង។

នៅទន្លឺមត្នាឥទ្ធិពលដ៏ខ្លាំងក្លា នៃ ម្ចាស់ក្សត្រីរ៉ៃធីតានេះ លោកមហាមន្ត្រីទទួលបន្ទុកមើលការខុសត្រូវក្នុងភ្នំង ក៍ប្រើអំណាចសង្កត់សង្កិនទៅលើហួងខ្លាំងណាស់ដែរ ព្រោះគាត់ចេះនិយាយបាភ្នំង និងមានការទាក់ទងយ៉ាងស្និទ្ធស្នាលជាមួយពួកអាណាព្យាបាលបាភ្នំង។ គាត់ប្រសប់ប្រើឫបាយកេងយកប្រយោជន៍ពីហួងណាស់ ហើយយកសុទ្ធតែគ្នីគ្នាគាត់ឲ្យទៅនៅជិតហួង។ ហួងមិនសូវយល់ពីគោលបំណងពិតប្រាកដរបស់លោកមហាមន្ត្រីទេ ម្ល៉ោះហើយលោកចេះតែព្រួយបារម្ភជានិច្ច។ ក្នុងការនិយាយស្តី គាត់មានប្រៀបលើហួងជានិច្ច អាចសុំឲ្យក្រុមគ្រួសារ ឬ បក្សពួកទៅធ្វើការកន្លែងណាក៍បាន។ កិច្ចការគ្រប់ជំពូកនៅក្នុងភ្នំង ស្ថិតក្នុងកណ្តាប់ដៃគាត់ទាំងអស់ ព្រោះគាត់ជាខ្មែរចេះបាភ្នំង គាត់ចង់ធ្វើអ្វីបានតាមចិត្ត ពុំចាំបាច់ស្តាប់បង្គាប់បញ្ជានរណាទេ ហើយគេក៍ពុំអាចធ្វើការដោយគ្មានគាត់បានដែរ បើសង្ឃឹមទៅលើស្តេចគឺគ្មានសមត្ថភាពអ្វីបន្តិចបន្តួចទាល់តែសោះ។

ក្រោយគេបំផុត គឺទណាម ដែលឡៀតឱកាសប្រើអំណាចខាងផ្លូវចិត្ត ជិះជាន់លើហួងខ្លាំងណាស់ដែរ គាត់រចនាផ្ទៃភ្នំងទៅតាមតែចិត្តនឹកឃើញ។ គាត់បានឡើងហាន:ជាម៉ម ហើយភ្លាយឈ្មោះជាម៉មទួ ដ៏ល្បីល្បាញ មានផ្ទះពីរជាន់សង់ទៅចុងផ្លូវធំ ក្បែរប្រាសាទភិមានអាកាស។ ម៉មទួ ស្រឡាញ់រាប់អានខ្ញុំណាស់ ហៅខ្ញុំសុទ្ធតែកូន ព្រមទាំងឲ្យមាសពេជ្រខ្ញុំពាក់ស្រោចខ្លួន រឃតទាល់តែខ្ញុំហួចម្ចាស់ក្សត្រីរ៉ៃធីតាឈឺងតែម្តង។

ឆាដ្សកាវីនខ័យក្លេច



Jeunes danseuses

ច្រើន ខែកន្លងទៅ... ការដែលគេលែងរវីរវល់គិតពីរឿងវិន័យរបៀបរៀបរយ បានធ្វើឲ្យភាំងភ្លាយទៅជាទីច្រកប្លកច្របល់រកមើលមិនយល់។ និយាយពី "ម្ចាស់ផែនដី" វិញ គឺបាត់ខ្លួនតែម្តង កម្រឃើញចេញមកក្រៅណាស់ មួយថ្ងៃៗ សម្លឹងឬ សោយអាហារ នៅតែក្នុងប្រាសាទ មេខលា ជួនកាលនៅរោជមន្ទីរ ជួនកាលនៅប្រាសាទបាញ់យ៉ាង ហើយស្រមោលហួងដែលសុគតទៅនោះ តែងមកលងអារម្មណ៍ហួងជាទិច្ច។

អ្នករបាំណាទំនេរ ម្ចាស់ក្សត្រីតែងហៅទៅឲ្យអង្គុយកំដរលោក សោយស្រាឬអាហារ យ៉ាងសប្បាយរីករាយ។ គេទើបនឹងបង្កើតស្រាថ្មីមួយមុខ ល្អជាងស្រាបារាំង ទិញនៅផ្ទះចិនទៅទៀត។ គេចាក់ស្រាច្រប់ពណ៌ ច្រប់ម៉ាក លាយគ្នាបន្តិចៗ និង ជាក់ទឹកកកមួយដុំ ហៅថា "ក្រៃម្ល" ហើយដឹកដបមួយភ្លឺកម្ងាក់ បញ្ជូនបន្តពីមួយទៅមួយ រហូតដល់ច្រប់គ្នាមួយដុំ។ អា "ក្រៃម្ល" ហ្នឹង ខ្ញុំក្រេបតែមួយភ្លឺក ក្តៅឆ្អលបំពង់ក ស្ទើរប្រកាច់ស្លាប់។

ពេលនោះ មានពួកថ្មីដែលភាគច្រើនសុទ្ធតែស្រីក្ងុតអ្នកស្រែ តាំគ្នាមកនៅក្នុងភាំង ដើម្បីបំពេញកន្លែងទំនេរបស់ពួកដែលចាកចេញឈប់នៅភាំង។ ពួកអស់នេះ រូបអាក្រក់ ដៃជើងត្រមីងត្រមាំង ពិបាកមើលណាស់ ហើយក្រីក្រគ្មានចាប៉ៅស្លត្រដង ខ្លះក៏មកសុំនៅក្នុងភាំងដោយខ្លួនឯង ខ្លះក៏មានត្រូសារផ្ញើនមក ដើម្បីឲ្យបាននៅបំរើអស់អ្នកអស់នាងមានអំណាចនៅក្នុងភាំង។ ពួកនេះ ដៃជើងរឹងធ្វើម្តេចអាចពត់ពេនគាំផ្ងយើងបាន? ម្ល៉ោះហើយ គ្មានចេង់រាំរើកទេ គ្រាន់តែសុំបំរើគេយកបាយបរិភោគប៉ុណ្ណោះ។ ខ្លះទៀតទំនេរគ្មានការធ្វើ ដើរប៉ើរពេញភាំង រង់ចាំទម្រាំថ្ងៃណាមួយម្ចាស់ក្សត្រីនាំយកទៅឲ្យបម្រើហួងនឹងគេ ក្រែងបានកម្រៃខ្លះ។

ពួកវាមកនៅក្រោយគេ សម្បុរខ្មៅគគ្រិចជាងគេ ប៉ុន្តែមានចិត្តលោភលន់ជាងគេ ទំនៅតាល់បំរើយកចិត្តម្ចាស់ក្សត្រីខ្លាំងណាស់ ដើម្បីឲ្យបានតាប់ត្បូរ។

ម្ល៉ោះហើយ ពួកយើងក្មេងៗត្រូវបាត់បង់អស់លើងនូវសេចក្តីសប្បាយរីករាយ ដែលយើងធ្លាប់ស្គាល់ពីមុនមក។ រាល់ថ្ងៃ ក្រោយពេលឈប់ហាត់រាំ យើងដើរជំនុំគ្នាពីផ្ទះមួយទៅផ្ទះមួយនៅក្នុងវែរ ហើយមួយថ្ងៃៗ យើងទៅមុជទឹក ពីរ-បីដង ដើម្បីផ្ងៀតកេនុកាសណ្តោះវាយតប់គ្នា។ អាឃ្លីងវាយតប់ ខ្ញុំស៊ីជាច់គេទាំងអស់ បណ្តាលឲ្យពួកវាទាំឃ្លីងទៅទូលម្ចាស់ក្សត្រីជាញឹកញាប់ ហើយម្ចាស់ក្សត្រីក៏តែងគំរាមកវាយ និងចាប់ខ្ញុំយកទៅដាក់គុកវែរ។

និយាយពីគុកនោះ ខ្ញុំគ្មានខ្លាចទេ ពីព្រោះខ្ញុំតែងគេចរកកន្លែងស្ងាត់ ទៅដេកជាមួយពួកស្រីមានទោស

ស្ទើរតែរាល់យប់ ទាល់តែស៊ាំទៅហើយ។ ម៉ើរពាត់ផ្តៅនោះ ទើបត្រូវឲ្យខ្លាចខ្លែង ប៉ុន្តែខ្ញុំច្រសាំកជាស្ងៀងនោះសារួចខ្លួនជាទិច្ច ហើយដើម្បីសងសឹកនឹងម្ចាស់ក្សត្រី ខ្ញុំលបទៅបើកម៉ាស៊ុតទឹកបង្ហូរចោលរាល់ម៉ាង។

កាលណាយើងចង់សប្បាយហ្វឹតហ្វឹតមែនទែន យើងប្រមូលគ្នាទៅជុះអាចម៍ទៅបង្គន់ឯងចុងភាំងខាងលិចឯណោះ។ កន្លែងនោះមានសល់ចន្លោះមួយសម្រាប់ចេញ-ចូលទៅខ្លាអាងលិច ដែលយ្យាទើបគេបើកម្តង ដើម្បីដឹកយកខ្មោចចេញទៅក្រៅភាំង។ មានជណ្តើរថ្មសម្រាប់ដើរឡើងទៅកាន់បង្គន់ដ៏ធំក្លិនស្អុយអាសោចម៍ ដែលសង់បន្តើតពីលើដីថ្មកមួយ ពេញហៀរទៅដោយដង្កូវរវិច ថ្លូចជារបងសម្រាប់ការពារមិនឲ្យនរណាមកត្រែងត្រាងក្បែរភាំងបាន។ យើងពុំអាចមើលទៅក្រៅឃើញទេ ប៉ុន្តែមានពួកមីច្រឡឹមខ្លះ វាគាស់ក្បឿងដំបូលបង្គន់ ហើយបន្តោងឡើងតាមជញ្ជាំង អើតករហង់មើលទៅក្រៅ។

ពេលយប់ គ្មានរណាហ៊ានដើរមកកន្លែងនេះដែលឮតែស្អូរហ៊ឹងយំទ្រហឹង និង ងងឹតចាក់ភ្នែកមិនយល់ត្បូរឲ្យខ្លាចនោះទេ។ នរណាឈឺជុំវិយប់ព្រលប់ ទៅត្រង់ណាក៏ទៅទៅឲ្យតែប្រទះ។ ហេតុនេះហើយបានជាយប់មួយ ខ្ញុំប្រហែសមិនបានមើល ជ្រុលជះទឹកមួយផ្តិលទៅលើម្ចាស់ក្សត្រី ដែលកំពុងអង្គុយច្រហោង ដោះខាល់នៅក្រោមផ្ទះយូនថាត់។

ទីភាំង ខ័ណ្ឌដាច់ពីទេសភាពខាងក្រៅដ៏ស្រពាប់ស្រពោន និង អាក្រក់មើលក្រៃលែង ដោយសារអន្លង់មួយ ដែលគេដឹកនៅក្រោយភាំង ទិសខាងលិច។ នៅឯច្រាំងម្ខាងនោះ មានផ្លូវដីតូចមួយ ដែលពួកកម្លោះតណ្ហាក្រាស់ តែងដើរមកលេងកំសាន្តពេលយប់ ទាំងភ័យខ្លាចភ្នែកនៅកញ្ជឹងក ដើម្បីស្រែកឬហួចស៊ីញ៉ូ ពួកស្រីភាំង ក្រែងលោបានខ្លួលសំបុត្រស្នេហា ឬ កន្សែងបញ្ជាំចិត្តពីអ្នកក្នុងភាំង ទុកជារបស់អនុស្សាវរីយ៍។ ប៉ុន្តែគួរឲ្យអាស្សារណាស់ ពួកកម្លោះអស់ហ្នឹងអត់ដឹងថា គ្មានក្រមុំខ្មារកមកចាំស្នេហាជាមួយខ្លួន ហើយបែរជាមានក្មេងច្រឡឹមកំពុងតាមលួចមើលខ្លួនទេ។ កាលណាយើងមើលស្គាល់នរណាម្នាក់ យើងស្រែកហៅចំឈ្មោះវា ដេរបញ្ឆោរ ព្រមទាំងជីសដុំថ្មតប់ចូលទឹកខ្ចាតភក់ប្រឡាក់ពួកនោះស្រមក។ កាលណាស្ងាត់អស់ហើយ មុខត្រឡប់មកវិញ យើងមិនដែលខ្ចាតឆែងអង្គុយច្រហោងក្នុងបន្ទប់បង្គន់មួយម្នាក់ ដែលខ័ណ្ឌគ្នាដោយជញ្ជាំងក្តារ ហើយលបមើល តើអ្នកជិតខាងធ្វើអ្វីខ្លះទេ។

នេះជាល្បែងក្មេងក្រើលជំពូកអស់យើង។ ក្មេងស្រីសព្វថ្ងៃនេះ ភាគច្រើនលេងផ្តៅសង្គាសង្គួចយើងទេ ព្រោះតែពេញជំនង់ភ្លាម វាយល់អស់អារឿងកិច្ចការប្តី-ប្រពន្ធ ហើយធ្វើឫកដូចជាមនុស្សក្រមុំអញ្ចឹង។

ពួកក្រមភាំងចាស់ៗ គាត់មួម៉ៅនឹងអាកប្បកិរិយាច្រឡឹមខុសឧបទេរបស់យើងខ្លាំងណាស់។ ប៉ុន្តែធ្វើម្តេចបើគាត់គ្មានពេលចាំត្រួតត្រាយើងឲ្យបានដិតដល់ ព្រោះមួយថ្ងៃៗ គាត់រវល់តែចាំឃ្លាំនំណើរចេញ-ចូលទៅក្នុងភាំង នៃ មនុស្សប្លែកៗ ដែលមានការមិនចេះអស់មិនចេះហើយជាមួយហួង។ យើងស្អប់ពួកក្រមភាំងហ្នឹងណាស់ ព្រោះគាត់ចេះតែគំរាមគំហែងចង់យកឃ្លីងយើងទៅទូលម្ចាស់ក្សត្រីឲ្យវាយយើង។ កាលពីប៉ុន្មានឆ្នាំមុន ដោយសារតែឃ្លីងច្រឡឹមរបៀបក្មេងនេះ ទើបស្រីរបាំម្នាក់ឈ្មោះ កែម នៅជំនង់នៅឡើយ ត្រូវឯគ្រោះរហូតបាត់បង់ជីវិត គឺវាទៅលួចបេះផ្កាកញ្ជាស់ក្សត្រីឈ្មោះ ម៉ៃ ន៏ឆ្នាស់ឆ្នើម ហើយត្រូវគេចាប់បាន យកទៅវាយនឹងដំបងដែក ធ្វើឲ្យណាមួយវាទាល់តែស្លាប់។

ប៉ុន្តែយើងចេះប្រើល្បិច ពុំងាយនរណាចាប់បានឡើយ ជួនកាលយើងថែមទាំងរត់ជាន់ពួកក្រមភាំង ដែលកំពុងដេកលក់ស្អេចខ្លួននៅលើកាំជណ្តើរទីតាំងដ៏ស្ងាត់ជ្រងំនោះផង។ យើងលួចបេះស្វាយ បេះល្មុត បេះផ្កាឬ លួចផ្ងំកែវ ផ្ងំស្ករ ផ្ងំទឹកត្រាប់ឃ្លី ដែលគេដាក់លំអលើចង្កៀងដ៏ល្អទិញមកពីអ៊ីរ៉ុប។ ស៊ុនឌិង ខ្ញុំពិសោធន៏មើលឃើញថា ផ្ងំត្រាប់ឃ្លីអស់នេះស្រណុកមួលដោះណាស់ ហើយយើងក៏លួចដោះយកមក

ប្រមៀលលេងតាមកាំជណ្តើរយ៉ាងសប្បាយ។ ប៉ុន្តែគេពុំដែលរកមុខអ្នកធ្វើអំពើទិលខូចនេះឃើញឡើយ។

យប់មួយនោះ ភ្លៃតែគេចាប់យើងបាន។ យើងកំពុងតែដើរលបៗឡើងទៅលើភនហាលទីតាំងតុសិត ប៉ុន្តែក្រុមភ័ងឃើញហ្វូងបាវីរបស់យើង ក៏លបឡើងមកតាមក្រោយ ដោយកាន់ឈើច្រត់ដងប្រាក់មកជាមួយផង។ យើងងាកក្រោយឃើញស្រមោលគាត់ ភ្ញាក់ព្រើត ក៏តប់កន្ទុយបាវីតម្រង់ក្បាលគាត់ ហើយរត់តម្រង់ជណ្តើរ ជាយចុះក្រោមទៅសម្ងំពួនក្នុងគុម្ពផ្កាបាត់ឈឹង។

ក្រោយបន្តិចមក ហ្វូងថ្មីក៏យាងមកទតការសមរប៉ាំ ដែលមានម៉ែមន្ទ័ភ្លឺផងដែរ។ ហាងរប៉ាំពេញចង្កៀតទៅដោយអ្នករប៉ាំ និងទស្សនិកជន ដែលភាគច្រើនសុទ្ធតែព្រះរាជវង្សានុវង្សទៅក្នុងភឺង។ ថ្ងៃនេះអ្នករប៉ាំគាប់ព្រះទ័យហ្វូង ចងផ្កាចម្ប៉ាទម្លាក់មកកៀនត្រចៀក ដៃពាក់កម្រងផ្កាម្ជិះ តែងខ្លួនហ៊ឺហា និង ទំរាំពត់ពេនល្អលើសសព្វមួយផង។ ទាល់តែហ្វូងត្រាំអត់មិនបាន ដើរកាត់ឆាកល្មោនទៅអង្អែលផ្តាល់ឥន្ទ្រផង នៃស្នំឯក។ មិនដឹងជាយ៉ាងម៉េច ស្រាប់តែម៉ែមន្ទ័ លូកដៃទាញកន្ត្រាក់សារុងសូត្ររបស់ហ្វូង ព្រមទាំងផ្ទះសំណើចខ្លាំងៗដូចជាសប្បាយចិត្តណាស់។ សារុងរបូតហួសក្បាលពោះ ប៉ុន្តែជាសំណាងល្អ ហ្វូងភ្ញាក់ព្រើតស្រាប់ទប់ទាន់ ហើយស្រែកដោយក្តីឈឺចាប់:

~ ម៉ែន្ទ, អូយ! ម៉ែន្ទ! អាណិតអញផង កុំទាញខ្លាំងដៃពេក!

ពេលនោះខ្ញុំឥតត្រូវចេញភំទេ ខ្ញុំនៅអង្គុយលាយឡំជាមួយគេឯង ដល់ឃើញរឿងរ៉ាវអញ្ចឹង ខ្ញុំទៅជាខ្មាសលាយភ័យមិនហ៊ានមើល។ ពួកទាម៉ីនអង្គុយនៅពីក្រោយខ្ញុំ ងាកមុខចេញស្រីក្បាល ហើយនិយាយជំនុំគ្នាថា:

~ ម៉ាមន្ទ ដូចជាជ្រួលបន្តិចហើយ! ទោះបីគាត់ជាស្នំឯក ក៏គាត់ជាភូនរាស្ត្រសាមញ្ញ មិនគួរហ៊ានលេងសើចជាមួយហ្វូងដល់ថ្នាក់ហ្នឹងសោះ!។

កាលពីជំនាន់ហ្វូងមុន ឲ្យតែនរណាហ៊ានធ្វើផ្តេសផ្តាសកណ្តាលចំណោមអញ្ចឹង ច្បាស់ជាត្រូវទណ្ឌកម្មទ្រមួនមិនខាន។ ហ្វូងថ្មីនេះ ក៏អៀនខ្មាសខ្លាំងណាស់ដែរ ប៉ុន្តែមិនហ៊ានធ្វើអ្វីគេ ក៏ចេះតែត្រាំធ្វើមុខក្រាស់ទៅ។ សកម្មភាពផ្តេសផ្តាសរបស់ម៉ាមន្ទ កាន់តែធ្វើឲ្យហ្វូងឆ្មើយណាយខ្លាំងឡើង រហូតដល់ក្រោយមកមិនយូរប៉ុន្មាន លោកក៏ឆ្លែតឆ្លង់ទឹងតាត់មែនទែនតែម្តង។

លុះមកដល់ខែអាសាធនៃឆ្នាំនេះ បាវ៉ាំងត្រូវធ្វើបុណ្យជាតិគេនៅក្នុងសួនច្បារវត្តភ្នំ ហើយលោកទេសាភិបាល បានមកសុំហ្វូងឲ្យក្រុមល្មោនទៅភំក្នុងឧកាសនោះផង។

ពាក្យសុំរបស់បាវ៉ាំង ក៏ដូចជាពាក្យបង្គាប់ដែរ ម្ល៉ោះហើយហ្វូងត្រូវតែធ្វើតាមបង្គាប់គេទាំងខឹសទាំងចាស់ ប៉ុន្តែមិនឲ្យយកអ្នករប៉ាំល្អៗទៅភំទេ យកតែពួកមិនដឹងខ្យល់អី ចែកលុយឲ្យពីរ-បីរៀលម្នាក់ ហើយឲ្យចេញទៅភំទៅ។ ហ្វូងផ្ចាល់ព្រះអង្គ, ក្សត្រា, ក្សត្រី និង អស់អ្នក-អស់ទាង ទាំងអស់ បានទៀបឃ្លួមក្នុងរាត្រីសមោសរនោះ ហើយខ្ញុំក៏តាមទៅទឹងគេដែរ ដើម្បីលួចមើលបាវ៉ាំងឲ្យឃើញច្បាស់ម្តង ព្រោះខ្ញុំខានដើរទៅលេងឯសង្កាត់បាវ៉ាំង តាំងពីយូរណាស់មកហើយ។

ក្នុងរាត្រីដ៏ភ្លឺព្រោងព្រាតដោយពន្លឺភ្លើងចម្រុះពណ៌យ៉ាងនេះ ខ្ញុំមើលមកខ្លួនឯងឃើញដូចជាស្អាត ដូចជាល្អប្លែកសព្វមួយផង។ មនុស្សគ្រប់សញ្ជាតិយ៉ាងច្រើនកុះករ មកប្រមូលផ្តុំគ្នានៅពីមុខរោងរប៉ាំ ដែលតុបតែងលំអរទៅដោយ ទង់ជាតិ និង ស្លឹកទន្សែ។ ក្បែរោងរប៉ាំ មានសង់ជាទីការឈើមួយទៀត ដែលនៅលើនោះពួកស្រីភ័ងអង្គុយបត់ជើងត្រៀបត្រា ដោយម្នាក់ៗសុទ្ធតែមានក្មេងប៉ប៉ី កាន់ប្រអប់ស្លា និង កន្ទោរស្ពាន់ នៅពីក្រោយខ្នងផង។

លោកទេសាភិបាល អង្គុយលើកៅអីលាបទឹកមាសខ្លីមកពីក្នុងភឺង ប៉ុន្តែគាត់អង្គុយតាបជាងហ្វូងបន្តិច។ ឫកពាគាត់ហ៊ឺហាថ្លៃថ្នូរមែន ប៉ុន្តែបើមើលមកហ្វូងយើង ដែលពាក់អាវក្រង់ឡេវមាស ស្បៀកសំពត់ចងក្បិនពណ៌បៃតងនោះវិញ ក៏មិនមែនអន់ណាស់ណាដែរ។

បាវ៉ាំងមួយហ្វូង អង្គុយខ្លះ, ឈរខ្លះ; ចាស់ក៏មាន, ក្មេងក៏មាន, តាបក៏មាន, ខ្ពស់ក៏មាន; សក់ជ្រីងក៏មាន; ក្បាលទំពែកក៏មាន។ ពួកប្រុសៗមានធំរាងសង្ហា ហើយហាក់ដូចជាយកចិត្តទុកដាក់ខឹងមើលរប៉ាំខ្លាំងណាស់។ ចំណែកឯស្រីៗវិញ ពាក់ម្លូចទួលកញ្ចើ គ្រាន់តែកដៃធំជាងកជើងយើងទៅទៀត។ គេជជែកគ្នាអែ ឆ្កាដៃឆ្កាជើង គ្មានវេលាមើលរប៉ាំរ៉ាំជ័កអ្វីទេ។ ដល់ពេលគេលើកយកហេសដ្ឋ: និង ថាសទំមកដូច ពួកស្រីៗអស់ហ្នឹងងឹកស៊ីកណ្តាលចំណោមគ្មានខ្មាសអៀន ហើយបែបគ្មានបណ្តាក់ពោះផង មើលទៅ។

ពេលនោះ ស្រាប់តែកើតមានចលាចលនៅចំកណ្តាលវេទិកា ធ្វើឲ្យយើងស្រឡាំងកាំងគ្រប់គ្នា។ ស្រីម្នាក់ពាក់អាវបំពង់ខ្មៅយឺងហៀរដល់កែងជើង មានឈ្នួលម្នាក់កាន់ស្បែកជើងឈើដើរតាមក្រោយ ដើរកន្ទងក្បាល ទាំងស្តេច ទាំងរាស្ត្រ ជាន់ដៃជាន់ជើងនរណាក៏មិនវេរ់ គិតតែដឹកផ្លូវប្រជ្រៀតឲ្យបានទៅដល់កៅអីផ្លូវមុខ។ អស់ពីឆ្ងល់ យើងត្រឡប់ជាភ្ញៅក្រហាយ ទាំគ្នាព្រួតបញ្ឆោះមើស្រីឃួនជម្លើយ ព្រមទាំងចាប់ច្រានវាចេញផង។ ប៉ុន្តែវាបែរជានិយាយខ្មែរប៊ែប្បាំៗ ដេរតបមកយើងវិញ:

~ ពួកឯងរាល់គ្នាអាងអីក៏សម្បើមម្ល៉េះ? អាងអំណាចស្តេចហ្នឹងហ្ល៉ៃ? ពួកឯងស្គាល់អញជានរណាទេ? អញជាប្រពន្ធលោកទេសាភិបាលណា៎! ឯងមិនដឹងថាប្តីអញជាម្ចាស់ស្រុកខ្មែរ ត្រួតត្រាលើក្បាលស្តេចរបស់ឯងទេឬអី?

ស្ល! មីស្រីស្បៀកពាក់មើលតែអ្នកលក់ទឹកត្រីអញ្ចឹង ហ៊ានអួតខ្លួនថាជាប្រពន្ធទេសាភិបាលបាវ៉ាំងផង។ ពួកយើងជជែកឈ្លោះគ្នាទ្រហឹងអឺងអាប់មិនដាច់មិនស្រេចសោះ។ លោកមហាមន្ត្រី រត់ត្រហេបត្រហបមកឃាត់ទាន់ពេល ដែលស្រីមួយហ្វូងធំកំពុងស្ទុះព្រួ ប្រុងចូលមកជួយគ្នាវា។ គាត់ទំឃាត់ឲ្យឈប់ឈ្លោះគ្នា ប៉ុន្តែម្ចាស់ក្សត្រី ជីប នៅតែប្រឹងប្រែកជំទាល:

~ បើមីហ្នឹងវាថា វាជាប្រពន្ធបាវ៉ាំង ម៉េចវាក៏មិនមកអង្គុយលើកៅអីមាសជិតប្តីវាទៅ?

ក្រោយបន្តិចមក រឿបរឿបរយក៏កើតមានឡើងវិញ ប៉ុន្តែរឿងរ៉ាវមិនទាន់ចប់ត្រឹមណេះទេ។

នៅពេលត្រឡប់មកភឺងវិញ ពួកអស់អ្នក-អស់ទាងនាំគ្នាផុកជាន់ឲ្យហ្វូងចាប់ស្រីជម្លើយនោះមកធ្វើទោស ព្រោះវានេះ ពីដើមគ្រាន់តែជាឈ្នួលប៉ប៉ីនៅក្នុងភឺងប៉ុណ្ណោះ ប៉ុន្តែដំណើរឿងវាបែរជាមានសភាពផ្ទុយទៅវិញ គឺស្រីនោះចូលមកតាស់ហ្វូង ដោយម្តងនេះស្បៀកពាក់ហ៊ឺហាអស្ចារ្យ ដើម្បីសុំឲ្យហ្វូងស្តីបន្ទោសពួកយើង ដែលហ៊ានជេរបញ្ឆោរវា។ ជាសំណាងល្អ ខ្ញុំរួចខ្លួន ពុំត្រូវបានគេហៅទៅទទួលទោសជាមួយអ្នកឯទៀតទេ បើសិនជាទៅ ប្រហែលជាខ្ញុំទទួលទោសធ្ងន់ជាងគេផងក៏មិនដឹង ព្រោះក្នុងពេលមានរឿងខ្ញុំជេរបញ្ឆោរខ្លាំងដៃណាស់។ ហ្វូងអស់សង្ឃឹមទន់ដៃទន់ជើង ប្រគល់កិច្ចការទៅឲ្យលោកមហាមន្ត្រីចាត់ចែងជំនួស។ ដើម្បីបំពេញចិត្តស្រី គេចាប់ម្ចាស់ក្សត្រី ចិត្តារ៉ង្ស ដែលគ្មានដឹងរឿងអ្វីសោះ យកទៅដាក់គុកលេងទេ ព្រោះគ្នាជាចៅស្តេចអង្គខ្លួង សាច់ញាតិឆ្ងាយពីគេ ហើយជាពិសេសទៅទៀត គ្នាកំព្រាគ្មានរណាជួយការពារផង។

♥ ♥
♥

ខ្ញុំអាយុបាន ១២ ឆ្នាំ ហើយ ប៉ុន្តែចរិតខ្ញុំ ឃើញហាក់ដូចជាគ្មានប្រែប្រួលប្លែកពីដើមសោះ ។ អ្នកឯមទទួលបន្ទុកខាងត្រួតត្រា ក្រុមចាំយាមបំរើហួង និង បើកប្រាក់ខែឲ្យពួកអស់អ្នក-អស់ទាង បានចុះឈ្មោះខ្ញុំទៅក្នុងបញ្ជីក្រុមយាមទីបួន ហើយខ្ញុំក៏ចូលទៅកាន់មុខការថ្មី ចាប់តាំងពីពេលនោះមក ។

ពួកស្រីយាមបំរើហួង មានចែកជាបួនក្រុម ដែលត្រូវចូលមកធ្វើការឲ្យបានខៀងខាត់បំផុត ។ ពួកធំៗក្នុងក្រុមនីមួយៗ ត្រូវចូលទៅគាល់ផ្ទាល់ដល់ក្នុងបន្ទប់ដែលហួងគង់តែម្តង សម្រាប់ម៉ៅបចំរឿអាហារ បញ្ជូនពាក្យបញ្ជាផ្សេងៗមកអ្នកបំរើ និង ម៉ៅបចំព្រះស្ងោយថ្វាយហួងសោយលើតុតាមរបៀបអ៊ឺរ៉ុប ហើយខ្លួនឯង បរិភោគបាយអង្គុយបត់ជើងផ្ទាល់លើកន្ទេលព័ទ្ធជុំវិញតុ ដោយស្រែកច្រៀងបទមហោរីកំដរជាប់រហូតផង ។ នរណាជាអ្នករបាំ ពុំបានបោះបង់ការហាត់រាំប្រចាំថ្ងៃរបស់ខ្លួនចោលទេ ម្ល៉ោះហើយមួយថ្ងៃៗគ្មានវាល់ជាប់ហួត រកពេលដើរកំសាន្តមិនបាន ឲ្យតែទំនេរ ក៏តាំងប្រុះដេកភ្លាម ព្រោះអស់កម្លាំង អត់ងងុយខ្លាំងពេក ។ ក្នុងរាជ្យហួងមុន តែនរណាបានមកបំរើហួងហើយ ទុកជាមិនបាច់ទៅហាត់រាំ ក៏គេមិនថាអ្វីដែរ ខុសប្លែកពីឥឡូវឆ្ងាយណាស់ ។

ប៉ុន្តែ យើងជាពួកក្មេងតូចៗ គេឲ្យនៅខាងក្រៅត្រង់រាជហោល ឬ ក្នុងបន្ទប់ណាមួយក្បែរបន្ទប់ហួង សម្រាប់ចាំជួយធ្វើការពួកធំៗ និង អង្គុយពាក្យខ្សែបក់ផ្ទិតព្យួរនៅពិតាន ឲ្យរហើយក្នុងកន្លែងហួងគង់ ។

មុខការពាក្យខ្សែបក់ផ្ទិតតាមប្រហោងជញ្ជាំងអញ្ចឹង វាមិនគាប់ចិត្តខ្ញុំសោះ ទម្រាំតែផុតយាមម្តងៗ ខ្ញុំអផ្សុកស្ទើររយៈដើមទ្រូង ។ ថ្ងៃមួយខ្ញុំយកខ្សែមកចងបន្តឲ្យបានជិងមែនទែន ដើម្បីចេញទៅទិញនំទៅខាងក្រៅ ស្រាប់តែខ្សែនោះដាច់ប៉ិត ខ្ញុំភ័យស្ទើរលោះព្រលឹង ។ ប៉ុន្តែជាសំណាងល្អ ពេលនោះហួងកំពុងផ្ទំលក់ស្កប់ស្កល់ ពុំបានឃើញកន្ទុយខ្សែរបូតទៅដល់ជិតត្រែទេ ។

ពេលមួយនោះ យើងកំពុងអង្គុយជុំគ្នាក្នុងបន្ទប់ខ្លួលភ្ញៀវ រង់ចាំហួង និង ស្នំគាប់ព្រះទ័យទាំងឡាយសោយ និង បរិភោគបាយរួច នឹងអាលគេរៀបចំឲ្យយើងបរិភោគម្តង ស្រាប់តែឮស្នូរសម្លេងហួងស្រែកខ្ចាំងៗហៅពួកយើងក្មេងតូចៗឲ្យចូលទៅបរិភោគបាយជាមួយពួកគេឯងខាងក្នុង ។

គ្រាន់តែឮអញ្ចឹងភ្លាម ពួកម៉ាកខ្ញុំស្ទុះរត់ប្រូចគេចបាត់អស់ ព្រោះពួកវាខ្លាចហួងផង ខ្មាសគេផង មិនហ៊ានចូលទៅស៊ីបាយជិតគេ ។ ខ្ញុំក៏រៀបរត់ទៅតាមគេដែរ ប៉ុន្តែហួងចូលមកទាន់ ឃើញខ្ញុំតែម្នាក់ឯងក៏តំហកសួរថា :

~ ពួកហ្នឹងវាទៅណាអស់ទៅ ? អញហៅវា វារត់ពួនអញ្ចឹងស្អែ ! មីក្មេងច្រឡឹមអស់ហ្នឹង សមតែកាត់កចោល... ហើយឯងម៉េចមិនរត់ទៅនឹងគេ ? ឯងឈ្មោះអី ?

~ ក្រាបទូល ខ្ញុំម្ចាស់ឈ្មោះ យ៉ែម (ខ្ញុំធ្លើយតបទាំងភ័យញាប់ញ័រ) ។

~ យ៉ែម ? មីណាក៏ឈ្មោះ យ៉ែម... យ៉ែមដូចគ្នាទាំងអស់តែម្តង ។ ហ៎ ! ទៅស៊ីបាយទៅ ចាំអញរកឈ្មោះថ្មីដាក់ឲ្យ ។

ខ្ញុំដើរចូលទៅក្នុង ហើយអង្គុយក្បែរពួកឃុនពួកម៉ម ដែលតាមសម្លឹងមើលខ្ញុំដោយញញឹមខ្លឹប ។ ម៉មទូចៅហ្វាយខ្ញុំក៏នៅទីនោះដែរ តាត់អង្គុយក្បែរកៅអីហួង ។ តាត់និយាយឡើងរបៀបម៉ិកម៉ក់ :

~ ខ្ញុំម្ចាស់សប្បាយចិត្តណាស់ ដែលឃើញព្រះអង្គចង់ប្រទានឈ្មោះឲ្យក្មេងនេះ ។ ខ្ញុំម្ចាស់ស្រឡាញ់វាណាស់ ព្រោះវាមានចរិតគួរឲ្យចូលចិត្ត ។

~ ឈប់ ម៉ែទូ, ចាំអញរកឈ្មោះល្អដាក់ឲ្យវា ។

ការបរិភោគបាយបានបន្តទៅទៀត ក្នុងបរិយាកាសសប្បាយរីករាយ ។

ខ្ញុំសង្កេតឃើញពួកចុងប្រុស អាចចេញចូលក្នុងបន្ទប់បានដោយសេរី ដើម្បីលើកម្ហូបអាហារបំរើហួង និងប្រពន្ធហួង ដែលជាការផ្តួយស្រួលកាលពីរាជ្យមុន ។ ពួកចុងនេះ ស្លៀកពាក់សង្ហាអស្ចារ្យ អ្នកខ្លះជាគ្រូនាម៉ឺនធំដុំផង សុខចិត្តមកធ្វើចុងហួង ព្រោះតែចង់នៅជិតអស់អ្នកអស់ទាង និង ស្រីរបាំ ។

នៅពីមុខតុហួង គេក្រាលកន្ទេលធំពីរលើកម្រាលព្រំ ហើយរៀបចំ ចានប្រាក់, ដបស្រាបារាំង និង បង្អែម ពោរពាសពីលើនោះ ។ ពួកស្រីបំរើតម្រៀបគ្នាជាជួរ លើកថាសមាសដាក់ បាយអង្គុយសក្ការៈ និង ម្ហូបអាហារផ្សេងៗ ពីតំណាក់ពិសេស មកហុចបន្តឲ្យចុងប្រុសយកមកម៉ៅបចំថ្វាយហួងលើតុ និង ម៉ៅបចំដាក់ឲ្យយើងបរិភោគលើកន្ទេល ហើយថយទៅអង្គុយលុតជង្គង់ពីក្រោយខ្នងយើង ចាំបម្រើហុចនេះហុចនោះទៀត ។

ខ្ញុំអង្គុយបត់ជើងផ្ទៀងខ្លួនបន្តិចច្រត់ទៅលើដៃឆ្វេងដូចពួកគេធ្យាដែរ សល់ទំនេរតែដៃស្តាំមួយ សម្រាប់កាន់ស្លាបព្រាឬសម ។ យើងអង្គុយចាំតែស៊ី មានឈ្នួលចាំបំរើ ដួសបាយ ហុចទឹក គ្រប់បែបយ៉ាងទាំងអស់ ។

ស្រីចាស់ពុំអង្គុយផ្លែកខ្នងទល់នឹងជញ្ជាំងជុំវិញបន្ទប់ ចាំយាមបំរើយើង ។ ក្នុងបន្ទប់នេះមានមនុស្សអ៊ូអែរ និង អុជភ្លើងភ្លឺព្រោងព្រាតពេញមួយយប់ទល់ភ្លឺ ។

ខ្ញុំសង្កេតឃើញក្នុងចំណោមពួកស្រីដែលអង្គុយបរិភោគបាយជុំវិញកន្ទេល មានពួកភ្ងូអ្នកស្រែទើបមកនៅភ្នំងថ្មីៗ ហើយត្រូវហួងហៅមកឲ្យស៊ីបាយជាមួយគេដែរ ដើម្បីលោកនិយាយបង្ហាប់បន្ទុះឲ្យអស់អ្នកអស់ទាង និង អ្នកបំរើ បានសើចលេងជាល្បែង ។ ខ្ញុំយល់ឃើញថា ស្តេចផែនដីដល់ធ្វើអញ្ចឹងទៅ វាដូចជាមិនស្មើរសមរម្យ ព្រោះវាដូចជាបង្ហាប់ស្រីបំរើឲ្យថោកជាងបោយលាងចានទៅទៀត ។ ទៅក្នុងរាជ្យថ្មីនេះអ្វីៗក៏ផ្លាស់ប្តូរទាំងអស់ គឺហួងមិនគ្រាន់តែអនុញ្ញាតឲ្យបោយប្រុស ចូលមកក្នុងបន្ទប់ផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងបង្ហាប់ឲ្យពួកនោះ និយាយរឿងចំអែសចំអាសនៅនឹងមុខយើងស្រីៗ ដើម្បីសើចលេងទៀតផង ។

ស្អែកឡើង ម៉មទូ ហៅខ្ញុំទៅ លាបម្សៅ, លាបទឹកអប់ ដើម្បីទៅគាល់ហួងសុំឈ្មោះថ្មី ។ ឃើញម៉មទូតាំងខ្ញុំមក ហួងញញឹមខ្លឹបងើបអង្គុយលើព្រែ សំយុងជើងមកជិតយើង ដែលអង្គុយបត់ជើងផ្ទាល់លើកន្ទេល ។ លោកងោក្បាលគិតយ៉ាងយូរ ហើយធ្វើមាត់ជីបអួចៗ សូត្រឈ្មោះដែលបានប្រទានឲ្យស្ទេចទៅហើយ : ស៊ីម៉ាញ, ស៊ីម៉ាយ៉ត, កេតស៊ីឌី, សុផាស៊ី, សុម៉ីរ៉ាន, កិតសុម៉ុន, សុផាយ៉ត, វីឡេញ, បុប្ផាភ្លង, សុម៉ារិន, ដួងបូរ៉ា, សយផា, ណារ៉ាកាន, សុម៉ន្ទមិត្រ, សយសង្វាន, ម៉ាញ៉ាស៊ី... ។ នៅទីបញ្ចប់ លោកមានបន្ទូលថា :

~ឈ្មោះ សុម៉ាយ៉ត ភាមិនសមទេ, ស៊ីម៉ាឡា ក៏មិនសម... កាលពីដើមមានស្តេចភូមាមួយអង្គមានប្រពន្ធបី ប្រពន្ធទីមួយឈ្មោះ សាវ៉ាម៉ាឌី, ទីពីរឈ្មោះ សុម៉ាយ៉ត និង ទីបីឈ្មោះ ស៊ីម៉ាឡា ។ ស្តេចស្រឡាញ់នាង សាវ៉ាម៉ាឌីណាស់ ព្រោះនាងចេះថ្នាក់ថ្នម ហើយជាពិសេសទៅទៀត នាងមានក្លិនប្រេសមួយ ទុកសម្រាប់ស្នងរាជ្យ ដែលជាហេតុធ្វើឲ្យប្រពន្ធទុងទាំងពីរកើតក្តីច្រណែនខ្លាំង រកឧបាយសម្លាប់ប្រពន្ធដើមចោលទៅ ។ ប៉ុន្តែបានគុណបុណ្យ នៃអំពើល្អលោកជួយ នាងក៏បានរស់រានមានជីវិតឡើងវិញ ហើយរស់នៅយ៉ាងសុខសាន្តជាមួយស្វាមីរៀងរហូតមក ។ អញឲ្យឈ្មោះឯងថា សាវ៉ាម៉ាឌី, ឯងទៅប្រាប់ឯម ឲ្យគេចុះឈ្មោះហ្នឹងដាក់ក្នុងសៀវភៅបញ្ជីទៅណា! ហើយនែ! អញផ្តាំផ្តាច់ បើអាណាហៅឈ្មោះឯងផ្សេងពីហ្នឹង កុំឆ្លើយឲ្យសោះ ។

ម៉មន្ទ អង្គុយក្រោយខ្នង លួចរ៉ូបប្រាប់ខ្ញុំឲ្យថ្វាយបង្គំហួងបីដង ប៉ុន្តែខ្ញុំថ្វាយបានតែម្តង ក៏ស្រាប៊ីងគាំងឆ្កឹត រកធ្វើតទៅទៀតមិនកើត ។ លោកមានបន្ទូលតទៅទៀត :

~ឯងបានឈ្មោះល្អអញ្ចឹង ទំបំរើអញឲ្យល្អណា កុំធ្វើច្នៃតថ្ងូចពួកមីឯទៀតនោះ អញស្តប់ណាស់ ។

ម៉មន្ទ ដឹកដៃខ្ញុំចេញទៅក្រៅវិញ ដែលនៅទីនោះ មានពួកម៉ាកខ្ញុំកំពុងឈរង់ចាំកុះករ ដោយចិត្តច្រណែនឈ្នានីសថា ឈ្មោះខ្ញុំល្អជាងវា ។ មីប៉ុនវាបានឈ្មោះថា កេតស៊ីឌីរួចទៅហើយ ប៉ុន្តែដល់ឃើញឈ្មោះខ្ញុំល្អជាង វាក៏ប្រាប់អ្នកឯមថា ខ្ញុំព្រមផ្លាស់ឈ្មោះជាមួយវា ឲ្យគាត់ចុះបញ្ជីថាឈ្មោះ សាវ៉ាម៉ាឌីនេះជាឈ្មោះវាវិញ ។ ខ្ញុំទៅទូលហួងពីរឿងនេះ ហើយហួងក៏ហៅ មីប៉ុនទៅស្តីឲ្យសន្ធឹកសន្ធាប់ ព្រមទាំងហាមមិនឲ្យនរណាផ្លាស់ឈ្មោះខ្ញុំជាដាច់ខាត ។

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំត្រូវបាឡូចខ្លួនពីមុខការទាញខ្សែបក់ធ្ងិត ប៉ុន្តែដោយខ្ញុំពុំចេះរបៀបរៀបចំខ្សៀអាហ៊ៀន គេគ្រាន់តែឲ្យខ្ញុំចាំទូលយកខ្សៀដែលគេ «ធ្វើ»រួចស្រេច ដើម្បីយកទៅថ្វាយហួងសោយតែប៉ុណ្ណោះ ។ មុខការនេះស្រណុកពេកណាស់ គ្រាន់តែប្រយ័ត្នប្រយែងបន្តិច ក៏គ្រប់គ្រាន់ណាស់ទៅហើយ គ្មានចាំបាច់ហាយខ្នងហាយចង្កេះទេ ។ ហួងផ្ទំសណ្តូកលើត្រែដ៏តូចហើយតាប ប្រកបទៅដោយពួកទន់ល្មើយមានកម្រាលកម្ទី ដែលគេផ្លាស់ប្តូរពណ៌រៀងរាល់ថ្ងៃ ម្តងបែរទៅខាងណោះ ម្តងបែរទៅខាងណោះ ដើម្បីទទួលខ្សៀអាហ៊ៀនពីស្រីពីរឬបួននាក់ អង្គុយអមសង្វាងត្រែ ជាអ្នកចាំហុចថ្វាយយកទៅបឺតបង្គុយ ។

ហួងមិនស្ទាវនិយាយស្តីអ្វីទេ ម្តងបែរទៅឆ្វេង ម្តងបែរទៅស្តាំ ដើម្បីហុចខ្សៀដែលសោយរួចហើយ ឬទទួលយកខ្សៀថ្មីមកទៀត..... ឃ្យាម្តង លោកស្ទាវយើងពីចំនួនខ្សៀដែលលោកបានសោយរួចហើយ ។ ខ្ញុំមិនដែលចាំថា ហួងសោយប៉ុន្មានខ្សៀទេ ម្ល៉ោះហើយគេក៏យកពែងមាសមកដាក់ពីមុខយើង កាលណាហួងសោយមួយខ្សៀ យើងត្រូវទម្លាក់គ្រាប់ក្រហមមួយទៅក្នុងពែងនោះ ។ ទោះបីគេធ្វើយ៉ាងហ្នឹង ក៏យើងនៅតែភ្លេចភ្លាំងជាញឹកញយ ដែលជាហេតុញ៉ាំងឲ្យហួងតវ៉ាថា លោកបានសោយ ច្រើនលើសចំនួនដែលយើងរាប់ឆ្ងាយណាស់ ។

ខ្ញុំចាំច្បាស់ថាក្នុងមួយថ្ងៃ យ៉ាងហោចណាស់ក៏ហួងសោយអស់ជាងមួយរយខ្សៀដែរ ។ កាលណាហួងសោយស្រេចហើយ លោកមិនវេរឲ្យរឿងយើងរាប់ខុសឬត្រូវទេ ប៉ុន្តែលោកជេរបញ្ឆោរយើងជាញឹកញាប់ ព្រោះយើងចេះតែលួចបាវីលោកចែកគ្នាជក់ និង ធ្លៀតពេលលោកផ្ទំលក់ ជជែកគ្នាខ្សឹបខ្សៀវ ឬ ចាក់ក្រមៀកប្រឡែងគ្នា ។

កាលណាហួងសោយអាហ៊ៀនអស់កម្លាំង ហើយសម្ងំផ្ទំ ម៉មន្ទ ក៏ឡើងទៅសម្រាន្តលើត្រែជិតលោក ឧបាតគ្នាទៅវិញទៅមក គ្មានគិតខ្មាសអៀនពួកយើងដែលនៅអង្គុយត្រៀបត្រានេះសោះ ។ ពេលនោះ

យើងតាំគ្នាថយទៅកាន់បន្ទប់មួយស្ថិតនៅជាប់គ្នានឹងបន្ទប់ហួង ហើយជីកមុងប្រះផេកទៅលើពួករនាបដែលគេរៀបចំទុក្ខចស្រេចសម្រាប់ឲ្យយើងសំរាក ។ យើងប្រះផេកកាលណា ក៏លក់ភ្លាមមួយរំពេច ពីព្រោះយើងពុំដែលគិតខ្វាយខ្វល់ព្រួយបារម្ភពីរឿងអត់ស៊ីមានស៊ីនៅថ្ងៃស្អែកឡើយ ។

យប់ខ្លះខ្ញុំភ្ញាក់ដឹងខ្លួនយប់កណ្តាលអាត្រាត្រ ស្រាប់តែឃើញហួងស្ងៀកសារុងលែងខ្លួនទេវេ ចេញក្បាលពោះធ្រេយុក ដើរពាសពេញបន្ទប់តែម្នាក់ឯង ឥតមានជាស់នរណាសោះ ។ ជួនកាលលោកដើរមកជិតមុង ឈរមើលពួកយើងផេកយ៉ាងយូរ ហើយទាញជើងមុងរៀបជាក់ឲ្យស្រួលឡើងវិញ ដើម្បីកុំឲ្យមូសចូលខាំយើង ។

កាលណាលោកដើរតម្រង់មកកន្លែងខ្ញុំផេក ខ្ញុំសម្ងំបិទភ្នែកធ្វើហាក់ដូចជាផេកលក់ រង់ចាំមាល់តែលោកចេញទៅផុត ទើបងើបលួចមើលតទៅទៀត ។ ហួងដើរយឺតៗកាត់បន្ទប់ខាងចេញទៅឈរលើរាងហាលស្រួបយកធាតុអាកាសត្រជាក់ នៃរាត្រីកាល ដែលមានសម្លេង ចង្រិត និង ង៉ែ បន្ធឺតតាចាំរយៈ ជាគ្រឿងកំដរសភាពស្ងប់ស្ងាត់ ។ ហួងរាប់ជំហានដើរទៅដើរមកជារបៀបហាត់ប្រាណ ដោយមិនបាច់ចេញទៅក្រៅកំផែងពីព្រោះគេកម្រនឹងអនុញ្ញាតឲ្យលោកចេញពីវាំងណាស់ ហួងរស់នៅសព្វថ្ងៃ ប្រៀបបាននឹងមនុស្សជាប់គុកយ៉ាងនោះដែរ ។ លោកអត់ចេះខ្លាចខ្មោចទេ ហើយឈរភ្លឺកហួចខ្លួន ហាក់ដូចជាគិតទៅជើងឆ្ងាយ ។

ហួងចូលចិត្តមើលយើងផេកណាស់ ប្រហែលពីព្រោះទស្សនីយភាព នៃយុវវ័យឥតក្តីទុក្ខព្រួយបែបនេះអាចធ្វើឲ្យលោកទន់ចិត្តអាណិតស្រឡាញ់យើងក៏មិនដឹង ឬមួយក៏លោកមើលប្រយ័ត្នក្រែងនរណាមួយផេកបម្រះរបួតសំពត់ ខ្លាចក្រែងអ្នកបំរើប្រុសវាដើរកាត់តាមនេះ មើលឃើញក្តិតភ្លាំងក៏មិនដឹង ។ ម្តងនោះ ខ្ញុំឃើញហួងយកជើងឆ្កេះជាស់ស្រីៗដែលផេកថ្ងារចង្ក្រានយះជើងឥតអាស្រូវ ហើយសំពត់របួតមកគ្របបក្បាលឯណោះវិញ ។ លោកស្តីឲ្យពួកនោះសន្ធឹកសន្ធាប់ណាស់ ព្រមទាំងប្រាប់យើងទាំងអស់គ្នាថា ក្រោយៗបើឃើញនរណាផេកប្រហែសអញ្ចឹង ឲ្យយកឈើតូសអុជមមិះក្តិតម្តង ទើបវារាង ។ របៀបប្រដៅបែបនេះអាចទម្លាប់ឲ្យយើងចេះរស់នៅក្នុងជំនុំចំណោម ក៏ថ្លងជាទីស្ងាត់កំបាំងពីភ្នែកអ្នកដទៃដែរ គឺយើងចេះផេកសមរម្យ មិនកន្ត្ងឹងកន្ត្ងាំងផ្តេសផ្តាសទេ ។

ដល់ពេលថ្ងៃសឹលម្តងៗ ហួងស្ងៀកពាក់ស ឥមមិនសោយថាយស្លាច អត់ហួតដល់ព្រឹកស្អែកមួយទៀត ។ ដោយអផ្សុកមិនដឹងធ្វើអ្វី លោកសោយអាហ៊ៀនបង្គុយជាប់រហូត ភ្នែកសម្លឹងមើលទ្រនិចទាឡិកាចោ៉ល ដោយក្តីអន្ទះអន្ទែង ហើយស្ទារត្រដែលៗតែពីរឿងគេចាញ់កាំភ្លើងព្រឹកព្រហាមហើយឬនៅ? ត្បូរឲ្យធុញទ្រាន់ពេកណាស់! ។

គ្រាន់តែមាន់រងាវមិនទាន់ លោកស្រែកជាស់គេជាស់ឯង នរណាមិនភ្ញាក់ ក៏ស្រែកជេរឲ្យឮឡាមាល់តែភ្ញាក់ ។ កាលណារឿងរ៉ាវដ៏អក័ព្វបែបនេះ ត្រូវធ្លាក់មកចំលើជនខ្ញុំ ខ្ញុំត្រូវងើបសើងមម៉ើងភ្នែកមម៉ីរ ទៅលាបម្សៅ, លាបទឹកអប់ ហើយចូលទៅអង្គុយគាល់ជាមួយមិត្តភក្តិឯទៀត ។ មួយប៉ប្រិចភ្នែកសោះ ម្ហូបអាហារក៏ប៉ៀបធ្ងំចស្រេច ហួងចាប់សោយផ្ងួចឃ្លានជាច់ជាបណាស់ ហើយចេះតែបង្ខំយើងឲ្យធ្វើផ្ងួចលោក ប៉ុន្តែយើងធ្វើតាមមិនកើតសោះ ព្រោះវាងងុយផេកជាងឃ្លាន ម្ល៉ោះហើយអ្នកខ្លះផេកលក់អង្គុយក៏មាន ។

ប៉ុន្តែក្រោយពេលបរិភោគហើយ ហួងតែងចែកបាវីស៊ីហ្គារធំស្តើរបៀមមិនជាប់ ឲ្យយើងជក់លេងកំសាន្តនិង រង្វាន់ផ្សេងៗទៀត ដែលជាហេតុធ្វើឲ្យយើងសប្បាយរីករាយ រហូតទាល់តែភ្លេចងងុយផេកអស់រលីង ។

នេះជាជីវភាពរបស់ហួង ដែលមានដំណើរប្រព្រឹត្តទៅចាប់តាំងពីពេលថ្ងៃលិចទៅទល់នឹងពេលថ្ងៃរះ ។ ទៅខាងក្រៅវាំងឯណោះ ស្នូរកាំភ្លើងម៉ោងថ្រាំភ្លឺបន្ទឺឡើង បណ្តាលឲ្យហួងក្អែកដែលកំពុងផេកទៅតាម

ដើមឈើទាទា ក្នុងសង្កាត់កំពង់ផែ ភ្ញាក់ផ្អើលខ្លៀវខ្វា ដើម្បីស្វែងរកចំណីអាហារក្នុងថ្ងៃថ្មីមួយទៀត។ កាលណាថ្ងៃក្តៅ ហួងផ្ទុំសោយអាកៀនកែអផ្សុកមួយថ្ងៃវាល់ល្ងាច។ ជាពិសេសក្នុងមួយថ្ងៃ ហួងមុជទឹក ពីរ-បី ដង ដោយមានអ្នកបំរើប្រែសជាអ្នកវៀបចំថ្វាយ ហើយលោកលាបទឹកអប់បាវាំង ដែលទិញមកទុកទាំងខ្លួ ឡើងក្រអូបលុយឈ្ងប់។ ខ្ញុំក៏ឧស្សាហ៍លួចលាបទឹកអប់ហ្នឹងជាញឹកញាយដែរ។

មានតែទេសាភិបាលបាវាំងទេ ដែលអាចមករំខានការសំរាកពេលថ្ងៃរបស់ហួងមួយដងមួយយាមបាន។ កាលណាគាត់ត្រូវការមកជួបហួងម្តងៗ គេសុទ្ធតែប្រាប់ពួកយើងឲ្យដឹងមុន ហើយនរណាចេះមើលម៉ាង ត្រូវទួលបញ្ជាចាំជាស់ហួងនៅវេលាម៉ោងបួន ដើម្បីលោកមានពេល មុជទឹក, ស្លៀកពាក់ទោអាវ និង ដកមេអាកៀន ពីរ-បី ខ្សៀសិន។

ការប្រែប្រួលខ្លាប់ប្រចាំថ្ងៃបែបនេះ តែងធ្វើឲ្យយើងច្រឡំម៉ោងពេលជាញឹកញាយ ម្ល៉ោះហើយហួងភ្ញាក់ឡើងហួសម៉ោង ក្រទីក្រខាដេរបញ្ជោប៉ាតណាប៉ាតណាបណ្តើរ ហៅយើងឲ្យទៅជួយ សឹកស្រាមជើង, ចងខ្សែស្បែកជើង បណ្តើរ។ រវល់តែឆ្គេមឆ្គួម ក្រុមហួងម៉ាទីល[3] នៅក្នុងសួនច្បារ ចាប់ប្រគុំឡើងជាសញ្ញាឲ្យដឹងថា លោកទេសាភិបាលមកដល់ស្រេចទៅហើយ។ លោកមហាមន្ត្រីចេញមកទួលភ្ញៀវជាន់ខាងក្រោម ប៉ុន្តែពួកបាវាំងថ្លងជាធុញទ្រាន់ខ្លាំងណាស់ ក្រពាត់ដែរដើរចុះដើរឡើងធ្វើមុខក្រញ៉ូវ។

នៅជាន់ខាងលើឯណោះ ហួងស្លៀកពាក់ ហើយនៅឲ្យគេយកទឹកអប់មកប្រោះលើខោអាវទៀត។

ឆ្លៀតនុកាសនោះ យើងបានលួចបាញ់ទឹកអប់លាបខ្លួនឯងផងដែរ។ បន្ទាប់មកហួងអង្គុយចុះ ឲ្យយើងយកផ្ទិតមកបក់ក្បាល ដើម្បីឲ្យឆាប់ស្ងួតសក់ ហើយមុខនឹងចុះទៅជួបភ្ញៀវ ដែលគេកំពុងតែអង្គុយចាំនោះ លោកឆ្លៀតបឺតអាកៀន ពីរ-បី ហឺតសិន។

នៅទីបំផុតហួងចុះទៅដល់ គោរពគ្នាទៅវិញទៅមក ហើយចាប់ចរចាគ្នាដោយមាន លោកមហាមន្ត្រីធ្វើជាអ្នកបកប្រែ។ យើងតាំគ្នាមកពួនពីក្រោយតាំង ដែលគេដាក់បាំងខ្លារខាងក្រោយ ដើម្បីលួចមើលឆាកសន្ទនានេះតាំងពីដើមដល់ចប់។ ក្រោយពេលភ្ញៀវបាវាំងចេញអស់ទៅ តែងមានតាមីនចូលមកតាល់បន្តបន្ទាប់គ្នា ហើយនៅពេលត្រឡប់មកបន្ទប់ឋិញ លោកមានទឹកមុខស្រពោនព្រួយបារម្ភអស់មួយយប់ ជួនកាលមានទាំងហៅម្ចាស់ក្បត្រីភួននោះ មកជែកគ្នាយ៉ាងសម្ងាត់ទៀតផង។

ពេលធម្មតា មានតែប្រជារាស្ត្រមកពីចុងកាត់មាត់ញក ដើម្បីមកសុំមានព្រះរាជទ្រព្យ ឬ មកសុំមើលព្រះភ័ក្ត្រហួងឲ្យបានច្បាស់ម្តងតែប៉ុណ្ណោះ។ ហួងចេញមកឲ្យអ្នកទាំងនោះថ្វាយបង្គំ ហើយប្រទានវង្វាន់បន្តិចបន្តួចឲ្យត្រឡប់ទៅវិញ។ យើងទួលភារៈកាន់សោខ្ជ ដាក់លុយ និង គ្រឿងអាលង្ការ មួយដងម្នាក់ ដែលជាភារៈធ្ងន់ធ្ងរឲ្យខ្ញុំភ័យព្រួយលើសអ្វីទាំងអស់ ពីព្រោះហួងឧស្សាហ៍ ដាក់លុយលើតុ, ដាក់ជាំរក្នុងជើងពាន ឬ ដាក់ទឹកអប់កន្លែងណាមួយ ហើយធ្វើជាភ្លេចចោល ដើម្បីចាប់ថ្នាក់យើងថាលួចរបស់លោកជាញឹកញាយ។

មុខការខ្ញុំកាន់តែយ៉ាប់ខ្លាំងឡើងៗ ហើយជាពិសេសនៅខៀត ខ្ញុំត្រូវទៅហាត់ភំរាល់ថ្ងៃ ឥតដែលខកខានពីព្រោះអ្នករបាំណាក៏ដោយ ឲ្យតែខកខានហាត់ ច្បាស់ជាធ្លាក់ខ្លួនឈឺ ចុកហាយដែរជើង លែងទន់ភ្លន់ភ្នាមមួយរំពេច។ រាល់ព្រឹក អ្នកគ្រូច្រចាច់ដែរជើង សម្រួលសាច់ដុំឲ្យខ្ញុំ ដែលជាហេតុធ្វើឲ្យរាងខ្ញុំរឹតតែខ្ងង់ឡើង

(3) ក្រុមហួងម៉ាទីលនេះ គឺជាក្រុមហួងបែបអឺរ៉ុប ដែលមានមកដល់ប្រទេសយើងមុនគេបង្អស់ សម្រាប់ប្រគុំក្នុងពិធីផ្សេងៗ របស់ហួង។ ហេតុដែលគាំឲ្យគេហៅថា ក្រុមហួងម៉ាទីល ពីព្រោះសមាជិកក្រុមនេះ សុទ្ធតែជាជនជាតិ ហ្វីលីពីន មកពីក្រុងម៉ានីល។

ហើយខ្ញុំក៏មិនស្វល់ឈឺថ្កាត់ក្នុងការចាំយាមបម្រើហួងនៅវេនទីបួននេះ។ ខ្ញុំបានឡើងហាន:ជាអ្នកគាល់បម្រើថ្នាល់ និង កាន់សោខ្ជព្រះរាជទ្រព្យតែម្តង។ វេនទីមួយៗ មានរយៈពេលដប់ពីរម៉ោងជាប់គ្នារហូត ដល់មានក្រុមថ្មីក្នុងចំណោមក្រុមបីផ្សេងទៀតចូលមកទួលវេន គឺថាក្នុងរយៈពេល ពីរយប់ពីរថ្ងៃ, សែសិបប្រាំបីម៉ាង យើងត្រូវចូលវេនដប់ពីរម៉ាង។ ប៉ុន្តែការដែលត្រូវឲ្យអផ្សុកបំផុត គឺក្នុងមួយអាទិត្យម្តង ខ្ញុំត្រូវដល់វេនបម្រើហួងសោយអាកៀន ពេញម្តែប្លួនម៉ោង។ ខ្ញុំស្រកសាច់ចុះស្គមសន្ធឹកណាស់ ដោយសារមិនសូវបានផេកសម្រាកឲ្យពេញភ្នែក ម្ល៉ឹងហើយកាលណាគេហៅខ្ញុំទៅ ច្រៀងមហោរី ឬ សក្រវាទី ជាមួយអស់អ្នកអស់ខាង ដែលគេជ្រើសរើសចម្រាញ់សុទ្ធតែជើងល្អឲ្យចូលក្នុងក្រុមតន្ត្រីនោះ ខ្ញុំក៏មិនដែលប្រកែកម្តងណាឡើយ។

ប៉ុន្តែ ទោះបីខ្ញុំខិតខំធ្វើការនឿយហត់យ៉ាងនេះក្តី ក៏ហួងមិនដែលមើលឃើញ សោតឯម្ចាស់ក្បត្រីក៏មិនដែលទួលហួងថាម៉េចដែរ ព្រោះតែខ្ញុំមិនចេះអារបៀបលុតក្រាបយកគាប់នៅទីងមុខផ្ទួចគេ។

ចំណែកឯមិត្តភក្តិខ្ញុំវិញ ខ្ញុំសង្កេតឃើញថា គេមានតែជួយជាន់ពន្លិចថែម ដើម្បីយកគាប់តួរសម្រាប់តែខ្លួនគេ។ ច្បាញ់ណាស់ទៅខៀត ថ្ងៃមួយហួងចោទប្រកាន់ថា ខ្ញុំលួចលុយពីរបៀល ដែលលោកបានដាក់ក្នុងថាសមាស ទោះបីខ្ញុំប្រកែកថាមិនដឹងយ៉ាងណា ក៏លោកមិនព្រមស្តាប់។ លុះដល់ខ្ញុំទៅខ្ជីលុយមើបានពីរបៀលមកសង លោកទួលយកភ្លាម ថែមទាំងនិយាយថា:

~ ហេងមែន! ចំលើពេលអញកំពុងខ្វះលុយផង! តែប៉ុណ្ណោះម៉េចក៏គ្រាន់ទឹងចាយបណ្តើរៗ ទម្រាំដល់ជាច់ខែដែរ។

ហើយលោកប្រទានលុយឲ្យបោយទៅទិញទឹកកកមកភ្លាមមួយរំពេច។ រំលងមកបានប៉ុន្មានថ្ងៃ លោកហ៊ានទិយាយដោយឥតអៀនខ្មាសថា លុយពីរបៀលនេះគ្មានទរណាលួចទេ គឺលោកយកខ្លួនឯង ប៉ុន្តែលោកចង់បំភ័យយើង ដើម្បីទក់មើលទឹកមុខ តើទរណាខ្លះភ័យច ខម្លាប់មានដែមានជើង។ លុយពីរបៀលនេះហួងឥតសងខ្ញុំរហូត។ ប៉ុន្តែក្រោយមកមិនយូរប៉ុន្មាន ម៉ែខ្ញុំបានចូលមកសុំគាល់ហួង ដើម្បីសុំព្រះរាជទ្រព្យខ្លះយកទៅជួសជុលផ្ទះ ព្រោះសសរពុកអស់ទៅហើយ ហើយជញ្ជាំង ដំបូល ក៏រហែកធ្ងុះធ្លាយខ្លាំងណាស់ដែរ។ ក្រោយពីបានស្គាល់ថាជាម្តាយខ្ញុំ ហួងក៏ប្រទានលុយសែសិបរៀលឲ្យម៉ែដោយផ្ទាល់ដៃ។

ឃើញហួងផ្ទួចជាសប្បុរសយ៉ាងនេះ ខ្ញុំក៏ប្រថុយទួលសុំច្បាប់ទៅលេងផ្ទះបងប្អូនឯស្រែបានពីរ-បី ថ្ងៃ។ មិនយូរប៉ុន្មាន សំបុត្រឭាយធ្លាក់មកមាន ទួក, ដីរ, រវេះ ខ្ញុំជ្រើសរើសយកមួយណាសម្រាប់ធ្វើដំណើរក៏បាន ព្រមទាំងមានក្រុមភាំងជួនដំណើរផង។ ខ្ញុំជ្រើសរើសយកដីរ ហើយនៅវេលាព្រលឹមស្រាងៗ នៃ ខែបុស្ស ខ្ញុំចេញដំណើរទៅជាមួយពុក និង ម៉ែ ដោយមានក្រុមភាំងចាស់ស្ងួតបួតម្នាក់ជួនទៅ។ យើងធ្វើដំណើរតាមបណ្តោយស្ទឹងព្រែកឆ្នោតពេញមួយថ្ងៃ ឆ្ពោះទៅកំពង់កន្ធួត។

សប្បាយអ្វីម្ល៉េះទេ! ខ្ញុំឆ្លូងខ្លួនចេញមកដកដង្ហើមស្រូបយកខ្យល់អាកាស នៃសេរីភាពនៅខាងក្រៅ។ ពុក សម្លឹងមើលមកខ្ញុំដោយក្រសែភ្នែកស្រទន់ គាត់ហ៊ីហាក្នុងចិត្តខ្លាំងណាស់ ដែលមានកូនស្រី ជាអ្នកបំរើហួង ជាអ្នកភំលោនហួង។ យើងអង្គុយលើកន្ទេលដែលក្រាលលើកូបដី ឃ្លេងឃ្លោងយោលខ្លួនប្រៀបបានទឹងជិះទូក ដោយសារចលនាបោះជំហានទៅមុខមួយៗ នៃ ពាហន:ជាជំនិះ។ ជុំវិញខ្លួនឃើញតែវាលស្រែតជាប់គ្នាឆ្ងាយជាច់ភក្តួយភ្នែក ខ្លះក៏ច្រូតហើយ ខ្លះមិនទាន់ច្រូតនៅឡើយ... ដើមស្នោតដុះ ឯណោះមួយដុំ ឯណោះមួយដុំ ឃើញតែដើមត្រង់ឆ្ពិត និង ស្លឹកមួយកញ្ជុំនៅពីលើ ហើយទៅឆ្ងាយជាប់នឹងជើងមេឃ ស្រមោលជួរភ្នំខៀវស្រងាត់ជាប់គ្នារដឹក។

យើងមានខ្ជប់បាយ និង ម្ហូបគោក ព្រមទាំងបង្អែមផ្លែឈើ មកផង ហើយយើងតាំគ្នាបរិភោគយ៉ាងឆ្ងាញ់

ក្រៃលែង ក្រោមជំនោរហើយ នៃ ហេមន្តវេរ៉ូ ។

នៅពេលទៅដល់កំពង់កន្ទួត ផ្តើលតាំងពី មេស្រុក, បាលដ្ឋ, សុភា, រហូតដល់អ្នកស្រុកអ្នកភូមិ មក ចោមរោមកុះករខ្ទួលខ្ញុំ ហើយសុំឲ្យខ្ញុំរាំឲ្យគេមើលម្តងផង ។ អ្នកស្រែខ្មៅក្រញោះ ហៅខ្ញុំសុទ្ធតែម្ខាស់ក្បត្រី ឃើញគ្រឿងអលង្ការដែល ម៉ាមន្ទ ឲ្យខ្ញុំខ្ចីពាក់មក គេជញ្ជក់មាត់សរសើរគ្រប់គ្នា ។ ម្តាយមីងខ្ញុំឈ្មោះ ម៉ុម ហៅ យើងឲ្យទៅសំណាក់នៅផ្ទះគាត់ ដែលសង់នៅទឹងមាត់ស្ទឹង ប៉ុន្តែហួងអ្នកស្រុកដែលទើបទឹងបានដឹងថា មានពួកលោកយុទមកក្នុងស្រុកខ្លួនអញ្ចឹង ចេះតែលើកគ្នាមកមើលមិនចេះអស់មិនចេះហើយសោះ ។

♥ ♥

♥

ក្រុមតន្ត្រីរាំព្រះរាជទ្រព្យ



Orchestre du Palais Royal

ឆ្នាំ ជាង ជិតទឹងផុតទៅហើយ តីហួងថ្មីឡើងគ្រប់គ្រងគេរបានពីរឆ្នាំហើយ ។ តាមការគន់គូររបស់ តាហោរ និង បាគូ ពិធីបុណ្យអភិសេកហួងឡើងសោយរាជ្យ ទឹងត្រូវរៀបចំធ្វើនៅដើមឆ្នាំមមី ខាងមុខនេះ ។

ជីវភាពរស់នៅក្នុងភាំងកាន់តែប្រែជាយ៉ាប់យ៉ឺនឡើងជាងពេលណាទាំងអស់ ។ ខ្ញុំត្រូវបំពេញមុខការជា ធម្មតាផង និង ត្រូវទៅហាត់រាំរៀងរាល់ថ្ងៃមិនដែលខកខានផង ដើម្បីចេញរាំក្នុងឧកាសបុណ្យធំមហោឡារិក នៅពេលខាងមុខនេះ ។ យើងទាំងអស់គ្នា កើតមានការព្រួយបារម្ភខ្លាំងណាស់ ពីព្រោះយើងដឹងថា ទេសាភិបាលបារាំងទឹងឡើងមកពីក្រុងព្រៃនគរ ដើម្បីមកបំពាក់មកុដរាជ្យជាទំមិត្តរួប នៃ អំណាច ថ្វាយហួង ហើយបើតាមពាក្យចចាមអារាម ដែលគេនិយាយពីមាត់មួយទៅមាត់មួយថា ហួងទឹងត្រូវចេញដំណើរទៅ ស្រុកបារាំង ឯទាយសមុទ្រទេឯណោះផង ។

ក្នុង ភាងជាង និង ផែវទៅទីធ្លាខាងក្រៅ ពួកជាងធ្វើការញាប់ដៃញាប់ជើង សង់ជាភាងឈើតាំងលំអ ដោយក្រដាសលាបពណ៌ ព័ទ្ធជុំវិញទេវិនិច្ឆ័យ និង សង់ជាភ្នំកែលាសក្លែងក្លាយមួយ ដែលហួងត្រូវឡើង ឈរលើកំពូលភ្នំនោះ ដើម្បីទទួលទឹកមន្តពី បាគូបុរោហិត ។ រាំងទាំងមូលអ្វីអរទាំងយប់ទាំងថ្ងៃ គឺទាមុីន ចេញចូលជំនុំគ្នាមិនដាច់មិនស្រេចសោះ ពីរឿងកាត់ភោអាវស្លៀកឲ្យបានហ៊ីហាក្នុងពេលបុណ្យ ។ លោក មហាទេព និង លោកមហាមន្ត្រី ត្រួតត្រាមើលជាងធ្វើការទាំងខាងក្នុងទាំងខាងក្រៅទេវិនិច្ឆ័យ ក្នុង ទេវាក្សិណ មហាមន្ទីរកន្លែងទទួលព្រះរាជវង្សានុវង្ស និង កន្លែងទទួលអស់អ្នកអស់ទាងក្នុងភាំង ឲ្យស្បថ សម្តែងភក្តីភាពចំពោះព្រះមហាក្សត្រ... ។

ពិធីបុណ្យអភិសេក រៀបចំធ្វើឡើងពេញប្រាំមួយយប់ប្រាំមួយថ្ងៃ ហើយក្នុងរយៈពេលនេះ មានល្ខោ បាភាំង ស្តេច និង ខ្ញុំរាជការ ចេញចូលក្នុងទេវិនិច្ឆ័យ ថ្វាយបង្គំច្រើនកុះករ ។

ព្រះសង្ឃគ្រប់ទីវរលឿង និមន្តមកស្វត្រធម៌គ្រប់ទាំងប្រាំមួយថ្ងៃ ហើយពួកបាគូបួងសក់ ពាក់អាវផាយ ប៉ាក់ឱនមាស ដៃកាន់ជួបសំណាក ព្រះវិស្ណុ ព្រះសិវៈ ព្រះខាន់ជ្យ និង ត្រា ជាសញ្ញា នៃ អំណាច គ្រប់បែបយ៉ាង ដែលគេប្រគល់មកឲ្យខ្លួនថែរក្សាទោះ ក៏វរលំខ្វែងដៃខ្វែងជើងខ្លាំងណាស់ដែរ ។

ហួងផ្ញើចជារីកមុខរីកមាត់សប្បាយចិត្តរកអ្វីមកប្រៀបឲ្យស្មើពុំបាន ។ លោកភ្លេចអស់គំនិតផ្តើសផ្តាសកាលពីមុន គេបង្គាប់ថាឲ្យលុតក្រាបយ៉ាងម៉េចតាមទំនៀមទម្លាប់ ក៏ចេះតែធ្វើតាមគេទាំងអស់ ។ លោកស្លៀកពាក់ស្អាតអស្ចារ្យ ដូរពណ៌ ស្វាយ លឿង ស ឬ ខ្មៅ ទៅតាមថ្ងៃ ព្រមទាំងទ្រង់គ្រឿងអលង្ការដ៏មានតម្លៃកាត់ថ្លៃមិនបាន ។

ប្រជារាស្ត្រ នៅក្នុងរាជធានីខ្លះ មកពីខេត្តក្រៅខ្លះ ឈរប្រជ្រៀតគ្នាណែនណាន់តាន់តាប់ ដើម្បីមើលពិធីនេះ។

មិនដឹងជាយល់ឃើញយ៉ាងម៉េច បានជាគេយកពួកល្ខោនមកឲ្យរាំក្នុងវេរិនិច្ឆ័យ ដែលពោរពេញទៅដោយតាមុីតគ្រប់ជាន់ថ្នាក់យ៉ាងនេះទៅវិញ។ ខ្ញុំជួចជាចាំថា ក្នុងរាជ្យមុនគេអត់ដែលមានធ្វើអញ្ចឹងទេ ឬមួយគេធ្វើតាមទំនៀមទម្លាប់បុរាណតាំងពីយូរណាស់ហើយក៏មិនដឹង។ នៅខាងក្រៅក្នុងទីធ្លាក្រោលអិដ្ឋនោះ មានសង់រោងសក្តារៈបួន ដាក់ត្រង់ទិសទាំងបួន ហើយមានអ្នករបាំបួនគាក់ឈរយាមប្រចាំការ រង់ចាំតែហ្លួងឲ្យសញ្ញាឡើង ទីឯអាលធ្វើពិធីបូជា ជាទិមិត្តរូប។

ក្រុមខ្ញុំមានគ្នាដប់ប្រាំមួយនាក់ ជាក្រុមសំខាន់ជាងគេ ត្រូវរាំនៅក្នុងវេរិតែម្តង។ ការដែលគេប្រគល់កិត្តិយសយ៉ាងនេះមកឲ្យខ្ញុំ ធ្វើឲ្យខ្ញុំឡើងជំនោរបន្តិចដែរ ប៉ុន្តែបើនិយាយពិតទៅ ខ្ញុំជួចជាខ្មាសខ្លាំងណាស់ដែលឲ្យមករាំមុខព្រះសង្ឃអញ្ចឹង ពីព្រោះវិន័យសង្ឃហាមផ្តាច់មិនឲ្យមើលរបាំរាំរបាកអ្វីទេ។ ប៉ុន្តែធ្វើម៉េចបើកាលៈទេសៈវាតម្រូវអញ្ចឹងទៅហើយ ។ យើងមានគ្នា ១៦ នាក់ តម្រៀបជាពីរជួរ, ជួរខាងឆ្វេងប្រាំបីនាក់ ដើរតួប្រុស, ជួរខាងស្តាំប្រាំបីនាក់ ដើរតួស្រី។ យើងដើរចូលមកក្នុងឆាក ដែលនៅទីនោះ គេមានតម្រៀបជើងពានដប់ប្រាំមួយជាពីរជួរទុក្សចស្រេច ហើយយើងអង្គុយចុះពីមុខជើងពានមួយម្នាក់ៗជើងៗខ្លួន។ ហ្លួងចាប់ប្រគុំបទបើកឆាក យើងម្នាក់ៗលូកដៃចាប់ជើងពានម្ជុំងៗខ្លួន ដែលមានផ្កាល់ត្រឿងប្លាជាផ្សែងៗ ផ្លូចជាសាច់ផ្អែក, មាន់ស្ងោរ, ផ្លែឈើ និង ចំណីច្រើនមុខទៀត ហើយយើងងើបឈរឡើងធ្វើកាយវិការរបាំជាទៅគ្រប់ទិសទាំងបួន។ របាំនេះចប់ទៅ យើងដាក់ជើងពានចុះទៅវិញ ហើយហ្លួងឆាបញ្ចុះក៏ចាប់ប្រគុំឡើងដោយមានហ្លួងវៅ បន្តរតាមក្រោយយ៉ាងញ៉ាទេទ្រើក ជាសញ្ញាប្រាប់ថា ដល់ពេលចូលទៅក្នុងឆាកវិញហើយ។ ពេលនោះ ពួកតួប្រុសយកដៃកៀកចង្កេះពួកតួស្រី ហើយបណ្តើរគ្នាមួយគូម្តងៗ ចូលបង្ហួសទៅដល់ក្នុងទីតាំងកណ្តាល។

ពិធីនេះមានធ្វើដដែលៗប្រាំមួយថ្ងៃជាប់គ្នានៅក្នុងវេរិនិច្ឆ័យ ហើយក្រោយពេលចប់រាំបួងសួង ខ្ញុំត្រូវចេញទៅរាំរឿងបុរាណឲ្យប្រជារាស្ត្រមើលលេងកំសាន្ត រហូតទល់ភ្លឺទៀតផង។

ទោះបីនឿយហត់យ៉ាងណាក្តី គឺខ្ញុំពុំដែលទម្រន់ខ្លួញឡែរដល់ម្តងណាឡើយ ពីព្រោះខ្ញុំដឹងខ្លួនថាបន្តិចទៀតខ្ញុំតង់ដឹងបានឡើងធ្វើជាតួឯកមិនខាន ហើយការដែលខ្ញុំអាចបំពេញក្តីប្រាថ្នារបស់ខ្លួនឯងបានយ៉ាងនេះ វាអាចធ្វើឲ្យខ្ញុំភ្លេចការនឿយហត់អស់រលីង ប្រសើរជាងរង្វាន់ដែលហ្លួងធ្លាប់ប្រទានឲ្យនោះទៅទៀត។

ផ្ទុយទៅវិញ មានមិត្តភក្តិតិចណាស់ ដែលមានយោបល់ស្របនឹងខ្ញុំ។ ហ្លួងឥតរវល់យកចិត្តទុកដាក់មើលរបាំរាំរបាកទេ លោកជាប់ចិត្តតែនឹងត្រឿងតុបតែងលំអខ្លួន នៃ ប្រពន្ធជាទីគាប់ចិត្តទាំងពីរ គឺ ម៉ាមន្ទ និង ម៉ាមប្រឹម រហូតដល់យល់ថា ស្មានរបស់អ្វីប្រសើរ និង មានប្រយោជន៍ជាងស្ត្រីទាំងពីរនាក់នេះទេ។ សិល្បៈពិតប្រាកដ ដែលមានលោកបង្កប់នូវតម្លៃអាថ៌កំបាំងក្នុងចលនាពត់ពេនទន់ភ្លន់ នៃ ពួកអ្នករបាំ ដែលអាចញ៉ាំងហ្លួងទស្សនិកជន ឲ្យសើច ឲ្យយំ ឲ្យរំភើបញាប់ញ័រ ទៅតាមជម្រៅធាតុពិត នៃ ចលនារបស់ខ្លួនទោះវាពុំអាចធ្វើឲ្យហ្លួងគាប់ចិត្តផងទេ។ ហេតុនេះ ទើបបានជាសព្វថ្ងៃ គេកាត់ដកស្រង់សាច់រឿងពីនេះបន្តិចពីនោះបន្តិច យកមកបញ្ចូលគ្នាគ្រាន់តែដើម្បីកាំបង្ក្រប់កិច្ចប៉ុណ្ណោះ គេលែងរាំរឿងនីមួយៗហូរហែតាំងពីដើមដល់ចប់ផ្តួចពីមុនទៀតហើយ សូម្បីតែពួកត្រូកីលែងត្រួតត្រាមើលឲ្យយើងស្ទៀកពាក់ត្រឹមត្រូវ មុនពេលចេញរាំម្តងៗដែរ។

ឬរឿងរ៉ាវដែលអាក្រក់ហួសពីអាក្រក់ទៅទៀតនោះ គឺសព្វថ្ងៃនេះគេពុំអាចរកពួកល្ខោនណាម្នាក់ ដែលចេះរាំពិតប្រាកដបានទេ។ ចំណែកឯហ្លួងវិញ កុំសង្ឃឹមថាលោកហ៊ានចំណាយព្រះរាជទ្រព្យ ដើម្បីរៀបចំក្រុមល្ខោនជាថ្មីឡើងវិញឲ្យសោះ ពីព្រោះ លោកមហាមន្ត្រី ទ្រង់ស្តីវង្ស និង ក្មួនចៅឯទៀត ដែលជាអ្នកត្រូវបានទទួលកេរ្តិ៍ពីហ្លួង គេឃើញហ្លួងចាស់ជរាជិតចូលទីវង្គត់យ៉ាងនេះ គេមិនព្រមឲ្យលោកយកព្រះរាជទ្រព្យទៅចំណាយឥតប្រយោជន៍ទេ ប៉ុន្តែគេឲ្យលោកយកទៅទិញ ផ្ទះសម្បែង ឬ មាសពេជ្រវិញ សម្រាប់កាលណាហ្លួងសុគតទៅ គេស្រណុកវាយចំណែកចែកគ្នា។

ចំពោះយើងជាអស់អ្នក-អស់ទាង ក្នុងរាំង ពេលមានរៀបចំធ្វើបុណ្យដែលគេទាំងអស់គ្នាត្រូវសប្បាយរីករាយយ៉ាងនេះម្តងៗ ផ្ទុយទៅវិញវាជាពេលដែលយើងត្រូវធ្វើការឡើយហត់ក្រៃលែង ម្ល៉ោះហើយយើងបន់មួយថ្ងៃដប់ដង ឲ្យតែបុណ្យចង្រៃនោះឆាប់ចប់ស្រឡះទៅ។

យើងត្រូវរាំប្រាំមួយថ្ងៃប្រាំមួយយប់ នៅលើឆាកខាងក្រៅកណ្តាលហ្លួងប្រជារាស្ត្រ ដែលឈរមើលប្រជ្រៀតគ្នាកកកុញ ធុំក្លិនស្អុយញើសជនមួយកាយៗមកដល់យើងស្ទើរទ្រាំពុំបាន ទោះបីយើងខំបាញ់ទឹកអប់លាបខ្លួនឲ្យក្រអូបយ៉ាងណាក៏ដោយ។

មកដល់យប់ទីប្រាំ ខ្ញុំអស់កម្លាំងខ្លះពុំជាប់ ទ្រាំរាំមាត់រាំរឿង ឯណាវបុស្បាតទៅទៀតស្ទើរមិនរួច... នៅពេលដែលស្តេចសញ្ជាវ៉ាហាងនោះ ពិតជាមាន់រងាវ មេឃក្រហមឯកើតស្រេចទៅហើយ។ ខ្ញុំដើរទ្រេតទ្រោតចូលទៅក្នុងភឹងវិញតាមទ្វារព្រលប់ ទាំងត្របកភ្នែកទន់បើកពុំរួច។ ទៅដល់ដំណាក់ម្ចាស់ក្សត្រី ខ្ញុំដេកលក់ឈរ បណ្តោយឲ្យគេដោះសម្លៀកបំពាក់ដែលរីស្អួតដងខ្លួនខ្ញុំ មួលខ្ចៅដោះកងដៃកងជើងតាមចិត្ត។ ត្រាន់តែដោះសម្លៀកបំពាក់ហើយភ្លាម ខ្ញុំមិនទាំងរវល់លប់មុខ លាងម្សៅយីហ៊ីនផង ខ្ញុំឡើងទៅដល់បន្ទប់ដេកនៅឯជាន់ទីមួយ នៃ អតីតដំណាក់ឃុនថាន់ ហើយប្រះដេកទៅលើគ្រែលក់ភ្លាមមួយរំពេច។

ខ្ញុំភ្ញាក់ពីដេកយឺតហួសពេលខុសធម្មតា ឃើញក្បួនដង្ហែហ្លួងជុំវិញរាជធានីនោះ ប្រុងប្រៀបចេញពីភឹងទៅហើយ។ ស្រីៗណាចង់ទៅតាមក្បួនដង្ហែ គេឲ្យជិះលើរទេះ ប៉ុន្តែខ្ញុំហាក់ផ្លូចជាគ្មានចិត្តគិតចង់ទៅជាមួយគេបន្តិចបន្តួចសោះ ទើបខ្ញុំដើរទៅមុខទីកសំអាតខ្លួនយឺតៗ គ្មានប្រញាប់ប្រញាល់អ្វីឡើយ។ ថ្ងៃនេះ ជាថ្ងៃបញ្ចប់បុណ្យ លែងមានរាំរឹកទៀតហើយ អ្នកឯទៀតក៏ចេញទៅក្រៅភឹងទាំងអស់គ្នាដែរ ផ្លូចេ្នះខ្ញុំទៅស្ងាត់ម្នាក់ឯង អាចឡើងតាមជណ្តើរទៅដល់កំពូលប្រាសាទបាញ់យ៉ុង ដើម្បីគយគន់មើលទិដ្ឋភាពក្រុងភ្នំពេញ ពីលើទីខ្ពស់មកយ៉ាងសប្បាយរីករាយ។

ទីធ្លាកិត្តិយសលាតសន្ធឹងនៅពីក្រោមខ្ញុំ ពេញចង្អៀតទៅដោយហ្លួងទស្សនិកជន ឃួន ចិន បាវ៉ាំង និង ស្ត្រីខ្មែរ ដែលគេអាចសម្គាល់យ៉ាងច្បាស់បានដោយសារក្រមាពណ៌ឆើតទន្សើរលើក្បាល។ នៅក្នុងថែវជុំវិញភឹង នាមុីនធំៗ ក្នុងរាជធានី និង មកពីគ្រប់ខេត្តទំណ្ង បានរៀបចំតុសម្រាប់មណ្ឌលរបស់ខ្លួនម្នាក់ៗដោយមានតាំយករបស់មានតម្លៃផ្សេងៗ មកតាំងលំអក្នុងឧកាសបុណ្យអភិសេកហ្លួងនេះផង។

ក្បួនដង្ហែដ៏ធំធេងចេញផុតក្លោងទ្វារ ហើយបត់ទៅខាងត្បូង តាមផ្លូវជាប់នឹងរបងភឹង។ នៅឯម្ខាងកំផែងសីមា ខ្ញុំមើលឃើញស្វេតច្ឆត្រលាបពណ៌មាស និង ត្រែស្នែងដែលមានហ្លួង ពាក់មកុដ និង គ្រឿងអលង្ការមានតម្លៃចាំងផ្លេកៗ អង្គុយឆ្ពុបពីលើនោះ។ ក្នុងសួចច្បារមាត់ច្រាំងកំពង់ផែ មនុស្សមិនស្ងៀកកកកុញពេកទេ ព្រោះគេរវល់តែរត់មកប្រជ្រៀតមើលក្បួនដង្ហែស្តេចសោយរាជ្យ នៅមុខភឹងឯណោះ។

ខ្ញុំចុះពីលើដំបូលប្រាសាទបាញ់យ៉ុង មកអង្គុយក្នុងដំណាក់ម្ចាស់ក្សត្រី ដើម្បីរង់ចាំទម្រាំក្បួនដង្ហែ

ត្រឡប់មកដល់ភ្នំងវិញ។ អស់រយៈពេលជាច្រើនម៉ោងក្រោយមក ទើបហួងត្រឡប់ចូលមកភ្នំងវិញតាមទ្វារខាងជើង ដោយជិះលើដីរ និង ដោះមកុដចេញ ពាក់មួកមាលជំនួសវិញ។ លោកយាងចូលរហូតដល់ទេវិនិច្ឆ័យ មានទាំងក្បួនហែហមជូនជាប់រហូតមក។

ឥឡូវ សម្តេចនុហាជ បានទទួលអភិសេកជាស្តេចសោយរាជ្យពេញលក្ខណៈហើយ ប៉ុន្តែការផ្លាស់ប្តូរនេះ វាពុំបានធ្វើឲ្យយើងខ្វល់ខ្វាយទេ ពីព្រោះខ្ញុំសង្កេតឃើញថា មុនពេលអភិសេក ឬ ក្រោយពេលអភិសេក ហួងនៅតែហួងដដែល គ្មានឃើញប្លែកអ្វីសោះ។ ហើយគ្រាន់តែពិធីអភិសេកចប់សព្វគ្រប់កាលណា ជីវភាពនៅក្នុងភ្នំងក៏ចាប់ប្រព្រឹត្តទៅជាធម្មតាដូចកាលមុនដែរ ឥតឃើញប្រែប្រួលបន្តិចបន្តួចសោះទេ។ ប៉ុន្តែមិនទាន់បានប៉ុន្មានផង ស្រាប់តែដំណឹងថា ហួងត្រូវយាងទៅស្រុកបាភ្នំង ដែលកាលពីមុនគ្មានឧកញ៉ាវល់យកចិត្តទុកដាក់គិតគូរសោះនោះ លេចឮឡើងជាថ្មីម្តងទៀត បណ្តាលឲ្យយើងភ័ន្តភាំងស្រឡាំងកាំងគ្រប់គ្នា។

យើងពុំយល់ថា ហួងយាងទៅស្រុកបាភ្នំងដើម្បីប្រយោជន៍អ្វីទេ ប្រហែលជាបាភ្នំងចង់តាំហួងយើងទៅឃុំឃាំងទុកឯស្រុកគេ ដើម្បីគេស្រួលរំលោភយកទឹកដីយើងក៏មិនដឹង? ប្រសិនបើអញ្ចឹងមែន យើងមិនត្រូវឆ្គួតទៅតាមហួង ឲ្យជាប់គុកវេទនានៅស្រុកគេ ឆ្ងាយពីម៉ែ-ឪ ពីស្រុកទេសទេ។ ពាក្យចចាមអារាមចេះតែមានលេចឮពីមាត់មួយទៅមាត់មួយ មានអ្នកក្រៅភ្នំងជួយថែមថយបន្តិចបន្តួចទៀត ហើយនរណាភ័យជាងគេ ក៏ចេះតែស្រមៃឃើញអាវ៉ាងភ័យ នាំយកមកនិយាយបន្ថាចឲ្យជ្រួលច្របល់អស់មួយផ្ទៃភ្នំង។ គេនិយាយថា បាភ្នំងអត់ឲ្យស៊ីបាយទេ គេបង្ខំឲ្យយើងស៊ីនំប៉័ងដូចគេអញ្ចឹង យើងត្រូវជិះកប៉ាល់កាត់សមុទ្រធំមើលកោះមើលត្រើយមិនឃើញ ហើយយើងគង់ឥងកើតជម្ងឺពុលរលក ក្លួចផ្អោរស្ទើរងាប់ស្ទើរស់មិនខាន។ នៅលើកប៉ាល់ បាភ្នំងហាមផ្តាច់មិនឲ្យមានមនុស្សឈឺទេ មើលតែនរណាបែបមិនស្លូវស្រួលគេចាប់បោះទៅក្នុងសមុទ្រ ឲ្យឆ្លាមក្រពើ ស៊ីភ្លាមមួយរំពេច។ ឮពាក្យសំដីអស់នេះ ខ្ញុំខ្លាចព្រឺសម្បុរគឺង្គក់!។

ម្ចាស់ក្បត្រី រ៉ែមធីតា ម៉ែមទួ និង ម៉ែមប្រឹម ត្រូវទទួលការៈជ្រើសជីវសម្អុរពុំបាសម្រាប់ដង្ហែហួងទៅស្រុកបាភ្នំង។ ពួកយើងច្រើនគ្នាណាស់បានប្រកែកជាច់អហង្ការពុំព្រមទៅ រហូតដល់អ្នកខ្លះទៀតសុខចិត្តយកជំនួសបន្តិចបន្តួចមកសូក ម៉ែមទួ និង ម៉ែមប្រឹម ដើម្បីឲ្យគាត់ជាក់ឈ្មោះខ្លួនថាមានជម្ងឺ ពុំអាចដង្ហែហួងទៅបានទៀតផង។ ពួកអ្នករាំជើងឆើត និង អស់អ្នកអស់តាងស្អាតៗ សុទ្ធតែប្រកែកពុំព្រមទៅ ផ្ទុយទៅវិញពួកស្រីចាស់ៗ អ្នកបំរើដ៏មានសូហងអាក្រក់ត្បូរខ្មាសអៀនោះ បែរជាលើកទឹពមកសុំចុះឈ្មោះឲ្យបានទៅជាមួយក្លួនខ្លួន។

អ្នកខ្លះ ដែលកាលពីដើម មិនដែលតាំងហ៊ានមកឡេមឡឺមក្បែរទ្វារភ្នំងផង ឥឡូវស្រាប់តែបានមកហែហមម្ចាស់ក្បត្រី ទៅស្រុកបាភ្នំងយ៉ាងក្រអឺត។ ត្រាំមិនបានហួងលាន់មាត់ថា:

~ ទេ! ទេ! កុំឲ្យមីនេះទៅហ្ន៎! រូបវាងអាក្រក់ម្ល៉ឹងៗឲ្យវាងង្ហែអញទៅ អញខ្មាសបាភ្នំងងាប់ហើយ!។

ប៉ុន្តែគ្មានឧកញ៉ាណាស្តាប់សំដីហ្នឹងទេ អ្នកមកចុះឈ្មោះចេះតែមានជាបន្តបន្ទាប់គ្នា រហូតដល់ពេលចេញដំណើរ ហើយនៅពេលកប៉ាល់ចេញដំណើរទៅនោះ ស្រាប់តែឃើញមានអ្នកខ្លះឡើងមកសម្ងំពួនតាំងពីយូរហើយផង។

ចំពោះខ្លួនខ្ញុំ ខ្ញុំដឹងច្បាស់ថា មិនអាចគេចផុតទេ ពីព្រោះខ្ញុំគ្មានជំនួលការពារខ្លួនឲ្យបានមាំមួនដឹងគេ។ ម្ល៉ោះហើយ គេចុចឈ្មោះ ខ្ញុំ និង ពួកម៉ាក ពីរ-បីនាក់ទៀត ឲ្យទៅភ្ជាំនៅស្រុកបាភ្នំង មុនឧកញ៉ាទាំងអស់។ ទោះបីម៉ែយំស្រែកមិនព្រមឲ្យខ្ញុំយកឆ្នឹងទៅចោលនៅស្រុកគេយ៉ាងណា ក៏ខ្ញុំនៅតែធ្វើស្មើង មិនខ្ជិឲ្យចាញ់

ចិត្តនរណាដែរ គឺខ្ញុំ ពុំព្រមប្រកែក ពុំព្រមអង្វរម្ចាស់ក្បត្រី អ្វីទាំងអស់។

ប៉ុន្មានអាទិត្យមុនពេលចេញដំណើរ ខ្ញុំត្រូវទំហាត់ភ្ជាំទាំងព្រឹកទាំងល្ងាច ទុកសម្រាប់ភ្ជាំនៅស្រុកបាភ្នំង។ គេរៀបចំវ៉ាយឡាំងជាក់ សម្លៀកបំពាក់ និង គ្រឿងតុបតែងខ្លួន សម្រាប់ឲ្យយើងស្លៀកពាក់ភ្ជាំនៅស្រុកបាភ្នំង។ ចំណែកខាងម្ចាស់ក្បត្រីវិញ វល់តែក័យព្រួយ ប្លឹងអត់ស៊ីតាមផ្លូវ និង នៅស្រុកគេ ទំរ៉ាចអង្គរត្រីងៀត ព្រមទាំងប្រហុកជាច្រើនពាង យកទៅជាក់លើកប៉ាល់ ទុកសម្រាប់បង្ការពេលអាសន្នអត់ក្រ ប៉ុន្តែក្រោយពេលចេញដំណើរទៅបានប៉ុន្មានថ្ងៃ ប្រហុកនោះវាឲ្យក្លិនខ្លាំងពេក ត្រាំមិនបាន លោកមហាមន្ត្រីក៏បង្គាប់ឲ្យគេលើកទម្លាក់ចោលក្នុងសមុទ្រចាត់ទៅ។

ចិនជាងវេរស្បែកជើង នាំយកស្បែកជើងម៉ូតរបៀបអ៊ីរ៉ុបទាំងកន្ត្រកៗមកប្រគល់ឲ្យយើង ប៉ុន្តែស្បែកជើងហ្នឹង វេរខ្លីខ្លាំពេកណាស់ មិនត្បូរជាទីពេញចិត្តសោះ។

លើយើង ស្លៀកពាក់ និង ពាក់ស្បែកជើង ហើយធ្ងុះកញ្ជក់មើលឃើញរូបខ្លួនឯងបែបត្បូរឲ្យចង់សើចពេកណាស់។

លើសពីអ៊ីវ៉ាន់ដែលអ្នករាជការភ្ជាំងគេរៀបចំជាក់ក្នុងឡាំងវ៉ាយបិទជិតនោះ យើងម្នាក់ៗសុទ្ធតែមានហិបជាក់របស់របរផ្ទាល់ខ្លួន ជាច្បងយកមកតរទុកវាយប៉ាំយពេញក្នុងភ្ជាំង។

ព្រឹកមួយនោះ បាភ្នំងរាងសង្ហា ប៊ី-បួនខាក់ ចូលរហូតមកដល់កន្លែងសមរបាំនៅខាងក្នុង ហើយអង្គុយមើលពួកល្ខោនដែលត្រូវដង្ហែហួងទៅស្រុកបាភ្នំង កំពុងហាត់រៀនយ៉ាងយកចិត្តទុកដាក់។ ស្រីបាភ្នំងម្នាក់ដែលចូលមកជាមួយពួកប្រុសៗនោះ សម្លឹងមើលខ្ញុំដោយញញឹមខ្ជិប ពុំដឹងជាគាត់ ញញឹមពេញចិត្ត ឬ ញញឹមពេលជ្រាយទេ។ ម្ចាស់ក្បត្រី និយាយលេងរាក់ទាក់ជាមួយភ្ញៀវទាំងនេះ ដោយមានអ្នកបកប្រែម្នាក់ជាជំនួយ ហើយខ្ញុំសង្កេតឃើញលោកអួតសរសើរប្រាប់បាភ្នំងតែពីប្លឹង មិនសូនក្លួនចៅលោក អត់មាននិយាយពីប្លឹងអ្វីផ្សេងទៀតសោះ ចាប់តាំងពីពេលនេះមក មិនសូនវាបានចិត្តឡើងចាងរហួត និង រឹតតែខំផ្តាប់ផ្តួនចៅហ្វាយវាលើសដើម។ មិនសូនេះ ពីដើមវាធ្លាប់តែដើរយួរស្បែកជើងតាមខ្ញុំប៉ុណ្ណោះ ឥឡូវវាហ៊ានបំបាក់មុខខ្ញុំនៅកណ្តាលជំនុំចំណោម គួរឲ្យចុកឈាមណាស់។ ប៉ុន្តែទោះបីជាយ៉ាងណា ក៏ពួកបាភ្នំងពុំមែនល្ងី រហូតដល់បណ្តោយឲ្យម្ចាស់ក្បត្រី បោកក្បាលគេលេងទទេបានដែរ គឺគេតាំគ្នាគយគន់មើលខ្ញុំយ៉ាងយកចិត្តទុកដាក់ជាទីបំផុត។

ក្នុងសភាពច្របល់ច្របល់មុនពេលចេញដំណើរ អស់អ្នកអស់តាងជាច្រើន រត់ខ្វែងដៃខ្វែងជើង រកខ្លីលុយគេសម្រាប់ចំណាយទិញរបស់កំប៉ិកកំប៉ុកប្រើប្រាស់ផ្ទាល់ខ្លួន។ ពួកចាស់ៗនៅក្នុងភ្ជាំង ជាសាច់ញាតិនឹងម្ចាស់ក្បត្រី សុខចិត្តឲ្យប្រាក់ពួកនោះខ្ចី ហើយទទួលកាត់ប្រាក់ខែសងវិញ ដោយយកការអារកគ្នាក្រៃលែង។ បើកុំតែខ្ញុំចេះមានគំនិតសុំហួងបានមួយរយៀល កុំអីខ្ញុំក៏មិនអាចជៀសមិនជំពាក់តើណាកបានដែរ។

ព្រឹកពេលចេញដំណើរមកដល់ហើយ! យប់នោះ នៅក្នុងភ្ជាំងគ្មានរណាម្នាក់ដេកលក់ទេ។ យើងជិះរទេះចេញពីភ្ជាំងហូរទឹកភ្នែកហាម ខំដកករហាច់សម្លឹងរកមើលនុពុក-ម្តាយ សម្លឹងសួនច្បារដែលប្រែជាស្ងាត់ជ្រងំ មើលពួកអ្នករាជការ និង ក្រុមភ្ជាំង ដែលឈរតម្រៀបគ្នាជារបងអមសង្កាងផ្លូវ មើលដើមគគីរធំៗដែលម្នាក់មែកសំយាកទៅលើដំបូលភ្ជាំង ដោយក្តីស្តាយស្រណោះរកហាមាត់និយាយមិនរួច។ ក្បួនដំណើរលឿនទៅមុខតាមចង្វាក់ជើងសេះ តម្រង់ទៅទិសខាងជើង គឺតម្រង់ទៅសង្កាត់បាភ្នំង ដែលជាកន្លែងកប៉ាល់ចោះយុថ្ការង់ចាំយើង។

មនុស្សម្នាមួយហ្វូងធំ ក៏បានចាំគ្នាមកមើលយើងចេញដំណើរនេះដែរ។ បាភ្នំងចោមរោមនិយាយលេង

ជាមួយហួងនៅលើកប៉ាល់ ហើយម្នាក់នោះមានធំដូចយក្ស ហ្អែកខៀវដូចត្រីស្ងោរ ទុកពុកមាត់ស្រមាម ត្រូវដង្ហែហួងហួតដល់ស្រុកបាភាំង ។ ដោយសារវាអ្វីអែរថ្នង់ខ្លាំងពេក យើងក៏តាំគ្នាសម្លុំនៅជុំវិញកប៉ាល់ សម្លឹងមើលមកមនុស្សដែលឈរកកកុញនៅលើច្រាំង ក្នុងទ្រូងចង្អៀតចង្អល់រកនិយាយអ្វីមិនចេញ ហូរតែទឹកភ្នែករហាម ។

នៅទីបំផុត កប៉ាល់ក៏ល្ងនចេញពីច្រាំង ចូលទៅដល់កណ្តាលទន្លេ ហួងពួកបាភាំងដែលប្រជុំគ្នានៅលើច្រាំង ក៏បំបែកអស់រលីង ។ ទោះបីកប៉ាល់បើកហួសឆ្ងាយមកហើយក្តី ក៏ខ្ញុំនៅតែចំណាំបានកំពូលភាំង កំពូលវត្ត និង ផ្ទះ អ៊ុពុក-ម្តាយ ដែលខ្ញុំទំនិតឲ្យជាប់ក្នុងអារម្មណ៍កុំឲ្យភ្លេច រួចបន្តិចក្រោយមក ផ្សែងអ័ព្ទ នៃ ទន្លេដែលហួរគាំយើងទៅកាន់សមុទ្រនេះ បាំងមិនឲ្យយើងមើលឃើញអ្វីទាំងអស់ ។

ចង្អៀតចង្អល់អ្វីម្ល៉េះទេនៅលើកប៉ាល់នេះ ដែលមានមនុស្សជិះដល់ទៅជាងមួយរយនាក់ ព្រមទាំងតាំន់ដីទៀតជាច្រើន! ហួងលែងវល់គិតគូរពីរឿងពួកយើងទៀតហើយ ។ លោកផ្ទុំក្នុងបន្ទប់ សោយអាហារទឹកព្រឹកឯង ជាមួយស្រីពីរនាក់ នៃ ក្រុមហួងមហោរី ។ យើងអង្គុយលើហិបរៀងខ្លួន ជជែកគ្នាអែប្រមែ ដើម្បីគ្រាន់និងលើកទឹកចិត្តគ្នាទៅវិញទៅមក កុំឲ្យភ័យព្រួយខ្លាំងពេក ។ ក្នុងចំណោមអ្នកដំណើរជិះលើកប៉ាល់ដែលត្រូវដង្ហែហួងទៅស្រុកបាភាំងនោះ តិចគ្នាណាស់ដែលមានការចាំបាច់ត្រូវទៅខាងមិនបានភាគច្រើនសុទ្ធតែមនុស្សអត់ប្រយោជន៍ មិនដឹងជាគេសណ្តោងយោងយកទៅធ្វើអ្វីទេ ។

នៅលើកប៉ាល់ មានតួនប្រុសហួងជាច្រើននាក់គឺ អ្នកអង្គម្ចាស់ឥស្សរវង្ស, អ្នកអង្គម្ចាស់ស្ងួវវង្ស ជាទីគាប់ចិត្តហួងជាងគេ និង ប្តូនប្រុសមួយទៀតឈ្មោះ ចិន្តានុវង្ស ដែលគិតតែនិយាយពីរឿងទៅ "លេង" ស្រីបាភាំងឲ្យចាស់ដៃម្តង ដូចជាស្តេចបងនោះដែរ ។ ព្រះសង្ឃប៉ុន្មានអង្គ ដែលសុំដោយសារតាមកប៉ាល់ទៅសិក្សាឯប្រទេសសើលង្កា លោកគង់បត់ជើងជាច់ឡែកឆ្ងាយពីពួកយើង ហើយនៅក្បែរនោះ ពួកក្រុមភាំង និង ពួករាជការភាំង អង្គុយស៊ីស្លាយ៉ាងស្ងៀមស្ងាត់ ហ្អែកសម្លឹងមើលទៅច្រាំងចំការ ស្រុកលើកដែក និង ស្រុកល្វាឯម ដែលរសាត់ហួសទៅជាបន្តបន្ទាប់គ្នា ។

ម៉ែអូន ធ្វើឫកបែបម៉ឺងម៉ាត់និយាយថា គាត់និងសរសេរកត់ទុកក្នុងសៀវភៅ ទ្វរម្បាំងហេតុទាំងអស់ក្នុងពេលធ្វើដំណើរនេះ ប៉ុន្តែយើងវល់តែព្រួយបារម្ភគ្រប់គ្នា គ្មានទេរណាគិតគូរស្តាប់គាត់ឡើយ សូម្បីតែបាយទឹក ក៏មិនទឹកឃ្លានផង ។ ម្ល៉ោះហើយ យើងពិតតែជក់បារីកែអង្សុក បង្គុយផ្សែងទ្រលោមទៅលើចាស់ៗ ដែលអង្គុយធ្វើមាត់ច្រហ ។ បន្តបន្ទាប់មានតិចពេក ពុំអាចឲ្យយើងដេកគ្រប់គ្នាបានឡើយ ម្ល៉ោះហើយយើងត្រូវតាំគ្នាដេកកណ្តាលវាលនោះទៅ ប៉ុន្តែជាសំណាងល្អម្យ៉ាងដែរ យប់នោះគ្មានមួសមួយគ្រាប់សោះ ។

បន្ទាប់ពីធ្វើដំណើររបៀបនេះអស់មួយថ្ងៃមួយយប់ ស្នែកព្រឹកឡើងយើងក៏បានចូលមកដល់ទន្លេចង្អៀតពេញពាសទៅដោយកប៉ាល់ខ្ពស់ត្រដែតដូចភ្នំ ។ មើលទៅច្រាំងឃើញអ្វីអែរ ខ្ញុំដឹងថាយើងមកដល់ក្រុងធំមួយហើយ លុះខ្ញុំសួរគេទៅទើបដឹងថា នេះជាក្រុងព្រៃនគរ ដែលអ្នកខ្លះគេហៅថាសៃហ្គង ។ បើតាមមើលទៅ ក្រុងព្រៃនគរហ្នឹងមិនស្ទះហ៊ឺហាជាងភ្នំពេញប៉ុន្មានទេ ។ កប៉ាល់យើងចូលទៅអែបជិតកប៉ាល់មួយទៀតធំអស្ចារ្យ ហើយយើងតាំគ្នាមើតាំន់ទៅជាក់លើកប៉ាល់ធំនោះវិញ ។

យើងតាំគ្នាជញ្ជួនអីវ៉ាន់ផ្ទាល់ខ្លួនទៅជាក់ក្នុងបន្ទប់តូចចង្អៀតនៅខាងក្រោយកប៉ាល់ ហើយក្នុងបន្ទប់ឥមួយៗ យើងត្រូវនៅដល់ទៅប្រាំ ឬ ប្រាំមួយនាក់ឯណោះ ។ ខ្លះប្រតែងប្រតោងឡើងទៅដេកលើគ្រែដែលគេព្យួរជាប់និងជញ្ជាំង ខ្ពស់សឹងតែអើតកមើលមិនដល់ ខ្លះទៀតក្រាលកំណាត់ លើឡាំង ឬ ផ្ទាល់និងក្តារ ដេកគរជើងលើគ្នា ។ ក្នុងបន្ទប់ហ្នឹងគ្មានខ្យល់អាកាសល្អគ្រប់គ្រាន់សម្រាប់ដកដង្ហើមសោះ ជាពិសេស

ទៅទៀត វាថែមទាំងធំក្លិនអាក្រក់ចង់ក្អួត ។ យើងស្រូតស្រួតតាំគ្នាចេញមកកន្លែងវាល ដែលនៅទីនេះមានអ្នកជំនួញបាភាំងលក់ គ្រឿងសំអាង និង ស្បែកជើងកែងចោទណួរចាប់ចិត្ត ។ ហួងទិញស្បែកជើងនេះចែកឲ្យយើងមួយគូៗម្នាក់គ្រប់គ្នា ដល់បានថ្មី យើងដោះស្បែកជើងចាស់ដែលចិនភ្នំពេញផ្សេរយកមកឲ្យទុកមួយកន្លែង ឬក៏ ឲ្យទៅយាយចាស់ៗ ដែលខំយកទៅញាត់ទុកក្នុងបង្វិចតាត់យ៉ាងប្រយ័ត្នប្រយែងក្រៃលែង ។

ពីលើកប៉ាល់មក យើងមើលឃើញ បាភាំង និង ឃួនឈរប្រជុំគ្នាកុះករលើច្រាំង ដើម្បីមើលស្តេចខ្មែរយាងទៅស្រុកបាភាំង ។

ខ្ញុំចង្ពើតជើងមើលតាមបង្អួច ឃើញវាលស្រែលិចទឹក ជាប់គ្នារហូតដល់ជើងភ្នំទៅទិសខាងជើង ស្រងៀងគ្នាគឹងវាលស្រែកំពង់លែង ដែលខ្ញុំធ្លាប់បានឃើញកាលពីក្មេង ក្នុងពេលពុកដឹកយកអីវ៉ាន់ទៅលក់តាមទន្លេសាបនោះដែរ ។ វល់តែជ្រួលច្របល់ប្លឹងម្យៀបចំអីវ៉ាន់ ខ្ញុំហួចគិតឈឹង មិនដឹងជាកប៉ាល់ចេញដំណើរពីថ្មើម៉ាន ស្រាប់តែមួយភ្លែតក្រោយមក ខ្ញុំមើលទៅក្រោយលែងឃើញអ្វីទាំងអស់ ក្រៅពីរលកទឹកបែកពពុះស្កុល និង ផ្ទៃទឹកធំល្ហល្ហេវ ។

ទេសភាពដ៏ធំល្វឹងល្វើយ សម្លឹងមិនយល់កោះត្រើយ ដែលពីដើមមកយើងធ្លាប់តែឮគេនិយាយក្នុងប្លឹងព្រេងបុរាណនោះ ឥឡូវយើងបានឃើញច្បាស់និងភ្នែក មិនអាចទប់ចិត្តមិនឲ្យរំភើបញាប់ញ័របានឡើយ ។ យើងហួតឆ្ងាយពីស្រុកភូមិណាស់ហើយ បណ្តាលឲ្យចិត្តយើងក្រៀមក្រំស្រពោនទឹកថា យើងនឹងត្រូវបាភាំងនាំយកទៅនិរទេសចោលនៅស្រុកគេ ជាមួយហួងជាពិតប្រាកដណាស់ ។

ផ្តុយទៅវិញ កាលណាយើងបែរភ្នែកមកមើលកន្លែងដេកដ៏ចង្អៀតចង្អល់ ទំហំទាវាន់ធំសម្បើម ដែលអាចឲ្យយើងដើរលេងទៅមក និងដូចឈរលើដី យើងដូចជាមានការកក់ក្តៅច្រើន ។

នៅប៉ែកខាងក្រោយកប៉ាល់ មានកំណាត់ចាំងកុំឲ្យត្រូវកំដៅថ្ងៃ ពួកយើងចង់លេងសើចយ៉ាងម៉េចបានតាមចិត្ត គ្មានទេរណាត្រួតត្រាទេ ។ បន្តបន្ទាប់យើងនៅខាងក្រោមជាប់ៗគ្នា ហើយក្រខ្វក់ដូចធុងសំរាម ពីព្រោះយើងនៅច្រើនគ្នាពេក ចេះតែចោលនេះចោលនោះផ្តេសផ្តាស ត្បូលីកប៉ាល់ចោសជ្រះសំអាតពុំឈ្នះ ។ ហួងនៅក្នុងបន្ទប់ខាងលើឯណោះ ក្បែរអស់លោកឧកញ៉ាមុីនភឹង និង បាភាំងមេធំលើកប៉ាល់នេះ ដោយមានតែប្រពន្ធតាប់ចិត្តប៉ុន្មានទាក់ប៉ុណ្ណោះ នៅចាំគាល់បំរើផ្ចាល់ ។ យើងជក់បារីជជែកគ្នា លេងល្បៀ ឬ ភំរឿងលេងតាមចិត្ត ហួងមិនដែលវល់មកមើលសុខទុក្ខពួកយើងដល់ម្តងណាឡើយ ។

ម្ចាស់ក្សត្រីភ័យណាស់ ខ្លាចតែយើងដេកស៊ីទំនេរពេកទៅ ភ្លាមៗឲ្យធាត់ដុសក្បាលពោះអស់រាងវ៉ៅម្ល៉ោះហើយលោកឧស្សាហ៍បង្គាប់ឲ្យយើងសមរបាំជាញឹកញាប់ ដែលជាហេតុទាំងឲ្យពួកបាភាំងដែលជិះលើកប៉ាល់ជាមួយគ្នា មកឈរមើលយើងត្រៀបត្រាយ៉ាងសប្បាយរីករាយ ។

តើដំណើរនេះត្រូវស៊ីពេលអស់ប៉ុន្មាន ? ខ្ញុំអត់ដឹងអីទាំងអស់... ប្រហែលជាមួយខែ ឬ ពីរខែ ក៏មិនដឹង ? ប៉ុន្តែខ្ញុំជឿជាក់ថា ដំណើរនេះត្រូវប្រើពេលយូរណាស់ ម្ល៉ោះហើយខ្ញុំមិនខ្លីវល់រាប់ថ្ងៃរាប់ខែ ធ្វើអ្វីទៀតទេ ។ រាល់ថ្ងៃឃើញតែទឹកសមុទ្រ ឥតកោះត្រើយដដែលៗយ៉ាងនេះ ខ្ញុំវង្វេងលែងស្គាល់ទិសតំបន់អ្វីទាំងអស់ ។ នៅខាងក្រោយឆ្ងាយឯណោះ សត្វស្លាបសហើរតាមរលកកប៉ាល់ ហើយកាលណាមានរលកធំៗរសាត់មកដល់ វាទំបណ្តែតខ្លួនលើរលក ប្រៀបបាននឹងកុកឬខ្វែក ដែលឈរលើពំនូកខ្សាច់ដុះកណ្តាលទន្លេក្នុងស្រុកយើងយ៉ាងនោះដែរ ។

ក្នុងចំណោមអ្នកធ្វើការលើកប៉ាល់មានយួនពីរ-បីនាក់ ក្រៅពីនេះសុទ្ធតែបាភាំងទាំងអស់ ដែលធ្វើជា

ត្រូលីដុះលាងសំអាតទឹកមាត់ស្អាលើក្តារកប៉ាល់រៀងរាល់ព្រឹក។ នៅចុងខាងក្រោយកប៉ាល់ មានបន្ទប់តូចមួយ ធំក្លិនអោសោចិ៍អស្ចារ្យ ជាកន្លែងដេករបស់តាកញាស់ម្នាក់ ដែលជាអ្នកលក់ទំ ម្សៅ និង សាច្ជីក្រអូបប៉ុន្តែរបាងគាត់អាក្រក់គគ្រិចស្មោកគ្រោកណាស់ ថែមទាំងថ្នង់ខៀតផង ហាវមាត់និយាយម្តងៗ ស្អុយមួយយោជន៍។

កាលណាគាត់ដេកលក់ យើងនាំគ្នាយកជើងធាក់ទ្វារភ្ជាំងៗ ដើម្បីវិនាទកុំឲ្យគាត់ដេកលួនបាន ហើយបើឃើញថា គាត់អត់នៅនឹងកន្លែង យើងលួចយកអីវ៉ាន់កំប៉ិកកំប៉ុករបស់គាត់ទៅចោះចោលលេងជាល្បែង។ ម៉ែចែម អ្នកឲ្យកែលេងសើចច្រើនជាងគេ ខុសឪាហ៍ស្រែកដាក់ត្រចៀកតាជំឡង់ប្រាំពីរសន្តានខោះថា៖ "អូ! ស្អុយមាត់តាប៉ិងណាស់!", តាហ្នឹងសើចញញឹមញញែម ប្រហែលជាគាត់ស្មានថា ម៉ែចែមនិយាយពាក្យស្នេហាជាមួយគាត់ហើយមើលទៅ។

ចុោយបាវាំង ដែលចូលមកចោសជ្រះសំអាតបន្ទប់ និង យកកន្តោរទឹកមាត់ទៅចាក់រាល់ថ្ងៃខោះ វាពុកពុកមាត់ប៉ុយៗ និង សិតសក់ស្អាតជានិច្ច, វានៅក្មេងរាងសង្ហា ថែមទាំងខំបំរើយកចិត្តយើងខ្លាំងណាស់។ យើងហៅវាថា "អាបាវាំងក្បាលពុក" ហើយវានិយាយរងាក់រដុបថាតាមយើង ក្តារឲ្យចង់សើចក្រៃលែង។ ម្តងខោះ សារិនពួកម៉ាកខ្ញុំ ឲ្យចិញ្ចៀតវាខ្លីពាក់លេង ស្រាប់ដល់ពេលដោះមកវិញ វាចង្អៀតជាប់ទ្រាមដៃ ទាល់តែដាក់ប្រេងទាញចង់ងាប់ទំរាំរួច។ ថ្ងៃមួយពួកធំៗប្រជុំគ្នាក្នុងបន្ទប់លេងបៀ ខ្លះអង្គុយលើកន្លែងដេក ខ្លះអង្គុយលើហិប លែងខ្លួនទេទាំងអស់គ្នា ដណ្តប់តែស្បែរស្តើងមួយប៉ុណ្ណោះ ស្រាប់តែទ្វាររបើកឡើង លេចចោយបាវាំងដៃកាន់អំបោសប្រុងដើរចូលមក។ ដល់ឃើញស្រីៗអង្គុយជួបជុំគ្នារួចសំពត់អាវអញ្ចឹង វាទៅជាស្រឡាំងកាំងធ្វើក្អែកស្ងើចហាមាត់ធ្លុង។

~ ក្លូនមីចោរ! (ម៉ែចែមស្រែកបញ្ឆោវវាដោយយកដៃទាំងពីរខ្ទប់ដោះ) ឯងមិនចេះសុជីវធម៌បាវាំងទេឬ? មុខនឹងចូល ឯងម៉េចមិនចេះគោះទ្វារ?

~ យីស! (ម៉ែអួនបន្តរតាមក្រោយ) អាហ្នឹងវាឆ្កួតទេ បានជាចូលមកគ្មានធ្វើសញ្ញាឲ្យអាណានឹងសោះអញ្ចឹង។

ខ្ញុំដេកទ្រាលលើត្រែពីលើក្បាលពួកគេអ្នកលេងបៀ, ខ្ញុំមិនវេរល់ទឹងអីទេ ពីព្រោះក្នុងវ័យដប់បីឆ្នាំនេះ ខ្ញុំពុំទាន់ចេះអៀនខ្មាសប៉ុន្មានឡើយ។

ពេលយប់ យើងត្រូវប្រយ័ត្នការពារខ្លួនទល់នឹងកូនស្តេចក្មេងៗ ដែលតែងដើរក្រឡឹងជិតកន្លែងយើង ដើម្បីសម្លឹងមើលឲ្យតែឃើញមីណាមួយបែបឲ្យដៃបន្តិច ក៏តាំងចូលដេកជាមួយមីនោះភ្លាម។ យប់មួយខោះ គេឃើញទាន់ម្ចាស់សុផល្លិកា កំពុងប្រគាក់ប្រគងគ្នាជាមួយ មីស៊ុន ហើយត្រូវម៉ែអួនស្រែកឡូឡាបណ្តេញចេញទៅវិញទាំងកណ្តាលយប់។

ទីបំផុត យើងក៏បានមកដល់កោះសើលង្កា ដែលចាស់ៗធ្លាប់និយាយប្រាប់ថា នេះជាឧត្តរភាពណ៍ដែលវាធ្លាប់យកនាងសិតា មកលាក់ទុកនៅទីនេះ។ កោះនេះមានភ្នំខ្ពស់ប្រកបទៅដោយទេសភាពស្រស់ធើតឆាយ ដូចដែលយើងធ្លាប់ស្រមៃឃើញតាមពាក្យនិទាន នៃ ឬឯរាមកេ្តិ៍ យ៉ាងនោះដែរ។

ព្រះសង្ឃនិមន្តចុះត្រង់កំពង់ផែក្រុង ភ្ញៀវមមូ។ ហ្លួងនាំយើងឡើងគោកជិះរទេះភ្លើង ដើម្បីទៅមើលព្រះវិហារ ដែលគេតម្កល់ទុកធ្មេញព្រះពុទ្ធ ហៅថាព្រះចង្កូមកែវ។ ក្រោយពេលត្រឡប់មកពីដើរកំសាន្តយ៉ាងរីករាយនោះវិញ កប៉ាល់យើងក៏បន្តដំណើរឆ្ពោះទៅមុខទៀត ដែលគ្មានយើញកោះត្រើយដាច់សង្វែងមិនត្រូវឲ្យសង្ឃឹមថានឹងបានទៅដល់។

រាល់ថ្ងៃយើងនាំគ្នាស៊ីតែត្រីងៀត ត្រីឆ្អើរដែលយើងនាំយកមកជាមួយប៉ុណ្ណោះ ពីព្រោះយើងមិនចូលចិត្តរួបបាវាំងសោះ ប៉ុន្តែបើនិយាយឲ្យចំ គឺយើងខ្មាសគេមិនហ៊ានទៅរៀបឬកតាមរបៀបបាវាំង អង្គុយស៊ីបាយលើតុក្នុងបន្ទប់បាយដ៏ធំទូលាយ កណ្តាលជំនុំចំណោមនេះឯង យើងចេះតែនាំគ្នាគេចឲ្យគេលើកបាយយកមកឲ្យដល់បន្ទប់ដេកតែម្តង។ ខ្ញុំចាំថា នៅពេលមកដល់ប្រទេសសូម៉ាលី ដែលកប៉ាល់ត្រូវចូលចតដើម្បីដាក់ឆ្យងបន្ថែមនោះ មានមនុស្សខ្មៅឃ្លឹក ខ្មៅជាងខ្មែរទៅទៀត ហែលទឹកក្រឡឹងជុំវិញកប៉ាល់ ដើម្បីចាំមុជដណ្តើមយកប្រាក់កាក់ដែលយើងទម្លាក់ទៅឲ្យវា។ ហ្លួងបង្គាប់ម្ចាស់ក្សត្រី ឲ្យយកលុយទៅទម្លាក់ទឹកឲ្យពួកនោះប្រជ្រាយគ្នាមុជទឹកដណ្តើម ដើម្បីបានសើចលេងសប្បាយ។

បន្ទាប់មកខ្យៃតបានប៉ុន្មានថ្ងៃ ខ្យល់ត្រជាក់ចាប់ផ្តើមបក់មកជាលើកដំបូងបំផុត។ នរណាម្នាក់បាននិយាយប្រាប់យើងថា ពីយប់មិញនេះកប៉ាល់យើងបានឆ្លងផុតព្រែកជីកធំ[៨] ចូលមកដល់សមុទ្រទ្វីបអ៊ីរ៉ុបហើយ។ ខ្ញុំស្តាយណាស់ដោយមិនបានឃើញព្រែកជីកនោះ ប៉ុន្តែបើតាមស្តាប់គេនិយាយ វាមិនមែនចម្លែក ឬ ធំជាង ព្រែកពាមផ្លុង[៩] ប៉ុន្មានទេ វាប្លែកតែត្រង់ព្រែកនេះ ជីកកាត់វាលខ្សាច់ប៉ុណ្ណោះ។

យើងរងាខ្លាំងណាស់... ផ្ទៃសមុទ្រប្រែជាមានរលកធំៗ ហើយសត្វស្លាបសមុទ្រ នៅតែហើរតាមក្រោយកប៉ាល់យើងពិចម្ងាយជានិច្ច។ តើសត្វនេះវាហើរតាមយើងតាំងពីព្រៃនគរមកឬ? ខ្ញុំមិនជឿថាអញ្ចឹងទេ ពីព្រោះវាអាចហើរយ៉ាងច្រើនណាស់បានពីរ-បីថ្ងៃ ក៏អស់កម្លាំងទៅហើយ ដូច្នេះអានេះវាជាសត្វផ្សេងទៀតទេ។

ពេលនោះ ថីបកឈ្មោះព្រុំ ចង្អុលប្រាប់ឲ្យយើងមើលស្រមោលអ្វីមួយនៅឆ្ងាយស្តុងៗឯណោះ ហើយគាត់និយាយថា នេះជាភ្នំភ្លើង, ស្រុកណាដែលមានភ្នំព្រួសភ្លើងអញ្ចឹង ធាតុអាកាសត្រជាក់អាក្រក់ណាស់។ ខ្ញុំមិនដែលស្គាល់ភ្នំភ្លើងយ៉ាងម៉េចទេ ម្ល៉ោះហើយគេនិយាយថាម៉េចក៏ចេះតែជឿទៅ។

នៅទីបំផុតសម្រែកថា: "ស្រុកបាវាំង, ស្រុកម៉ារ៉ីស៊ី" រសាត់មកប៉ះនឹងត្រចៀកយើង ជាសញ្ញាប្រាប់ឲ្យដឹងថា ដំណើរយើងចប់ហើយ។ ទុក្ខវេទនារបស់យើងក៏នឹងត្រូវបញ្ចប់ក្នុងពេលជាមួយគ្នានេះដែរ។ ខ្ញុំមើលទៅខាងដីគោក ឃើញភ្នំស្រុកបាវាំងសស្គុស ឃើញផ្ទះពណ៌ប្រផេះ មានផ្សែងហុយចេញតាមដំបូល ឃើញដងក្តោងកប៉ាល់ច្រូងច្រាង ឃើញថ្មគេចាក់លយចូលជ្រៅមកក្នុងសមុទ្រ ហើយនៅពីក្រោយនោះកប៉ាល់ចតតម្រៀបគ្នា មានខ្លះធំជាងកប៉ាល់ដែលខ្ញុំជិះនេះទៅទៀត។ បន្ទាប់មក នៅលើដីខួលមួយនោះមានរូបចម្លាក់លាបទឹកមាសធំអស្ចារ្យ។ ទស្សនីយភាពនេះជ្រៀបបានទៅនឹងនគរយក្ស ដែលយើងធ្លាប់ស្រមៃឃើញក្នុងរឿងព្រេងនិទាន ហើយដែលយើងពុំធ្លាប់សង្ឃឹមថានឹងបានស្គាល់សោះ។ ពាក្យដែលចាស់ៗនិយាយទាំងប៉ុន្មាន គឺជាពាក្យភូតភរទាំងស្រុង ពីព្រោះសមុទ្រខោះបើធំយ៉ាងណា ក៏មនុស្សនៅតែអាចឆ្លងកាត់បាន ហើយនៅឆ្ងាយពីប្រទេសយើង មានទ្វីបមួយទៀតដែលលាតសន្ធឹងធំល្វឹងល្វើយ ក្រោមផ្ទៃមេឃដ៏ត្រជាក់។

ត្រាន់តែកប៉ាល់អែបចូលតម្រង់ផែ ទាំងគេទាំងយើងវល់តែងាកមកវៀបចំអីវ៉ាន់ ម្ល៉ោះហើយគ្មាននរណាបានគយគន់មើលទិដ្ឋភាពមាត់ច្រាំង នៅពេលកប៉ាល់ចូលចតទេ។ ពួកយើងស្ទើរតែពាក់សំពត់អាវក្រាស់ពាក់ស្រោមដៃ និង មានផាហ៊ីរកទៀតផង ប៉ុន្តែខ្ញុំដូចជារកទឹកហ៊ីហាមិនឃើញសោះ ពីព្រោះសម្លឹងមើល

(៨) ព្រែកជីក សុយអេស៍។

(៩) ព្រែកពាមផ្លុង ពីដើមស្ថិតនៅមុខចំណតអយស្ទ័យយានក្រុងភ្នំពេញ ប៉ុន្តែសព្វថ្ងៃនេះ គេចាក់ដីលុបបំពេញបាត់ទៅហើយ។

មកគ្នាឯង យើញសុទ្ធតែខ្មៅក្រញ៊ះ ។

ប្រសិនបើហ្លួងនាំយកមកជាមួយតែពួកក្មេងស្អាតៗ ម្ល៉ះយើងមិនសូវខ្លាចគេពេបជ្រាយប៉ុន្មានទេ ប៉ុន្តែអ្នកដង្ហែមក សុទ្ធតែចាស់ទ្រេតធ្មេញគ្រហឹប ស៊ីស្លាក្រហមប្រតាកពេញមាត់ ជាហេតុធ្វើឲ្យយើងខ្មាសគេងើបមុខមិនួច ហើយប្រហែលជាបាវាំងគេស្មានថា ស្ត្រីខ្មែរសុទ្ធតែគ្រិចទាំងអស់ញើងផងក៏មិនដឹង ។

ហ្លួងយាងចុះទៅកណ្តាលចំណោមបាវាំងមួយហ្លួងធំ ដោយមានទាម៉ីនវាំងហែហមពីក្រោយជាប់ រួចហើយយាងទៅបាត់ជាមួយពួកទាហានបាវាំងដែលស្លៀកពាក់ហ៊ីហាដិះសេះ ទុកយើងចោលលើកប៉ាល់ជាមួយម្ចាស់ក្សត្រី បណ្តោយឲ្យពួកគ្វលីកប៉ាល់មកវិជញ្ជនអីវ៉ាន់យើងតាមចិត្ត ។

យើងដូចជាមិនសូវទុកចិត្តសោះ ! មេឃស្រទុំជាប់ ហើយខ្យល់ត្រជាក់បក់បោកមកឥតឈប់ឈរ បណ្តាលឲ្យយើងរងាចងាំរងាំតាម... លុះដល់ពេលល្ងាច គេមកហៅឲ្យយើងចុះពីកប៉ាល់ទៅ ។ ពួកក្រុមភឹង និង ស្លៀកហ្លួង ស្លៀកពាក់ខោអាវក្រាស់ ពាក់មួកហ៊ូត្រ មើលទៅវាគ្មានញើញហ៊ីហាត្រង់ណាឡើយ ប៉ុន្តែពួកយើងក៏មិនមែនហ៊ីហាជាងពួកគាត់ប៉ុន្មានដែរ, យើងប្រជ្រៀតដណ្តើមគ្នាដើរកណ្តាលពពាក់ពពូនដូចហ្លួងគោ តម្រង់ទៅរកវរនេះសេះធំៗដែលចតចាំយើង ។ ម្ចាស់ក្សត្រីបង្គាប់ឲ្យគេ លើកកៅអីផ្តៅ បាវអង្គរត្រីងៀត និង អីវ៉ាន់ទាំងអស់ ដាក់លើខ្នងសេះ រួចទើបយើងឡើងជិះចេញទៅ ប៉ុន្តែផ្លូវសុទ្ធតែក្រាលថ្មរដិបរដុប រលាក់ស្ទើរក្រឡុកថ្នើមប្រមាត់ ។

បាវាំងឈរប្រជុំគ្នាជង្ហែតាមមាត់ផ្លូវ និយាយឲ្យគ្នាហៅចំណោះហ្លួងយើងតែម្តង ហើយមានអ្នកខ្លះថែមទាំងបោះបាវីឲ្យយើងជក់ទៀតផង ។ នៅស្រុកនេះស្រណុកមើលដឹងអ្នកមានអ្នកក្រ ណាស់ គឺអ្នកមានគេពាក់អាវកន្ទុបចងក្រវាត់ អ្នកក្រអត់មានសម្លៀកបំពាក់អញ្ចឹងទេ ប៉ុន្តែទាំងអ្នកមានទាំងអ្នកក្រ សុទ្ធតែពាក់មួក ពាក់ស្បែកជើងឃ្លុបដូចគ្នាទាំងអស់ ។ យើងមើលមកខ្លួនឯងឃើញដូចជាតួចហោងហាង គ្មានបង្គោលទីពឹងមាំមួន បណ្តោយវាសនាឲ្យសោត់អណ្តែតទៅតាមជើងសេះ ដែលកំពុងបោះជំហានទៅមុខ ពុំដឹងជាចង់នាំយើងទៅកាន់ទីណាឡើយ ។

ការដែលហ្លួងបោះបង់យើងចោលយ៉ាងនេះ ធ្វើឲ្យយើងទឹកមួម៉ៅខ្លាំងណាស់ ។ ចំណែកឯម្ចាស់ក្សត្រីវិញ លោកវិតតែព្រួយបារម្ភនឹងរឿងយើងជាងខ្លួនយើងទៅទៀត ហើយលោកមិនសប្បាយចិត្តសោះ ចំពោះការដែលបាវាំងមិនសូវកាក់ខាក់ទទួល បណ្តោយឲ្យយើងជិះរវេះជាមួយអីវ៉ាន់អញ្ចឹង ។

ពេលមកឃើញបន្ទប់ដែលគេឲ្យយើងដេកនោះ យើងវិតតែហួសចិត្តណាស់ទៅទៀត ពីព្រោះគេមិនឲ្យយើងនៅជិតហ្លួងទេ ហើយមិនដឹងជាបានទាហានខ្មែរពីណា យកមកដាក់ឲ្យចាំយាមឃ្លាំមើលយើងដូចមនុស្សជាប់គុក ។

ក្នុងបន្ទប់នេះខ្វះខ្លួនគ្រប់... ម្ចាស់ក្សត្រីបានផ្តុំក្នុងបន្ទប់មួយមានត្រែគ្រាំ ចំណែកពួកលោទាំញ នាំគ្នាក្រាលពួកដេកលើកំរាលក្តារស្រល់ ដែលមានបិទក្រដាសការសែតពាសពីលើ ។ កាលណាពួក ស្តេច ឬ ទាម៉ីន ចូលមកឃើញកន្លែងយើងដេក គេញាក់មុខញាក់មាត់ ជាហេតុបណ្តាលឲ្យយើងខ្មាសគេងើបមុខមិនួចសើចមិនសម ។

យើងមិនដែលឃើញចានចាយប្រាក់របស់បាវាំងដែលគេតែងអួតប្រាប់យើងនោះទេ រាល់ថ្ងៃគេដាក់តែចានដីទិញពីចិនលក់អេតចាយនៅព្រៃនគរឯណោះឲ្យយើងស៊ី ។ ចំណែកឃ្លួនអ្នកងាំបាយនោះវិញ វាធ្វើម្ហូបឲ្យ យើងស៊ីខ្លីខ្លាជាងម្ហូបអ្នកទោសនៅស្រុកខ្មែរទៅទៀត ហើយយើងមិនអាចរកទិញអ្វីស៊ីបន្ថែមបានឡើយ ។ ម្ចាស់ក្សត្រីច្រឡំរឿលក្បុង មិនព្រមចាំសោះពីរបៀបចាយ កាក់មាស កាក់ប្រាក់ របស់បាវាំង ។ និយាយពី

ក្រុមភឹងដែលម្ចាស់ក្សត្រីប្រើឲ្យទៅផ្សារនោះវិញ ស្រាប់តែត្រឡប់មកវិញដៃទទេ ភ័យញ័រខ្លួនទៅទើក ពីព្រោះលុយឲ្យទៅប៉ុន្មាន ត្រូវចោរចក់យកអស់រលីង ។ ឮអញ្ចឹងភ័យចង់ត្រូតទាំងអស់គ្នា រត់ទៅទីងតឹងខ្លួនឯងមិនត្អូរឆ្ងាតមកស្រុកគេឲ្យវេទនាខ្លួនសោះ ។ ចាប់តាំងពីនោះមក យើងលែងហ៊ានចេញទៅទីឆ្ងាងក្រៅស្មោះតែម្តង ណាមួយខ្លាចចោរ ណាមួយខ្មាសមនុស្សម្នា ដែលមកប្រជុំគ្នាអើតករហង់មើលយើងហាក់ដូចជាយើងនេះជាមនុស្សចម្លែកខ្លាំងណាស់ ។

យើងមិនដឹងជាបង្គន់នៅកន្លែងណាទេ ឬមួយ ប្រហែលជាផ្ទះនេះអត់មានធ្វើបង្គន់ក៏មិនដឹង ម្ល៉ះហើយមីខ្លះវាជុះអាចម៍ ដាក់ចានដែកសម្រាប់ដាក់ទឹកមុជ ដាក់ចានសម្ល ហើយសើចហ៊ោសប្បាយដោយបានសងសឹកឲ្យបាវាំងយកអាចម៍វាទៅចាក់ចោល ។

ពេលស៊ីបាយយើងបិទទ្វារបិទបង្ហួចខ្លាចគេឃើញ ពេលយប់យើងដេកនុបដែរងាស្ទើរឹងពោះលើពួកវរាប ដែលស្អាយយកមកជាប់ជាមួយតាំងពីស្រុកខ្មែរ ។

ប៉ុន្តែ ស្រុកនេះសម្បូរណ៌ុយអ្វីម្ល៉ះទេ ! រុយហើរអ៊ូដូចឃ្មុំ ហាមមនុស្ស ហាមបាយសម្ល ដួចហាមអាចម៍ ហើយបើតាមមើលទៅ រុយនេះវាបែបចង់សម្បូរណ៌ជាងមួសទៅស្រុកខ្មែរផង ។

ថ្ងៃមួយម្ចាស់ក្សត្រីបានប្រាប់ថឹបកឈ្មោះព្រុំ ឲ្យយកទឹកផឹកមកថ្វាយលោក បោយបាវាំងទៅចាំបម្រើយើង វាបែរជាយកកំប៉ុងដូចចានទឹកត្រីយួនមកថ្វាយទៅវិញ ។ ម្ចាស់ក្សត្រីប្រកែកពុំព្រមសោយទឹកនោះ ហើយប្រើស្រីម្នាក់ឲ្យទៅយកថ្ពិលមាសថ្ពិលប្រាក់ មកថ្វាយ រួចលោកប្រាប់ថឹបកឲ្យពន្យល់បាវាំងថា លោកធ្លាប់សោយទឹកសុទ្ធតែក្នុង ថ្ពិលប្រាក់ ថ្ពិលមាស គេមិនដែលប្រើកំប៉ុងអញ្ចឹងជាមួយស្តេចទេ ។

ជាសំណាងដែរ ការស្នាក់នៅរបស់យើងក្នុងផ្ទះដ៏អភ័ព្វនេះ មានរយៈពេលតែពីរ-បី ថ្ងៃប៉ុណ្ណោះ ។ ម្ចាស់ក្សត្រីបានទៅអង្វរករលោកមេទ័ពទាហានជើងទឹកបាវាំង ទាល់តែគាត់រកផ្ទះមួយដ៏សមត្អូរ មានសួនច្បារ មានដើមឈើ ឲ្យយើងបានទៅស្រួលជាងមុន ។ ទោះជាយ៉ាងណាក៏យើងមិនសូវបានដើរទៅមើលស្រុកភូមិគេដែរ ពីព្រោះឲ្យតែយើញមុខយើងទៅកន្លែងណា ពួកបាវាំងចោមរោមមើលអ៊ូមួយវាំពេចហាក់ដូចជាយើងនេះជាមនុស្សចម្លែកខុសពីពួកគេអញ្ចឹង ។

ទៅពេលដែលយើងត្រូវចេញវាំ ពួកខ្លះ សម្លៀកបំពាក់ក៏មិនដឹងជាគេយកទៅទុកនៅឯណា ហើយជាពិសេសទៅទៀត រោងល្មោនទោះទៅឆ្ងាយរាប់គីឡូពីកន្លែងដេក គឺគេរៀបចំធ្វើទៅក្នុងវិមានមួយធ្វើពីថ្មប្រកបទៅដោយសួនច្បារស្រស់បំព្រង ។

ក្នុងទីនេះ បាវាំងរៀបចំធ្វើបុណ្យតាំងតុរបស់គេ ដោយមានតាំងឲ្យមើលទូវរបស់ចម្លែកៗជាច្រើនទាំយកមកពីគ្រប់ប្រទេស ។ របស់ចម្លែកទាំងនោះ យើងគ្រាន់តែក្រឡេកឃើញប៉ុណ្ណោះ ឥតបានមើលឲ្យសព្វគ្រប់តាមចិត្តចង់ទេ ។ ប៉ុន្មានថ្ងៃក្រោយមក ហ្លួងលះបង់យើងចោលមែនទែន ដោយលោកយាងទៅទីក្រុងបារីស៍បាត់ ទាំយកទៅជាមួយតែក្រុមភ្លេងមហោរីជាងដប់នាក់ប៉ុណ្ណោះ ដែលសុទ្ធសឹងជាមនុស្សកំដិល គ្មានបានការអ្វីក្រៅពី រៀបចំខ្សៀវអាវៀន និង ដេញវាយនាត តាំងពីព្រលឹមទល់ព្រលប់ ។ យើងដំទៃទៀតជាអ្នករបាំ ស្ងើយមួយចប់ វេទនាមួយចប់ បែរជាហ្លួងត្រូវបោះបង់ចោលដូចជាខ្ទុំកញ្ជះគេដាច់ថ្ងៃទៅវិញ ។ យើងមិនដឹងជាគិតខុស ទាំគ្នាហែហមស្តេចឆ្ងងកាត់សមុទ្រធំធេង មកដល់ស្រុកគេអញ្ចឹងសោះ ពីព្រោះទោះបីយើងស្ងើយហត់យ៉ាងណា ខិតខំធ្វើការអស់ពីកម្លាំងចិត្តយ៉ាងណា ក៏ហ្លួងនៅតែមើលមិនឃើញ ហើយទំនងបែបដូចជាធុញទ្រាន់នឹងពួកយើងទៀតផង ។ ម្ចាស់ក្សត្រី ពីមុនមកធ្លាប់គិតខុស ធ្លាប់មានគំនិតអាក្រក់ក៏ពិតមែន ប៉ុន្តែក្នុងកាលៈទេសៈនេះ លោកប្រែជាស្រឡាញ់យើង លើសពេលណាទាំងអស់ ។

លោកបានប្រថុយឆ្កាំថ្មើទៅទូលហួងបិតា ឲ្យលោកបានយល់ពីទុក្ខវេទនារបស់ពួកយើង ដែលត្រូវលោកបោះបង់ចោលនេះដែរ ប៉ុន្តែហួងគ្រាន់តែឆ្កាំតាមគេមកវិញថា ឲ្យម្ចាស់ក្សត្រីទាំយើងទៅបើកប្រាក់ខែ ពេលដាច់ខែ នៅឯក្រុងប៉ារីសីតែប៉ុណ្ណោះ ។

រង់ចាំខម្រើតែជល់ដាច់ខែ យើងខ្វះសព្វខ្វះគ្រប់ ម្ល៉ោះហើយយម្ចាស់ក្សត្រី លោកពិបាកចិត្ត គិតតែសោយស្រាថ្លងគេផឹកទឹក ហើយនិយាយពីឃ្យឹងស្រាខោនវិញ បាវាំងជញ្ជួនយកមកផ្តល់ឲ្យមិនដែលឲ្យខ្វះខាតទេ ។ បើតាមស្មាន នៅស្រុកត្រជាក់ ប្រហែលជាគេត្រូវការផឹកស្រាច្រើន ដើម្បីកំដៅពោះអញ្ចឹង ហើយមើលទៅ ។ ធាតុអាកាសត្រជាក់ធ្វើទុក្ខយើងខ្លាំងណាស់ ហើយក្តីព្រួយបារម្ភវាតែងតាមញាំញីយើងជាប់ជានិច្ច ប៉ុន្តែយូរៗទៅ យើងថ្លងជាធ្លាប់នឹងជីវភាពរបៀបនេះបន្តិចដែរ ។

យើងនុស្សាហ៍ចេញទៅអង្គុយលេងក្នុងសួនច្បារ អង្គុយលេងលើកាំជណ្តើរថ្មជុំវិញអាងទឹក ឬ អង្គុយលេងលើវាលស្មៅជាឃ្យឹយៗ ហើយមានពួកបាវាំងក្មេងៗ មកស៊ីញ៉ែដើងសុំថតរូបយើង ទុកជាអនុស្សាវីយ៍ ។

ប៉ុន្តែសាសន៍ស្អីគេហ្នឹងថ្លងជាចម្លែកណាស់ ស្បៀកពាក់មិនស្អាតបានត្រឹមត្រូវសោះ គឺគេមិនរវល់បិទបាំងត្រឿងអៀនខ្មាសថ្លងយើងឡើយ ។ មានឃ្យឹងផ្សេងទៀតដែលប្លែករកគិតមិនយល់ទាល់តែសោះ ថ្លងជាពេលយប់មានរយៈពេលខ្លីណាស់ ក្រោយពេលបាយល្ងាចហើយ យើងទើបនឹងដក់បារីអស់ពីរ-បីដើម ស្រាប់តែថ្ងៃចាប់រះឯកើតទៀតទៅហើយ រួចព្រះអាទិត្យតែរះហើយ ហាក់ថ្លងជាពុំព្រមចង់លិចទៅវិញសោះ ។

យើងដាច់សោហ៊ុយទាំងអស់គ្នា ស្អីឲ្យតែម្ចាស់ក្សត្រី ក៏ថ្លងជាអផ្សុកតប់ប្រមល់ខ្លាំងណាស់ដែរ ។ ពួកក្រុមភឹងដ៏អភ័ព្វ ពីដើមគាត់ធ្លាប់ធ្វើជាអ្នកចាំយាមឃ្លាំមើលយើង ឥឡូវត្រូវធ្លាក់ខ្លួនមកជាអ្នកបំរើយើងយ៉ាងស្មោះត្រង់បំផុត ។

កាលណាត្រឡប់មកពីផ្សារម្តងៗ ក្រុមភឹងអស់ហ្នឹងតែងទិញបានរបស់ចម្លែកៗមកផ្ញើយើង ថ្លងជាប្រភេទម៉ាស៊ីនចេះលោត កាលណាគេមួលខ្លៅ បាល់កៅស៊ូ ទំ ផ្លែឈើ កំណាត់ស្បែ ។ របស់ទាំងនេះថ្លៃបប់ពពក ប៉ុន្តែយើងចេះតែទំទិញជាក់ពេញហិបគ្រប់គ្នា ដើម្បីបានយកទៅបង្ហាញ ឪពុក-ម្តាយ ឲ្យបានស្គាល់របស់ចម្លែកនៅស្រុកគេ ។

ល្ងាចមួយនោះ យើងត្រូវចេញដំណើរឆ្ពោះទៅកាន់ក្រុងប៉ារីស៍ទាំងអស់គ្នា ដោយជិះលើរទេះភ្លើងបើកតាមផ្លូវដែក ថ្លងកាលនៅស្រុកស៊ើលង្កាដែរ ។ បន្តបន្ទាប់ធ្វើដំណើរក្នុងរទេះនេះទូលាយស្រួល មានកៅអីក្រាលពូកសម្រាប់អង្គុយ មានចង្រៀងឆេះឯងអុជបំភ្លឺ មានបង្គន់សព្វគ្រប់ទាំងអស់ ។ បានធ្វើដំណើរស្រួលអញ្ចឹង យើងថ្លងជាទុកចិត្តហើយធូរទ្រូងខ្លាក ប្រៀបបានមនុស្សទើបនឹងរួចពីគុក ។ យើងអើតតាមបង្អួចតយតន់មើលដើមឈើនិងផ្ទះក្នុងផ្ទៃអន្ធការ នៃ រាត្រីកាល ដែលរសាត់ថយក្រោយហ៊ាសស្ទើរមើលមិនទាន់ ។

រំពេចនោះ ស្រាប់តែយើងមើលទៅក្រៅលែងឃើញអ្វីទាំងអស់ គឺរទេះភ្លើងបើកចូលទៅក្នុងរូងដែលជីកទម្លាយជើងភ្នំពីម្ខាងទៅម្ខាង ដោយបញ្ចេញសូរស័ព្ទខ្ពរខ្ចារ ហាក់ថ្លងជាដីភ្នំរលំសង្កត់មកលើយើង ។

ស្អែកព្រឹកឡើង រទេះភ្លើងនៅតែបើកទៅមុខដដែល ឆ្លងកាត់វាលស្រែពណ៌បៃតងស្រស់ ព្រៃស្បាត និងឆ្លងស្ពានច្រើនរាប់មិនអស់ ។ ស្រុកស្រែស្រុកចំការនៅស្រុកបារាំង ភាគុសគ្នាស្រឡះពីស្រុកយើង គឺគេដាំដំណាំឥតឲ្យសល់ដីទំនេរមួយដុំណាឡើយ ។

ទីបញ្ចប់ នៅពេលយើងមកដល់កន្លែងមួយ ដែលថ្មៃមេឃប្រែជាខ្មៅអាប់ជាងនៅឯ ស្រុកម៉ាស៊ីទៅទៀតនោះ មានឧរណាម្នាក់ប្រាប់ថា យើងជិតមកដល់ក្រុងប៉ារីស៍ហើយ ។ គឺក្រុងប៉ារីស៍នេះហើយ ដែលគេតែងសរសើរស្រប់មាត់ថា ជាទីសប្បាយលើសកន្លែងណាទាំងអស់ មើលពីចម្ងាយ ឃើញក្រុងនេះលាតសន្ធឹងលើដីវាលាបស្មើ ប្រកបទៅដោយផ្សែងខ្មៅក្រមដណ្តប់ពីលើ និង មានផ្ទះថ្មខ្ពស់ៗ សង់ឯណោះមួយដុំ ឯណោះមួយដុំ ។ សូម្បី ជញ្ជាំងផ្ទះ រាងហាល ដី ពពក ក៏មានផ្សែងខ្មៅស្តិតនៅប្រឡាក់លាយឡំដែរ ។

រទេះភ្លើងទីមួយៗ សណ្តោងរ៉ឺម៉ករាប់រយ បើកជឿសន្ធាខ្លាត់ខ្លែងលើផ្លូវដែក, ខ្ញុំភ័យស្ទើរលោះព្រលឹងទឹកអស់គុណម៉ែគុណឪ ព្រោះថាបើមានតែរទេះភ្លើងណាមួយបើកច្រឡំផ្លូវ ច្បាស់ជាបុកគ្នាក្រឡាប់ស្លាប់អស់អ្នកជិះមិនខាន ។ ហើយនៅឆ្ងាយឯណោះ យើងមើលឃើញប្រាសាទដែកមួយ ដែលមាចុងកំពូលល្អតខ្ពស់ហួសកំពូលកណ្តាល នៃ ប្រាសាទអង្គរវត្តរបស់ខ្មែរទៅទៀត ។

នៅពេលមកដល់ក្រុងប៉ារីស៍ ខ្ញុំហាក់ថ្លងជាវិលមុខភ្លេចភ្លាំងអ្វីទាំងអស់ ឃើញតែហួងមនុស្សច្រើនកុះករ សម្លេងអ្វីអរ និង ក្លិនអាក្រក់ជះមកស្ទើរទ្រាំមិនបាន ។ ផ្លូវថ្នល់ធំទូលាយហើយស្អាតជាងនៅម៉ាស៊ីមែន ប៉ុន្តែធំក្លិនផ្សែងប្រេងសាំង និង មានមនុស្សរាប់ម៉ឺនាក់ប្រជ្រៀតគ្នាឆ្លងកាត់ថ្នល់ទៅមក គួរឲ្យចង់ទស្សនា ។

ជាសំណាងល្អណាស់ដែលនៅទីបញ្ចប់យើងបាន មកជួបមិត្តភក្តិ មកជួបហួងវិញ ។ ហួងគង់នៅក្នុងដំណាក់មួយធំ ប៉ុន្តែនឹងប្រាសាទបាញ់យ៉ុងនៅភ្នំពេញដែរ ស្ថិតនៅជាប់ផ្លូវធំ មានដាំដើមឈើលើចិញ្ចើមថ្នល់អមសង្កាត ព្រមទាំងមានឡានើបកបន្តកន្ទុយគ្នាទៅមកឥតដាច់ ។

យើងស្នាក់នៅក្រុងប៉ារីស៍បានតិចថ្ងៃណាស់ ហើយយើងត្រូវវាំតែពីរដងប៉ុណ្ណោះ ។ ទីមួយវាំនៅផ្ទះលោកប្រធានាធិបតីបារាំង និង ទីពីរវាំនៅក្នុងសួនច្បារ ដែលមើលទៅល្អថ្លងស្ពានស្មេនយ៉ាងនោះដែរ ។ ហួងបង្គាប់ឲ្យគេនាំយើងដើរលេង ទៅមើលស្បៀកដែលមានមនុស្សប្រុសស្រីស្បៀកពាក់ស្អាតៗ ហើយនាំគ្នាដែលឡើងជិះសេះ ដែលកំពុងផាយពេញល្បឿន មានមនុស្សឡើងជិះត្រួតលើគ្នាលើកជើងឡើងលើមានមនុស្សវាយប្រជាល់គ្នា... ។

ម្ចាស់ក្សត្រី ក៏បាននាំយើងទៅមើលប្រាសាទដែកដ៏ធំគួរឲ្យខ្លាច រហូតដល់មានពួកយើងខ្លះ ខ្លាចមិនហ៊ានឡើងមើល សុខចិត្តអង្គុយចាំគេនៅខាងក្រោមវាងៗនុបដៃកំប្រោន ។ ខ្ញុំប្រថុយឡើងទៅលើជាមួយម្ចាស់ក្សត្រី និង ពួកម៉ាកពីរ-បីនាក់ រហូតដល់ជាន់ទីមួយ ។ គេឲ្យយើងចូលទៅក្នុងរទេះមួយបិទជិតស្រដៀងគ្នានឹងរទេះដែលនឹកយើងពីម៉ាស៊ីមកប៉ារីស៍ដែរ ហើយស្រូតសណ្តោងឡើងទៅ ពុំចាំបាច់ឲ្យយើងដើរឡើងតាមជណ្តើរទាំហាន់ទេ ។ នៅលើជាន់ទីមួយនេះមានលក់ខំលក់ស្រា មើលទៅក្រោមឃើញក្រុងប៉ារីស៍លាតសន្ធឹងធំល្វឹងល្វើយ ក្របកទៅដោយកំពូលប្រាសាទ និង សសរច្រងច្រាង ហើយនៅឆ្ងាយមួយហ្វរកាត់ទីក្រុង មានស្ពានច្រើនរាប់មិនអស់ សម្រាប់ឆ្លងពីច្រាំងម្ខាងទៅច្រាំងម្ខាង ។ ប៉ុន្តែខ្ញុំមិនអាចមើលទៅឆ្ងាយឃើញដល់ជើងមេឃទេ ពីព្រោះផ្សែងដែលហុយចេញមកពីគ្រប់ដំបូលផ្ទះនោះ ភាធ្វើឲ្យថ្មៃមេឃទាំងមូលប្រែជាងងឹតជាស ។

គ្មានឧរណាម្នាក់ហ៊ានឡើងខ្ពស់ជាងនេះទៀតទេ ។ នៅពេលចុះមកវិញ គេសម្រេតរទេះលឿនស្ទើហាក់ថ្លងជាយើងរួតធ្លាក់មកឥតមានអ្វីទ្រពីក្រោមជើងថ្លងនោះដែរ ដែលជាហេតុទាំឲ្យយើងវិលមុខ រកកលក្លតចង្អោរ ។

ក្នុងថ្ងៃធ្វើបុណ្យជាតិបាភាំង គេយករវេះមកដឹកហួង និងពួកយើងជាបរិវារទាំងអស់គ្នា ហើយបរចេញទៅតាមផ្លូវដ៏ធំទូលាយ និងស្អាតក្រៃលែង។ បាភាំងមានធំៗ ស្បែកពាក់ខោអាវក្រហម ពាក់មួកជិះសេះអមសង្ខាងក្បួនរវេះយើងជាប់ហួត។ គេយាមការពារប្រយ័ត្នប្រយែងម្ល៉ឹងៗ ប្រហែលជាគេនាំហួងទៅដាក់គុក ឬនាំទៅសម្លាប់ចោលក៏មិនដឹង។ យើងនុស្សាហ៍លួចចោលកន្ទុយភ្នែកមើលទៅពួកជិះសេះទាំងសង្ខាងហ្នឹងជាញឹកញាយ មើលយូរទៅរឹតតែខ្លាចខ្លាំងឡើង ខ្លាចរហួតទាល់តែមិនហ៊ានស្លប់! បាភាំងរាប់លាននាក់ឈរនៅសង្ខាងផ្លូវ ស្រែកហ៊ោកញ្ជ្រៀវរកស្តាប់មិនយល់ នៅពេលឃើញក្បួនរវេះយើងមកដល់ ដែលជាហេតុធ្វើឲ្យយើងភ័យញ័រខ្លាចខ្លើក។

ក្បួនរវេះមកឈប់ក្នុងទីវាលមួយដែលគេមានសង់វេទិកាធំៗ អាចដាក់ទស្សនិកជនបានរាប់ពាន់នាក់។ ហួងចុះទៅឈរក្បែរប្រធានាធិបតីបាភាំង ប៉ុន្តែខ្ញុំសម្លឹងពីចម្ងាយរកចំណាំមុខគាត់ហ្នឹងមិនបានសោះ។ តាហានតម្រៀបជួរដើរស្រុះជើងគ្នាលើវាលស្មៅ បន្ទាប់មកមានអ្នកជិះសេះកាន់ជាវ៉ានៅដៃ ធ្វើដំណើរកាត់មុខហួងរាស្ត្រប្រជា ដែលស្រែកអបអរសាទរឡើងទ្រហឹងអឺងអាប់រកស្តាប់ទិសតំបន់អ្វីមិនយល់ បើកុំតែមានរបាំផែកបាំងជាប់ កុំអីពួករាស្ត្រមុខតែធ្លាយមកជាន់តាហានដែលកំពុងដើរនេះមិនខាន។ ទស្សនីយភាពនេះមានសភាពសម្បើមគួរកោតស្ញប់ស្ញែងក្រៃលែង។

ល្ងាចនោះ បាភាំងអុជកាំជ្រួចនៅកណ្តាលទន្លេដែលហូរកាត់ក្រុងបារីស៍ ភ្លឺរន្ទាលព្រោងព្រាត ក្អេងប្រេសស្រីស្រែកច្រៀងសប្បាយ ហ៊ោកញ្ជ្រៀវបន្ធូរតាមបរហួង ព្រមទាំងបង្ហោះប៉េងប៉ោងចម្រុះពណ៌ ឲ្យហើរពេញផ្ទៃមេឃ។

ហួងវល់តែសប្បាយរីកថ្កើមនឹងការដែលបាភាំងលើកកិត្តិយស សប្បាយទាល់តែភ្លេចគិតដល់ពួកយើង។ ពួកស្រីក្រមហួងមហោរី ដែលបានដង្ហែហួងមកក្រុងបារីស៍មុនយើង គេនិយាយរឿងចម្លែកៗស្តើរឿពុំបានប្រាប់យើង ប៉ុន្តែសុទ្ធសឹងជារឿងពិតទាំងអស់។ សូម្បីហួង និងអ្នកអង្គម្ចាស់ស្តីវ៉ង្ស ជាកូនប្រុសបណ្តូលចិត្តរបស់ហួងនោះ ក៏បាននិយាយប្រាប់យើងដោយឥតលាក់លៀម ពីស្រីបាភាំងដែលលោកបាន "ជួប" ហើយលោកបញ្ជាក់ថា ស្រីបាភាំងគេចេះ "ម៉ែត្តត" ច្រើនបែបណាស់ មិនមែនល្ងង់ដប់គត់ផ្ងចខ្មែរទេ។

គេដណ្តើមគ្នាមើលរូបថតដែលអ្នកអង្គម្ចាស់ស្តីវ៉ង្សទិញមក ឃើញរូបបាភាំងប្រុសបាភាំងស្រីស្រាតខលតកទាំងអស់គ្នា ហើយប្រើរបៀបចំតិតចំត្វងប្លែកៗអស្ចារ្យ សូម្បីស្រីសំផឹងនៅស្រុកយើង ក៏គ្មានមីណាគឺកឃើញធ្វើផ្ងចអញ្ចឹងដែរ។ ពួកយើងទើបនឹងមកដល់ក្រុងបារីស៍ក្រោយគេ ហើយបានឃើញរូបថតនេះជាលើកដំបូងបំផុត ខ្លះមិនហ៊ានមើលយកដៃខ្ទប់ភ្នែក ខ្លះក្អួតចង្អោរនៅពេលបានឃើញឆាកដ៏សែនអាសអាភាសនេះ។

ខ្ញុំចេះតែនឹកបារម្ភក្នុងចិត្តថា បើយើងនៅក្នុងស្រុកបាភាំងតែពីរ-បីអាទិត្យទៀត ថ្ងៃណាមួយហួងតង់នឹងបង្គាប់ឲ្យយើងចំតិតចំត្វងផ្ងចក្នុងរូបថតថ្វាយលោកមិនខាន។ ពួកយើងចង់តែចាកចេញពីដីស្រុកបាភាំងឲ្យបានឆាប់បំផុត ហើយរហួតមកដល់សព្វថ្ងៃនេះក្តី នៅក្នុងភាំងចតុមុខ ក៏ពួកស្រីៗដែលធ្លាប់បានដង្ហែហួងទៅស្រុកបាភាំង នៅតែស្តាយថា មិនគួរនាំគ្នាទៅស្រុកអាសអាភាសអញ្ចឹងសោះ។ តាមស្តាប់សំដីម្នាក់ៗទាំង នាម៉ឺនរាជការ ពួកល្ងោន នរណាក៏សុទ្ធតែឆ្ពេតនឹងស្រុកបាភាំងដែរ។

មានតែហួងមួយអង្គឯងទេ បែបផ្ងចជាខុសគេ កាលណាលោកយាងចេញកំសាន្តទៅណាម្តងៗ លោកបាចគាទលុយទៅលើផ្លូវឲ្យបាភាំងដណ្តើមគ្នាជីសផ្ងចឆ្កែ ឲ្យមានរបៀបនេះ បើនៅស្រុកខ្មែរវិញ សូម្បីអត់ឃ្លានយ៉ាងណាក៏គេមិនខ្ជីជីសយកដែរ ហើយពួកបាភាំងនេះ មិនមែនជីសតែលុយទេ សូម្បីកន្ទុយបារីដែលយើងដក់ជិតអស់ ត្រវាត់ចោលទៅក្នុងសួនច្បារនោះ ក៏គេជីសយកទៅដក់ នៅស្រុកខ្មែរមិនដែលមានឧរណាធ្វើឫកថោកដល់ថ្នាក់ហ្នឹងឡើយ។

ពេលយប់ ក្មួនស្តេចក្មេង១ពីរនាក់ បានទៅមើលឃើញគេធ្វើ ស្រា, ស្ករស និង ទំប៉ុង ក្នុងរូងក្រោមដីក្រខ្វក់រកអ្វីមកប្រៀបឲ្យស្មើពុំបាន។ ចាប់តាំងពីពេលនោះមក ម្ចាស់ទាំងពីរអង្គ ដើរប្រាប់គេប្រាប់ឯងថា លោកសោយតែបាយទេ ឈប់ល្មកប៉ះពាល់ម្ហូបបាភាំងទៀតហើយ ពីព្រោះវាគក្រៃចត្តរឲ្យខ្ពើមដាងប្រហុកទៅទៀត។

បើនិយាយឲ្យខ្លី តាមអ្វីៗដែលយើង បានឈើញ បានដឹង បានឮ យើងអាចសន្និដ្ឋានបានថា របៀបរបបនៅស្រុកបាភាំង វាខុសគ្នាស្រឡះពីស្រុកយើង ឥតឃើញមាន សាសនា សេចក្តីថ្លៃថ្នូរ សីលធម៌ ឥតមានធ្វើបុណ្យប្រាថ្នាស្វែងរកសុខក្នុងបរលោកផ្ងចយើងទេ។ បាភាំងជាមនុស្សខ្លាំងឡកែ តែល្ងង់ គិតតែនាំគ្នាធ្វើការឡើយហត់ គិតតែបង្កើតរបស់ប្លែកៗ ប៉ុន្តែមិនអាចរកផ្លូវទៅនិព្វានឃើញឡើយ។

មនុស្សម្នាត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ឥតមានពេលឈប់សំរាក មើលទៅគួរឲ្យវេទនាភ្នែកក្រៃលែង ហើយយើងជាប្រជាពលរដ្ឋខ្មែរ ក៏គង់នឹងត្រូវទទួលរងវាសនាកម្មផ្ងចគ្នានេះដែរ ពីព្រោះយើងកាន់តែធ្លាក់ខ្លួនជាខ្ញុំបាភាំងបន្តិចម្តងៗហើយ!។

ការចាប់បង្ខំខ្មែរ ឲ្យធ្វើការផ្ងចទាសករ ការឥម្តើងថ្លៃពន្ធអាករ ការឥម្តើងថ្លៃទំនិញ ពួកបរទេសលើកគ្នាមកនៅក្នុងក្រុងកាន់តែច្រើនឡើងៗ... ទាំងអស់នេះឬ ជាសុភមង្គលដែលបាភាំងនាំយកមកឲ្យខ្មែរ ជាថ្នូរនឹងការដែលគេដកហូតយកឯករាជ្យរបស់យើងនោះ?...

យើងបែកចេញពី ហួង និង ក្រុងបារីស៍ដោយក្តីសប្បាយរីករាយក្រៃលែង ដើម្បីត្រឡប់មកកាន់ក្រុងម៉ាស៊ីដ៏ស្ងាត់ជ្រងំវិញ ដែលយើងអាចធ្វើដំណើរទៅណាមកណាបានតាមចិត្ត ពុំចាំបាច់មានតាហានជិះសេះអមសង្ខាង ផ្ងចមនុស្សខោសទេ។

ក្នុងពេលធ្វើដំណើរពីបារីស៍មកម៉ាស៊ី ម្ចាស់ចិត្តវ៉ង្ស ក៏ធ្វើដំណើរមកជាមួយយើងដែរ ស្រាប់តែវង្វេងបាត់ម្តាយលើរវេះហ្នឹង ក៏តាំងស្រែកឮញញួរដូចកូនក្មេង ដើរកកេញរវេះហ្នឹង ប៉ុន្តែនៅពេលចូលមកដល់ក្នុងបន្ទប់យើង ម្ចាស់ខ្ងចនេះបែរជានិយាយរឿងផ្តេសផ្តាស កាលពីពេលម្ចាស់ស្តីវ៉ង្សជាបងនោះ តាំងៅផ្ទះសំផឹងបាភាំងវិញ ហើយយើងក៏ចាប់ច្រានចេញទៅវិញភ្លាម ព្រោះយើងមិនចង់ស្តាប់រឿងអាសអាភាសនេះ។

មកដល់ម៉ាស៊ី បាភាំងលើកគ្នាភ្ញកទឹកភ្ញកដីមកសុំថតរូបយើងច្រើនណាស់ ហើយពួកនេះមក មិនសូវជីសពេលវេលាផង ជួនកាលមកចំលើពេលបាយ យើងក៏ត្រូវឈប់ស៊ីបាយសិន ដើម្បីទៅឈរឲ្យគេថត។

ព្រឹកនៃការធ្វើដំណើរវិលត្រឡប់មកកាន់ស្រុកខ្មែរវិញមកដល់ហើយ! យើងរៀបចំឡើងលើកប៉ាល់ជាមួយម្ចាស់ក្បូន្រើ ហើយទាល់តែថ្ងៃជិតត្រង់ ទើបឃើញហួងយាងមកដល់។ បន្តិចក្រោយមក កប៉ាល់ក៏ចាកចេញពីច្រាំង ដឹកនាំយើងមកកាន់មាតុប្រទេស ដែលយើងតែងនឹកគិតឥតភ្លេច។

ក្មួនស្តេចជាច្រើនឥតត្រឡប់មកវិញទេ តើគេទៅរៀនក្នុងស្រុកបាភាំង។ ពួកអស់ហ្នឹងរៀនស្អី? រៀនចម្លងយកទំនៀមទម្លាប់អាសអាភាសមកផ្សាយក្នុងស្រុកខ្មែរឬ?... ប៉ុន្តែខ្ជួយទៅវិញ នៅលើកប៉ាល់មានមនុស្សថ្មីខ្លះ ដែលយើងពុំដែលឃើញសោះកាលពីពេលទៅ គឺពួកជាងដែលគេនឹកយកមកពីស្រុកខ្មែរតាំងព័យូរណាស់មកហើយ ដើម្បីសង់វិមានថ្មទៅម៉ាស៊ី ជាកន្លែងយើងឆ្លាប់ទៅរាំនោះ។

ពួកអ្នកធ្វើការលើកប៉ាល់ ពុំមែនជាមនុស្សដដែលដែរ គឺច្រោកដជាកប៉ាល់ផ្សេងមួយទៀតហើយ ទោះបីរូបរាងកប៉ាល់នេះផ្ទួចគ្នាបេះបិតនឹងកប៉ាល់ដែលយើងជិះមកក៏ដោយ។

ព្រឹត្តិការណ៍សំខាន់ជាងគេក្នុងពេលធ្វើដំណើរ គឺរឿងដែលគេឃើញ ម៉ែមន្ទ កំពុងសាហាយជាមួយលោកមហាមន្ត្រី នៅក្នុងបន្ទប់ទឹក។ រឿងនេះគេខំខ្ចប់លាក់លៀមខ្លាំងណាស់ គ្រាន់តែខ្យិបខ្សៀវអេចអ្វួចពីមាត់មួយទៅមាត់មួយប៉ុណ្ណោះ។ ហ្លួងក៏បានដឹងរឿងអពមង្គលនេះដែរ ប៉ុន្តែមិនហ៊ានមាត់កថាផ្ទួចម្តេចពីព្រោះសព្វថ្ងៃនេះ លោកមហាមន្ត្រីកំពុងមានអំណាចខ្លាំងណាស់។ ប៉ុន្តែទោះជាយ៉ាងណា ក៏លោកកាន់តែជិនឆ្នន់នឹង ម៉ែមន្ទ ខ្លាំងឡើងៗ។

ចាប់តាំងពីថ្ងៃនោះមក ម៉ីវ៉ែន និង មីស៊ុន ពួកម៉ាកខ្ញុំតាំងពីក្មេងៗមក គេប្រសប់អែបអបយកគាប់ត្រូវក៏បានឡើងហ៊ាន:ជាអ្នកគាប់ចិត្តហ្លួង បានត្រួតត្រាមើលក្រុមអ្នកគាស់បម្រើផ្ទាល់ព្រះអង្គ ព្រមទាំងបានទទួលវង្វាន់ជាកិត្តិយស និង គ្រឿងអាលង្ការច្រើនណាស់។ ម៉ីវ៉ែនខ្មៅក្រញ្ជេះ បានប្រែឈ្មោះជាវណ្ណរតន៍ ហើយបានត្រូវគេទាំងអស់គ្នាគោរពអ្នតសរសើរ សុទ្ធតែវាហ្នឹងជាស្រីគ្រប់លក្ខណ៍ ហើយម្ចាស់ខ្លួនវាទោះទៀត ដល់បានឡើងបុណ្យអញ្ចឹង វាហ្លួចអស់ជាតិកំណើតវាជាដង្វាវ ហ្លួចអស់ពួកម៉ាកដែលកាលពីដើមធ្លាប់ស៊ីបាយមួយចានពីរនាក់ ជក់បារីមួយដើមពីរនាក់។

ប្រហែលជាទេវតារក្សាសមុទ្រ ចង់ផ្តន្ទាទោសចំពោះពួកអ្នកដំណើរដ៏មានគំនិតខ្ចូចម៉ៀចវ៉ ហ៊ានសាហាយស្មន់គ្នាលើកន្លែងដែលគេថែរក្សាហើយមើលទៅ! ខ្យល់ខ្លាំងបក់មកពីទិសនិរតី លាន់ឮសន្ធឹកផ្ទួចព្យុះសង្ឃរា បង្កើតជារលកធំៗជាងផ្ទះ បក់បោកមកលើកប៉ាល់ បណ្តាលឲ្យឈ្លួងឈ្លោងរកលនឹងលិច។ ទឹកភ្លៀងបោកឡើងលិចដល់ក្តារកប៉ាល់ ហើយហៀរចូលតាមបង្ហួចបិទមិនជិត លិចទាំងបន្ទប់ដែលយើងដេកនោះផង។ យើងទាំងអស់គ្នាកើតជម្ងឺពុលរលក ក្តួតជាក់លើខ្លាំងឈើលើពូក ប្រឡាក់អស់គ្នាទសល់។ ខណៈដែលពីមុនមកធ្លាប់អួតថាខ្លួនគ្រាន់បើនោះ ក៏លែងអួតក្អេងក្អាង ត្រឡប់ជារត់រកធ្លួមកអុជសំបួងសង្រួង ទឹកអស់គុណម៉ែ-គុណនុ ហើយអ្នកខ្លះទៀត យំស្រែកទ្រហឹងអឺងអាប់។ និយាយពីហ្លួងវិញ ធ្លាក់ខ្លួនឈឺពុលរលកប៉ុណ្ណឹងហើយ នៅឆ្លៀតដេរបញ្ជោរបាវាំង ស្តីឲ្យអ្នកត្រួតត្រាធំជាងគេលើកប៉ាល់ថា នាំលោកចេញឆ្ងាយពីត្រាំងមកដល់កណ្តាលសមុទ្រទាល់តែវង្វេងផ្លូវរកទិសតំបន់មិនឃើញ។ លោកទឹកអស់គុណដីផ្ទួដីតា ព្រមទាំងសារភាពទទួលកំហុសទាំងអស់ដែលលោកបានប្រព្រឹត្ត សុំឲ្យតែួចរស់ជីវិតមួយគ្រានេះ។

ក្នុងពេលនោះ គ្មានរណាម្នាក់ហ៊ានសង្ឃឹមថា នឹងគេចផុតពីកណ្តាប់ដៃសមុទ្រទេ។ យើងម្នាក់ៗទឹកឃើញអស់រឿងសព្វសមុទ្រក្រពើឆ្លាម ហើយគំនិតយើងរសាត់ទៅដល់មាត់ត្រាំងដ៏រកាយ ក្រោមរស្មីព្រះអាទិត្យនៃមាតុភូមិរបស់យើង ដែលពេលនេះប្រហែលជា ង៉ុពក-ម្តាយយើង កំពុងអង្គុយលើភនហាលផ្ទះ ទឹកព្រួយបារម្ភពីវាសនាយើង ភ្នែកមើលទៅជើងមេឃដ៏ឆ្ងាយឥតព្រិចែន...។

នៅទីបញ្ចប់ មហាសមុទ្រក៏រំងាប់ភ្លើងកំហឹងខ្លួនទៅវិញ... យើងត្រឡប់មកដល់ប្រទេសសើរលង្កាដោយសុវត្ថិភាព។ ក្រោយពេលឃ្លាតទៅអស់ពេលប៉ីខែដ៏យូរប្រៀបបានប៉ីឆ្នាំ យើងបានវិលមកឃើញត្រាំងភ្លុសាំងស៊ីន ក្រុងព្រៃនគរ ទន្លេធំ និង ដីចំការស្រុកលើកផែកវិញ ដោយក្តីសប្បាយរីករាយរកអ្វីមកប្រៀបឲ្យស្មើពុំបាន។ ទឹកដែលហូរនាំដីល្បប់មក ជន់ឡើងលិចដល់ត្រាំង ទំនងផ្ទួចជាចង់លិចដល់សួនច្បារកំពង់ផែផង។ កប៉ាល់ចូលមកចតចំមុខភាំងតែម្តង... ទូកច្រើនរាប់មិនអស់ មកចោមរោមម៉ាំវិញកប៉ាល់... ខ្ញុំឃើញ ពុក និង ម៉ែ ឈឺស្រកសាច់ស្គមជាងមុនឆ្ងាយណាស់ ព្រោះគាត់ព្រួយចិត្តខ្លាំងពេក ស្មានថាខ្ញុំ

ស្លាប់មិនបានមកជួបគាត់វិញទេ។ គេដង្ហែពួកយើងចុះពីកប៉ាល់ ដើរតាមផ្លូវហួតដល់មាត់ទ្វារកំផែងសីមា។


ពេលបានមកឃើញផ្ទះង៉ុពកម្តាយខ្ញុំនឹងច្រឡឹងក្រោមរស្មីព្រះអាទិត្យនេះវិញ ការតាឥតីងក្នុងចិត្តទាំងប៉ុន្មាន ក៏រលាយបាត់អស់ដោយឯកឯង។

អស់អ្នក-អស់នាង ដែលមិនបានទៅស្រុកបារាំងនឹងគេ ដណ្តើមគ្នាស្តាប់យើងនិយាយប្រាប់ ឡើងចំហមាត់ ហើយប្រញាប់គ្នាដណ្តើមយកអស់របស់របរដែលយើងទិញបានមកទាំងប៉ុន្មាន ឥតមានសល់អ្វីបន្តិចបន្តួចឡើយ ក្រៅតែពីអនុស្សាវរីយ៍ដ៏ល្វីងជូរចត់ ដែលយើងខំបំភ្លេចចោលឲ្យបានឆាប់ជាទីបំផុត។

♥ ♥

♥

ក្រុមតន្ត្រីរបាំព្រះរាជទ្រព្យ



Orchestre du Palais Royal

ពីមួយវេនេះ ខ្ញុំមានការពិសោធន៍ត្រប់គ្រាន់ ខ្ញុំអាចនឹងយ៉ាងច្បាស់ដោយខ្លួនឯងថា ចាប់តាំងពីពេលនេះតទៅ ក្តីសង្ឃឹមថានឹងបានក្លាយទៅអ្នករាំមានក្តីឈ្មោះល្បីក្នុងថ្ងៃណាមួយខាងមុខនោះ រលាយសាបសូន្យអស់ហើយ។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយ នៃ ការរស់នៅក្នុងភាំង ខ្ញុំជួបប្រទះតែនឹងរឿងរ៉ាវគួរអស់សង្ឃឹម គួរឆ្អែតចិត្តផ្ទួនៗគ្នា។

ខ្ញុំអាយុបានដប់បីឆ្នាំហើយ គឺខ្ញុំនេះពេញវ័យល្មមគេចាត់ទុកថា ជាស្ត្រីម្នាក់ហើយ។ ភ្លៅខ្ញុំប្រែជាមានសាច់ណែនមួលក្អឹ ហើយខ្ញុំភ័យណាស់ខំរត់ទៅលបសួរម៉ែនៅពេលឃើញមានដុះរោមត្រឡាចត្រង់ចន្លោះគល់ភ្លៅទាំងពីរ។ ត្រគាកខ្ញុំរីក ហើយដោះខ្ញុំក៏ចាប់ផ្តើមដុះធំប្រហែលប៉ុនមេដៃប៉ុណ្ណោះ ប៉ុន្តែឈឺពាល់មិនបាន។

ខ្ញុំមិនដែលហ៊ានទិយាយរឿងអស់នេះប្រាប់ពួកម៉ាកទេ ព្រោះពួកមីអស់ហ្នឹងវាសុទ្ធតែស្រួតត្រប់ការមុនខ្ញុំទៅទៀត។ ប៉ុន្តែពួកវាទៅតែប្រមែ្លងដេញគ្នាពេញសួនច្បារ ស្រែកហ៊ោកញ្ជ្រៀវ ឬ ស៊ីតំកាន់សំញែងផ្លែចក្ងេង ឥតឃើញវាផ្ចាស់ប្តូរចរិតត្រង់ណាបន្តិចបន្តួចសោះ។ ចំណែកខ្ញុំវិញ ខ្ញុំលែងហ៊ានទៅដង្ហែតទឹកម៉ាស៊ីនទៅកណ្តាលវាលផ្លែចមុនទៀតហើយ ដោយខ្លាចប្រុសៗផ្លែចជា ចោយ ឬ អ្នកធ្វើចាយហួង អ្នកភ្លេងបងប្អូន ឬ ឪពុកម្តាយពួកណ្តោន ឬ ក្មួនស្តេចតួចៗក្បាលខ្លែច គេដើរទៅមកឃើញ។

សេចក្តីអៀនខ្មាសវាតម្រូវឲ្យខ្ញុំលះបង់សើរភាពខ្លះចោលចេញ គឺខ្ញុំត្រូវប្រយ័ត្នប្រយែងងូតទឹកតែក្នុងបន្ទប់ស្រួលបួល។ ស្រីៗខ្លះបានចូលដល់ក្នុងបន្ទប់ទឹក ក៏តាំងលែងខ្លួនទេ ស្ទៀកតែសារុងចង្កិចកប់ក្រលៀនផ្លែចប្រុស។ ទោះបីខ្ញុំមានការអៀនខ្មាសខ្លះយ៉ាងនេះក៏ដោយ ក៏ខ្ញុំនៅតែភ្លីភ្លើមិនស្អប់នឹងអីនៅតែមានចរិតក្មេងនៅឡើយ។ ពេលទំនេរក្រោយពេលហាត់រាំ នៃ ថ្ងៃណាដែលខ្ញុំពុំត្រូវជ្រែចូលគាល់បំរើហួង ខ្ញុំចំណាយពេលសម្រាប់ ដេរអាវ ឬ ជ្រលក់សំពត់ មិនឲ្យទំនេរឥតប្រយោជន៍។

ខ្ញុំយកចិត្តទុកដាក់ថែទាំរបស់ប្រើប្រាស់ខ្លាំងណាស់ ហើយមីពួកម៉ាកអស់ហ្នឹង បើខ្ចីសំពត់អាវខ្ញុំយកទៅស្ទៀកម្តងៗ វាស្ទៀកពង្រិចពង្រិលទាល់តែ ប្រឡាក់គគ្រិច ឬ រហែកធ្ងន់ឆ្ងាយ ទើបវាយកមកសងវិញ ម្ល៉ោះហើយខ្ញុំខ្ជិលយកវិញ សុខចិត្តឲ្យវារហូតតែម្តង។

ឥឡូវខ្ញុំមានបន្ទប់ផ្ទាល់ខ្លួនតូចមួយ សម្រាប់ដេកម្នាក់ឯងដាច់ខ្សែកពីគេ ទៅក្នុងរោងដែលពីដើមឃុនថាន់ គាត់សង់ឲ្យក្មួនណ្តោនគាត់នៅ។ ផ្ទះនេះធ្វើពីឈើ មានពីរជាន់ សង់ខ្ពស់ពីដីបន្តិច ពិបាកក្រៃលែងក្នុងការលួចចូលបោសសំរាមដែលគរស្រួយរលួយនៅក្រោមផ្ទះ តាំងពីច្រើនឆ្នាំណាស់មកហើយ។ ជណ្តើរនាំឡើងទៅកាន់ជាន់ទីមួយ ដែលជាកន្លែងដេករបស់ពួកណ្តោន វាយខ័ណ្ឌជាបន្ទប់ដាច់ឲ្យពីគ្នា។

នៅជាន់ខាងក្រោម ក៏ផ្ទួចជាជាន់ខាងលើដែរ ពិតាឈើពុកអស់ កាលណាភ្លៀងម្តងៗ លិចផ្ទួចដេកកណ្តាលវាលអញ្ចឹង។ ពីកន្លែងដេកទៅ ខ្ញុំអាចមើលឃើញ សួនច្បារ ផ្ទះក្រាលថ្ម ដើមឈើធំៗ និង កំពូលប្រាសាទលបទឹកមាសល្បីឆ្ងិនឆ្ងៅ ហើយទៅខាងត្បូងឯណោះ ដងទង់ នៃ វត្តព្រះកែវ ល្អឥន្ទស់ជាច់គេ។

គ្រឿងប្រើប្រាស់ទាំងអស់ សុទ្ធតែជារបស់ផ្ទាល់ខ្លួនខ្ញុំ ដែលពុកទិញយកមកឲ្យ គឺគ្រែឈើមួយ មានមុងពួកក្រាលកម្រាលខ្មៅ កន្ទេល ខ្នើយ ហិបពីរសម្រាប់ដាក់សំពត់អាវ និង ប្រាក់កាស និង ទូកញ្ជក់ភ្លូចមួយដែលនៅក្នុងនោះ ខ្ញុំតម្រៀបដាក់ ដបទឹកអប់ កំប៉ុងម្សៅ និង រមៀត សម្រាប់លាបសំអិតសំអាងកាយរាល់ថ្ងៃ។ លើសពីនេះទៅទៀត ខ្ញុំមានរបៀប ជរ អំបោះហុង ម្ជុល កន្ត្រៃ សំពត់ ជាហ៊ឹ សារុង បត់តម្រៀបគរលើគ្នា ព្រមទាំងមានដាក់ ផ្កាចម្ប៉ា ផ្កាចេកទុំ ផ្កាំរចេក នៅជាមួយនោះ សម្រាប់អប់សំពត់អាវឲ្យក្រអូប។

ខ្ញុំខុសហ៊ានទទួលភ្ញៀវពីក្រៅ គេមកលេងជាញឹកញយ ប៉ុន្តែខ្ញុំមានកន្ត្រោរស្តាន់មួយសម្រាប់ការពារកុំឲ្យភ្ញៀវស្តោះទឹកមាត់ស្លាដាក់លើក្តារ។ ពួកភ្ញៀវស្រីអស់ហ្នឹងចាមកលេង ប៉ុន្តែតាមពិតគេតម្រង់មករកសុំសំពត់អាវ ឬ លុយកាក់ទៅវិញទេ ហើយខ្ញុំក៏កម្រប្រកែកចាមិឲ្យណាស់ ពីព្រោះថ្ងៃណាមួយខ្ញុំនឹងត្រូវពឹងពាក់អ្នកអស់នោះវិញមិនខាន។ ជួនកាលទៀត ភ្ញៀវអស់ហ្នឹងមានរឿងផ្សេងៗ គឺគេលាក់ សាច្រក្រអូបទឹកអប់ស្រុកបារាំង ម្សៅកញ្ចប់ ឬ ទំចំណី ដែលសុទ្ធជារបស់មានតម្លៃ យកមកឲ្យខ្ញុំ ហើយសារភាពប្រាប់ថានេះជាបញ្ជើ របស់អ្នកនេះ របស់អ្នកនោះ ដែលធ្លាប់ឃើញខ្ញុំរាំ ហើយចាប់ចិត្តស្រឡាញ់ខ្ញុំ។ គេសុំឲ្យធ្វើកន្សែងមួយទៅឲ្យគេវិញ ទោះជាកន្សែងទោះចាស់ហែកយ៉ាងណាក៏ដោយ ឲ្យតែមានដាប់ក្លិនខ្លួនខ្ញុំ! ខ្ញុំធ្វើឫកជាខឹងនឹ ។កមេអណ្តើកនេះ ដោយនិយាយកំញើញថា នឹងទៅទូលហួងឲ្យចាប់ យកទៅវាយធ្វើបាបយកទៅដាក់គុ..រស់អាយុមិនខាន ប៉ុន្តែទោះជាយ៉ាងណា ខ្ញុំក៏នៅតែទទួលយករបស់ជំនូនដែរ ដើម្បីយកទៅចែកពួកម៉ាកស៊ីសើចលេងសប្បាយ ដោយមានផ្តាំផ្ញើពាក្យផេះបញ្ជោរឲ្យទៅពួកកម្លោះស្នេហារលុងខ្លោះផង។

ខ្ញុំខំរៀបចំបន្ទប់ឲ្យបានស្អាតជាងបន្ទប់ពួកម៉ាកឯទៀត។ មានតែ កាហ៊ូនប្អូនស្រីជីដូនមួយខ្ញុំទេ ដែលមកនៅជាមួយខ្ញុំរាល់ថ្ងៃ ជាអ្នកបំរើ ជាពួកម៉ាក ជាអ្នកមើលខុសត្រូវលើទ្រព្យសម្បត្តិខ្ញុំ និង ជាអ្នកតាំងលីងពីខ្ញុំទៅផ្ទះ និង ពីផ្ទះមកខ្ញុំ។

រាល់ថ្ងៃ វាពិបាកបំផុតត្រង់អារឿងបោសសំរាម និង រៀបចំអីវ៉ាន់ដែលពួកភ្ញៀវច្រូលមកបីរុះតាមចិត្ត។ ពួកម៉ាកខ្លះនៅក្នុងថ្ងៃវាទោះ ពិបាកពេកវាតាំតាមួយបួន-ប្រាំទាក់ មកដេកពេញកន្លែងខ្ញុំ ថែមទាំង លេងបៀជក់ចាវី ពង្រាយគ្នារឲ្យចុញទ្រាន់ក្រៃលែង។ ដើម្បីបណ្តេញវាចេញទៅវិញ ទាល់តែប្រើកម្លាំងបាយ ឬ ធ្វើចរិតឲ្យកាចឃោរឃៅបន្តិច ប៉ុន្តែខ្ញុំពុំបានគិតស្មានថា ការដែលខ្ញុំធ្វើផ្លូវច្នេះវាអាចជាហេតុនាំឲ្យគេយកទៅទូលហួង ទូលម្ចាស់ក្សត្រី ថាខ្ញុំកាចឆ្នាស់ ដើម្បីដណ្តើមយកសេចក្តីគាប់គួរសម្រាប់ខ្លួនគេវិញសោះ។

ពេលព្រលប់ មានចង្កៀងចេះឯងព្យួរទៅនឹងពិតានបំភ្លឺពេញបន្ទប់ ហើយមានចង្កៀងមួយទៀតដាក់នៅក្រោមបង្ហិចបន្ទប់ខ្ញុំ សម្រាប់បំភ្លឺសួនច្បារហូតទល់ព្រឹក។ រាល់ព្រឹក ខ្ញុំ និង កាហ៊ូន កាន់អំបោសស្រកីផ្លូងមួយម្នាក់ ដើម្បីបោសច្រាសបន្ទប់សព្វអស់កន្ទុកកន្ទៀត បន្ទាប់មកខ្ញុំងូតទឹកសំអាតខ្លួន ហើយបើចំលើពេលត្រូវជ្រែចូលបំរើហួង ខ្ញុំត្រូវងូតទឹកយូរជាងសព្វមួយដង។

កាលណាកាហ៊ូន វាទៅយកបាយពីផ្ទះមកទទួលទាន ម៉ែឧស្សាហ៍តាមមកជាមួយវា ដើម្បីមកលេងនឹងខ្ញុំ។ ចំណែកពុកវិញ យូរៗទើបបានមកលេងម្តង ប៉ុន្តែមកម្តងណា ក៏ផ្ទួចម្តងណា ពុំដែលបានលុយ

មួយសេនពីខ្ញុំយកទៅផ្ទះទេ មានតែខ្ញុំខ្វេះកកាយយកអស់ពីហោចៅគាត់ ហើយបើមានបារីប៉ុន្មាន គាត់បារ ឲ្យខ្ញុំទាំងអស់ សុទ្ធចិត្តអត់ខ្លួនឯង ។

ក្នុងបួនថ្ងៃ ខ្ញុំទំនេរបានបីថ្ងៃ... ក្នុងពេលទំនេរនេះ ខ្ញុំមិនសូវរៀងសំអាតខ្លួនប៉ុន្មានទេ ហើយខ្ញុំ ចុះទៅទិញនំដែលគេជាក់លក់នៅក្នុងសួនច្បារ បន្តាប់មកយើងប្រជុំគ្នាដើរលេងទាំងក្រុមៗ ដោយមាន ម៉មសំអយ, សំអាង, ថែម, ស៊ុត, សួញ្ជាយ អ្នកភ្លាហានជាងគេ ជាមេអ្នកដឹកនាំ ។ យើងលួចអស់ មាន់ទា ផ្លែពុទ្រា ផ្លែល្មុត ដែលស្តេចចាស់ៗ និង អស់អ្នកអស់នាង ថែទាំស្រោចទឹកយ៉ាងធ្ងិតផ្ងង់បំផុត ។ កាលណា យើងលួចឆ្អែតឆ្អន់ហើយ យើងនាំគ្នាទៅអង្គុយផឹកលេងនៅកន្លែងភៀងងឹត ។ ពួកធំៗបង្គាប់គ្នា ទៅញៀវទៅមកថា មានទាក់ទងជាមួយស្មៀនធ្វើការ នៅប៊ុយរ៉ូប៉ស៊ីដង់បាកាំង ឬ នៅប៊ុយរ៉ូកុង្សី ពីព្រោះ កាលពីពេលចេញរាំលើកមុន គេសង្កេតឃើញអ្នកនេះលួចឲ្យកន្ទុយភ្នែកអ្នកនោះច្បាស់ណាស់ ។ អ្នកខ្លះ ទៀត និយាយសារភាពប្រាប់គ្នីគ្នាពីការមិនពេញចិត្ត ចំពោះជីវភាពក្នុងភឹង ចំពោះការដែលហួងមិនសូវ រវៃវល់គិតគូរដល់ខ្លួន ព្រមទាំងអួតសរសើរពីការសប្បាយរីករាយ នៃ ជីវភាពដែលពោរពេញទៅដោយ សើរភាពនៅខាងក្រៅភឹង ដែលប្រុសអាចតាមមើលស្រីបានដោយឥតភ័យខ្លាចជាប់គុក ដែលស្រីអាច តែងខ្លួនស្អាតបាតដោយមិនចាំបាច់លាក់លៀមពីក្អែកពួកក្រុមភឹង ។ គេជជែកគ្នាអែប្រមែរហួតដល់យាម ទីពីរ ទើបនាំគ្នាទៅផេកមៀង១ខ្លួន ។ ខ្ញុំងងុយផេកឆ្ងន់ក្បាល ប្រផេកភ្លាមក៏លក់ភ្លាម ឥតមានគិតខ្វាយខ្វល់ ដល់ពាក្យសំដីដែលពួកធំៗគេនិយាយគ្នានោះទេ ខ្ញុំស៊ីមួយថ្ងៃសម្រាប់រស់មួយថ្ងៃ ឥតមានភ័យព្រួយពី ថ្ងៃស្អែក រស់ប្រៀបបានតឹងសត្វយ៉ាងនោះដែរ ។

វិន័យ និងរបៀបរៀបរយ នៅក្នុងភឹង ត្រូវគេបោះបង់ចោលទាំងស្រុង ។ ភឹងសព្វថ្ងៃ ក៏មិនខ្វល់ភឹងកាល ពីដើមដែរ ពីព្រោះអ្នកធំចេះតែមានគំនិតបង្កើតរបៀងមិនល្អប្លែកៗគ្នាមិនចេះអស់ ម្ល៉ោះហើយអ្នកតូចតាច ចាំតែយកសម្រាប់តាម នរណាមិនចូលចិត្តយកតម្រាប់តាមគេទេ ក៏ត្រូវតែចាកចេញពីភឹងទៅនៅក្រៅវិញ ។ មិនបានប៉ុន្មានឆ្នាំផង អស់អ្នកអស់នាង អ្នកហួង អ្នករាំ ត្រូវរាំ រហូតដល់អ្នកបំបើ សុទ្ធតែផ្គាស់ថ្មីទាំងអស់ ។

កាលពីដើម មានក្រុមល្ខោនបី ឥឡូវនៅសល់តែមួយគត់ ក្រោមកិច្ចដឹកនាំ នៃ ម្ចាស់ក្សត្រី ដែលសំអាង យកអំណាចខ្លួនជាកូនស្រីច្បង នៃ ស្តេចសោយារជ្យ មកធ្វើជាធំលើសគេទាំងអស់ ។ មុខងាររបស់លោក មានត្រឹមតែជ្រើសរើសស្រីក្មេងៗកូនអ្នកស្រែរាំយ៉ាំឃារ មកបំពេញកន្លែងខ្វះចន្លោះតែប៉ុណ្ណោះ ។ ប៉ុន្តែអស់ នេះ ហួងមើលមិនឃើញទេ ពីព្រោះទាំងយប់ទាំងថ្ងៃ លោកសម្ងំនៅតែក្នុងប្រាសាទបាញ់ឃ្មុំង ។ សូម្បី ទិដ្ឋភាពនៅជុំវិញដំណាក់ហួងក៏ប្លែកពីដើមដែរ អ្នកលក់នំចំណី អ្នកសុំទាន ចូលមកដល់ជិតដំណាក់ហួង បង្កើតជាភាពក្រខ្វក់ត្រប់ទឹកន្លែង ។

ពួកមីដែលថា មកសុំនៅក្នុងភឹងនៅពេលក្រោយៗនេះទាំងប៉ុន្មាន វាគ្រាន់តែ ប៉ៀនលាបម្សៅយីហ៊ុន ប៉ៀនពត់ដៃពត់ជើង ដើម្បីធ្វើជាលេសប៉ុណ្ណោះ តាមពិតវាមកលួច សំពត់អាវ មាសពេជ្រ របស់គេឯងរាល់គ្នា យកទៅកប់លាក់ទុកក្នុងកន្លែងណាមួយ រង់ចាំតែយប់ណាមានឱកាសល្អ វានឹងទៅកកាយយករបស់ ទាំងនោះ ហើយលួចរត់ចេញពីភឹងទៅបាត់តែម្តង ។ រាល់យប់តែងតែមានមីណាមួយលួចរត់ មិនសូវលោះ ខានឡើយ ។

ពួកអ្នកធ្វើព្រះស្ងោយហួង និង ពួកកូនចៅ ឱស្សាហ៍និយាយប្រាប់ខ្ញុំថា កាលគាត់ចេញទៅផ្សារ គាត់ បានឃើញ មីនេះ មីនោះ ដែលធ្លាប់មកនៅភឹងបានប៉ុន្មានថ្ងៃ ហើយលួចរត់ចេញទៅវិញ ធ្វើឫកដូចជាសំធឹង ដើរទាក់ទង ជាមួយចិន ជាមួយបាកាំង អួតសុទ្ធតែខ្លួនវាហ្នឹងជាពួកល្ខោនហួង ។

ជំនាន់នោះ មានតែពួកយើងមិនដល់ដប់នាក់ផង ដែលជាអ្នករាំយកចិត្តទុកដាក់ក្នុងការងារគឺ ល្ងេ មិត សំអាង ម៉ាប៉ាន់ យ៉ាន វ៉ែន ហើយនិង ខ្ញុំ ។ ពួកយើងសុទ្ធចិត្តនៅហាត់រៀនជាមួយគ្រូចាស់ៗ ជាជាង ឡៀតពេលទំនេរ ដើរអង្គុយលេងឥតប្រយោជន៍ដំណាក់ហួង ។ ប៉ុន្តែក្នុងចំណោមអ្នករាំប៉ុន្មានគាក់នេះ មានតែយ៉ាន និងខ្ញុំទេ ដែលហាក់ដូចជាលេចមុខខ្ពស់ជាងគេ ។ ទោះបីពាក្យទំនាយរបស់អ្នកអង្គម្ចាស់ ផ្ងងមធុរា ដែលលោកទាយទុកថា យើងពីរនាក់នឹងក្លាយទៅជាតារា នៃ ក្រុមល្ខោនហួងនោះ ពុំអាចសំរេច ទៅបាន ដោយហេតុកាលៈទេសៈថ្មីវាប្រែប្រួលប្លែកពីដើមយ៉ាងណាក៏ដោយ ក៏ទឹកមុខញញឹមរបស់អ្នកគ្រូ សម្តែងសេចក្តីពេញចិត្តចំពោះយើង វាជាកម្លាំងលើកទឹកចិត្តម្យ៉ាងដែរ ពេលណាយើងត្រូវចេញរាំលើឆាក ម្តងៗ ។

យ៉ាន និង ខ្ញុំ ត្រូវចេញរាំមុខអ្នករាំទាំងពីរផ្សេងជាទិច្ច ។ យើងមានសៀតកន្សែងស្តុតពណ៌ ក្រហម ឬ ស នៅខ្សែក្រវាត់រៀងខ្លួន ហើយកាលណាយើងចូលមកជិតគ្នា យើងលួចកេះលួចក្តិចគ្នា ទៅញៀវទៅមក យ៉ាងពេញចិត្ត ។ យើងពីរនាក់ជាតួរាំឆើត អាចពត់ពេទន់ភ្លន់ទៅតាមចង្វាក់ភ្លេងត្រូវឥតខ្ចោះ ប៉ុន្តែ ឥតមានរណាវល់យកចិត្តទុកដាក់នឹងយើងប៉ុន្មានឡើយ ព្រោះសព្វថ្ងៃនេះគេរើសយកធ្វើជាតួឯក តែ នរណាដែលជាទីពេញចិត្តរបស់ហួង ឬរបស់ម្ចាស់ក្សត្រី ប៉ុណ្ណោះ ទោះបីអ្នកនោះគ្មានលក្ខណៈជាអ្នករាំ ក៏ដោយ ។

ពួកអ្នកគ្រួយល់ច្បាស់ណាស់ថា តួ យ៉ាន និងខ្ញុំ ពុំអាចយករណាផ្សេងទៀតមកផ្គាស់ជំនួសបានទេ ប៉ុន្តែគាត់ក៏មិនដឹងធ្វើម៉េចដែរ សុទ្ធចិត្តតែនៅស្ងៀមទៅ ពីព្រោះសព្វថ្ងៃ មិនសូនវាគាប់ជាងគេ វាត្រូវតែបាន ឡើងធ្វើតួឯកអញ្ចឹង ។ ពេលចេញរាំម្តងៗ វាជាក់មាសពេជ្រស្រោចខ្លួន ពីព្រោះវាឮកែបញ្ជោរចៅហ្វាយនាយ យកគាប់គួររកនរណាប្រៀបឲ្យស្មើពុំបាន ប៉ុន្តែតាមពិត វាគ្រាន់តែជាអ្នករាំរាយរងប៉ុណ្ណោះ ។

ហេតុនេះហើយ ទើបបានជាសព្វថ្ងៃគេត្រូវបង្ខំចិត្តជ្រើសរើសយកពួកអ្នកមិនចេះអីសោះ មកជាក់ បំពេញកន្លែងហាត់រាំ និង រត់ទៅពឹងអ្នករាំជើងចាស់ ដូចយ៉ាង ម៉មទួ ម៉មប្រឹម ម៉មសំអយ ជាដើម ដែលគេ បំភ្លេចចោលទៅហើយនោះ ឲ្យត្រឡប់មកជួយបង្ហាត់ភ្លេងសារក្រោយផង ។

ខ្ញុំនេះល្ងង់ពេកណាស់ ពុំអាចកាត់យល់បានពីអំពើអយុត្តិធម៌ផ្សេងៗ ដែលគេធ្វើមកលើខ្ញុំបានទេ ។ ខ្ញុំចេះតែគិតថា បើខ្ញុំខិតខំធ្វើការបានល្អ គង់នឹងមានគេមើលឃើញ ហើយគេនឹងលើកខ្ញុំឲ្យធ្វើជាតួឯក មិនខាន ។ ពេលចេញរាំម្តងៗ ខ្ញុំម្ខម៉ៅណាស់ គេឲ្យខ្ញុំធ្វើតែតួរាយរង អត់បានស្ងៀកពាក់សំពត់អាវល្អនឹងគេ បានពាក់តែមកុដជ្រលក់ទឹកមាសតែប៉ុណ្ណោះ ។ ជួនកាលខ្ញុំឈឺចិត្តទ្រាំមិនបានទាល់តែស្រក់ទឹកភ្នែក នៅ ពេលឃើញគេប្លុងមិនឲ្យខ្ញុំរាំតួដែលខ្ញុំហាត់រាប់ខែមកហើយ ។ ការខំប្រឹងប្រែងរបស់ខ្ញុំ ពុំបានធ្វើឲ្យម្ចាស់ក្សត្រី ពេញចិត្តទេ ប៉ុន្តែលោកហាក់ដូចជាជិនឆ្នន់នឹងខ្ញុំកាន់តែខ្លាំងឡើងៗជាលំដាប់ ។

សូម្បីពួកមីកូនចៅម្ចាស់ក្សត្រី ក៏បញ្ចេញឫកពេបជ្រាយដាក់ខ្ញុំខ្លាំងណាស់ដែរ ដែលជាហេតុធ្វើឲ្យខ្ញុំ យល់បានខ្លះថា គំនិតត្រង់ក្លឹងស្លូតស្លាប់របៀបខ្ញុំនេះ ពុំមែនជាទីពេញចិត្ត នៃ ម្ចាស់ក្សត្រី ឡើយ ពីព្រោះ លោកបានសោកល្បងទាញខ្ញុំឲ្យទៅរស់នៅក្នុងចំណោមកូនចៅលោកច្រើនផងណាស់ហើយ ពុំដែលបាន សំរេចសោះ ។

យ៉ាន ក៏មិនមែនសប្បាយចិត្តជាងខ្ញុំប៉ុន្មានដែរ ប៉ុន្តែធ្វើម៉េចគ្នាជាកូនកំព្រាគ្មានទីពឹង ចេះតែទ្រាំទៅ ឲ្យតែ មានបាយស៊ី មានដំបូលជ្រក ប៉ុណ្ណឹងវាគ្រប់គ្រាន់ណាស់ហើយ វាមិនចង់យកគាប់ត្បូរ ជាមួយម្ចាស់ក្សត្រី ជាមួយហួង អ្វីទាំងអស់ ។

ឥឡូវ ខ្ញុំក៏ខ្លាចហួងណាស់ដែរ បើកុំតែអញ្ចឹងខ្ញុំមិនបាច់ទៅហាត់កាំ ទាំងឿយហត់អត់ប្រយោជន៍ទេ ចាំមើលតែស្អែកឡើងដល់ពេលចេញកាំ យប់នេះទៅនាយអាយជាមួយហួងមួយសន្ទុះ ច្បាស់ជាបានធ្វើឆ្លងកមិនខាន ។

ហេតុដែលនាំឲ្យខ្ញុំខ្លាចហួង គឺថ្ងៃមួយជាវេនខ្ញុំគាស់បំរើហួង ខ្ញុំអង្គុយជជែកគ្នាលេងជាមួយពួកម៉ាក ពីរ-បីនាក់ នៅលើក្បាលដណ្តើរប្រាសាទបាញ់យ៉ាំង រង់ចាំទម្រាំហួងភ្ញាក់ពីផ្ទំវិញ ។ ពេលនោះហួងឲ្យគេ ហៅមីស៊ុនឱងមីវ៉ែន ចូលទៅក្នុងបន្ទប់ផ្ទាល់ព្រះអង្គ ហើយបិទទ្វារចាក់សោជាប់ ។ ប្រហែលមួយម៉ោង ក្រោយមក ទើបឃើញវាទាំងពីរនាក់ចេញមកវិញ ធ្វើឫកបែបអៀនប្រៀន ក្អែកក្រហម សំពត់ខ្ទិកខ្ទុកខ្ទេចខ្ទីអស់ ហើយវារត់ទៅសម្ងំនៅក្នុងបន្ទប់ដេកបាត់ ។ ពួកធំៗគេនាំគ្នាសើចគិល ដែលជាហេតុអាចឲ្យខ្ញុំកាត់យល់ឃើងហេតុសព្វគ្រប់ទាំងអស់បានដោយងាយ ។ បន្ទាប់ពីមានឃើងនេះបន្តិចមក ដល់វេនហួងហៅទាងម៉ាឡា ដែលទើបនឹងគ្រប់ការថ្មីៗឲ្យចូលក្នុងបន្ទប់ម្តង ហើយមួយសន្ទុះក្រោយមក ស្រាប់តែឮហួងស្រែកឲ្យឡាវេញវាថាឲ្យទៅលាងក្តិតសិន ហើយត្រឡប់ចូលមកវិញ ។ ខ្ញុំពុំដែលគិតថា ឃើងវ៉ាវបែបនេះនឹងកើតមានចំពោះខ្ញុំឡើយ ព្រោះខ្ញុំធ្លាប់តែស្រឡាញ់ហួងទុកដូចជាជីតាខ្ញុំយ៉ាងនោះដែរ ម្ល៉ោះហើយខ្ញុំភ្ញាក់ផ្អើលខ្លាំងណាស់ នៅពេលឮពួកធំៗគេនិយាយបំភ័យថាខ្ញុំឆ្កួត ថាកាលណាគេចូលមកបម្រើហួង គេត្រូវតែស្រឡាញ់ហួងដូចស្រឡាញ់ប្តីអញ្ចឹង ។

បន្ទាប់ពីកើតឧប្បត្តិហេតុនេះមក ថ្ងៃមួយមីពួកម៉ាកម្នាក់ក្បាលខូច វាធ្វើជានិយាយលេងស្រែកខ្លាំងៗ ពីឃើងខ្ញុំខ្លាចហួង ទាល់តែឮដល់លោក, លោកខំសាកសួរគេឯងរកដើមហេតុ ដែលនាំឲ្យខ្ញុំខ្លាចលោកយ៉ាងនេះ ហើយលោកដូចជាចង់លេងសើចនឹងសភាពល្ងង់ខ្លៅរបស់ខ្ញុំខ្លាំងណាស់ ។ រាល់ថ្ងៃខ្ញុំខំធ្វើការប្រយ័ត្នប្រយែងក្រៃលែង ដើម្បីជៀសវាងកុំឲ្យហួងស្តីបន្ទោស ប៉ុន្តែខ្ញុំពុំបានគិតឃើញថា លោកពិតតែស្អប់ខ្ញុំលើសដើម ដោយហេតុលោកពុំអាចសំរេចបំណង ដែលក្រមួចមាត់ប៉ងប្រាថ្នារួបខ្ញុំតាំងពីយូរហើយនោះទេ ។ ជួនកាលលោកសំរាមកំហែងគិតធ្វើបាបខ្ញុំ ជួនកាលលោកបន្តុះបង្អាប់ដោយប្រើពាក្យមានន័យជ្រៅ គិតទៅឃើញក្បាលខ្ទម្រាំយល់ ។ ថ្ងៃមួយខ្ញុំកាន់ខ្សៀអាហ្សៀនយកទៅថ្វាយលោកដែលកំពុងផ្ទំលើត្រែ ដោយមានអាកប្បកិរិយាភ័ក ហាក់ដូចជាកំពុងគិតទៅឃើងអ្វីមួយផ្សេងទៀត លោកក៏លាន់មាត់ថា :

~ ស្តាយណាស៊ី មនុស្សមិនត្បូរស្អាតហើយហ្អើដល់ម្ល៉ឹងសោះ ! សាវ៉ាម៉ាឌីដូចគោអញ្ចឹង ប្រហែលជាវាមានសាហាយនៅឯណា ចង់រត់ចោលអញហើយមើលទៅ.....! ។

ខ្ញុំធ្វើជាមិនឮ ព្រោះខ្ញុំមិនយល់ថា ហួងចង់និយាយពីអ្វីទេ ។ នេះជាសំណាងរបស់ខ្ញុំហើយ ដែលទៅតាលោកជួយបិទបាំងមិនឲ្យខ្ញុំយល់អ្វីទាំងអស់ បើកុំតែអញ្ចឹង ម្ល៉ោះសមខ្ញុំនឹងត្រូវធ្លាក់ខ្លួនទៅក្នុងចំណោមប្រពន្ធដ៏ច្រើនរាប់មិនអស់របស់ហួងមិនខាន ។

♥ ♥

♥

ពេលឥឡូវចេះតែធ្វើដំណើរទៅមុខលំដាប់...

ថ្ងៃមួយ ពេលដល់ម៉ោងហួងងើបពីផ្ទំ មីងព្រែតអ្នកលក់ មាសពេជ្រ មកសុំចូលគាល់ ដើម្បីថ្វាយហួងខតត្រឿងអលង្ការខ្លះ ព្រែងលោកត្រូវការទិញ ។ ហួងអនុញ្ញាតឲ្យគាត់ចូលមក គាត់ក៏អង្គុយរៀបចំប្រមូលប្រឡូកប្រឡាយហើយ ដាក់ប្រអប់ដែកទៅលើកម្រាលព្រំ ហើយលូកវាយកកញ្ចប់តូចៗច្រើនណាស់ ចេញពីក្នុងស្បោងដែលធ្លាប់នឹងខ្សែក្រវាត់ទម្លាក់ទៅក្រោមក្បាលពោះគាត់ ។ ហួងក្រពាត់ដៃដើរទៅដើរមកនិយាយថា :

~ មីងព្រែតឯង ចំជាមនុស្សមានទ្រព្យសម្បត្តិច្រើនមែន សូម្បីអាកន្លែងហ្នឹងក៏មានមាសពេជ្រដែរ, នែ ! បើមនុស្សធម្មតា លូកទៅកន្លែងហ្នឹង ច្បាស់ជាបានមមិះជាប់ដៃស្រេមាមមិនខាន ។

មីងព្រែត ញញឹមមិនវែលឆ្លើយតបថាម៉េច គិតតែតម្រៀបកងដៃដាំពេជ្រ ចិញ្ចៀនត្បូង ក្រវិល ទំហ្អែ ដាំពេជ្រ ថ្វាយហួងខត ។

ពេលនេះជាពេលដើមខែ មីងព្រែតគាត់ប្រសប់បើសពេលវេលាណាស់ គឺគាត់មកចំលើពេលដែលហួងកំពុងសម្បូរលុយ ។ ថ្ងៃនេះជាវេនខ្ញុំកាន់សោ ហួងក៏ប្រើឲ្យខ្ញុំទៅយកការប្រមូលដាក់ក្រដាសប្រាក់ពេញហៀរមកថ្វាយ ។ ខ្ញុំធ្វើតាមបញ្ជាយ៉ាងប្រយ័ត្នប្រយែងក្រៃលែង ដោយភ័យខ្លាចព្រែងត្រូវហួងជេរបញ្ឆោវផ្ទួចមីពួកម៉ាកខ្ញុំកាលពីវេនទីបីនោះទៀត ពីព្រោះមីនោះ គេឲ្យយាមមើលខ្ទូ វាមើលតែខ្ទូទេ បណ្តោយឲ្យម៉មប្រឹម លួចយកលុយទៅសងបំណុលគាត់ឯផ្សារអស់រលីង តែមួយវៀលក៏ឮនៅសល់ផង ។ ហួងរាប់លុយទិញត្រឿងអលង្ការ ចេញលុយដល់ដៃឲ្យខ្លះ ខ្ទះប៉ុន្មានជំពាក់សិន ។ មីងព្រែត ថ្វាយបង្គំលា ហើយដើរខ្នងៗចេញទៅវិញ ដាក់ស្បោងលុយលាក់ក្នុងអាវជិតល្អណាស់ ។

ខ្ញុំអង្គុយបត់ជើងក្បែរហួង រង់ចាំព្រែងលោកមានប្រើធ្វើអ្វីផ្សេងទៀត ។ អស់អ្នក-អស់ទាងជាច្រើន ខំទាំគ្នាតែងខ្លួនលាប ទឹកអប់ ប្រេង ម្សៅ ក្រអូបឈ្ងុយឈ្ងប់ ដើម្បីចូលមកគាល់ហួង សង្ឃឹមព្រែងបានអ្វីបន្តិចបន្តួចនឹងគេ ។ ហួងសម្លឹងមើលខ្ញុំឥតប៉ប្រិចភ្នែក ហើយហុចក្រវិលមួយគូមកឲ្យខ្ញុំ ប៉ុន្តែនៅពេលដែលខ្ញុំលូកដៃខ្ទួលទាំងចិត្តសប្បាយរីករាយចំពោះរង្វាន់ដ៏ល្អនេះ ស្រាប់តែលោកដកដៃចេញវិញ ព្រមទាំងនិយាយបញ្ឈឺចិត្តថា :

~ ទេ ! ឯងនេះខ្ជិលណាស់ កុំអាលយកអី ចាំថ្ងៃក្រោយទៅចាំយក ហើយលោកប្រគាត់ក្រវិលនោះទៅឲ្យ មីប៉ុន ដែលវាឆ្លៀតចោលកន្ធយភ្នែករបៀបចំអកមើលមកខ្ញុំទៀតផង ។ ខ្ញុំឈឺចិត្តស្រក់ទឹកភ្នែកច្រោកវត់ត្រឡប់មកកាន់បន្ទប់ដេកវិញ ស្រាប់តែប្រទះឃើញម៉ែដែលមកលេងនឹង ម៉មទូ ។ ចាប់តាំងពីពេលត្រឡប់

មកពីស្រុកបារាំងវិញ ហួងមិនស្ទាវរីវរល់នឹកនាដល់ ម៉ែមន្ទ ដូចពីដើមទេ ប៉ុន្តែទោះជាយ៉ាងណា ក៏ម៉ែមន្ទ សន្យាថា នឹងជូនខ្ញុំទៅសុំគ្រឿងអលង្ការពីហួងឲ្យបាន ព្រោះគាត់មិនហ្អែចខ្ញុំដែលជាកូនចៅចាស់ ធ្លាប់បម្រើគាត់តាំងពីដើមមកនោះទេ ។

ព្រឹកមួយ ត្រូវវេនគាល់បំរើហួង ខ្ញុំអស់កម្លាំងពេក ក៏ប្រះដេកទៅលើពូកក្នុងបន្ទប់ដែលហួងទើបនឹង ងើបចេញទៅក្រោយពីផ្តុំសោយអាហារនៃអស់ពេលដ៏យូរ ។ ពេលនោះ ស្រាប់តែ ម៉ែមន្ទ ចូលទៅដល់និយាយ ថា :

~ ក្រាបទូល ! ខ្ញុំម្ចាស់អាណិត សាហ៊ាម៉ាន ណាស់ ព្រោះគ្មានមាសពេជ្រពាក់នឹងគេសោះ ។ វានេះជា កួយរបស់ខ្មោចលោកអគ្គមហាសេនា ជាកូនគេអ្នកត្រឹមត្រូវ ហើយធ្វើការម៉ឺងម៉ាត់ល្អណាស់ ។

~ ស្អី ! ធ្វើការម៉ឺងម៉ាត់ ? (ហួងសំកសំដីមកឲ្យវិញភ្លាម) មើលវា ! គេធ្វើការគ្រប់គ្នា វាទៅសម្ងំដេក បើម្តុំៗឲ្យអញស្រឡាញ់វាយ៉ាងម៉េចនឹងកើត ។

លោកអត់និយាយថាម៉េចតទៅទៀតទេ... ម៉ែមន្ទ ដើរចេញទៅវិញដោយឆ្លៀតលួកក្តិចដាស់ខ្ញុំឲ្យភ្ញាក់ ផង ប៉ុន្តែខ្ញុំមានដេកលក់ឯណា ឥណានិយាយថាអីក៏ខ្ញុំស្តាប់ឮតាំងអស់ ។

ខែបន្តាប់មក ដល់ពេលចែកគ្រឿងអលង្ការជាថ្មីម្តងទៀត ខ្ញុំនឹកទៅដួចជាកួចចិត្តខ្លាំងពេក មិនខ្លីចង់បាន អ្វីទាំងអស់ ទើបមិនរវល់ទៅមើលហួងចែកនឹងគេ ។ ហួងកាន់ក្រឹលពីរតួ មួយតួតួចលោកប្រទានឲ្យ មីយ៉ាន ហើយប្រើគេឲ្យមកហៅខ្ញុំទៅយកអាមួយតួធំ ប៉ុន្តែ មីយ៉ាន វាមានគំនិតខ្លួចខ្លួលហួងថា ត្រចៀកវាធំជាង ត្រចៀកខ្ញុំ បើវាបានពាក់ក្រឹលធំទើបសមជាង ហើយលោកក៏ប្រទានអាធំនោះឲ្យវាទៅ ។

ខ្ញុំបានអាតួចឥតពេញចិត្តសោះ ហើយហួងក៏នឹងថាខ្ញុំមិនពេញចិត្តដែរ ទើបលោកបង្ខំឲ្យខ្ញុំពាក់ទៅនឹង មុខលោកតែម្តង ក្រឹលនេះខ្ញុំពាក់ជាប់នឹងត្រចៀករហូតដល់សព្វថ្ងៃ ឥតដែលដោះផ្លូវទៅណាឡើយ ។ ដល់ពេលចែកចិញ្ចៀន លោកស្តីឲ្យកិតសាម៉ែច្រើនណាស់ ព្រោះក្រចកវាមិនស្អាត ។ ដល់វេនខ្ញុំ លោក ប្រទានចិញ្ចៀនបីវង់ ព្រមទាំងសរសើរថា ខ្ញុំចេះថែដែរដើងបានស្អាតទៀតផង ។

អ្នកដែលគាប់ចិត្តហួង ពុំមែនសុទ្ធតែបានខ្លួលវង្វាន់ច្រើនជាងគេនោះទេ គឺជេរបញ្ឆោរក៏ញយជាងគេ រំពាត់ក៏ត្រូវញឹកជាងគេ ។

អ្នកដែលបានឡើងជាស្នំគាប់ចិត្តក្រោយពេលដែល ម៉ែមន្ទ អស់បុណ្យទៅនោះ គឺ វ៉ែន, ស៊ុន និង ស្អាត ប៉ុន្តែតាមចិត្តហួង ស្រឡាញ់ម្ចាស់ក្សត្រីជីប ជាចៅស្រីរបស់លោក លើសនរណាទាំងអស់ ។ នេះហើយ អំពើឆ្កួតលីលារបស់ស្តេច សមតាមពាក្យដែលប្រជារាស្ត្រតែងនិយាយថា "ស្តេចក៏ដូចជាឆ្កែដែរ សូម្បី បងប្អូនកូនចៅឯង ក៏ចេះយកគ្នាជាប្តីប្រពន្ធទៅកើត" ។ ស្នំឯកទាំងនេះគ្មានអំណាចអ្វីជាធំទុំទេ ហួងតែង និយាយថា :

~ អញមិនមែនភ្លើទេ, ពួកមីអស់ហ្នឹងវាគ្មានស្រឡាញ់អញសោះ, វាស្រឡាញ់តែលុយអញប៉ុណ្ណោះ ។

ដូច្នេះ នរណាក៏យល់ដែរថា តណ្ហារបស់ហួង គ្រាន់តែជាអំពើខ្លួចខ្លួលមួយភ្លែតៗ ម្តងគាប់នឹងអ្នកនេះ ម្តងគាប់នឹងអ្នកនោះ រកប្រាកដប្រជាលើនរណាមួយពុំបានឡើយ ។

ចំណែកខ្ញុំ ខ្ញុំមិនដែលត្រូវរំពាត់ទេ ប៉ុន្តែម្តងនោះខ្ញុំភ័យញ័រខ្លើក ស្មានថាមិនអាចគេចួចពីរំពាត់ផ្តៅ ហួងឡើយ ។ តើខ្ញុំមានធ្វើអ្វីខុស ? យ៉ាន រត់មកជាស់ខ្ញុំទាំងកណ្តាលយប់ ពេលដែលខ្ញុំទើបនឹងប្រះដេក លក់លើក្រែក្នុងបន្ទប់ ម៉ែអួន ហើយទោះបីខ្ញុំជជីកសួរវាយ៉ាងណា ក៏វាអត់ដឹងអីសោះ ។ ខ្ញុំរកគិតមិនយល់ សោះ តើមានរឿងអ្វី បានជាហួងខឹងដល់ម្ល៉េះ ? លោកប្រើឲ្យខ្ញុំយកកន្ទេលថ្មីបួនទៅជូន ម៉ែមន្ទ ម៉ែប្រឹម

ម៉ែមសំអុយ និង ម្ចាស់ជីប ប៉ុន្តែខ្ញុំឃើញលោកកំពុងសោយព្រះស្ងោយ ក៏ផ្លៀតចូលលេងផ្ទះ ម៉ែអួន មួយភ្លែត សិន គិតថាចាំបន្តិចទៀតសឹមយកទៅជូនគេក៏បានដែរ ហើយដោយអស់កម្លាំងពេក ខ្ញុំក៏ដេកលក់មួយ ស្រឡេតទៅ ។ តើកំហុសនេះល្មមត្រូវរំពាត់ដែរឬអ្វី ?

មីពួកម៉ាកខ្ញុំអង្គុយត្រៀបត្រា វាសប្បាយចិត្តណាស់នឹងឃើញហួងវាយខ្ញុំ វាបួញមាត់ចង្អុលបង្ហាញរំពាត់ ដែលហួងផ្អែកទុកនៅកៀនជញ្ជាំង ។

ហួងស្ទៀកសាវង់ទឹកជោកចេញមកស្រែកសួរគេថា តើខ្ញុំមកដល់ហើយឬនៅ ? គ្រាន់តែក្រឡេក យើញខ្ញុំភ្លាម លោកដេរបញ្ឆោរកប់អាកាស ប៉ុន្តែលុះមកឃើញខ្ញុំក្រាបញាក់ទទើកក្បែរជើង លោកដួចជា អាណិតរកលើកដៃវាយមិនួច ហើយនិយាយថា :

~ ឯងនេះបានចំជាល្ងង់រកលេខជាក់ស្តែង ! បើគេអ្នកមានប្រាថ្នាតែបន្តិចបន្តួច គេឃើញអញខឹងអញ្ចឹង មិនបានអីក៏គេចេះសុំទោសដែរ... ។

ទោះបី ចូលចិត្តក្តី មិនចូលចិត្តក្តី ក៏ខ្ញុំត្រូវតែធ្វើការបំរើហួងឲ្យបានដិតដល់ជាទីបំផុត ។ ហួងខ្លួនឯង បានទិយាយប្រាប់ខ្ញុំថា :

~ អាល្ងោចហ្នឹងវាបានការអី ? វាមានប្រយោជន៍ដល់ អ-ម៉ែអញ, ដល់ខ្លួនអញ ត្រង់ណាខ្លះ ? បើឯង ខានទៅហាត់ភំ ច្រើនណាស់ម្ចាស់ឯងគេរកឱ្យឯងបន្តិចបន្តួចប៉ុណ្ណឹង ប៉ុន្តែបើអញរកហៅប្រើមិនឈើញ អាហ្នឹង ច្បាស់ជារំពាត់ស៊ីខ្លួងហើយ ។

ដើម្បីផ្តាប់ចិត្តចៅហ្វាយម្តងពីរទាក់អញ្ចឹង ខ្ញុំត្រូវធ្វើការឿយហត់ទ្វេមួយ ជាពីរជាបី ក្នុងវ័យដប់បួនឆ្នាំ ដែលគេត្រូវការ សម្រាកច្រើន ដេកច្រើន ជាទីបំផុត ម្ល៉ោះហើយខ្ញុំនុស្សាហ៍ធ្លាក់ខ្លួនឈើជាញឹកញយ ។ យប់ខ្លះដែលពុំត្រូវវេនខ្ញុំយាមសោះ ពេលពាក់កណ្តាលអាធ្រាត្រកំពុងតែដេកធ្លាញ់ ស្រាប់តែមានគេមក ដាស់ឲ្យទៅអង្គុយកំដរហួងសោយស៊ុប ខ្ញុំត្រូវដាស់កាហ៊ិន ឲ្យវាជួយស្ទៀកពាក់ ជួយសំអិតសំអាងខ្លួន ហើយទៅអង្គុយកំដរហួងក្នុងបន្ទប់ទទួលភ្ញៀវ នៃ ប្រាសាទបាយ័ងុ អង្គុយជុំវិញកន្ទេលដួចគេឯងទាំងអស់ គ្នា រហ័យស៊ីធ្វើឫកដួចជាធ្លាញ់ ដួចជាសប្បាយណាស់ ប៉ុន្តែតាមពិតខ្ញុំដេកលក់ក្នុងទៅហើយ ។

♥ ♥

♥

ចាប់តាំងពីពេលទើបនឹងឡើងសោយរាជ្យភ្លាមមកម្ល៉េះ ចិត្តគំនិតហួងប្រែជាស្រពាប់ស្រពោនខ្លាំងណាស់។ ខ្ញុំឮគេនិយាយថា លោកកើតមានវិបត្តិសារីចំពោះរឿងអ្វីមួយដែលតាមលងបន្ទាចអារម្មណ៍លោកទាំងយប់ទាំងថ្ងៃ ទោះបីលោកខំសោយអាហារយ៉ាងណា ក៏ពុំអាចរំលាយអារម្មណ៍ជើរវាយផ្តេសផ្តាសអស់នេះបានដែរ។ ស្ងមីម្ចាស់ក្សត្រីយើង ជាភូតស្រីច្បង និង ម្ចាស់ស្ងីរវង្ស ភូតប្រុសសម្លាញ់ចិត្ត ក៏ពុំអាចលួងលោមលោកឈ្នះដែរ។ ជួនកាល លោកយាងទៅសំរាកឯទីតាំងផែ ឬ ឯរោងបញ្ជា ឬ ជួនកាលទៀត លោកលួចចេញទៅដើរកំសាន្តក្នុងសួនច្បារឯកំពង់ផែ ក្រុមវាំងពីរបីនាក់ទៅចាប់ប្រអូសប្រខាញមកវិញមិនចេង់ឈ្នះ។

លោកមិនមែនជាស្តេចសោយរាជ្យទេ ប៉ុន្តែជាអ្នកទោស ដែលគេយាមល្បាតជាប់ទាំងយប់ទាំងថ្ងៃយ៉ាងប្រយ័ត្នប្រយែងក្រៃលែង។ ក្នុងវាំងមិនដឹងជាមានតិញបាវាំងប៉ុន្មានទាក់ទេ ពួកអស់នោះយកលេសថាមកមើលត្រួតត្រាកិច្ចការក្នុងវាំង ប៉ុន្តែតាមពិតគឺគេមកឃ្លាំមើលហួងនេះឯង។

លោកមហាមន្ត្រីប្រសប់លើកជើងបាវាំងណាស់ ដើម្បីការពារអំណាចគាត់ ហើយគាត់មកល្បួងលួង-លោមទាល់តែហួងសុខចិត្ត លះបង់ឯករាជ្យ លះបង់ប្រទេសទាំងមូល ឲ្យទៅជនបរទេស ដើម្បីជាថ្នូរយករាជ្យបល្ល័ង្កមកអង្គុយសោយរាជ្យ ត្រួតត្រាលើតែផ្ទៃវាំងមួយក្រឹចតូចប៉ុណ្ណោះ។

ទុក្ខក្រៀមក្រំគ្របដណ្តប់លើផ្ទៃវាំងទាំងមូល ដែលប្រែជាគ្មានរបៀបរបៀបរយ រកកលតែនឹងធ្លាក់ទៅជាចំណី នៃ ពួកមនុស្សមានគំនិតពុតត្បុតអាក្រក់។ ចាប់តាំងពីពេលហួង សុវណ្ណកោដ្ឋ ចូលទីវង្គតទៅ ពួកយើងរឹតតែហោងហាងរកទីពឹងឲ្យមាំមួនពុំបាន។ ហួងថ្មីជាមនុស្សគ្មានអំណាចជាអ្នកទោស គ្មានការទាក់ទងជាមួយរាស្ត្រ គ្មានអំណាចគ្រប់គ្រងលើប្រទេស បណ្តោយឲ្យជនបរទេសធ្វើអ្វីបានតាមចិត្ត។ វាំងគឺជាគុកនៅកណ្តាលទីក្រុង ជាលំនៅ នៃ មនុស្សខ្លាក់ ដែលឥតមើលឃើញដល់ទុក្ខវេទនា នៃ រាស្ត្រប្រជាដែលត្រូវគេជិះជាន់។ ហួងខ្លួនឯងក៏ដឹងច្បាស់ថា លោកមានអំណាចធ្វើអ្វីបានតាមចិត្ត តែនៅក្នុងវាំងនេះទេ។

ម្ល៉ោះហើយហួងមិនដឹងធ្វើអ្វី មួយថ្ងៃៗគិតតែពីផ្ទុំ សោយអាហារ សោយក្រយា ជជែកលេង ហើយផ្ទុំទៀត...។

យើងអាចសុំស្រឿងឈើ ឬ ជាងពីក្នុងវាំង ឲ្យទៅជួសជុលផ្ទះ ង៉ុកង-ម្តាយ យើង ដោយគ្មានភ័យព្រួយខ្លាចហួងបដិសេធឡើយ។ ប៉ុន្តែហួងខ្វល់តាមពាក្យសុំហើយ ច្រើនតែថាឲ្យយើងចាំខែក្រោយ ដោយលោកសារភាពប្រាប់តាមត្រង់ថា ខែនេះលោកអត់មានលុយទេ ពីព្រោះមួយខែៗ លោកត្រូវចំណាយច្រើនណាស់

ដើម្បីរៀបចំទទួលភ្ញៀវបាវាំង ដើម្បីជួនវត្តអនុស្សាវរីយ៍ដ៏មានតម្លៃចំពោះគេ...។

កាលណាអង្គុយរកគ្នាជជែកមិនបាន លោកនិយាយប្រាប់យើង ពីរឿងកាលលោកទៅភ្នែង ទៅរៀនឯក្រុងបាងកក ពីរឿងដែលលោកទើបនឹងចេះលេងស្រីជាលើកដំបូង ដោយឆ្លៀតអួតថា ពេលកំពុងពេញកម្លាំង មួយយប់លោកអាចលេងស្រីដប់នាក់ក៏បានដែរ។ ដោយឃើញពួកយើងភ័យធ្វើមុខក្អើ លោកសើចសប្បាយខ្លាំងណាស់។

ល្ងាចមួយនោះ ហួងងើបចេញពីតុសោយក្រយា ដើរក្រឡឹងព័ទ្ធជុំវិញអស់អ្នកអស់ទាងដែលកំពុងអង្គុយផឹកង់បរិភោគបាយនៅលើកន្ទេល ហើយចែកបារីស៊ីហ្គារ័ឲ្យយើងមួយម្នាក់ៗ ព្រមទាំងនិយាយដោយរីករាយមកកាន់យើងថា:

~វ៉ៃ! ពួកភ្នែងៗ អញតាំយក ខេត្តបាត់ដំបង និង ខេត្តអង្គរ[១០] ពីសៀមបានមកវិញហើយ អញទាំងឯទាំងអស់គ្នានៅរាំថ្វាយទេវតារក្សាទីកដី នៃ ខេត្តទាំងពីរនោះម្តង...។

ការធ្វើដំណើរលើកនេះពុំបានធ្វើឲ្យយើងភ្ញាក់ផ្អើលដូចកាលមុនចេញដំណើរទៅស្រុកបាវាំងទេ។ អ្នកដែលធ្លាប់បានធ្វើដំណើរយ៉ាងកំសត់ក្រម ឆ្លងកាត់សមុទ្រធំមិនយល់កោះត្រើយម្តងរួចហើយនោះ វាហាក់ដូចជាថ្នឹកមិនខ្លាច សព្វបើគ្រាន់តែជិះកប៉ាល់ឆ្លងទន្លេមួយប៉ុណ្ណោះទេ ប៉ុន្តែអ្នកឯទៀតដែលស្គាយមិនបានទៅស្គាល់ស្រុកបាវាំង ម្តងណោះក៏ប្រថុយដើរមើលឲ្យស្គាល់ស្រុកទេសនឹងគេដែរ។

ការរៀបចំសម្រាប់ធ្វើដំណើរ ត្រូវចំណាយពេលអស់ជាច្រើនសប្តាហ៍ សោតឯការសេមរបាំ ក៏មានដំណើរប្រព្រឹត្តទៅយ៉ាងសកម្មឡើងវិញដែរ។ យើងម្នាក់ៗ រៀបចំអីវ៉ាន់ប្រើប្រាស់ផ្ទាល់ខ្លួនយ៉ាងផ្ចិតផ្ចង់ក្រៃលែង។ ជាងចិនវេរស្បែកជើងម៉ូតបាវាំងមកឲ្យយើងទាំងកន្ត្រក។ ហើយហួងបង្ខំឲ្យយើងពាក់ស្បែកជើង ពាក់ចិញ្ចៀន ធ្វើខ្លួនឲ្យស្អាតដើម្បីទៅបង្ហួតអ្នកស្រុកបាត់ដំបង។ យើងដឹងថា តែងខ្លួនតាមបញ្ជាហួង វាគ្មានស្អាតត្រង់ណាសោះទេ ឬ វាគាំឲ្យគេពេបជ្រាយវិញផងក៏មិនដឹង។

ពេលរៀបចេញដំណើរទៅណាម្តងៗ វាជួនចំលើតែពេលអត់លុយ ឃាយមែនត្រូវជាសាច់ញាតិនឹងម្ចាស់ក្សត្រី គាត់សម្បូរណ៍លុយណាស់ ឥណាចង់ចងការប៉ុន្មានក៏បាន ប៉ុន្តែទាស់ត្រង់គាត់យកការថ្ងៃពេក។ ខ្ញុំខ្ចីគាត់ហាសិបរៀល ដល់សងវិញ គាត់កាត់យកប្រាក់ខែខ្ញុំអស់ទាំងដប់រៀល ទាល់តែគ្រប់ប្រាំបីខែទើបួចជំពាក់។ ពុកនិងម៉ែ ជួលទូកមួយជិះតាមទៅជាមួយគេឯងដែរ ហើយគេមានតាំយកពួកបំរើប្រុសស្រី ទាហានរក្សាព្រះអង្គ បង្ការព្រែកមានចោរឆ្នូញតាមផ្លូវ ក្រុមហួងពិណពាទ្យ និង ហួងបាវាំង ព្រមទាំងម្ហូបម្ហាស្រប់មុខ មានតាំងពីទឹកម៉ាស៊ីនជាច្រើនពាង ទៅជាមួយផង។

ថ្ងៃមួយ នៃ រដូវវស្សា ហួង និង បិពារទាំងអស់ មានចំនួនច្រើនរយនាក់ ចាកចេញពីវាំង ចុះសំប៉ាន ចុះទូក ដែលចងសណ្តោងទៅនឹងកប៉ាល់ធំមួយ ហើយធ្វើដំណើរចេញទៅ។ ស្តេច និង តាម៉ីនធំៗ សុទ្ធតែមានទូកជិះផ្ទាល់ខ្លួន។ ចំណែកអ្នកណាដែលចង់តាមទៅលេងនឹងគេក្រៅផ្លូវការ ក៏ជួលទូកជិះទៅជាមួយគេដែរ។ អ្នកបំរើ, តាហាន និង អ្នកភ្នែង ជិះប្រជ្រៀតគ្នាលើដំបូលកប៉ាល់ មានជាក់ចង្រ្កានឆ្នាំងគ្រប់គ្រាន់ទាំងអស់។

ក្បួនទូកចេញពីកំពង់ផែ ក្រោមស្នូរស័ព្ទហ៊ោកញ្ជ្រៀវគឹកកង នៃ ហួងប្រជារាស្ត្រ ដែលឈរប្រជ្រៀតគ្នាកកកុញពេញមាត់ទន្លេ ហើយធ្វើដំណើរលឿនស្ទើរឆ្ពោះទៅទន្លេសាប ដោយមានខ្សែទឹកជួយហូរច្រានផង។ ពេលនោះ ព្រលប់ងងឹតខ្លាំងណាស់ទៅហើយ មើលទៅក្រោយខ្នង ឃើញពន្លឺភ្លើងព្រិចៗរាប់ពាន់ នៃ

(១០) ខេត្តសៀមរាប។

ព្រះរាជធានី ចាំងឆ្លុះកណ្តាលផ្ទៃអន្ទការ។

ខ្ញុំជិះលើទីតាំងសក្តិក្រសេម ចាំគាល់បំរើហួងជាមួយអស់អ្នក-អស់ទាង ជាងសែសិបពាក់ ស្រីបំរើម្នាក់ និង ក្រុមាំងម្នាក់ដែលប្រសប់អស្ចារ្យខាងជួសជុលខ្លៅ កងដៃ កងជើង របស់ពួកលោង។ ដើម្បីឲ្យបានការហ៊ុនទៅជាមួយ ខ្ញុំយកវាទៅលាក់ជាមួយអ្នកបំរើ។ ពីក្រោយ និង ពីចំហៀងសង្កាងយើង ឃើញសុទ្ធតែទូកតូច-ធំពាសពេញទន្លេ ហើយបន្តកន្ទុយទៅជិងឆ្ងាយស្ទើរផុតកន្ទុយភ្នែក។ ទូកតម្រៀបជិតៗគ្នាល្អណាស់ គេអាចដើរឆ្លងពីមួយទៅមួយបានយ៉ាងស្រួល។

នៅលើទីតាំងសក្តិក្រសេម ហួងកំពុងសម្ងំផ្តុំក្នុងបន្ទប់ធំជាងគេ។ អស់អ្នក-អស់ទាង ដេកប្រគាក់ប្រគងលើគ្នាក្នុងមុងធំៗដែលចងលាតសន្ធឹងនៅកណ្តាលកប៉ាល់ ខ្លះដេកលក់ ខ្លះនៅនិយាយជជែកគ្នាខ្សិបខ្សាវនៅឡើយ។ ខ្ញុំអង្គុយក្រៅមុងសម្លឹងមើលទៅត្រាំង ឃើញខ្មៅខុងក្រោមផ្ទៃមេឃស្រឡះល្អល្អើ មានពពកឯណោះមួយចុំ ឯណោះមួយចុំ... យូរៗម្តង ស៊ីជីកកប៉ាល់បន្តិចឡើងជាសញ្ញាប្រាប់ឲ្យទូកដែលកំពុងធ្វើដំណើរឆ្លងកាត់ទន្លេ ចៀសចេញពីផ្លូវយើង។

យើងឆ្លងហួសអន្លង់រាជ ដែលជាកន្លែងលាក់ខ្លួនពួនអាត្មា នៃ ត្រីធំៗប៉ុនខ្លួនមនុស្ស... សម្លេងមាន់រងាវរសាត់តាមរលកទឹកពីខាងលិចភ្នំវ៉ុតដ្ត មកប៉ះនឹងត្រចៀកយើងឮល្វើយៗតួរ ស្រងេះស្រងោចក្នុងចិត្តវៃក្រៃលែង។

ធាតុអាកាសត្រជាក់ខ្លាំងណាស់! ម្ខសហើរប្រណាំងនឹងទូកតាមខាំយើងជាប់ហួត មានតែផ្សែងបារីរេដែលអាចបណ្តេញវាបាន។ ខ្ញុំជីកមុងចូលទៅប្រះដេក ដើម្បីយកកម្លាំងទុកសំរាប់ចូលវេនគាល់បំរើហួងនៅពេលព្រឹកស្អែក។ ក្រោមពន្លឺចង្កៀងប្រទីប ខ្ញុំឃើញពួកស្រីៗដេករង្គុកវណែលប្រជ្រៀតគ្នា។ ល្វេនកេះក្បួយដៃខ្ញុំ ហើយឱបប្រាប់ឲ្យខ្ញុំមើលទៅកៀនក្បែរបន្ទប់ហួងតង់។ ខ្ញុំពិនិត្យមើលយូរណាស់ នៅតែមិនស្គាល់ថាជានរណា ឃើញតែស្រីពីរនាក់ រមួតអាវ រមួតសាវុង ចេញអស់ពីខ្លួនស្រាតទទេល កំពុងនុបីតគ្នា អង្អែលដោះ អង្អែលក្តិតគ្នា។

~ ល្វេន! ល្វេន! (ខ្ញុំនិយាយតិចៗ) ពួកវាធ្វើអីហ្នឹង?

~ កុំមាត់! ទុកឲ្យគេធ្វើអីក៏ធ្វើទៅ (ល្វេនធ្លើយតបមកវិញ) សាវ៉ាម៉ាឌីឯង មើលមិនស្គាល់ទៅហ្ន៎? មីយ៉ាន និយាយនិង បងវ៉ា កំពុងលេងគ្នាណា!... ។

ស្អែកឡើងយើងមកដល់កំពង់ឆ្នាំង។ ខ្ញុំខាងមកឃើញស្រុកនេះ ច្រាំ ឬ ច្រាំមួយ ឆ្នាំហើយ ប៉ុន្តែហាក់ដូចជាគ្មានឃើញប្លែកត្រង់ណាសោះ ចម្លែកតែត្រង់មានដោតទង់ជ័យនៅតាមមាត់ផែ មានទាំមីនរាជការ និង មនុស្សច្រើនកុះករ មកឈរចាំទទួលហួងប៉ុណ្ណោះ។ ក្រុមហួងអ្នកស្រុកកំពង់ឆ្នាំង ចាប់ប្រគុំសំដែងពរស្វាគមន៍ថ្វាយហួង ហើយក្រុមហួងវិញក៏ប្រគុំឆ្លើយតបវិញយ៉ាងសប្បាយរីករាយ។ នៅលើផែមានបាវាំងរាងក្មេងម្នាក់ ឈរនិយាយឆ្គាដៃឆ្គាជើងជាមួយចីបករបស់ហួង។ ពួកយើងដណ្តើមគ្នាមើលបាវាំងនោះចំហមាត់ ពីព្រោះមានអ្នកខ្លះនិយាយថា ដូចជាធ្លាប់ឃើញតាត់នេះម្តងនៅឯស្រុកម៉ាស៊ី ប៉ុន្តែខ្ញុំយល់ច្បាស់ថា នេះគ្រាន់តែជាបូកមាយាធ្វើឲ្យគេភោតថា វាធ្លាប់បានទៅស្គាល់ស្រុកបាវាំងតែប៉ុណ្ណោះ។ ពួកវាស្មៀកពាក់អញ្ចឹង ដើម្បីបង្ហួតអ្នកស្រុកឲ្យគេភោតវា ប៉ុន្តែខ្ញុំយល់ថា សម្លៀកបំពាក់នេះពុំមែនជាការសមរម្យទាល់តែសោះ ហើយវាថែមទាំងអាចធ្វើឲ្យគេមានគំនិតយល់ឃើញមិនល្អ ចំពោះស្រីក្នុងវាំងទៀតផង។

ហួសពីកំពង់ឆ្នាំងទៅ កប៉ាល់អត់មានតាមសណ្តោងទៀតទេ គឺយើងត្រូវបន្តដំណើរដោយចែវនឹងដៃ

ម្តង។ នៅត្រង់កន្លែងចូលទៅកាន់បឹងធំ មានភ្នំអមសង្កាង ហើយភ្នំដែលនៅខាងកើតនោះឈ្មោះថាភ្នំទាងកង្រី។

គ្រាន់តែទៅដល់ជើងព្រៃភ្នាម ក្បួនទូកបំបែកគ្នាចេញអស់។ ពួកម៉ាឡាយូមានរមាំ ជួតក្បាលក្រហមឈរពីមុខពីក្រោយទូក ចែវស្រុះគ្នាដោយស្រែកច្រៀងបន្តរចង្វាក់ជាភាសាសាសន៍គេថា "ហៃអើម៉ាអ៊ីរ៉ុំ" ញាំងទូករាប់រយឲ្យលឿនទៅមុខ តាមចន្លោះដើមឈើលិចដល់ម៉ែកដោយសារទឹកជំនន់ នៃ ទន្លេសាប។

យើងធ្វើដំណើរតាមទិសខាងជើង ជីកផ្លូវកាត់ព្រៃលិចទឹក នៃ ខេត្ត ស្ទោង ជីក្រែង និង សៀមរាប... ដំណើរនេះប្រព្រឹត្តទៅអស់រយៈពេលជាច្រើនថ្ងៃ ហើយពីមួយថ្ងៃទៅមួយថ្ងៃ យើងកាន់តែរំកិលចូលជ្រៅឡើងៗ ទៅក្នុងបរិវេណ នៃ ទន្លេសាប។

ហួងគិតតែសោយអាហារ ចាក់ម៉ាស៊ីនច្រៀងស្តាប់ សើចលេងជាមួយស្រីអ្នកគាល់បំរើ។ ជួនកាលលោកចេញមកក្រៅបន្ទប់ ស្មៀកសាវុងសំយេះហួសដង្ហិត ពួកម៉ាឡាយូអ្នកចែវទូក នុនមុខ ឬ ងាកមុខចេញមិនហ៊ានមើលដោយក្តីអៀនខ្មាស។ ប៉ុន្តែដល់ឃើញគេអៀនខ្មាសមិនហ៊ានមើលអាកប្បកិរិយាអាក៉ាបូករបស់ខ្លួនយ៉ាងនេះ ហួងបែរជាសើចសប្បាយទៅវិញ។

ខ្យល់បក់មកមួយរឹប បណ្តាលឲ្យក្បួនទូកឈ្លងឈ្លោង ញាំងអ្នកដំណើរឲ្យភ័យញើរញើរ ប្រញាប់ស្រូត្បដំណើរឲ្យឆាប់បានដល់ដើមឈើណាមួយ គ្រាន់ទឹងទីពឹងជាបណ្តោះអាសន្នសិន។ អស់អ្នក-អស់ទាងយំសស្រាក់ រត់ទៅនុបជើងហួងឲ្យជួយ ប៉ុន្តែឲ្យលោកធ្វើម៉េច បើលោកកំពុងតែភ័យក្នែកនៅកញ្ចឹងកវែរ។ មីស្នាត វាក្តួតចាក់ទឹងហ៊ឹងហោង អ្នកខ្លះទៀតធ្លាក់ខ្លួនឈើដោយធឹកទឹកមិនស្នាត ពីព្រោះទូកអ្នកចុងភៅ ធ្វើដំណើរមិនដែលខាន់គេទេ។

មកដល់កន្លែង មានដើមឈើច្រើនគួរសម ហួងបែរបង្ហួចជាអន់ភ័យបន្តិច ក៏តាំងប្រែកដេរបញ្ជោរអ្នកធ្វើបាយ ដែលចង់បង្គត់ក្ងូនចៅលោក ឲ្យងាប់ពោះស្លាប់។ នៅទីបញ្ចប់ យើងបានមកឃើញដីគោកមួយកន្លែង គេក៏ផ្ទុំត្រែហៅប្រមូល ទូកទាំងអស់ ឲ្យមកជួតជុំសំរាកនៅកន្លែងនេះ សិន។

ត្រង់កន្លែងឆ្នេរខ្សាច់ដែលយើងចុះចតនេះ យើងអាចមើលទៅគ្រប់ទិស ឮានទើសពាក់អ្វីទាំងអស់។ នៅខាងត្បូងហួសឆ្ងាយពីបឹងទន្លេសាបទៅទៀត ខ្ញុំឃើញភ្នំពេធ៌សាត់ និង ភ្នំក្រវាញ ហើយមានរណាម្នាក់ឡើងលើដំបូលទូកមើលទៅខាងជើងឯណោះ ឃើញរហូតដល់ទៅភ្នំតូលែន។

មិនបានប៉ុន្មានម៉ោងផង ទីដែលធ្លាប់តែស្ងាត់ជ្រងំគ្មានមនុស្សរស់នៅសោះ បានក្លាយទៅជាប្លីហួងអ្វីអស្ចារ្យណាក្រៃលែង។ អ្នកចុងភៅ និង ចោយ ធ្វើការញាប់ដៃជើង រហូតដល់ហួង និង អស់អ្នក-អស់ទាងបានសោយ និង បរិភោគ យ៉ាងឆាប់ទាន់ចិត្ត។ ក្រោយពេលបាយ ហួងចែកលុយឲ្យយើងប្រាំរៀលម្នាក់ ដើម្បីលេងបៀថ្វាយលោកឧត្តមឲ្យសប្បាយភ្នែកម្តង។ ខ្ញុំមិនចេះលេងបៀទឹងគេ គិតថាទុកលុយនេះសម្រាប់ទិញទំបិរភោគនៅពេលធ្វើដំណើរទៅដល់ផែខាងមុខ ប៉ុន្តែហួងមិនព្រមឲ្យខ្ញុំទុកលុយទេ លោកកំញើញថាបើខ្ញុំមិនលេងបៀ លោកយកលុយវិញឥឡូវហ្នឹង។ ជាសំណាងល្អ កំពុងតែនិយាយ ស្រាប់តែទូកម្ចាស់ក្បត្រីមកដល់ ហើយហួងវល់តែបែរទៅគិតប្លីងថ្មី ឮចប្លីងខ្ញុំសួរឲ្យឈឺ។

ចាប់តាំងពីពេលទើបទឹងចេញពីភ្នំពេញមក ម្ចាស់ក្បត្រីបានខិតខំខ្លាំងណាស់ ដើម្បីឲ្យមីសួន ជាកូនយសម្លាញ់ចិត្តរបស់លោក បានជិះលើទីតាំងជាមួយហួង ដើម្បីប្រជែងយកឈ្នះខ្ញុំ ប៉ុន្តែមិនបានសំរេច ទើបតែពេលនេះ ដែលទូកទាំងពីរចូលមកកៀកគ្នា ម្ចាស់ក្បត្រីក៏ថ្វាយបង្គំហួង ហើយនិយាយថា:

~ ក្រាបទូល, ខ្ញុំម្ចាស់យល់សប្តិឃើញខ្មោចម្តាយខ្ញុំម្ចាស់មកប្រាប់ថា គាត់មកចាប់ជាតិជាទាងសួន

ហើយ សុំឲ្យព្រះករុណាជួយមើលខុសត្រូវឲ្យបានស្រួលបួលផង ។

នេះជាពាក្យប្រឹងតយ៉ាងស្មាត់ជំនាញ ដើម្បីឲ្យ មីសួន បានចូលមកតាល់បំរើហួង និងអាលឆាប់បានតាប់តួរ ហើយវាក៏ជាកន្តាមួយបង្ហាញឲ្យឃើញនូវលក្ខណៈទន់ខ្សោយ នៃ ចិត្តរបស់ហួង ដែលបណ្តាយខ្លួនឲ្យគេប្រើល្បិចបោកបញ្ឆោតបានយ៉ាងងាយ ។

~ ហា! ហា! (ហួងសើចសប្បាយ) វ៉ែម, ក្មួនឯងយល់សប្តិឃើញអញ្ចឹងហ្ល៎ ? អញក៏ធ្លាប់យល់សប្តិឃើញផ្ទួចគ្នាបេះបិទអញ្ចឹងម្តងដែរ ។ ឯណា ទាងសួន, ឲ្យវាឡើងមកលើទូកអញមក៏, វាធំល្មមប្រើប្រាស់បានហើយ មែនទេ ?

ប៉ុន្តែដោយហេតុថ្ងៃនោះ ទីតាំងហួងចង្អៀតខ្លាំងពេក លោកក៏បញ្ជូនមីសួន ឲ្យត្រឡប់ទៅជិះទូកជាមួយម្ចាស់ក្បត្រីវិញ ដែលជាហេតុធ្វើឲ្យម្ចាស់ក្បត្រីក្តៅក្រហាយក្រៃលែង ប៉ុន្តែលោកពុំមែនអស់សង្ឃឹមត្រឹមនេះទេ ។ ពេលនេះជាឱកាសល្អ គួរណាស់តែខ្ញុំធ្វើតយកតាប់នឹងហួងឲ្យបានមុនមីសួន ប៉ុន្តែខ្ញុំឥតទីកឃើញធ្វើអញ្ចឹងសោះ ពីព្រោះតែកាលណាទីកដល់ហ្ម៎ឹង មីស៊ុន មីវ៉ែន និង ស៊ីម៉ាឌ្យា ខ្ញុំចេះតែភ័យខ្លាចហួងស្តើមិនហ៊ានដើរជិតផង ។

នៅលើទូកមួយផ្សេងទៀត គេនាំគ្នាសើចលេងសប្បាយនឹងឆាកស្នេហារវាង ម្ចាស់ផ្ទះមធុរា និង ម្ចាស់ក្បត្រីសីរីវង្ស ។ ម្ចាស់ផ្ទះមធុរា អង្គុយលើទូកស្រែកហៅម្ចាស់ក្បត្រីសីរីវង្ស ដែលកំពុងអង្គុយលើដីខ្សាច់មាត់ទន្លេ សុទ្ធតែប្រើពាក្យអូសបន្ទះ ដើម្បីឲ្យឡើងមកផ្តុំជាមួយលោកលើទូក ។ ម្ចាស់ក្បត្រីខ្មាសគេក៏ស្រែកឃាំហើយអ្នកឈរមើលទាំងអស់គ្នាសើចគិលឡើង ដើម្បីលើកដើងម្ចាស់មធុរា ព្រោះនរណាក៏ដឹងដែរពីការទាក់ទងរវាងអ្នកទាំងពីរ ។ បន្តិចក្រោយមក ម្ចាស់ក្បត្រីសីរីវង្ស ក៏សុខចិត្តឡើងទៅតាមទូសង្ឃារ ហើយបណ្តើរគ្នាចូលទៅក្នុងបន្ទប់លើកប៉ាល់សម្ងំឈឹង... ។

រាជការស្រុកបានទទួលដំណឹងថា ហួងយាងមកដល់មណ្ឌលខ្លួន ក៏នាំយកម្ហូបអាហារជាច្រើនមកថ្វាយសម្រាប់ទុកធ្វើជាស្បៀងបន្តទៀត ។ ហួងចែកសាច់ផ្រកឲ្យពួកម៉ាឡាយូអ្នកចែវទូកគ្រប់គ្នា ប៉ុន្តែទោះបីអស់កម្លាំងឃ្លានយ៉ាងណា ក៏គ្នាមិនហ៊ានបរិភោគដែរ ពីព្រោះសាសនាអ៊ីស្លាមហាមផ្តាច់មិនឲ្យបរិភោគសាច់ផ្រកទេ... ។

ស្អែកឡើងដល់រសៀល ក្បួនទូកយើងមកដល់ បឹងកន្ទាយកុំ និង ចំការតាយ៉ែម ស្ថិតនៅត្រង់ផ្លូវបំបែកទៅកាន់សៀមរាប ។

នៅកណ្តាលទីព្រៃលិចទឹក មានភ្នំថ្មមួយដុះលេចឡើងខ្ពស់ផុតពីទឹកប្រៀបបានដូចកោះ ប្រកបទៅដោយដើមឈើដុះ ឯណោះមួយគុំ ឯណោះមួយគុំ ។ ក្បួនទូកបន្តធ្វើដំណើរតាមជើងព្រៃ ផ្អើលអស់សត្វបក្សាបក្សី, ហួងដើរចេញពីបន្ទប់ ហើយនិយាយថា :

~ នោះ ពួកកែវកីគេមកទទួលយើងហើយ! ។

ពួកកែវកី គឺជាក្មេងស្រីក្មួនអ្នកស្រុកសៀមរាបច្រើនរយនាក់ជិះលើទូកងជើងៗ ហើយចែវប្រណាំងគ្នាល្បឿនស្មើ តម្រង់មកចំយើង ។ លុះចូលមកដល់ជិតគ្នាមែនទែន ខ្ញុំអាចមើលឃើញពួកនោះ មានរង្វង់មុខមូល ជាត់ម្សៅសក្សស ចងផ្កាព្យួរតែងតោងនៅនឹងត្រចៀក ហើយស្រែកច្រៀងបន្ទះទំនុកខ្លីរបំពងព្រៃ ។ អស់អ្នក-អស់នាងនៅលើទូកម្ចាស់ក្បត្រីអត្តតារី ស្រែកច្រៀងតទៅវិញយ៉ាងសប្បាយរីករាយ ។ បន្ទាប់មកសម្លេងចម្រៀងបទសក្រវាឌីលាន់ឮឡើងពីត្រប់ទូក ហើយក្បួនទូកក៏កាន់តែរសាត់ចូលទៅជិតច្រាំងណាស់ហើយដែរ... ។ ពេលនោះយប់ងងឹតបន្តិចទៅហើយ ក្រុមហួងពិណាពាទ្យនៅនឹងជើងភ្នំក្រោម ចាប់ប្រគំ

ទទួលដំណើរហួង យ៉ាងស្រងេះស្រងោច ។

ខ្ញុំដល់ជួនចូលតាប់បំរើហួងជាមួយអស់អ្នក-អស់នាង នៃ ជួនទីបួន ។ យប់នោះ ខ្ញុំថ្វាយខ្សៀអាហ៊ួនឲ្យហួងសោយអស់ប្រហែលសាមសិបខ្សៀ ហើយដៃគូខ្ញុំនៅខាងម្ខាងទៀតនោះ ក៏បានថ្វាយសាមសិបខ្សៀដែរ... ។ ហួងសម្លឹងផ្តុំលក់ យើងក៏ថយចូលមកដេកក្នុងមុងធំ ត្រចៀកប្រុងស្តាប់ជាទិច្ច ក្រែងលោកត្រូវការប្រើប្រាស់អ្វីទៀត ។ ស្អែកឡើងហួងសម្រេចថា ចាំត្រឡប់មកពី បាត់ដំបងវិញ សឹមធ្វើងចូលទៅអង្គរ ហើយយើងក៏ចាកចេញពីដីច្រាំង សៀមរាប ទាំងស្តាយស្រណោះ ដើម្បីបន្តដំណើរដ៏គួរឲ្យធុញទ្រាន់នេះទៅមុខទៀត ។ អ្នកខ្លះបានឡើងទៅដល់កំពូលភ្នំក្រោម គេនិយាយប្រាប់ថា ពីលើកំពូលភ្នំ គេអាចមើលឃើញផ្ទៃទន្លេសាបទាំងមូល ហើយនៅខាងជើងឯណោះ គេមើលឃើញកំពូលប្រាំ នៃ ប្រាសាទអង្គរវត្ត លូតខ្ពស់ហួសព្រៃព្រឹក្សា... ។

ស្ទឹងសង្កែ ជាដៃទន្លេធំមួយ ហូរកាត់ភូមិស្រុកមានមនុស្សអ្វីអរ ជួនកាលយើងប្រទះឃើញមានវត្តអារាមនៅជាប់នឹងមាត់ស្ទឹងទៀតផង ។ នៅក្រុងបាត់ដំបង ផ្ទះលោក ផ៉ាកាថាថន អតីតចៅហ្វាយខេត្តសៀម ល្អលើសគេទាំងអស់ ប៉ុន្តែសព្វថ្ងៃនេះលោក កាថាថន ត្រឡប់ទៅនៅឯស្រុកសៀមវិញបាត់ទៅហើយ ។

ពេលក្បួនទូកធ្វើដំណើរចូលមកដល់ទីក្រុង គេមានបាញ់កាំភ្លើងទទួលអបអរសាទរ ទាម៉ឺន បាវ៉ាំង និង សៀម ព្រមទាំង ទាហាន និង ប្រជាពលរដ្ឋ ច្រើនកុះករមកឈរឆ្ងាំសំដែងគារវកិច្ចចំពោះហួង ... ។

គេរៀបចំធ្វើបុណ្យលេងសប្បាយច្រើនថ្ងៃណាស់ ។ ខ្ញុំត្រូវរាំជូនទស្សនិកជនមើលកំសាន្តពីរថ្ងៃជាប់គ្នាហើយបន្ទាប់មក ត្រូវទៅរាំជូនសួងវត្តសក្តិសិទ្ធិ ទៅឯប្រាសាទបាក់បែកណាមួយនោះ ដែលគេនិយាយថាប្រកបទៅដោយគ្រោះថ្នាក់សម្បើមណាស់ ។ ណាមួយខ្លាច ណាមួយអស់កម្លាំង ខ្ញុំក៏ប្រកែកមិនព្រមទៅរាំនៅទីនោះ ប៉ុន្តែមីពួកម៉ាកខ្ញុំដែលទៅរាំតាំងប៉ុន្មាន វាត្រឡប់មកវិញសុខសប្បាយទាំងអស់គ្នា ។

យើងដើរមើលសព្វកន្លែកទៀតក្នុងខេត្ត បាត់ដំបង មើលតាំងពីផ្ទះលោកចៅហ្វាយខេត្តសៀម ដែលគេកំពុងសង់ និង វត្តដ៏រស មើលអ្វីៗទាំងអស់ដែលយើងចង់ឃើញ ។ ស្រីស្រុក បាត់ដំបង ភាគច្រើនស្អាតៗណាស់ ស្អាតជាងអ្នកភ្នំពេញទៅទៀត ។ លើសពីរបស់ហវដែលអ្នកស្រុកនាំយកមកថ្វាយហួង គេមានថ្វាយស្រីក្រមុំបីទាក់ឈ្មោះ ស្រួយ, ទួន និង ព្រិល សម្រាប់ធ្វើជាស្នំ ដែលហួងទទួលឲ្យជិះលើទូកជាមួយអ្នកម្នាងម្ជិះ ។ ពួកវាមិនអាក្រក់ ប៉ុន្តែក៏មិនស្អាតណាស់ណាដែរ ហើយវានិយាយខ្មែរងងឹង ស្តាប់គួរឲ្យចង់សើច ។

ពុកទិញបាន ទឹកដោះគោកំប៉ុង ទំប៉ុង និង ត្រីខប្រអប់ ពីផ្ទះចិនឯផ្សារយកមកផ្ញើខ្ញុំ ប៉ុន្តែមីពួកម៉ាកអត់ឃ្លានជាច់ជាបអស់ហ្ម៎ឹង វាជណ្តើមស៊ីអស់ ខ្ញុំគ្មានបានលេបមួយម៉ាត់ទេ ។

ក្រោយពេលដែលធ្វើបុណ្យនៅនឹងខេត្ត បាត់ដំបង ចប់សព្វគ្រប់ហើយ យើងក៏ធ្វើដំណើរត្រឡប់មកសៀមរាបវិញ វាងតាមចុងខាងលិចបឹងធំ ហើយបត់ក្បាលតំរង់ទៅរកប្រាសាទអង្គរវត្ត ។

ខ្ញុំមិនដែលឃើញស្រុកណាល្អដូចស្រុកនេះទេ! ទឹកស្ទឹងថ្លាឆ្វង់ហូរចាក់ពីភ្នំតូលែនមក ទោះបីក្នុងរដូវស្ងួតមានភ្លៀងធ្លាក់ច្រើនយ៉ាងណា ក៏ទឹកឡើងមិនហួសត្រាំងដែលមានស្មៅលាស់ខៀវខ្ចីក្រោមម្លប់ដ៏សែនសុខុម នៃ ដើមត្នោត ដើមផ្លុង និង ដើមស្វា ។

នៅលើត្រាំង រនេះគោបរទៅមុខលាន់ង៉ែតង៉ែត... តាមបណ្តោយដងស្ទឹងដ៏មានមនុស្សរស់នៅកុះករដូចទៅបាត់ដំបងដែរ ។ អ្នកស្រុកស្លៀកពាក់ស្អាតបាត ទាំងលុតជង្គង់ថ្វាយបង្គំទីតាំងហួង ខ្លះរត់ដើម្បីទៅឲ្យបានដល់ភូមិដែលស្ថិតនៅពាក់កណ្តាលផ្លូវទៅអង្គរនោះ មុនយើង ។

ដល់កន្លែងណាក៏មែនទែនពុំអាចចែវកើត គេក៏ចាប់អ្នកស្រុកឲ្យចុះទៅក្នុងទឹកត្រឹមដើមទ្រូង ដើម្បីអូសទូកឡើងទៅលើ បញ្ហាសម្រាប់ទឹកហូរ។ យើងប្រញាប់ប្រញាល់រៀបចំស្មៀកពាក់ ស្មានថាជិតដល់ហើយ ប៉ុន្តែតាមពិត យើងត្រូវធ្វើដំណើរយឺតៗបែបនេះអស់រយៈពេលជាច្រើនម៉ោង។ មិនដឹងជាចង្រៃអី ខ្ញុំស្រាប់តែឈឺនោម រាន់ចង់លេចស្ទើរទ្រាំខ្លាប់មិនជាប់។ កន្លែងបង្គន់នោះ គឺជាធុងឈើមួយមានចោះប្រហោង ជាក់ចងជាប់នឹងចង្កេះទូក លយចេញទៅលើទឹក។ តាមប្រហោងបង្គន់ គេអាចមើលឃើញក្បាលអ្នកអូសទូកច្បាស់ក្រឡែត ហើយបើខ្ញុំចូលទៅបត់ជើងក្នុងហ្នឹង គេងើយមើលពីក្រោមមក ក៏ឃើញច្បាស់ក្រឡែតដូចគ្នា។ ខ្ញុំខំទ្រាំអត់ចង់ខ្សល់ចាប់ នៅតែរកមធ្យោបាយដោះស្រាយមិនឈប។ ម៉ែអូន ម្ដីងម៉ាត់ណាស់ មើលឃើញទឹកមុខខ្ញុំបែបមិនស្រួល គាត់យល់ការទាំងអស់ ក៏ផ្ដល់យោបល់ដ៏ល្អមួយ នៅខាងក្រោយទូក គេមានរៀបចំកន្លែងមុជទឹក ខ្ញុំផ្ទាស់សាវុងចាស់ ស្រោចទឹកលើខ្លួនធ្វើដូចជាងូតទឹក បន្ទំនោមបានយ៉ាងស្រួល គ្មានរណាចាប់ភ្លឹកសង្ស័យទេ។

ប៉ុន្តែ ម៉ែអូនខ្លួនឯង កំពុងកើតទុក្ខធ្ងន់ជាងខ្ញុំទៅទៀត គឺគាត់ឈឺជុំអាចម៍។ គាត់ឆ្លៀតច្រាសច្រាលដូចមានរកពង រកកន្លែងដោះខាល់មិនបានសោះ។ គាត់ចូលទៅក្នុងបន្ទប់ហួងបាត់មួយសន្ទុះ ទើបឃើញចេញមកវិញ មានកាន់ទាំងប្រអប់ក្រដាសទទេមួយដែលគេចំណាំដាក់បារីស៊ីហ្គារ៍ មកជាមួយផង។ គាត់ខ្សឹបប្រាប់ខ្ញុំថា:

~ កុំទៅឆ្ងួត ពួកឯទៀតគេនោមពាសណាពាសណីដូចតែគ្នាហ្នឹង!

គាត់ចូលទៅក្នុងបន្ទប់ លើកចំហរប្រអប់ដាក់លើប្រហោងបង្គន់ ដើម្បីដោះខាល់បានយ៉ាងស្រួល។ រួចហើយគាត់បិទប្រអប់វិញយ៉ាងស្អាត ទើបបោះចោលតាមប្រហោងទៅក្នុងទឹក ប្រអប់នោះអណ្ដែតស្ទឹងបញ្ចិតស្មាពួកអ្នករុញទូក ប៉ុន្តែគេចាប់មិនបាន វាចេះតែសាត់ចេញទៅដល់ក្បែរទូកមួយទៀត។ ម៉ែអូនកាន់ផ្ដិលទឹកឈរជិតខ្ញុំ មុខញញឹមពព្រាយតាមមើលប្រអប់។ បន្ដិចក្រោយមក ពួករុញទូកខាងក្រោយចាប់បានស្មានថាប្រអប់បារីល្អ បើកមើលយ៉ាងរហ័ស ដល់ឃើញសុទ្ធតែអាចម៍ ក៏ធ្វើមុខជូរហួញ គ្រវាត់ចោលព្រួស។ ម៉ែអូន និង ខ្ញុំ ញាំគ្នាសើចស្ទើរឆ្កែងពោះ...។

បន្ដិចក្រោយមក ស្ទឹងប្រែជារួមទូចទៅៗ... នៅពីមុខអតីតជម្រកនៃ លោកចៅហ្វាយខេត្តសៀមមន្ត្រីបាក់រឹង, សៀម និង ខ្មែរ ញាំគ្នាមកឈរវង់ចាំទទួលហួងយ៉ាងច្រើនកុះករ។

គេសង់ឆាងរបាំក្បែរផ្ទះថ្មមួយ ដែលមានដាក់កាំភ្លើងធំយោធប្រចាំការនៅជុំវិញ ប៉ុន្តែមុនទីឆាងរាំឲ្យអ្នកស្រុកសៀមរាបមើលលេងកំសាន្ត ហួងបានបញ្ជាឲ្យយើងទៅរាំបួងសួងថ្វាយវត្តសក្តិសិទ្ធិឯអង្គរវត្ត ជាមុនសិន។

យើងនាំគ្នាចេញដំណើរទៅកាន់ប្រាសាទបាក់បែកនោះតាំងពីព្រលឹមស្រាងៗ... ពួកក្មេងតូចៗភ័យខ្លាចគេមិនឲ្យទៅមើលអង្គរវត្ត ភាំខំយំស្រែកតាមអង្វរម្ចាស់ក្បត្រីខ្លាំងណាស់ ទម្រាំលោកព្រមយកវាទៅជាមួយ។

រទេះគោ រទេះក្របី តម្រៀបបន្ដកន្ទុយគ្នា ជិងអន្លាយតាមបណ្ដោយដងស្ទឹង លើផ្លូវដ៏មានដើមឈើជុំវិញអមសង្កាត់ ចោលជាម្ចប់ត្រជាក់ស្រួលក្រៃលែង។ អ្នកស្រុកម្ចាស់រទេះចិត្តបានណាស់ គាត់សុខចិត្តដើរជើងទទេអូសគោពីមុខ ដើម្បីទុកកន្លែងទូលាយឲ្យយើងបានអង្គុយស្រួល។ ប៉ុន្តែទោះជាយ៉ាងណា ក៏វានៅតែចង្អៀតដដែល ពីព្រោះក្នុងមួយរទេះ យើងត្រូវជិះប្រជ្រៀតគ្នាដល់ទៅបីឬបួនទាក់ឯណោះ។ អ្នកចែមជើងកំប្លែង យកជន្ធញចាក់ក្ដិតគោ បណ្ដាលឲ្យវាផ្ដើលស្ទុះរត់ត្រណាត់ត្រណែង ខ្ញុំអង្គុយពីក្រោយខ្នងគាត់ជាមួយអ្នករាំម្នាក់ទៀត រលាក់ក្រឡុកស្ទើរបែកថ្ពើមប្រមាត់។ ហួងមិនទាន់ចេញដំណើរមកទេ លោកចាំយាងមកតាមក្រោយជាមួយពួកទាម៉ឺនសព្វមុខមន្ត្រី។ ចំណែកខោអាវសម្រាប់ស្មៀកពាក់រាំនោះវិញ គេដឹកផ្សេង យើងពាក់ជាប់នឹងខ្លួនតែគ្រឿងអលង្ការបន្ដិចបន្ដួចប៉ុណ្ណោះ។

ក្បួនរទេះធ្វើដំណើរទៅមុខយឺតៗ... ស្ងរភ្លៅរទេះសង្កៀតគ្នាលាន់ ង៉ើត... ង៉ើត... ៗ... ហ៊ឹងត្រចៀកហើយកង់រទេះនោះទៀតសោត ម្ដងទៅធ្វេង ម្ដងទៅស្ដាំ យោលប្រៀបបាន៥ឹងជិះទូកយ៉ាងនោះដែរ។ មួយសន្ទុះក្រោយមក ផ្លូវបែកចេញពីមាត់ស្ទឹង មើលលែងឃើញ ច្បារដំណាំ និង ផ្ទះសម្បែងអ្នកស្រុក អ្វីទាំងអស់ ឃើញតែព្រៃស្រោងស្រឹងស្ងាត់ជ្រងំ ហាក់ដូចជារ៉ាំដែលមានមនុស្សដើរទៅមកកាត់តាមនេះឡើយ។

បន្ទាប់មក ផ្លូវរទេះត្រូវឆ្លងកាត់គ្រហុកដីជាច្រើនកន្លែង ហើយរំពេចនោះ យើងស្រែកភ្ញាក់មាត់ស្រុះគ្នាទាំងអស់:

~ យី, មើលន៎! មើលឯនោះន៎!

ព្រមទាំងលើកដៃចង្អុលទៅទិសខាងកើត ដែលបង្ហាញទិដ្ឋភាពដ៏ល្អត្រកាលក្រោមផ្ទៃមេឃក្រហមព្រឿងៗនាពេលព្រឹកព្រហាម។ នៅចំងាយប្រហែលម្ដែដំហានពីផ្លូវ យើងឃើញផ្ទុំថ្មពណ៌ទ្មៅប្រផេះ ព័ទ្ធព័ន្ធទៅដោយវល្លិ៍ និង ស្មៃ ជាក់ឥរម្រៀបគ្នាទៅសង្កាងផ្លូវ កន្លែងខ្លះបាក់បែកធ្លាក់ទៅក្នុងអន្លង់ទឹកដ៏ជ្រៅ ដែលគេជីកពីក្រោម។ អន្លង់នេះគ្រាន់តែទទឹងប្រជិងសឹងប៉ុនទន្លេ ប្រកបទៅដោយទឹកនឹងថ្ពល់ មានផ្កាឈូក និង ភីរជាតិដ៏ខៃទៀត ផុះផេះផាសពីលើ បង្កើតបានជាកម្រាលធម្មជាតិមួយបែបដ៏ប្រណិតក្រៃលែង។

នៅច្រាំងខាងម្ខាងឯណោះ រីតតែល្អជាងនេះទៅទៀត កំពែងថ្មលាតសន្ធឹងកាត់ព្រៃ សសរ និង ក្លោងទ្វារធំៗ មានបន្ដបកំពូលថ្មពីលើ ចាំងឆ្លុះច្បាស់ក្រឡែតពីលើផ្ទៃទឹក ប៉ុន្តែកំពូលថ្មាំងនេះបាក់បែកស្ទើរតែទាំងអស់ទៅហើយ ឃើញតែផ្ទុំថ្មរលួតធ្លាក់មកនៅរាយពាសពេញដី។ បន្ទាប់ពីកំផែងនេះទៅឆ្ងាយជ្រៅខាងក្នុង មានភ្នំថ្មមួយប្រកបដោយកំពូលជ្រាំបន្ដបពីលើ កំពូលបួនទៅគ្រប់ជ្រុងទាំងបួន និង កំពូលកណ្ដាលខ្ពស់ជាងគេ លេចត្រដែតហួសអស់ព្រៃព្រឹក្សាហើយទៅគង់វង់ទាំងអស់ ឥតមានឃើញបាក់បែកត្រង់ណាទេ។

ស្ងរទេះស្ងាត់ទៅវិញម្ដងមួយៗជាបន្ដបន្ទាប់គ្នា... ក្បួនរទេះឈប់តកន្ទុយគ្នាជិងអន្លាយតាមបណ្ដោយមាត់ប្រឡាយទឹកព័ទ្ធជុំវិញអង្គរ ដែលមានស្ពានថ្មធំទូលាយនៅចំកណ្ដាល សម្រាប់ឆ្លងពីម្ខាងទៅម្ខាង។ រូបសិល្បៈពីរបាក់បែកស្ទើរតែមើលមិនចង់ស្គាល់ទៅហើយ នៅឈរយាមល្បាតនឹងថ្ពល់ត្រង់ផ្លូវចូល។ យើងឆ្លងផុតមកដល់ក្លោងទ្វារ ដែលតាមស្មានមើលទៅ កន្លែងនេះពីដើមជាកន្លែងតាហាន់ឈរយាម ប្រកបទៅដោយ ជញ្ជាំង សសរ និង បង្ហួច មានក្បាច់ចម្លាក់ឆ្លាក់ដោយដៃជិតក្រអឺប៉ិនប្រសប់គ្មានពីរក្នុងលោក។ រូបទេពអប្សរ និង អ្នករាំ ពាក់មកុដដ៏ខាន់ឫកណា ញញឹមពព្រាយហាក់សម្ដែងពរស្វាគមន៍ចំពោះយើង។ បន្ដពីក្លោងទ្វារនេះ មានផ្លូវក្រាលថ្មមួយទៀត លាតសន្ធឹងជិងរហូតដល់កាំជណ្ដើរអង្គរវត្ត។ រូបខាតជិងដែលគេធ្លាក់ធ្វើជាបង្កាន់ដៃនោះនៅតង់វង់នៅឡើយ ប៉ុន្តែទ្រេតទ្រោតរកកលនឹងបាក់ធ្លាក់ទៅលើវាលស្មៅនៅខាងក្រោម។ ផ្ទៃប្រាសាទទាំងមូល មានសភាពស្ងប់ស្ងាត់គួរឲ្យខ្លាច ទោះបីពួកយើងនាំគ្នានិយាយឡូឡាយ៉ាងណា ក៏ពុំអាចបង្កើតជាភាពអ៊ូអរបានដែរ នៅតែស្ងាត់ ស្ងាត់គួរឲ្យស្រងេះស្រងោចក្នុងចិត្ត។

យើងដើរមកដល់ជណ្ដើរថ្មបួនកាំ ដែលនៅក្បែរនោះមានវត្តមួយសម្ងំបួនយ៉ាងសុខសាន្ត កណ្ដាលសភាពស្ងប់ស្ងាត់ក្រោមម្លប់ពុទ្ធជាតិធំៗស្អីកត្រសុំត្រសាយ។ អ្នកភ្នំពេញ និង អ្នកបាត់ដំបង ជាច្រើនទាក់

បានមកដល់ទីនេះមុនយើងទៅទៀត ហើយគេដើរទៅដើរមកអួរអពាសពេញ។ ពួកក្រុមហ៊ុនប្រយ័ត្នប្រយែងខ្លាំងណាស់ តាត់តាមហ្វាលយើងជាប់ត្រប់ជំហាន ដើម្បីការពារកុំឲ្យស្មៀនក្មេងៗដែលធ្វើដំណើរមកជាមួយនាម៉ឺនសេព្វមុខមន្ត្រីនោះ តាមឆាឆៅយើងបាន។ ពួកក្មេងកម្លោះអស់ហ្នឹង ពុំមែនប្រាថ្នាមកមើលអង្គរវត្តប៉ុន្មានទេ ប៉ុន្តែតាមពិតគឺគេមកតាមមើលយើងនេះតែម្តង។ នៅពេលដែលយើងទាំគ្នាដើរចូលទៅកន្លែងងងឹត ខ្ញុំសម្គាល់ឃើញអស់អ្នកអស់នាងជាច្រើន បានខំចោលឫកចោលពារ ដើម្បីឲ្យគេយកតាមខ្លួន ដែលជាហេតុអាចឲ្យខ្ញុំកាត់យល់បានថា ពួកទាំងនេះសុទ្ធតែធ្លាប់ទាក់ទងគ្នាតាំងពីយូរណាស់មកហើយ ហើយគេប្រហែលជាមានសន្យាថានឹងរៀបការជាមួយគ្នាក្នុងពេលណាមួយទៀតផង។ អារបៀប ឲ្យកន្ទុយភ្នែក ឬញញឹមស្អីអញ្ចឹង ខ្ញុំមិនរវល់យកចិត្តទុកដាក់មើលទេ ពីព្រោះក្បាច់ចម្លាក់អង្គរវត្តល្អពេកណាស់ មើលហើយជក់ភ្នែកចង់តែមើលទៀត! សម្លេងមនុស្សជជែកគ្នាចេកចាចលាន់ឮមកពីត្រប់ទីកន្លែង ហើយនៅតាមច្រកងងឹតនោះ ធុំក្លិនស្អុយអាចម៍ប្រចៀវគួរឲ្យចង់ក្តួត។

ជណ្តើរមានត្រប់កន្លែង ងាកទៅខាងណាក៏ឃើញ មិនដឹងជាឡើងទៅដល់កន្លែងណាខ្លះទេ មកដល់ក្មេងទ្វារទីមួយៗតែមិនបានប្រយ័ត្នមើលក្រោម ច្បាស់ជាជំពប់ជើងជួលផ្តាំបំមុខមិនខាន។ នៅតាមជញ្ជាំងជីង មានឆ្នាក់រូបល្អណាស់ រូបទេពអប្សរដែលឆ្លាក់ជាប់នៅនឹងជញ្ជាំង សុទ្ធតែមានដោះរលោងស្រិលពីព្រោះនរណាដើរមកឃើញក៏អង្អែលគ្រប់ៗគ្នា។

មានកន្លែងមួយនោះ ឲ្យតែគក់ទ្រូង លាន់ឮស្ទុះខ្លាំងឆ្ងើយតបមកវិញ។ ហេតុតែចង់ស្តាប់សម្លេងខ្លាំងនេះ ខ្ញុំគក់ទ្រូងខ្លួនឯងខាល់តែចុក។

ក្រោយដែលដើរលេងនៅកន្លែងងងឹតអស់ហើយ យើងក៏ដើរចេញមកដល់ទីធ្លាមួយក្តីច្បាស់ក្រឡែតដែលមានដុំថ្មធ្លាក់មកពាយបាំយពាសពេញ។ កន្លែងនេះឥតមានដុះដើមឈើធំៗផ្តួចផ្តើមទៀតទេ ហើយនៅពីមុខយើង កំពូលទាំងប្រាំលូតខ្ពស់ត្រដួចត្រដឹមគួរឲ្យខ្លាច បន្តបពីលើពំនូកថ្មធំសាម៉ឺមប៉ុន្មឹ។ ជណ្តើរសម្រាប់ឡើងទៅកាន់កំពូលនោះ មានច្រើនណាស់ ជណ្តើរសម្រាប់ស្រីផ្សេង សម្រាប់ប្រុសផ្សេង មិនច្រឡូកច្រឡំគ្នាទេ។ ម្ចាស់ក្បត្រី អស់កម្លាំងពេកឡើងទៅទៀតមិនរួច សុខចិត្តអង្គុយចាំនៅខាងក្រោម ពួកយើងដោះស្បែកជើងទាំគ្នាឡើងយើតៗយ៉ាងប្រុងប្រយ័ត្នក្រៃលែង មិនហានងាកក្រោយមើលមកក្រោមពីព្រោះជណ្តើរនោះចោតសន្ធឹម ប្រកបទៅដោយកាំនីមួយៗតូចជាន់មិនពេញជើង។ បានឡើងទៅដល់លើយើងអាចមើលឃើញទិដ្ឋភាពផ្តែអង្គរវត្តទាំងមូល ដែលល្អប្រៀបបានទៅនឹងប្រាសាទទិព្វផុះចេញកណ្តាលទ្រូងព្រៃស្រោងស្រឹង ស្ទើរតែពុំអាចជឿថាជាស្នាដៃមនុស្ស។ ខ្ញុំឮគេប្រាប់ថា នៅជិតៗនេះមាន អង្គរធំ, ប្រាសាទលលៃ, ប្រាសាទតាព្រហ្ម និង ប្រាសាទផ្សេងៗទៀតជាច្រើន ដែលខ្ញុំភ្លេចឈ្មោះអស់ទៅហើយ ប៉ុន្តែខ្ញុំរកមើលមិនឃើញមួយសោះ ព្រោះព្រៃផុះគ្របពីលើជិតអស់ទៅហើយ... ឃើញតែព្រៃខៀវស្រងាត់លាតសន្ធឹងជីង រហូតទៅដល់ទន្លេសាប។

ដោយសារខ្ញុំចេញមុខការពារ កាហ៊ីនវាបានតាមមកជាមួយគេជាប់ហូត វារត់ឡើងជណ្តើរលឿនផ្ងួចកណ្តុរ។ យើងដើរមើល ខាងឆ្វេងបន្តិច ខាងស្តាំបន្តិច ត្រចាំគ្នាអុជធូបបូជាវិបសំណាកឆ្លាក់ជាប់ទីងទ្វារមួយនោះ រហៀបតជាជញ្ជាំងអញ្ចឹង។

ថ្ងៃខ្ពស់ណាស់ហើយ... យើងក្តរពោះឃ្លានបាយ ហើយក៏អស់កម្លាំងបន្តិចដែរ ជាពិសេសគឺខ្ញុំនេះឯងដែលអស់កម្លាំងខ្លាំងជាងគេ ពីព្រោះខ្ញុំមិនរវល់កាត់ភាឲ្យតួសង្ខារមើលដូចពួកគេឯទៀតទេ។ ខ្ញុំហាក់ដូចជាឈឺចុកចាប់ពេញខ្លួន ទ្រាំមិនបានក៏ចូលទៅសម្ងំដេកក្នុងរោងស្លឹកដែលគេសង់ទុកសម្រាប់ឲ្យពួកហិរញ្ញវត្ថុ

ហ្លួងចូលឈប់សម្រាកកំដៅថ្ងៃ។ ការឡើយហាត់ក្នុងពេលធ្វើដំណើរ ចាប់ផ្តើមធ្វើទុក្ខខ្ញុំខ្លាំងឡើងៗជាលំដាប់រហូតដល់ពេលថ្ងៃត្រង់ខ្ញុំធ្លាក់ដាបមែនទែន ប៉ុន្តែខ្ញុំត្រាំរាំថ្វាយ វត្តុសក្តិសិទ្ធិ និង ទេវតារក្សាទីកដី ជាមួយគេឯងខាល់តែចប់ចុងចប់ដើម។

ខ្ញុំធ្វេចភ្នែកមមើមមាយឃើញតែប្បីងផ្តេសផ្តាសត្សរឲ្យខ្លាច ហើយមួយសន្ទុះក្រោយមក ខ្ញុំក៏សន្ធប់លែងដឹងខ្លួនសោះតែម្តង... ពេលត្រឡប់មកវិញ គេម្នាក់ៗសង្កាតយោងអាត្មាតែរាល់ខ្លួន គ្មានរណោតិតត្សរឹកតាដល់ខ្ញុំដែលដេកលក់ស្លុកស្តឹងតែម្នាក់ឯងនៅលើកន្លេលក្នុងរោងនោះទេ។ ថ្ងៃនោះបើកុំតែបានពុកម៉ែទៅតាមជាមួយ ម្ល៉េះសមគេហ្លួចទុកខ្ញុំចោលកណ្តាលព្រៃមិនខាន។ មកដល់សៀមរាបវិញ ខ្ញុំដេកស្តឹកនៅលើទីតាំងសក្តិក្រសេម រង់ចាំទម្រាំអ្នកឯទៀតត្រឡប់មកពីរាំបួងសួងឯអង្គរធំវិញ ទើងអាលនាំគ្នាត្រឡប់មកភ្នំពេញ។ ខ្ញុំដឹងថា នេះជាជម្ងឺពេលឡើងខ្លួន ប៉ុន្តែជម្ងឺនេះវាធ្វើទុក្ខខ្ញុំខ្លាំង រហូតដល់ជីវិតវាយវង្វេងស្មារតីពុំដឹងជាអស់រយៈពេលយូរប៉ុណ្ណា ស្រាប់តែមានរណាអង្រួនដាស់ខ្ញុំ សម្លឹងមើលទៅឮជាមុខ យ៉ានពួកម៉ាកខ្ញុំ។ វាខ្សឹបប្រាប់ថា ពេលដេកមមើមមាយ ខ្ញុំវាសដៃទៅប៉ះក្បាលម៉ែមន្ទ ដែលជាហេតុបណ្តាលឲ្យគាត់ខឹងច្រឡោត ហើយខ្ញុំហាក់ដូចជាស្រមៃឮ ម៉ែមន្ទ និយាយល្មើយៗកំពុងទូលពិតហ្លួងថា៖ ខ្ញុំព្រហើនណាស់ គ្រាន់តែបានទូលជូនគាប់ចំរីហ្លួងប៉ុណ្ណឹង ស្រាប់តែឡើងចាងហ៊ានវាយក្បាលគាត់ ដែលមានថានៈជាម៉ែ ព្រមទាំងសុំឲ្យហ្លួងវាយប្រដៅខ្ញុំម្តង កុំឲ្យព្រហើនដាក់គាត់ខ្លាំងពេក។ ខ្ញុំឮសម្លេងហ្លួងឆ្លើយតបមកវិញថា:

ម៉ែមន្ទអើយ កុំធ្វើបាបវាអី! មិនឃើញជាវាកំពុងឈឺមមើមមាយមិនដឹងខ្លួនទេឬ? ក្មេងអាយុប៉ុណ្ណឹងវាតែងឈឺអញ្ចឹងហើយ ឈប់ផ្សាំទាំទៅ ទុកពេលឲ្យអញដេកឲ្លួនខ្លះផង។

ប៉ុន្តែ ម៉ែមន្ទ គាត់មិនងាយឈប់ផ្ងិភ្លាមទេ ពីព្រោះគាត់ចង់ចិត្តស្អប់ពួកយើងក្មេងៗ ដោយសារសព្វថ្ងៃហ្លួងសព្វព្រះទ័យនឹងពួកយើងជាងគាត់។

បន្ទាប់ពីពេលកើតឧប្បត្តិហេតុនេះមក ខ្ញុំហាក់ដូចជាបានស្រួលខ្លួនបន្តិចឡើងវិញ... ខ្ញុំមើលតាមបង្អួចឃើញទីតាំងល្បើនលយទៅមុខតាមចង្វាក់ច្រវា កាត់តំបន់ព្រៃលិចទឹកក្នុងស្រុកកំពង់លែង... យើងជិតទៅដល់កំពង់ឆ្នាំងហើយ មកដល់កំពង់ឆ្នាំង ម៉ែអួតធ្វើជានិយាយទូលហ្លួងថា ខ្ញុំឈឺធ្វើការមិនកើតអញ្ចឹង ឲ្យជិះលើទីតាំងសក្តិក្រសេមទាំតែធ្ងន់ទូកឥតប្រយោជន៍ ដោយសារមធ្យោបាយនីប៊ិនប្រសប់នេះ ខ្ញុំក៏បានចុះទៅជិតទូកជាមួយពុកម៉ែ ដើម្បីឲ្យគាត់បានមើលថែទាំខ្ញុំដោយផ្ទាល់។ កប៉ាល់ម៉ាស៊ីន សណ្តោងទូកទាំងអស់ត្រឡប់មកដល់ភ្នំពេញក្នុងរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ ហើយហ្លួងបានអនុញ្ញាតឲ្យម៉ែយកខ្ញុំទៅមើលទៅផ្ទះ ចាំកាលណាជាស្រួលបួលសឹមត្រឡប់មកធ្វើការវិញ។

ខ្ញុំសប្បាយចិត្តក្រៃលែង ដោយបានវិលមកស្គាល់ជីវភាពគ្រួសារ ដែលខ្ញុំបំភ្លេចចោលតាំងពីច្រើនឆ្នាំណាស់ហើយ។ ផ្ទះខ្ញុំផ្លាស់ប្តូរប្លែកពីមុនទាំងអស់។ កាលឆ្នាំទៅ មានភ្លើងឆេះផ្ទះ រាលដាលពេញម្តុំខាងជើងកំពង់ផៃ បណ្តាលឲ្យពុក-ម៉ែ គាត់ប្រញាប់ជញ្ជូនអីវ៉ាន់និងរុះរើផ្ទះខ្ទេចខ្ទីអស់ ប៉ុន្តែភ្លើងនោះមិនបានឆេះមកដល់ផ្ទះយើងទេ ណាមួយរៀងរាល់ឆ្នាំ ពីច្រាំងទន្លេចេះតែបាក់ទាំងឆ្នាំងៗធ្លាក់ចុំទៅក្នុងទន្លេ ពុកក៏លើកផ្ទះមកសង់ទៅខាងលើឯណោះវិញ ដើម្បីឲ្យបានឆ្ងាយពីមាត់ទន្លេបន្តិច។

ប្រាក់ខែពុកតិចពេក ពុំអាចឲ្យគាត់រកប្រាក់គ្រប់គ្រាន់ល្មមសង់ផ្ទះមួយធំទូលាយ សមតាមចិត្តប្រាថ្នាម្ល៉ោះហើយផ្ទះថ្មីនេះធ្វើពីស្លឹកដដែល មានពីរបន្ទប់ និង ឥសំយាកចេញជាផ្ទះបាយ ព្រមទាំងមានវាលហាលទៅពីមុខ ដែលពុកដាំផ្កាដាក់តាំងជាលំអផង។ នៅក្រោមផ្ទះមានជាក់របស់ប្រើប្រាស់ផ្សេងៗ ដូចជា

ពាងទឹក ត្បាល់បុកស្រូវ ចង្អេរ កញ្ជើ និង ឫស ជាដើម។ ពុក កាប់គាស់ដីរៀបចំធ្វើជាសួនច្បារត្រួចមួយ ខ័ណ្ឌ ជាប់ពីផ្ទះអ្នកជិតខាងដោយសារបងប្អូនស្ទឹ ដែលនៅទីនោះមានដាំ ដើមចេក ដើមល្ហុង ប្រកបទៅដោយ ផ្លែរយើងរយោងផ្លែមត្រដាក់។ ពុកគិតថា បើយ៉ាងហោចណាស់ក៏ពីរឆ្នាំទៀតដែរ ទម្រាំជការដេញយួរផ្ទះ ផ្ទះនេះ ហើយក្នុងរយៈពេលនេះ គាត់នឹងរំសន្សំលុយទុកសម្រាប់ដើររកទិញដីនៅកន្លែងថ្មីទៀត។ ខ្ញុំ អាណិតពុកណាស់!... ខ្លួនគាត់ចាស់សក់ស្កូវសព្រោង ជុះពុកមាត់ស្រមួម ក៏មិនរវល់គិតគូរ គិតយ៉ាងណា ឲ្យតែកូនស្រីតែមួយ បានសប្បាយ បានស្រួល ពីព្រោះតទៅថ្ងៃមុខគាត់សង្ឃឹមថានឹងបាន ខ្ពស់មុខ ខ្ពស់មាត់ ស៊ីពោះលោះកម្លាំងដោយសារកូនស្រីដែលជាអ្នកកំណើតហួងនេះហើយ។ គាត់ស្រមៃឃើញថា ការដែល គាត់សុខចិត្តលះបង់កូនសម្លាញ់ចិត្តថ្នាយទៅហួង យូរឬឆាប់ គាត់គង់នឹងបានទទួលការគាប់ក្បាលពីហួងវិញ មិនខាត។ កាលណាខ្ញុំឮញញែរថ្លែងពីសេចក្តីអស់សង្ឃឹមក្នុងការរស់នៅក្នុងភាំង គាត់តែងលួងលោមថា ឲ្យ ខ្ញុំព្រំនៅបន្តិចទៀតចុះ យ៉ាងហោចណាស់បើមុនឆឹងចេញមក ក៏ចាំគាត់រកផ្ទះថ្មីបាននៅស្រួលបួលជាមុន សិនដែរ។

គាត់បានទិញ ក្តារខៀនខ្មៅមួយ និង ដីសមួយប្រអប់ សម្រាប់បង្រៀនឲ្យខ្ញុំ ចេះសរសេរ ចេះអាន អក្សរខ្មែរ ពេលណាគាត់ទំនេរ។ ប៉ុន្តែខ្ញុំខ្ជិលរលួយ មិនចង់រៀនស្ងួតស្រោះ ដែលជាហេតុធ្វើឲ្យពុកអស់ សង្ឃឹមលែងស្តី។

គាត់គិតតែម្យ៉ាង គឺធ្វើយ៉ាងណាដើម្បីរៀបចំអនាគតខ្ញុំឲ្យបានភ្លឺស្វាងថ្លូចគេឯង ហើយទោះបីគាត់ មិនស្ទាត់ធៀយស្តី មិនស្ទាត់ចេះថ្នាក់ថ្នម ក៏ខ្ញុំនៅតែអាចកាត់ស្មានយល់ដល់ជម្រៅចិត្តគាត់ថា គាត់ស្រឡាញ់ ខ្ញុំ គិតខ្វាយខ្វល់ឱ្បឹងខ្ញុំជាងខ្លួនគាត់ទៅទៀត។ ពេលឃើញពុកសន្សំបានប្រាក់បន្តិចបន្តួចសល់ពី ប្រាក់ខែ និង. ប្រាក់រកបានក្រៅដោយសារគាត់ជួយសរសេរពាក្យបណ្តឹងឲ្យគេ ហើយទិញរបស់កំប៉ុកកំប៉ុកមកទុក ឲ្យខ្ញុំប្រើប្រាស់ ម៉ែនិយាយចំអន់ឲ្យខ្ញុំថា៖

~ ពុកឯង គិតរៀបចំឲ្យឯងមានប្តីហើយ!

ផ្ទះខ្ញុំស្អាត ហើយសប្បាយរីករាយជាទិច្ច... ក្នុងទូកញ្ជក់តួចៗមានដាក់ ថ្នាំ ដបទឹកអប់ និង កំប៉ុង ម្សៅ ជាពិសេសទោះបីខ្វះខាតលុយយ៉ាងណា ក៏គាត់មិនព្រមលក់បញ្ចាំខ្សែក្រវាត់ប្រាក់របស់ខ្ញុំដែរ សុខចិត្ត តែទុកជាក់តាំងសំញែងក្នុងទូ។

កាលណាអ្នកជ័កទឹកក្រយកទឹកមកចាក់ឲ្យ គាត់មិនហៅមនុស្សប្លែកឲ្យជ័កទឹកចូលរហេតរហូតក្នុងផ្ទះ ទេ សុខចិត្តដោះអាវ័លងខ្លួនទេ លីផងជ័កទៅត្រែងទឹកម៉ាស៊ីនជ័កយកមកផ្ទះ មិនរវល់ខ្លាចនរណា គេសើចយ៉ីអ្វីទាំងអស់ ធ្វើម៉េចឲ្យតែមានទឹកសម្រាប់ខ្ញុំងូតសំអាតខ្លួន។

~ ពុកហ្ន៎ (ខ្ញុំឃាត់គាត់) ពុកធ្វើអញ្ចឹង ខ្ញុំខ្មាសគេណាស់។

ប៉ុន្តែគាត់មិនស្តាប់ខ្ញុំទេ ហើយកាលណាម៉ែមិនទៅផ្ទះ គាត់ថែមទាំងរៀបចំដាំបាយធ្វើម្ហូបម្ហាដោយខ្លួន ឯងទៀតផង។ គាត់នៅតែសង្ឃឹមជាទិច្ចថា ថ្ងៃណាមួយខ្ញុំជួយទូលសុំហួងឲ្យគាត់ បានឡើងបុណ្យសក្តិ ឬ បើយ៉ាងហោចណាស់ក៏សុំព្រះរាជទ្រព្យខ្លះ យកមកសង់ផ្ទះឈើប្រក់ក្បឿងឲ្យបានសមរម្យដែរ ពីព្រោះ អ្នកបាំងថែទៀត គេធ្លាប់សុំបានច្រើនគ្នាហើយ។ ប៉ុន្តែគាត់មិនហ៊ានធៀយប្រាប់ខ្ញុំសោះ ហើយខ្លួនគាត់ ទៀត ក៏ចេះតែគេចវេះមិនដែលចូលទៅគាល់ឲ្យស្គាល់មុខនឹងគេសោះ។

ថ្ងៃមួយគាត់ទិញផ្លែឈើមួយថាស ថាឲ្យខ្ញុំយកទៅថ្វាយហួង ប៉ុន្តែខ្ញុំលួចស៊ីអស់រលីង មិនបានយកទៅ ថ្វាយហួងឡើយ។ ក្រោយមកយូរណាស់ ទើបគាត់ដាច់ចិត្តហ៊ានសួរខ្ញុំ ពីរឿងគាត់ពឹងឲ្យទៅសុំហួងនោះ

តើវាបានការយ៉ាងម៉េចទៅហើយ? ខ្ញុំ ឆ្លើយក្រោយ និង ខ្មាសខ្លួនឯងយ៉ាងខ្លាំង ដែលពុំបានសងគុណ ពុកម្តាយឲ្យសមតាមទំហំទឹកចិត្ត ដែលគាត់ទំស្រឡាញ់ថ្នាក់ថ្នមខ្ញុំ។

យើងក្រពិតមែន ប៉ុន្តែយើងមិនដែលខ្វះខាតទេ។ ពុកត្រូវទំធ្វើការរកប្រាក់ឲ្យបានច្រើនលើសពេលមុន ព្រោះសព្វថ្ងៃនេះខ្ញុំធ្លាក់មកលើបន្ទុកគាត់ទាំងស្រុង ប្រាក់ខែភាំងមួយខែដប់រៀលរបស់ខ្ញុំនោះ ត្រូវគាត់សង លុយជំពាក់កាលខ្លីគេទៅបាត់ដំបងសៀមរាបអស់ទៅហើយ។ ហេតុនេះគ្រួសារយើងចាយវិតត្បៀតជា ទីបំផុត ដើម្បីជៀសវាងកុំឲ្យជំពាក់គេ។

ពុក និង ម៉ែ មួយថ្ងៃៗធ្វើការតែតទំនេរតែម្តង មួយផ្ទះនៅសល់ទំនេរតែខ្ញុំ ដែលតែងធ្វើការអ្វីទាំងអស់ ក្រៅតែ ពីតែងខ្លួនសំអិតសំអាងកាយ។ ម៉ែ និង កាហ៊ិន ទៅផ្សារ ដាំបាយ ស្លសុក បោកគក់សំពត់អាវខ្ញុំ គ្រប់ បែបយ៉ាង។ សុខភាពខ្ញុំបានស្រួលឡើងវិញជាលំដាប់ ប៉ុន្តែនៅពុកបែរជាធ្លាក់ខ្លួនឈឺ ម្តងក្តៅ ម្តងរងា ត្រូវឲ្យព្រួយបារម្ភក្រៃលែង។ តាំងពីត្រឡប់មកពីអង្គរវិញ មួយយប់ៗគាត់ភ្នកទល់ភ្លឺ ជួនកាលមានធ្លាក់ឈាម ទាំងដុំមកផង ពេលភ្នកម្តងៗទ្រូងគាត់ក្តៅផ្ទួចហ្អឹង។ គាត់ជក្រសែភ្នែកពោរពេញទៅដោយ ក្តីស្នេហា និង ក្តីព្រួយបារម្ភ សម្លឹងមើលខ្ញុំ សម្លឹងមើលផ្ទះ សម្លឹងមើលម៉ែដែលគិតតែអង្គុយយំ ឥតធ្វើអ្វីកើតទាំងអស់។ គាត់ហៅខ្ញុំចូលទៅជិត ហើយខ្ទួនថា៖

~ កូនឯងនៅក្នុងភាំងហួតទៅណា? ពីព្រោះបើចេញមកនៅក្រៅ កូនឯងគ្មានបង្គោលទីពឹងមាំមួនទេ។

យើងពុំបានចាប់ភ្ញក់គិតថា គាត់ឈឺខ្លាំងខាល់តែសោះ ហើយខ្លួនគាត់ប្រហែលជាខំលាក់មិនឲ្យយើង ដឹង ខ្លាចយើងព្រួយចិត្តហើយមើលទៅ។

ត្រាន់តែមានកម្លាំងបន្តិចឡើងវិញភ្លាម ខ្ញុំមានសើរភាពពេញបរិបូរណ៍ អាចលេងសើច ឬ ធ្វើអ្វីបានតាម ចិត្ត ព្រោះនៅផ្ទះគ្មានក្រមភាំងចាំតាមយាមគ្រប់ជំហានដូចនៅភាំង។ ចាប់តាំងពីពេលធំពេញវ័យពេញវ័យមក ខ្ញុំសង្កេតឃើញពុកតាត់ប្រឹតប្រៀងរឿងខ្ញុំខ្លាំងណាស់។ ថ្ងៃមួយគាត់ឃើញខាត់ខ្ញុំកំពុងងូតទឹកនៅ មាត់ទន្លេ ឥតចេះអៀនខ្មាសដល់គេឯងដែលមុជអ្វីអាវនៅជិតនេះសោះ គាត់ក៏ដេញឲ្យខ្ញុំត្រឡប់មកផ្ទះវិញ ព្រមទាំងស្តីបន្ទោសខ្ញុំយ៉ាងច្រើន ប៉ុន្តែគាត់ស្តីមួយម៉ាត់ ខ្ញុំឆ្លើយតៅវិញដប់ម៉ាត់ មិនព្រមចាញ់គាត់ទេ។ ឃើញថាប្រដៅខ្ញុំមិនបាន គាត់ក៏ទៅប្រាប់ម៉ែថា ខ្ញុំនេះឆ្នាស់រកនរណាប្រៀបឲ្យស្មើពុំបាន ហើយចាប់តាំង ពីពេលនោះមក គាត់រឹតតែឃ្លាំមើលខ្ញុំ ប្រយ័ត្នប្រយែងជាងពេលមុនទៅទៀត។ ខ្ញុំក្លាយខ្លួនទៅជាមនុស្ស ទោសជាប់ឃុំឃាំង ពុំអាចដើរចេញទៅណាមកណាតែម្នាក់ឯងបានឡើយ ហើយខ្ញុំត្រូវតែយល់ថា ការ ប្រែប្រួលប្រយ័ត្នរបស់ពុកជាការត្រឹមត្រូវ ពីព្រោះនៅក្នុងទីក្រុងមានមនុស្សប្រុសខ្វះចិលច្រើនណាស់ ស្រីអាយុ ដំណាលខ្ញុំ ត្រូវចេះការពារខ្លួនឲ្យមុឺងម៉ាត់ ដើម្បីកុំឲ្យធ្លាក់ខ្លួនទៅក្នុងអន្ទាក់ពួកវា។ លើសពីនេះទៅទៀត ខ្ញុំមិនត្រូវភ្លេចថា ខ្លួនេះជាអ្នកបំរើហួង លោកឧស្សាហ៍ប្រើក្រមភាំងឲ្យមកតាមស៊ើបសួរដំណឹងពីខ្ញុំជា ប្រើយៗ ឲ្យតែហ៊ានថ្នោះធ្នោយបន្តិច លេចឮទៅដល់ភាំង ច្បាស់ជាត្រូវទណ្ឌកម្មធ្ងន់ខ្លួនមិនខាន នេះមិន និយាយពីរឿងគេបណ្តេញឈប់ឲ្យនៅភាំងផង។

មានកើតឧប្បត្តិហេតុមួយ ដែលជាសញ្ញាព្រមានថា ឲ្យខ្ញុំត្រូវតែប្រយ័ត្នខ្លួនចាប់តាំងពីពេលនេះតទៅ ហើយពុក-ម៉ែ ក៏រឹតតែតឹងតែងខ្លាំងឡើងទៀតដែរ។ ថ្ងៃមួយខ្ញុំអង្គុយជក់ចាប៊ីរ ជជែកគ្នាជាមួយ កាហ៊ិន លើរាងហាល ក្អែកសម្លឹងមើលមនុស្សម្នាដែលដើរមកតាមផ្លូវមុខផ្ទះ ស្រាប់លេចឃើញចាប៉ាក់ងម្នាក់ មុខ ក្រហមងាំង សក់ក្បាលបះកន្ត្រើង ពុកមាត់ស្រមួម ស្លៀកពាក់ស ពាក់ម្ហកស ដែលជាការចម្លែកពេកណាស់ ពីព្រោះក្នុងភូមិខ្មែរមិនសូវមានចាប៉ាក់ចេញចូលញឹកញាប់ទេ។ ក្រឡេកមកឃើញខ្ញុំ ស្រាប់តែវាបត់ក្បាល

ដើរចូលរ៉ាយ តម្រង់មកចំផ្ទះខ្ញុំតែម្តង ខ្ញុំភ័យស្ទើរលោះព្រលឹង រត់ចូលទៅក្នុងផ្ទះស្រែកឆោឡោ :

~ ពុក ! ម៉ែ ! បាក់ឆ្កែងចូលផ្ទះយើងហើយ ធ្វើម៉េចទៅ ?

ពុកស្រវាតាញបានទុកទ្វារ ម៉ែតាញបានជន្លួលបង្ហួច យកមកលាក់ក្រោយខ្នង ចេញទៅឈរពាំងមាត់ទ្វារ ។

~ លោករកអី ? (ពុកសួរទៅបាក់ឆ្កែងដែលទើបនឹងឡើងផុតកាំជណ្តើរ ដើរខ្វែតខ្វោតចូលមក) ។

បាក់ឆ្កែងនេះធំក្លិនស្អុយស្រាហួង វាសើចខ្ចិរ ព្រមទាំងនិយាយគ្រលស្ទើរស្តាប់មិនចង់បាន :

~ ខ្ញុំរកប្រពន្ធខ្ញុំ វានៅទីហ្នឹងទេ ?

~ អត់មានប្រពន្ធលោកនៅទីនេះទេ, លោកអញ្ជើញទៅរកកន្លែងណាផ្សេងទៀតទៅ !

ខ្ញុំ និង ហ៊ុន ពួនពីក្រោយជញ្ជាំង លួចមើលតាមប្រហោងជញ្ជាំងភ័យញ័រទន្ទ្រើក ដោយឃើញពុកខ្ពស់មិនដល់ស្មាបាក់ឆ្កែងផង ។ ប៉ុន្តែសំណាងល្អ អាបាក់ឆ្កែងហ្នឹងវាស្រីងស្រាខ្លាំងណាស់ វាព្រមចុះដើរចេញទៅវិញតាមសម្រួល ដោយលូកដៃស្តាំមកចាប់ដៃពុកជាសញ្ញាលាគ្នាផង ។ ហ្នឹងនេះវាធ្វើឲ្យផ្តើលអស់មួយភូមិ គេនាំគ្នាមកសាកសួរពុក-ម៉ែ ហើយយកទៅនិយាយសើចលេងពេញម្តុំកំពង់ផែអស់ពីរ-បីថ្ងៃ ។

ផ្ទះខ្ញុំនុស្សហ៍មានភ្ញៀវឡើងចុះណាស់ ហើយក្នុងចំណោមភ្ញៀវទាំងអស់ ខ្ញុំសង្កេតឃើញថាមានប្រុសកម្លោះពីរនាក់ ដែលខ្ញុំធ្លាប់ស្គាល់តាំងពីយូរមកហើយ ដោយធ្លាប់ឮគេនិយាយទៅក្នុងភឹង និង ធ្លាប់ឃើញក្នុងពិធីបុណ្យផ្សេងៗ មួយឈ្មោះ ទុន មួយទៀតឈ្មោះ នុរ ជាអ្នកឡើងចុះញឹកញាប់ជាងគេ ។ ជួនកាលវាមកលេងខុសពេលគ្នា ជួនកាលមកជួបគ្នាតែម្តង ដែលជាការគួរឲ្យចុះឆ្ងាត់ពេកណាស់ ព្រោះម្នាក់ៗ សុទ្ធតែប្រជែងគ្នាទិញនេះទិញនោះយកមកជូនម៉ែដើម្បីផ្គាប់ផ្គង, ខ្ញុំក៏មិនមែនខ្វាក់មិនយល់ពីគោលបំណងរបស់វានោះទេ ។ ម៉ែក៏មិនលាក់ល្បិងនេះនឹងខ្ញុំដែរ គាត់ប្រាប់ខ្ញុំថាឈ្មោះ ទុន និង នុរ ជាភ្ញៀវដែលចង់ស្តីដណ្តឹងខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងជាសំរេចចិត្តស្រឡាញ់មួយណា គឺខ្ញុំស្អប់ឪពុកទាំងពីរនាក់តែម្តង គ្រាន់តែមិនចេញស្តីឲ្យនរណាដឹង ។

នុពុករបស់ ទុន ជាតាម៉ីនធំ ស្លាប់តាំងពីយូរណាស់ហើយ ក្នុងពេលច្បាំងជាមួយសៀម ។ សព្វថ្ងៃ ទុន រស់នៅជាមួយម្តាយមេម៉ាយ និង បងប្អូនស្រីច្រើនទាក់ទៀត, គ្រួសារគេជាពូជព្រាហ្មណ៍បារតួសុទ្ធ ។ ទុន សម្បុរខ្មៅស្រអែម មានធំ រាងសង្ហា ចេះគួរសម មិនប្រកាន់ខ្លួន ទោះបីម្តាយទំរើសក្អួតប្រុសតែមួយ ទិញ ឥន្ទ្រីកា, ខែ្សដៃមាស, កង់យ៉ាងខាន់សម័យ បំពេញចិត្តមិនឲ្យខាស់យ៉ាងណាក៏ដោយ ។ ផ្ទះម្តាយ ទុន ស្ថិតនៅខាងត្បូងវត្តបទុម ពីក្រោយស្រះស្រង់, ធំទូលាយល្អណាស់ ។

នុរ ជាភ្ញៀវចៅក្រមធំ អាយុស្របាលគ្នានឹង ទុន ដែរ ប៉ុន្តែវាជាភ្ញៀវចៅចិន ហើយជាមនុស្សខ្ចីខ្ជា មិនសូវគិតគូរពីរឿងអីទេ ។

ទុន និង នុរ ធ្លាប់ស្គាល់គ្នាតាំងពីក្មេង ដោយធ្លាប់រៀនៅក្នុងសាលាបាក់ឆ្កែងជាមួយគ្នា ឈប់រៀនក៏ដំណាលគ្នា ហើយដល់ពេលបួស ក៏បួសក្នុងវត្តជាមួយគ្នាទៀត ។ លុះសឹកមកវិញ ទំនេរមិនទាន់ចូលធ្វើការ គេក៏រឹតតែរាប់អានគ្នាលើសដើម ដើរទៅណាក៏ពីរនាក់ កម្រឃើញដើរបែកគ្នាណាស់ ។ គេមិនសូវមានតម្រិះជ្រៅជ្រះក៏ពិតមែន ប៉ុន្តែគេអាងសម្បត្តិម៉ែឪ មិនសូវភ័យព្រួយរឿងរកស៊ីធ្វើការ ជួចយើងជាភ្ញៀវអ្នកក្រឡើយ ។ ខ្ញុំដឹងថាពីមុន ទុនធ្លាប់មានទាក់ទងនឹងពួកល្មោនម្នាក់ ប៉ុន្តែក្រោយមកបែកបាក់គ្នាទៅវិញ ដោយសារមីនោះលួចសាហាយគ្នាជាមួយស្មៀនលោកកុង្សីទៅលើ កប៉ាល់ដែលដឹកយើងត្រឡប់មកពីស្រុកបាក់ឆ្កែងវិញ ។ នេះជារឿងចាស់មួយ, ហើយក្រោយមកខ្ញុំសង្កេតឃើញថា កាលណា អស់អ្នក-អស់

នាងក្នុងភឹងចេញទៅវត្តព្រះកែវខ្ចី ទុនដែលដើរក្បែរខ្ញុំ [illegible] មាយាម្ចិកម្ល៉ាក់របស់នរណាទេ តាមសម្លឹងមើលតែខ្ញុំម្នាក់ប៉ុណ្ណោះ ។

ចំណែក នុរវិញ ក៏មានទាក់ទងស្នេហាទៅក្នុងភឹងជាមួយមីមួយនោះឈ្មោះ [illegible] ចាស់មេអណ្តើកបែរជាច្រឡំទៅទាក់ទងនឹងម្នាក់ផ្សេងទៀតឈ្មោះ ពុទ្ធចន្ទាឈើ ។ [illegible] ពីរនាក់ វាឈ្មោះជេរបញ្ឆោតគ្នាផ្តើលណាណា ពីព្រោះវាសុទ្ធតែមិនដែលស្គាល់មុខម្ចាស់សំបុត្រផង ដូចគ្នា ។ ចាប់តាំងពីពេលច្រឡំម្ល៉ុយបែកការខ្មាស់គេម្តងមក នុរលែងហ៊ានរើរវល់ហ្នឹងនេះសោះតែម្តង ។

ខ្ញុំចេះតែឆ្ងល់ ហេតុដូចម្តេចបានជាខ្ញុំទាក់ទងស្គាល់ប្រុសកម្លោះពីរនាក់នេះ ? ខ្ញុំគិតយូរណាស់ទម្រាំឥតឃើញ ។ ទុនប្រហែលជាចាប់ស្រឡាញ់ខ្ញុំបន្ទាប់ពីពេលបានជួបគ្នាដោយចៃដន្យនៅក្នុងទិព្វវត្តព្រះកែវក្នុងថ្ងៃសីល ដែលខ្ញុំដង្ហែម្ចាស់ក្សត្រីយកចង្ហាន់ទៅប្រគេនព្រះសង្ឃជាមួយអស់អ្នក-អស់ខាង ដ៏ទៃទៀត នោះហើយមើលទៅ ។

កាលនោះ នៅក្នុងភឹងមានស្រីភ្ញៀនស្តេចម្នាក់កំព្រា មិនដឹងជាភ្ញៀនចៅស្តេចណាទេ ឈ្មោះ ចិន្តាវង្ស មានបន្ទប់ដេកនៅក្បែរខ្ញុំ ម្ចាស់នេះនៅជាមួយមីងចាស់ម្នាក់ឈ្មោះយាយអ៊ូ ដែលស្រឡាញ់រាប់អានខ្ញុំណាស់ ហើយថែមទាំងស្គាល់គ្រួសារ ទុន ច្បាស់លាស់ទៀតផង ។ គាត់ត្រូវគេជួលឲ្យលុយយ៉ាងច្រើន ដើម្បីធ្វើមេអណ្តើក រហូតដល់ហ៊ានលួចដាហ៊ីចាក់ជរាណ៍ក្រហមរបស់ខ្ញុំយកទៅឲ្យ ទុន ទាល់តែខ្ញុំគំរាមកំហែងខ្លាំងមែនទែន ទើបគាត់យកមកសងវិញ ។ ឃើញថាទាក់ទងជាមួយខ្ញុំមិនបាន គាត់ក៏បែរទៅទាក់ទងជាមួយពុក-ម៉ែម្តង ហើយម៉ែនោះ ចេះតែនៅស្ងៀមហួត ។ ថ្ងៃមួយគាត់កំពុងមកលេងជាមួយខ្ញុំនៅឯភឹង ស្រាប់តែមានគេមកតាមថា ពុកឲ្យហៅត្រឡប់ទៅផ្ទះវិញជាប្រញាប់ ។ ទៅដល់ផ្ទះគាត់ភ្ញាក់ព្រើត ដោយឃើញមនុស្សមួយហ្វូងធំកាន់ចាសដាក់ទំចំណី មានម្តាយ ទុន ជាអ្នកនាំមុខចូលមកចែវស្តីដណ្តឹងខ្ញុំ ។

ដោយខ្លាចអំណាចគេជាអ្នកមាន ពុកមិនហ៊ានឆ្លើយថាយ៉ាងម៉េចឲ្យច្បាស់លាស់ គាត់យកអំណាចហ្នឹងមកដឹកមុខថា មានតែហ្នឹងទេដែលអាចសំរេចរឿងប្តីសី នៃ ពួកល្មោនរបស់លោកបាន ។ ពុកមិនបានបដិសេធជាច់ស្រេចអញ្ចឹង ទើបបានជា ទុន នៅតែទៅមករើរើចុះផ្ទះខ្ញុំជាញឹកញាប់ ហើយទំយកចិត្ត ពុក-ម៉ែ លើសដើម ។

ថ្ងៃមួយ ទុនតាំ នុរមកលេងផ្ទះខ្ញុំ ដើម្បីបង្ហាញឲ្យម៉ែបានស្គាល់ពួកម៉ាកសង្ហាញ់ចិត្តរបស់គេ ហើយចាប់តាំងពីពេលនោះមក នុរក៏នុស្សាហ៍មកលេងតែម្នាក់ឯងជាញឹកញាប់ ដោយសំអាងថា ជាពួកម៉ាកជិតជិតនឹង ទុន ប៉ុន្តែតាមពិត អាគាត់ហ្នឹងចង់ដើរខ្សែលើពួកម៉ាកតែម្តង ។ នុពុករបស់ នុរ បានជួបជាមួយពុកស្នើចង់ភ្ជាប់សាច់ឈាមរវាងគ្រួសារយើងទាំងពីរផង ប៉ុន្តែពុកក៏មិនបានឆ្លើយឲ្យជាក់លាក់ថាយ៉ាងម៉េចដែរ ។

ថ្ងៃមួយ យាយអ៊ូមកសុំផ្ទះសំណាក់ពីរ-បីអាទិត្យ ដើម្បីងាយបញ្ជះបញ្ជួលពុក-ម៉ែ ឲ្យបាក់ចិត្តទៅលើ ទុន ពីព្រោះគ្រួសារនេះបានចំណាយលុយជួយគាត់អស់ច្រើនណាស់ ដើម្បីសំរេចការឲ្យគេ ។ ម៉ែគាត់ស្ងប់ហើយចិត្តល្អពេក បណ្តោយឲ្យគេបង្វិលទៅឆ្វេងទៅស្តាំបានតាមចិត្ត ទាល់តែពុកបន្ទោសថាគាត់ល្ងី មិនចេះខ្លាចអ្នកជិតខាងគេពេបជ្រាយថាឯងដឹកញីបស៊ីឈ្មោលសោះតែម្តង ប្រយ័ត្នតែរឿងនេះលេចឮទៅដល់ហ្លួង ច្បាស់ជាកើតរឿងរ៉ាវធំមិនខាន ។

បើនិយាយដោយពិត នុរវាមានលក្ខណៈគួរឲ្យខ្ញុំមិនចូលចិត្តច្រើនជាងទុន គឺវាចេះធីកស្រា, ចិត្តកាចឆេវឆាវ ហើយស្ងប់បំផុតត្រង់វាមានតំនិតខ្វងស៊ីលើពួកម៉ាកឯង ។ ថ្ងៃមួយ ខ្ញុំជួបវាដោយចៃដន្យ ឃើញកំពុងអង្គុយជជែកអែបរមែជាមួយមិត្តភក្តិពុកជាច្រើនទៀត ខ្ញុំក៏ក្មេងឿលថាឲ្យវាច្រើនណាស់ ប៉ុន្តែវានៅតែធ្វើមុខ

ផ្តែ មិនព្រមដឹងខ្លួនសោះ ។

ពុកនិងម៉ែ បានជំទុំគ្នាស្រេចបាច់ចហើយថា នោះជាយ៉ាងណាក៏គាត់មិនព្រមលើកខ្ញុំឲ្យទៅ នរ ដែរ ប៉ុន្តែគាត់មិនហ៊ានប្រាប់វាឲ្យដឹងខ្លួនឡើយ ព្រោះថាគួរប្រដែងមានដល់ទៅពីរនាក់ បើមួយដឹងខ្លួនថា គេមិនចូលចិត្តនឹងខ្លួនហើយ វាអាចមានការកុំឲ្យធ្វើទុក្ខបុកម្នេញគ្រួសារយើងទៅថ្ងៃក្រោយ ។ ខ្ញុំសម្គាល់ឃើញថា ពុកពេញចិត្តនឹង ទុន មែន ប៉ុន្តែគាត់ចេះលាក់ទុក ពុំងាយបញ្ចេញឲ្យម្ចាស់ខ្លួនវាដឹងទេ ដើម្បីកុំឲ្យវាបានចិត្ត ។

រឿងណាដែលមានជាប់ទាក់ទងមកក្នុងរឿងនេះ ម៉ែនិយាយប្រាប់ខ្ញុំទាំងអស់ គ្មានលាក់ប៉ុសែវសែសក់ឡើយ ហើយសំដីព្រោកប្រាជ្ញរបស់យាយអ្ចឹ អាចឲ្យខ្ញុំដឹងអស់សព្វកន្ទុកកន្ទៀត ព្រមទាំងអាចឲ្យខ្ញុំរិះរកមធ្យោបាយសម្រាប់ការពារខ្លួនជាមុនបានផង ។ យាយអ្ចឹបន្ទោសខ្ញុំថា មិនគួរធ្វើឲ្យប្រុសៗវង់ទុក្ខជាទេ ចំបែងចិត្តអញ្ចឹងសោះ ខ្លាចគេទៅថ្ងៃមុខគេតាមព្យាបាទដើម្បីសងសឹកនឹងខ្ញុំវិញ ប៉ុន្តែខ្ញុំបានសឹកសៀតសំដីឲ្យគាត់វិញច្រើនខ្លាំ ទាល់តែគាត់សើចលែងសម ។

ថ្ងៃមួយ ម៉ែចេញទៅផ្សារស្លេតាំងពីព្រលឹមស្រាងៗ ពាក់អាវរហែក ស្បៀកសំពត់ចាស់ ព្រមទាំងមានកណ្តៀតកប៉ុញ្ចែងមួយយ៉ាងខ្ចីខ្ចាំបំផុត ដោយអាងថាជិតផ្ទះឆាប់ត្រឡប់មកវិញ ។ ទៅដល់កណ្តាលផ្សារក្បែរដើមពោធិ៍ ស្រាប់តែជួបវាក់ត្នាតឹងពួកកម្លោះមួយហ្វូងដិះកង់មក, គេនាំគ្នាចុះពីលើកង់ ដោះមួកហើយលើកដៃសំពះ :

~ មីងអញ្ជើញទៅណាហ្នឹង ? (ទុន, នរ និង មិត្តភក្តិគេទាំងអស់ នុខានព្រមគ្នា) ។

ម៉ែអៀនខ្លួនជៀបឫកមិនត្រូវនៅចំមុខសេចក្តីគួរសម នៃ ពួកកូនអ្នកមានទាំងនេះ ណាមួយគាត់ស្បៀកពាក់មិនស្អាតសមរម្យផង ដែលជាហេតុធ្វើឲ្យអ្នកដើរទៅតាមផ្លូវគេបែរមើលគ្រប់គ្នា ។ ដើម្បីគេចចេញពីពួកនេះ ម៉ែប្រាប់ថាឲ្យពួកវាមកផ្ទះមុនចុះ ហើយគាត់បង្ហួសមកផ្សារតែម្នាក់ឯង ។ ម៉ែទំពីរទៅផ្សារយូរណាស់ ដើម្បីឲ្យ ទុន, នរ ភ្ញៀវចេញពីផ្ទះយើងទៅវិញ ប៉ុន្តែគាត់គន់គួរខុស មកដល់មាត់ទ្វាររបងស្រាប់តែឃើញកង់ផ្អែកគ្រៀបគ្រា នៅមាត់ជណ្តើរ និង សរសរផ្ទះ គាត់ហួសចិត្តមិនចេញស្តី សរសៀវដើរលបៗមិនឲ្យគេឃើញ យកកប៉ុញ្ចែងត្រីទៅទុកនៅឯចង្ក្រានបាយ ។ ខ្ញុំពួនទៅក្នុងបន្ទប់ខាងក្រោយជាមួយហ៊ុន លបមើលតាមប្រហោង ឃើញម៉ែលើកដៃលើកជើងឲ្យសញ្ញាទៅពុក ដែលកំពុងអង្គុយកណ្តាលហ្វូងពួកក្មេងកម្លោះ ។ គាត់និយាយកំបុតៗ បញ្ចេញទឹកមុខមិនសប្បាយចិត្ត ដើម្បីបង្ហាញឲ្យភ្ញៀវដម្លើយឃើញថាគាត់ធុញទ្រាន់ណាស់ ។ ពុកមើលយល់ទាំងអស់នូវកាយិការ ម៉ែ ដែលមានន័យថាឲ្យបណ្តេញភ្ញៀវចេញទៅ ដើម្បីឲ្យគាត់មានពេល រៀបចំផ្ទះសម្បែង ដាំបាយទឹកផង ព្រោះថ្ងៃកាន់តែខ្ពស់ណាស់ទៅហើយ ប៉ុន្តែមើលទំនងហាក់ដូចជាគ្មានសេណាមួយប្រែងងើបសោះ ។ ត្រាំមិនបានពុកក៏សុំទោសភ្ញៀវថា គាត់រវល់ជួសជុលសសរផ្ទះបន្តិច ហើយងើបឡើងទាញយកកន្ទបទៅដើរទៅក្រោមផ្ទះបាត់ គាត់សំពងសសរភ្លាមៗ... រញ្ជួយញ័រពួនផ្ទះ ធ្លាក់កំទេចស្លឹកព្រោងព្រាតមកលើក្បាលកម្លោះមុខក្រាស់ ។ ទាល់តែធ្វើអញ្ចឹងទើបពួកវាសំពះលាចេញទៅ ។ មានអារម្មណ៍ខ្លះលួចសើចសប្បាយខ្លួនផង ។

ខ្ញុំចេញពីកន្លែងពួនមកវិញ ដេរប្រទេចពួកនោះច្រើនណាស់ ហើយម៉ែក៏ប្រញាប់ប្រញាល់លាងអង្ករដាក់ដាំបាយដែរ ។ ពុកកាន់ពូថៅដើរឡើងមកលើផ្ទះវិញ និយាយអ្ចឹថា :

~ ពួកអាច្រឡឺមអស់ហ្នឹង វាចង់បង្អត់បាយកូនស្រីអញដល់ថ្ងៃត្រង់ម្តង ! ។

ចាប់តាំងពីថ្ងៃនោះមក មិនសូវឃើញ ទុន មកលេងញឹកញាប់ដូចមុនទេ ។ យាយអ្ចឹ និយាយប្រាប់ម៉ែថា គាត់តែងសង្កេតឃើញ ម្ចាស់កណ្តៀន មកផ្ទុំខ្ទុយក្បែរផ្ទះរាល់យប់ គឺប្រាកដជាមកនឹតខ្ញុំហើយ ហើយគាត់ធ្វើ

ឫកជាស្តប់ម្ចាស់ហ្នឹងខ្លាំងណាស់ ។

ចំណែកអាផ្តែ នរវិញ មុខក្រាស់រកគ្មាន គេធ្វើប៉ុណ្ណឹងហើយនៅមិនដឹងខ្លួនទៀត វានៅតែមកគួរសមជាមួយម៉ែជាទិច្ច ព្រោះវាដឹងថាម៉ែស្លូត ។ វាបញ្ចុះបញ្ចូលពន្យល់ម៉ែថា :

~ មីងកុំទុកចិត្តអានុនពេក ព្រោះវាជាមនុស្សមានពុតត្បុតអាក្រក់ ហើយវាមិនមែនស្រឡាញ់មីងដោយស្មោះទេ ។

ក្រោយមកខ្ញុំបានដឹងថា នុន មានប្រពន្ធមួយឈ្មោះខ្វែន ដែលវាធ្លាប់យកមកនៅលើផ្ទះជាមួយគ្នាអស់រយៈពេលជាច្រើនថ្ងៃ ។ ចាប់តាំងពីពេលនោះមក ពុកសម្រេចថានឹងមិនលើកខ្ញុំឲ្យទៅ នុន ឬ នរ អ្វីទាំងអស់ព្រោះពីរនាក់នេះវាគ្មានសេណាគ្រាន់បើជាងសេណាទេ ។ ខ្ញុំបណ្តេញ យាយអ្ចឹ ឲ្យចុះចេញពីផ្ទះ ហើយថែមទាំងពោលពាក្យបញ្ជីឲ្យគាត់ទៅនៅជាមួយអាផ្តែទៅ នុន នោះចុះ ។

ក្រោយបន្តិចមក លេចឃើញ នុន មកដើរក្រឡឹងផ្ទះខ្ញុំរាល់យប់ ប៉ុន្តែយប់មួយនោះងងឹតចាក់ភ្នែកមិនយល់ ស្រាប់តែមានមនុស្សមិនស្គាល់មុខមួយក្រុមព្រួតគ្នាវាយវាំបែកក្បាល ហើយរត់គេចខ្លួនបាត់ទៅ ។ ខ្ញុំយល់ច្បាស់ណាស់ ប្រាកដជាអានុរតែម្តង ដែលជួលអ្នកលេងឲ្យមកវាយពួកម៉ាកឯង ប៉ុន្តែអានេះប្រសប់ធ្វើថ្លងជាមិនដឹងអ្វីទាំងអស់ ។

រឿងវ៉ាវាធ្ងន់ដល់ប៉ុណ្ណោះហើយ ពុកព្រួយបារម្ភណាស់ខ្លាចក្រែងតែគេសងសឹកមកលើខ្លួនខ្ញុំទៀត ។ ស្ទើរតែរាល់យប់ មនុស្សប្រុសទាំងហ្វូងៗ មកប្រជុំគ្នាអ៊ូអែរក្បែរផ្ទះខ្ញុំ ទាល់តែពុកកាន់ពូថៅចុះទៅសម្លុតទើបវាបំបែកគ្នាដើរចេញ ។ ម្តងនោះ វាលបគប់ដុំថ្មមកលើដំបូលផ្ទះយើងទៀតផង ។ រាល់យប់ ពុកមិនដែលហ៊ានសម្រាន្តទេ ។ គាត់អង្គុយយាមទើសភ្ជ ហើយគាត់ឲ្យខ្ញុំឡើងដេកលើគ្រែរងើគ្រាស់ ដោយខ្លាចក្រែងមានគេលបចាក់ពីក្រោមមកតាមប្រហោងក្តារ ។

នុន ចង់សម្លាប់ នរ ឲ្យបានដើម្បីសងសឹក ប៉ុន្តែចិត្តវាមិនសូវស្ទើងផ្លូចមាត់សោះ ។ ជាសំណាងល្អស្ថានការណ៍ដ៏ធ្ងន់ធ្ងរនេះបានប្រែជាធ្ងន់ស្រាលឡើងវិញ ដោយលោកអ៊ុមជាមេខាហាន ត្រូវហ្វូងគ្រាស់បង្គាប់ឲ្យទៅការពារសន្តិសុខឯទេត្តបាត់ដំបង ដែលទើបនឹងយកបានពីសៀមមកវិញ ហើយគាត់ក៏យក នុន និង នរ ទាំងពីរនាក់ឲ្យទៅជាមួយ សម្រាប់ធ្វើជាស្មៀន ។

មុនពេលចេញដំណើរទៅ នុន បានមកជំរាបលាពុក ធ្វើមុខត្អូរឲ្យអាណិត បង្ហាញឲ្យឃើញថា វាមិនទាន់អស់សង្ឃឹមទេ ។ វាប្រាប់ពុកថា ឲ្យប្រយ័ត្ន កុំទុកចិត្តអានុរពេក សំបុត្រធ្វើមកពីបាត់ដំបង ប្រសិនបើគ្មានវាស៊ីញ៉ែ គឺប្រាកដជាអានុរ ធ្វើមកក្លែងក្លាយហើយ ។ ប៉ុន្តែពុកនិយាយប្រាប់ខ្ញុំថា គាត់បានទៅរកលោកតាយ ខែឆ្នាំ នុន និងខ្ញុំ ឃើញថា វាមិនមែនជាគ្រូព្រេងខ្ញុំទេ ថ្ងៃក្រោយខ្ញុំត្រូវមានប្តីជាជនបរទេស និងឲ្យពុកប្រយ័ត្នខ្លួនមែនទែន ព្រោះគាត់ជិតដល់ពេលអស់អាយុហើយ ។ ពេលនេះពុកកំពុងឈឺស្រាប់ផងដល់ថ្នាក់ថាគាត់ជិតស្លាប់អញ្ចឹង ខ្ញុំរឹតតែព្រួយចិត្តទ្វេមួយជាពីរ ។

មើលទៅពុក គ្មានឃើញបានធ្ងរស្រាលបន្តិចសោះ សមនឹងកើតមានរឿងពិបាកចិត្តផង គាត់ក៏កាន់តែជាបទៅ ។ ខ្លែងភ្លៅដំដូចគេបំពក់ភ្លើង ភ្នកធ្លាក់ឈាមមកពាំងខ្ញីៗ... ម៉ែដូចជាមិនសូវភ័យព្រួយប៉ុន្មានទេ ដែលជាហេតុធ្វើឲ្យខ្ញុំទុកចិត្តស្លុកថា ពុកតង់ទឹងជាសះស្បើយមិនខាន ។ ខ្ញុំចូលគិតមិនយល់ ហេតុអ្វីបានជាពុកប្រែប្រួលចរិតប្លែកពីមុនខ្លាំងម្ល៉េះ ? ចាប់តាំងពីពេលធ្លាក់ខ្លួនឈឺមក គាត់ប្រែជាសញ្ជប់សញ្ជឹង ហើយឆាប់ខឹងច្រឡោតណាស់ ។ កាលណាមានមនុស្សប្រុសឡើងមកលើផ្ទះ គាត់ធ្វើមុខមាំភ្លាមមួយរំពេច សម្លឹងសម្លក់មើលខ្ញុំសព្វគ្រប់តាំងពី សម្លៀកបំពាក់ និង កាយិការឡើងទៅ ហាក់ដូចជាចាំតែខ្វាមចាប់ទោស

កំហុស។ ម្តងនោះ ភ្ញៀវកំពុងជជែកគ្នាជាមួយពុក ខ្ញុំសម្ងំនៅក្នុងបន្ទប់ពីរនាក់ ហ៊ុន ប្រឡែងគ្នាសើចលាន់ឮទៅដល់ក្រៅ លុះភ្ញៀវលាទៅវិញមិនទាន់ចេញផុតរបងផង គាត់ក៏ចូលមកក្នុងបន្ទប់ បើកភ្នែកធំៗហើយនិយាយថា :

~ ល្អណាស់ហើយ ស្រីក្រមុំដួចឯង ដែលសើចឲ្យអ្នកក្រៅឮអញ្ចឹងនោះ... ក្រែងម៉ែឯងធ្លាប់ប្រដៅដែរឬទ្បើថា នៅមុខប្រុសឈ្មោលមិនត្រូវធ្វើឫកអញ្ចឹងទេ ហើយក៏មិនត្រូវធ្វើជាអៀនរត់គេច ចង់ឲ្យគេដើរតាមខ្លួននោះដែរ។ ឯង ចង់ធ្វើឲ្យអញខ្មាស់គេ ចង់ឲ្យគេមើលងាយ ដួចស្រីដើរហ៊ីហាតាមផ្សារអញ្ចឹងហ្អែ។

ខ្ញុំមិនអស់ចិត្តសោះ ត្រាន់តែកំហុសប៉ុណ្ណឹង មិនគួរគាត់ខឹងខ្លាំងដល់ម្ល៉ឹងទេ។ ខ្ញុំស្រក់ទឹកភ្នែកច្រោកទឹងញ៉ីដៃ ក៏ត្រជឹងចោលប្រអប់ដែលកាន់នៅដៃ ត្រូវកញ្ចក់ខ្ទួបែកខ្ចាយ។ ពុកស្ទុះចូលមកខ្នះស្មារខ្ញុំមួយដែងធាំង! ខ្ញុំងើបឈរនិយាយតឹងសរសៃកទៅរកគាត់វិញ :

~ ពុក មិនដែលវាយខ្ញុំទេ មិនដែលស្តីឲ្យខ្ញុំទេ ឥឡូវពុកវាយខ្ញុំ! ពុកជេរខ្ញុំ! ពុកលែងស្រឡាញ់ខ្ញុំហើយឬ? ចាប់តាំងពីថ្ងៃហ្នឹងតទៅ ខ្ញុំក៏លែងស្រឡាញ់ពុកឯងដែរ។

ពុកដើរចេញទៅវិញ ទាញទ្វារបិទភ្លាំង មិនចាំស្តាប់ខ្ញុំនិយាយដល់ចប់ឡើយ។ ខ្ញុំខឹងខ្លាំងម៉ែនទែនលែងគិតខុសត្រូវអ្វីទាំងអស់។ ខ្ញុំ ទាត់ប៊ីបែកកញ្ចក់ទ្ខ វាយបំបាក់កៅអី ទាញបណ្តាច់មុង លាន់ឮងតាងផ្អើលពេញផ្ទះ ដើម្បីសងសឹកនឹងការដែលពុកវាយខ្ញុំ។ បន្តាប់មក ខ្ញុំគិតថានឹងរត់ទៅនៅកាំងវិញឲ្យបាត់លែងឲ្យម៉ែនុឃើញមុខតែម្តង។ ខ្ញុំបើកហិបឈើប្រមូលយក គ្រឿងអលង្ការ សំពត់អាវ ជាហ្ស៊ី និង របស់ប្រើប្រាស់ផ្ទាល់ខ្លួនទាំងអស់ ជិចក្នុងសារុងចាស់មួយ... ប៉ុន្តែខ្ញុំគ្មានលុយមួយសេនសោះ ព្រោះប្រាក់ខែភំងនោះ ត្រូវគេកាត់យកអស់រាល់ខែ នៅយូរទៅមុខទៀតណាស់ ទំរាំផុតលុយជំពាក់, ធ្វើម្តេចខ្ញុំនឹងរត់ទៅកើត បើអត់មានលុយសោះយ៉ាងនេះ? ខ្ញុំបែកគំនិតបើកកាយថតតុដែលចំណាំឃើញគាត់អង្គុយធ្វើការរកឃើញប្រអប់ក្រដាសមួយដែលមានដាក់ ប្រាក់កាក់បួន និង លុយបួនរៀល។ ពេលនេះទើបខ្ញុំដឹងច្បាស់ថា ពុកឥតមានសល់លុយច្រើនដួចដែលខ្ញុំធ្លាប់ស្មានទោះទេ។ តើគាត់បានប្រាក់ពីណា សម្រាប់ចិញ្ចឹមខ្ញុំ, សម្រាប់ទិញរបស់ប្រើប្រាស់, ថ្នាំជក់, ទឹកអប់ ដើម្បីបំពេញចិត្តខ្ញុំរាល់ថ្ងៃ។ ខ្ញុំស្រមៃឃើញយ៉ាងច្បាស់នូវសប្បុរសធម៌ដ៏ធំធេងដែលពុកបានធ្វើចំពោះខ្ញុំ ហើយដែលពីមុនមកខ្ញុំពុំធ្លាប់បានដឹងគាល់តែសោះ។ ខ្ញុំទឹកអាណិតគាត់ខ្លោចចិត្ត សុខចិត្តដាក់លុយទៅក្នុងប្រអប់វិញ ត្រាត់បង្ខៀចទៅកៀនជញ្ជាំង ហើយប្រដេកទៅលើត្រែ យំខ្សឹកខ្សួលទឹកស្តាយមិនគួរធ្វើឲ្យ ឪពុកម្តាយ ពិបាកចិត្តដោយសារខ្លួន។

ល្ងាចនោះ ពូប៉ុល ធ្វើដំណើរពី ព្រែកថ្មី ទាំងណឹងដ៏ក្រៀមក្រំមកប្រាប់ថា ជីតាខ្ញុំឈ្មោះ ស្វាយ នោះស្លាប់ទៅហើយ ដែលជាហេតុធ្វើឲ្យយើងភ្លេចអស់ប្លឹងទាស់ទែងគ្នាក្នុងគ្រួសារ ហើយសំរេចថា ព្រឹកស្អែកនេះ យើងនឹងទៅធ្វើបុណ្យសព តាស្វាយ ទាំងអស់គ្នា ..... ។

យាយកែម អង្គុយធ្វើមុខស្រពោនត្រមង់ត្រមោចតែម្នាក់ឯង តតវល់យកចិត្តទុកដាក់នឹងបងប្អូនញាតិមិត្តដែលមកជួបជុំគ្នាពេញផ្ទះឡើយ។ ឃើញយើងទៅដល់ គាត់ញញឹមស្ងួត ហើយនាំយើងដើរតម្រង់ទៅរកចេតិយដ៏កល់ធាតុគ្រួសារ ដែលគេទើបនឹងយកសំណល់ នៃ សាកសពប្តីគាត់មកទុកទៅទីនេះដែរ។ ខ្ញុំយំអណ្តឺតអណ្តកបណ្តើរ អុជធូបដោតនៅមុខចេតិយបណ្តើរ រួចឡើងទៅលើផ្ទះដើម្បីស្តាប់យាយគាត់និយាយរៀបរាប់ប្រាប់ពីបុព្វហេតុ នៃ មរណភាពរបស់តាស្វាយ។

យើងមកដល់ឃើតពេលបន្តិច មិនបានឃើញមុខខ្មោចតាទេ ព្រោះគេមូជាហើយស្រេចតាំងពីម្សិលមិញម្ល៉េះ។ យាយកែម ពឹងគេឲ្យជួយរុះរាន់ហាលផ្ទះ ដើម្បីយកគ្រឿងឈើទៅប្រគេនលោកវត្តកោះអន្លង់ចិន

សម្រាប់ជាកុសលបញ្ជូនទៅឲ្យខ្មោចប្តីគាត់។ យើងសម្រេចចិត្តថានឹងនៅកំដរយាយពីរ-បីថ្ងៃ ចាំគាត់អន់ព្រួយចិត្តសឹមត្រឡប់មកវិញ។ មរណភាព នៃ ជីតាខ្ញុំ ធ្វើអ្វីៗប្រែប្រួលទាំងអស់ ទីធ្លាដែលធ្លាប់តែស្អាតរលីងនោះ ក៏ប្រែជាមានស្មៅដុះព្រៃបន្តែល គោក្របីត្រូវគេលែងចោលឲ្យដើរអាវិសែពាសវាលពាសកាលមាន់ដើរកកាយដីគ្មានភ័យព្រួយឡើយ ពីព្រោះគ្មានទណាមើលថែទាំសំអាតអ្វីទៀតទេ។

ពេលយប់ខ្ញុំដេកជាមួយយាយ ដើម្បីកំដរគាត់កុំឲ្យស្ងាត់ពេក។ ព្រឹកមួយទោះ ខ្ញុំងើបពីដេកឡើងតាំងពីព្រលឹមស្រាងៗដឹងថា ភ្លៅទាំងសង្ខាងត្រជាក់ស្រឹតហាក់ដួចជាទឹកទឹក លុះស្ទាបមើលឃើញសុទ្ធតែឈាម ខ្ញុំភ័យស្លុតនឹកស្មានថាសត្វអ្វីខាំ ក៏ប្រញាប់ដាស់យាយឲ្យភ្ញាក់ឡើង ដើម្បីប្រាប់គាត់ពីការកើតភ័យរបស់ខ្ញុំ។ យាយបន្ទោសខ្ញុំថាជាក្មេងល្ងី ហើយគាត់ប្រាប់ឲ្យខ្ញុំទៅស្ងៀមឈប់និយាយ ពីព្រោះខ្ញុំធំពេញក្រមុំហើយ ហើយក៏ដល់ពេលត្រូវ "ចូលម្ចាស់" ដែរ។ ត្រាន់តែប្រសៅចុះអស់ពីលើផ្ទះភ្លាម យាយយកម្សៅងនេះទៅប្រាប់ម៉ែ និង ម៉ីង ខ្ញុំ ឲ្យបានដឹងគ្រប់គ្នា រួចបន្តាប់មកគេលើកកន្លែងខ្ញុំដេកទៅដាក់ក្នុងបន្ទប់ឯងខាងក្រោយ ឆ្ងាយពីភ្នែកអ្នកផង។ គេខ្នាន់ឲ្យខ្ញុំតាំងចិត្តស្ងួតបួត កុំឲ្យខ្ញុំចេញពីបន្ទប់នេះក្នុងរយៈពេលមួយខែ កុំឲ្យបរិភោគត្រី សាច់ និង អ្វីៗទាំងអស់ដែលខ្ញុំធ្លាប់ចូលចិត្តកាលពីមុន។ មានតែស្រីៗទេដែលអាចចេញចូលកន្លែងខ្ញុំបាន ប៊ុន និង ហ៊ុន ជាបងប្អូនជីដូនមួយខ្ញុំនោះ មានការៈត្រូវលើកយកម្ហូបអាហារ និង ទឹកសម្រាប់ឆ្អែត មកឲ្យខ្ញុំដល់ក្នុងបន្ទប់តែម្តង។ ខ្ញុំធ្លាក់ខ្លួនឈឺស្រៀវស្រាញ ពុកដើរកត្រមើលឃើញថាត្រូវខ្មោចធ្វើគាត់ប៉ៀបចំធ្វើពែយកទៅសែនថ្វាយអ្នកតាដើមស្រល៉ៅ ដែលល្បីថាមានមហិទ្ធិឫទ្ធិខ្លាំងពូកែណាស់។

រស់នៅក្នុងកន្លែងឃុំឃាំងផ្ទួចមនុស្សជាប់ទោសអញ្ចឹង ពេលវេលាហាក់ដួចជាធ្វើដំណើរទៅមុខយឺតខុសធម្មតាគួរឲ្យធុញទ្រាន់ស្ទើរប្រេះទ្រេងស្លាប់ ហើយត្រណមពិបាកទ្រាំជាងគេ គឺការហាមឃាត់មិនឲ្យបរិភោគត្រីសាច់នេះឯង ម្ល៉ោះហើយជួនកាលខ្ញុំចូលទៅក្នុងចង្ក្រានបាយ លួចបានត្រីអាំងយកមកបរិភោគមិនឲ្យទណាដឹងឡើយ។

ទីបំផុត ខ្ញុំក៏បានួចទុក្ខទោសចេញពីម្ចាប់មកវិញ។ ស្ត្រីក្រមុំក្នុងភូមិនាំគ្នាផ្អើលមកមើលខ្ញុំ ហើយសរសើរថាខ្ញុំស្អាតណាស់ ដែលជាហេតុធ្វើឲ្យខ្ញុំអៀនខ្លួនមុខក្រហម រកហារមាត់និយាយថាម៉េចមិនកើត។ គេខ្នាន់ខ្ញុំជាថ្មីឲ្យបោះបង់ចោលនូវទម្លាប់ឆ្នាសកាចសាហាវ ដើម្បីធ្វើខ្លួនឲ្យបានភ្ញាយទៅជាស្ត្រីថ្លៃថ្នូរត្រឹមត្រូវនៅពេលអនាគត។ រាល់យប់មុនពេលចូលដំណេក យាយ និង ម៉ែ អុជចង្កៀងប៉ភ្លឺមើលសាស្ត្រា ច្បាប់ស្រីច្បាប់ក្លួនចៅ និង ច្បាប់ផ្សេងៗ ឲ្យខ្ញុំស្តាប់ ប៉ុន្តែខ្ញុំតតវល់យកចិត្តទុកដាក់ស្តាប់ឡើយ ព្រោះវាគ្មានកន្លែងណាគួរឲ្យពិរោះជក់ចិត្តទាល់តែសោះ។

ម៉ែ ធ្វើដំណើរមកភ្នំពេញបាត់ពីរថ្ងៃ ដើម្បីមកទូលម្ចាស់ក្សត្រីកុំឲ្យលោកទន្ទឹងខ្លាំងពេក ដោយការលោកថាខ្ញុំឈឺធ្ងន់ណាស់ ហើយពេលត្រឡប់មកវិញ គាត់ថែមទាំងខ្ចី គ្រឿងអលង្ការ និង សំពត់អាវចាំមួយសម្រាប់មកផ្ញើខ្ញុំផង។ ប៉ុន្តែពុកមានគំនិតមួយ គាត់ទៅប្រាប់តាចាស់ម្នាក់ជាអ្នកចូលរួបអារក្សថា ឲ្យខ្ញុំទៅរាំថ្វាយអ្នកតាដើមស្រល៉ៅម្តង ព្រោះលោកធ្លាប់បានជួយខ្ញុំឲ្យសះស្បើយជាជម្ងឺ។ អ្នកស្រុកសប្បាយចិត្តណាស់ ឮថាពួកណូនហ្លួងមកវាំ គេស្រុះគ្នាសង់រោង បោសសំអាតទីដីជិតខ្ទមអ្នកតា ព្រមទាំងរៀបចំសែនព្រេនតាមទំនៀមម្លាប់។

តួបអ្នកតា គឺជាខ្ទមតូចមួយសង់បន្តបលើសសរបួននៅកណ្តាលព្រៃ ដែលគេអាចដើរចូលមកបានតាមផ្លូវតែមួយគត់ កាត់កណ្តាលចំការចេក។ អ្នកភូមិព្រែកថ្មី និងឫស្សីស្រុក ទាំងអស់គ្នាមកជួបជុំអ្វីអញ្ចេញព្រៃ លុះឃើញ ពុកម៉ែ និង បងប្អូនខ្ញុំ ដើរហែហមទាំងខ្ញុំទៅដល់ គេគយគន់មើលខ្ញុំ ស្ងៀកពាក់ជាអ្នករាំ ពាក់គ្រឿង

អលង្ការ ហើយជញ្ជក់មាត់សរសើរគ្រប់គ្នា ។ នៅមុខខ្នមអ្នកតា គេកាប់ឈើសង់ធ្វើជារោងរបាំក្បែរដីដំបូក ។ ត្បូបអារក្សអង្គុយលើកន្ទេល ដៃសំពះ ដ្អែកបិទមមីរ... ខ្ញុំជីកគេជីកឯងចូលទៅដល់មុខ ឃើញគេតម្រៀបគ្រឿងសំណែនច្រើនត្រៀបត្រាពីមុខខ្នមអ្នកតា ដោយមានដុតធូបហុយក្រលោម ។ ពួកក្មេងកម្លោះគេស្ទាត្រចិត្តយកគ្រឿងភ្លេង មកលេងកំដរពិធីលៀងអារក្សនេះ ដោយពុំយកលុយកាក់ឡើយ ។

រូបអារក្សធ្វើមាត់ជិបអួចៗសូត្រមន្តអាគម រាងកាយញាក់ទទ្រើកដូចមនុស្សត្រូវខ្យា ។ បន្ទាប់មកភ្លេងក៏ចាប់លេងបទឆាបញ្ចុះ រតេតរួតគ្នាត្រូវបែបបទបន្តិចសោះ ប៉ុន្តែម៉ែត្រានខ្លាំងពេក ខ្ញុំក៏ចេញរាំទាំងខែសខាល់ ។ ស្រាប់តែរូបអារក្សស្រែកវ៉ាស! ខ្ញុំភ្ញាក់ស្ទើរលោះព្រលឹង ឈរទ្រឹងភ្លេចរាំមួយសន្ទុះធំ... គឺអ្នកតាចូលមកសណ្ឋិតក្នុងខ្លួនតានេះហើយ ។ ភ្លេងលេងរឹតតែញាប់ឡើងៗ ហើយខ្ញុំក៏រឹតតែប្រយ័ត្នប្រយែងខ្លាចខុសណាស់ដែរ ព្រោះតានេះបើកដ្អែកក្រហមផ្លែសម្លក់ខ្ញុំឥតប៉ប្រិចសោះ ព្រមទាំងលោតចាក់ត្អូកក្រមាច់ក្រមើមដូចមនុស្សឆ្កួត ។ មនុស្សដែលឈរមើលទាំងប៉ុន្មាន លើកដៃសំពះសុំស្រណុកសុខសប្បាយ អារក្សនោះក៏និយាយងើវៗថា :

~ មិនអីទេ, កុំភ័យយើងជួយថែរក្សាហើយ!

មួយសន្ទុះក្រោយមក តានេះធ្វើមឹងមាំងដូចមនុស្សទើបនឹងងើបពីដេក ហើយនិយាយថា "គេចេញទៅវិញហើយ" ។

លុះចប់សព្វគ្រប់ហើយ យើងក៏លាយាយកែមត្រឡប់មកភ្នំពេញវិញ ។ នៅពេលដើរពីផ្ទះពុកចុះទូកពុកចង្កៀលជ្រាប់ដីមានដាំដើមស្វាយ ដែលជាចំណែកមត៌កខ្មោចលោកអ៊ុំមហាសេនាប្រគល់ឲ្យខ្ញុំ ។ គាត់គិតថា កាលណាខ្ញុំឈប់នៅភាំង គាត់នឹងមកសង់ផ្ទះនៅទីនេះវិញ ។

ឮប៉ុល ចែវទូកជូនហួតមកដល់ភ្នំពេញ ប៉ុន្តែយើងដើរមិនទាន់ដល់ផ្ទះផង ស្រាប់តែជួបនឹងស្រីម៉ាឃ្យូម្នាក់ខ្វាក់ដ្អែកទាំងសង្កាង នៅក្មេងនៅឡើយ ដែលពុកធ្លាប់ជួបនៅជ្រោយចង្វាម្តង ហើយដែលធ្លាប់ល្បីខាងធ្វើស្នេហ៍ជូនលោកស្រីនៅភ្នំពេញ ។ គាត់ស្គាបខ្ញុំ ហើយរៀបរាប់ប្រាប់ហាងខ្ញុំគ្មានខុសត្រង់ណាបន្តិចសោះ ដែលជាការតួរឲ្យចូលពេកណាស់ ។ បណ្តោយឲ្យគាត់ធ្វើអីតាមចិត្តចង់លមើល តើគាត់ទាយឆុតឬមិនឆុត ។ គាត់និយាយប្រាប់ខ្ញុំថា ស្រីនៅក្នុងភាំងដែលបានគាប់ត្អូនឯងហួង ក៏ដោយសារបានស្នេហ៍ពីគាត់យកទៅប្រើប្រាស់, ម៉ាមន្ទ ដ៏ល្បីល្បាញ ដែលប្រែជាត្រូវហួងស្នប៉ាញនោះ ក៏ព្រោះតែ ម៉ាមន្ទ ពុំបានឲ្យលុយគាត់ច្រាំរយរៀល ដូចពាក្យសន្យា ។

មឹងខ្វាក់បង្គាប់ឲ្យខ្ញុំអង្គុយចុះទៅលើតុំថ្មមានក្រាលកន្ទេលពីលើ យកអំបោះដៅមកចងកដៃខ្ញុំ ដើម្បីការពារកុំឲ្យខ្មោចព្រាយបៀតបៀនបាន ហើយគាត់អុជទៀនធូបដាក់លើជើងពាន ព្រមទាំងសូត្រមន្តអាគមខ្លីបៗរួចទើបនិយាយមកកាន់ខ្ញុំថា :

~ អ្នកមានសត្រូវច្រើនណាស់ ធ្លាប្រយ័ត្នខ្លួនឲ្យមែនទែន គឺពួកម៉ាមឃុនៅក្នុងភាំង គេចង់ឈ្នានីសអ្នកស្រាប់តា ។

គាត់ប្រគល់ទឹកអប់និងម្សៅឲ្យខ្ញុំ ព្រមទាំងផ្តាំថា ចាំដល់ភាំងសឹមប្រើ ដើម្បីឲ្យគេអាណិតស្រឡាញ់។

ខ្ញុំរៀបចំខ្លួនហៀបនឹងត្រឡប់ទៅភាំងវិញ ស្រាប់តែលេចឃើញ យាយអភ័ម្នាក់ ដែលម្ចាស់ក្សត្រីបញ្ជូនឲ្យមកមើលខ្ញុំតាមបញ្ជាហួង ។ យាយនេះខ្ញុំស្គាល់គាត់ច្បាស់ណាស់ ហើយនៅពេលឃើញខ្ញុំ គាត់ហាក់ដូចជាសប្បាយរីករាយរកអ្វីមកប្រៀបឲ្យស្មើពុំបាន ។ គាត់អង្គុយលើកន្ទេលជិតខ្ញុំ ហៅខ្ញុំសុទ្ធតែកូន, គាត់លូកដៃអង្អែលជង្គង់ខ្ញុំ, អង្អែលស្មា, លូកស្ទាបរហូតដល់ពោះ, ស្រាប់តែភ្ញាក់ភ្លាត់មាត់ :

~ កូនអើយ! មីណាមាត់អាក្រក់វាទៅទូលហួងថា កូនឯងផើម!

យើងស្រឡាំងកាំងគ្រប់គ្នា ទាល់តែយាយនេះនិយាយពន្យល់សព្វគ្រប់ទើបបាត់ឆ្ងល់ បែរជាខឹកឃើញហួសចិត្តចង់សើយទៅវិញ គឺមានលេចឮសំដីទៅដល់ត្រចៀកហួងថា ការដែលបាត់ខ្ញុំយូរ មិនឃើញត្រឡប់ទៅភាំងវិញយ៉ាងនេះព្រោះខ្ញុំផើម ចង់លាក់មិនឲ្យគេដឹង ។ ប៉ុន្តែនេះវាកើតឡើងដោយសារតែមានប្រុសកម្លោះចេះតែឈ្លក់ឡើងចុះផ្ទះខ្ញុំរាល់ថ្ងៃ ប៉ុន្តែហួងមិនទាន់ជឿ ទើបប្រើគេឲ្យមកមើល ឃើញថាខ្ញុំឥតមានកំហុសដូចគេថាទេ ឲ្យទាំខ្ញុំត្រឡប់ទៅភាំងវិញ ។

♥ ♥

♥

អ្នកបំពើ



Servantes

ឡូណា ពុក និង ម៉ែ ហើយឡើងជិះរទេះជាមួយ យាយអកវ៍ ដោយយក ហ៊ុន ទៅតាមជាមួយផង។ មួយសន្ទុះក្រោយមក យើងក៏បានមកដល់ទ្វារព្រលប់ នៃ រាជវាំង ដែលផុតពីនេះទៅ គេហាមមិនឲ្យមនុស្សប្រុសចេញចូលជាដាច់ខាត លើកលែងតែ ក្រុមវាំងចាស់ៗ និង ចោយប៊ីហួង។

ខ្ញុំវ័ត៌ទៅគាល់ម្ចាស់ក្សត្រី ដើម្បីបង្ហាញខ្លួនឲ្យលោកឃើញថាខ្ញុំមកដល់ហើយ លោកអាក់ខាក់ទទួលខ្ញុំបន្តិចដែរ។ លោកប្រាប់ខ្ញុំឲ្យរៀបចំខ្លួនដើម្បីចូលជួនគាល់ប៉ាប៊ីហួងជាបន្ទាន់ ព្រោះហួងទន្ទឹងផ្លូវខ្ញុំយូរណាស់ហើយ។ ខ្ញុំត្រូវតែចូលទៅកាន់បន្ទប់ដេកមួយភ្លែតជាចាំបាច់ ដើម្បីលុបលាង និងតែងខ្លួន។ ខ្ញុំងូតទឹក, ដូរសំពត់, ដូរជាហ៊ុំ និង លាបទឹអប់, លាបម្សៅដែលត្រូម៉ាឡាយូឲ្យមកត្រួចស្រេចទើបចុះដើរតម្រង់ទៅកាន់ប្រាសាទបាញ់យ៉ាំង ទុក ហ៊ុន ឲ្យនៅបាសត្រាសសំអាតបន្ទប់តែម្នាក់ឯង។

ទៅដល់ក្នុងថែវ មានបោយភ្លឺភ្លើម្នាក់ឥតមើលឃើញខ្ញុំទេ ស្មានថាស្ងាត់នៅម្នាក់ឯង វាឆ្លុះកញ្ចក់លើកដៃទំនងផ្ទួចជាកាន់ថាស ហើយដើរទៅដើរមក ហាត់រៀនរបៀបលើកទៅថ្វាយហួងឲ្យបានសម ត្បូវឲ្យចង់សើចពេកណាស់។ ខ្ញុំភ្លក្រហែមពីចម្ងាយដើម្បីឲ្យវាដឹងខ្លួន វាភ្ញាក់ប៉ុនគេចោល ស្រាប់ចាប់ក្រណាត់មកផ្ទួតកញ្ចក់ធ្វើព្រងើយ។ ដល់ឃើញខ្ញុំដើរទៅជិត វាពិតប្រាស្រឿតខ្លួនជាប់ទឹងជញ្ជាំង ដើម្បីទុកផ្លូវឲ្យខ្ញុំដើរ។ លុះខ្ញុំដើរហួសបន្តិច វាកំសៀកខ្លួនឥតគេចទៅណាបាត់។

ខ្ញុំឈប់ទៅមុខកញ្ចក់ ឆ្លុះមើលរូបខ្លួនឯងតាំងពីក្បាលរហូតដល់ចុងជើង ត្រួចលូកដៃទៅក្រោយកញ្ចក់ទាញយកក្រដាសចិនពណ៌ក្រហមមកលាបបបូរមាត់ញញឹមស្នេញស្នាញតែម្នាក់ឯង ស្រាប់តែលេចឃើញហួងបើកទ្វារ ឈរច្រឹងស្ងៀមនៅមុខបន្ទប់ ខ្ញុំក៏បែរទៅលុតជង្គង់ថ្វាយបង្គំលោកភ្លាម លោកឈ្វោកសម្លឹងមើលខ្ញុំយ៉ាងយូរ ទើបប្រាប់ឲ្យខ្ញុំចូលទៅក្នុងបន្ទប់ដែលពេញចង្អៀតទៅដោយអស់អ្នក-អស់នាង ចូលជួនគាល់ប៊ីហួ។ លោកនិយាយរបៀបលេងសើចមកកាន់ខ្ញុំថា:

~ នែ ឯងទំនងផ្ទួចជាផើមមែនទេ?

~ ក្រាបទូល ខ្ញុំម្ចាស់អត់ដឹងទេ។

~ ថាឯងកើតជំពៅនោះ តើជំពៅត្រង់ណា? បង្ហាញអញមើល។

ខ្ញុំទាញលើកសំពត់បន្តិច បង្ហាញស្មាមបូសទ្រនិចនៅត្រង់កំភួនជើង។ ហួងសម្លឹងមើលមួយសន្ទុះ ទើបនិយាយបន្តទៅទៀត:

~ ប៉ុណ្ណឹងមិនអីទេ, អញស្មានថាឯងកើតជំពៅវែងលួយពេញខ្លួន។

និយាយហើយ លោកឡើងទៅផ្តិលើត្រែ បង្គាប់ឲ្យគេរៀបចំខ្សៀវអាហារថ្វាយ។ ផ្តិតនៅពីលើក្រឡាបន្តុំ

បក់ទៅបក់មក សាយភាយក្លិនអាហារឈ្ងុយពេញបន្ទប់ដ៏ស្ងាត់ជ្រងំ ហាក់ផ្ទួចជាមនុស្សទាំងអស់គ្នានៅក្នុងបន្ទប់នេះ ដេកលក់អស់ទៅហើយ។

ខ្ញុំចេញចេញទៅអង្គុយនៅក្រៅបន្ទប់ រង់ចាំក្រែងហួងប្រើឲ្យធ្វើអ្វីទៀត។ មីស៊ុន មីវ៉ែន និង មីស្ពាត បានឡើងហាន:គាប់ព្រះទ័យហួងខ្លាំងណាស់ គេមិនសូវរាក់ទាក់ទឹងខ្ញុំទេ ហើយទំនងផ្ទួចជាច្រណែនឈ្នានីសទឹងខ្ញុំទៀតផង។ មីស៊ុន ចេញតាមមកនិយាយពេបជ្រាយឲ្យខ្ញុំ:

~ អញកោតឯងណាស់, ហ៊ានបង្ហាញកំភួនជើងឲ្យហួងមើល! ប្រសិនបើអញវិញ អញខ្មាសគេងាប់ហើយ!។

~ ចុះត្រង់ឯងស្រាតសំពត់ឲ្យហួងមើលស្អីៗផ្សេងទៀតនោះ ម៉េចក៏មិនថាខ្មាសគេផង?

ត្រូវមួយថ្លែ វាបាត់មាត់ផ្ទួចគេចុក បើកភ្នែកធំៗសម្លក់ថ្មែរ។

~ មីសាវ៉ាម៉ាឌី! វាទៅពួនឯណាបាត់ទៅហើយ? (ហួងស្រែកស្នរពីក្នុងបន្ទប់)។ ខ្ញុំស្ទុះចូលទៅក្នុងបន្ទប៊ីវិញ ព្រមទាំងស្រែកឆ្លើយតប:

~ ព្រះពរម្ចាស់!

~ ណេះ, (ហួងនិយាយ ព្រមទាំងហុចខ្សៀវអាហារធំមួយឲ្យខ្ញុំ) យកខ្សៀនេះទៅឲ្យ ខាងដកម៉ែ គេធ្វើឲ្យស្រួល ហើយចាំយកមកវិញភ្លាមណា!

ខ្ញុំថ្វាយបង្គំរួចចេញទៅវិញ ចាប់ខ្សៀដាក់លើលើស្មា ប៉ុន្តែពេលនោះព្រលប់ធំមេរយងងឹតជាសទៅហើយ ខ្ញុំក៏ហៅក្មេងម្នាក់ឲ្យវាជូនទៅ ពីព្រោះផ្ទះអ្នកដកម៉ែ នៅខាងចុងសួនច្បារឆ្ងាយឯណោះ។ ធ្វើរួចខ្ញុំយកមកថ្វាយហួងវិញ ស្រាប់តែលោកប្រើឲ្យខ្ញុំយកខ្សៀទីពីរទៅធ្វើទៀត... ហើយខ្សៀទីប៊ី... ហើយខ្សៀទីបួន... រហូតដល់ខ្សៀទីប្រាំ។ ខ្ញុំចេះតែធ្វើតាមបង្គាប់ ដើរទៅដើរមកត្រឡប់ត្រឡិន មិនឆីកឃើញហត់ មិនបានចាប់ក្លិកឆ្ងល់អ្វីទាំងអស់។ លុះត្រឡប់មកវិញជាលើកទីប្រាំ ខ្ញុំឃើញ អស់អ្នក-អស់នាង អង្គុយព័ទ្ធជុំវិញហួងសើចកាច់កកាច់សុងគ្រប់គ្នា មីមួយនោះវាលើកដៃចង្អុលខ្ញុំព្រមទាំងសើចហៀរទឹកភ្នែក មើលទៅហួងអង្គុយលើត្រែ ដៃលើកខ្សៀអាហារសើចសប្បាយជាមួយគេឯងដែរ។ ពេលនេះទើបខ្ញុំភ្ញាក់ខ្លួនដឹងថា ហួងចង់លេងកំប្លែង។ កំប្លែងរបៀបនេះ វាផ្ទួចជាជ្រួលបន្តិច! ខ្សៀអត់ខ្លួចសោះ លោកប្រើឲ្យខ្ញុំដើរបួន-ប្រាំត្រឡប់ លេងទេ ខ្ញុំឈឺចិត្តស្ទើរស្រក់ទឹកភ្នែក ប៉ុន្តែខំទប់ធ្វើជាសើចលេងនឹងគេដែរ។

ក្នុងពេលជាបន្តមកទៀត កាលណាឃើញខ្ញុំ ហួងចេះតែញញឹម ដែលជាហេតុធ្វើឲ្យមិត្តភក្តិទាំងប៉ុន្មានតើតែច្រណែនឈ្នានីសខ្លាំងឡើងៗជាលំដាប់។ ពេលនេះ បើខ្ញុំចេះឆ្លៀត ខ្ញុំនឹងបានឡើងធ្វើជាតួឯកឈ្នានហួងមិនខាន ប៉ុន្តែខ្ញុំដឹងច្បាស់ថា ហ៊ានៈនេះម្ចាស់ក្សត្រីលោករក្សាសម្រាប់តែទុកឲ្យ មីស្ងួន ក្មួយសម្លាញ់ចិត្តរបស់លោកម្នាក់ប៉ុណ្ណោះ ម្ល៉ោះហើយខ្ញុំមិនខ្ចីរវល់ប្រកួតប្រជែងយកឈ្នះនរណាឡើយ។

ផ្លូវច្នេះ ការរស់នៅក្នុងវាំងវាគ្មានប្រយោជន៍អ្វីទៀតទេសម្រាប់ប្អូនខ្ញុំ ហើយដែលខ្ញុំចេះតែត្រាំនៅតទៅទៀត ក៏ព្រោះតែខ្ញុំធ្លាប់ដឹងជីវភាពនេះ ហើយណាមួយពុក-ម៉ែ ក៏ចេះតែថាឲ្យខ្ញុំត្រាំៗសិនទៅដែរ។

ការដែលហួងនុស្សាហ៍លេងសើចជាមួយខ្ញុំ បានធ្វើឲ្យក្រុមអ្នកច្រណែនឈ្នានីសគេសង្ស័យថាខ្ញុំ ប្រើស្នេហ៍ ប្រើមន្តអាគម ទាក់ទាញចិត្តហួងដើម្បីជែងយកឈ្នះអ្នកដែលកំពុងគាប់ត្បូរ។

ថ្ងៃមួយ ខ្ញុំឃើញទាន់ មីប៉ុន លបចូលមករុះជីអីវ៉ាន់ក្នុងបន្ទប់ខ្ញុំ យកសំពត់កញ្ចាស់ទៅបោកបក់លើខ្នូ ហើយយកខ្នើយចាក់ជារបស់ខ្ញុំមកជាន់ញីទឹងជើង ដើម្បីបស្បាបស្នេហ៍។ ខ្ញុំធ្វើជា មិនឃើញ មិនដឹង មិនឮ អ្វីទាំងអស់ ប៉ុន្តែខ្ញុំសង្កេតឃើញថា ចាប់តាំងពីថ្ងៃនោះមក ហួងមិនសូវលេងសើចនឹងខ្ញុំទៀតឡើយ។

ខ្ញុំហាក់ដូចជារស់នៅត្រមង់ត្រមោចតែម្នាក់ឯងដាច់ខ្សែកពីគេ, កាហ៊ីនប្អូនដីដូនមួយខ្ញុំនេះ វានៅក្មេងពេក មិនអាចយល់ទុក្ខធុរៈខ្ញុំបានទេ។ មិត្តភក្តិទាំងអស់ សុទ្ធសឹងជាមនុស្សអាត្មានិយម គិតតែប្រយោជន៍ផ្ទាល់ខ្លួនម្នាក់ៗ ម្ល៉ោះហើយខ្ញុំជឿថា គ្មានឥណាមួយគេបាន់អានខ្ញុំដោយស្មោះត្រង់ឡើយ។ ខ្ញុំឃើញពួកគេប្រជុំគ្នាជាក្រុមតូចៗ ជក់អាភៀន លេងបៀ ជជែកគ្នាព្រោកប្រាជ្ញ ពីរឿងប្រុស ពីរឿងរៀបការ, សូម្បីមើក្មេងតូចៗមិនទាន់ដុះដោះនៅឡើយ ក៏វាចំណាប់ណាស់ដែរ។ បើនិយាយពីដំណាក់ម្ចាស់ក្បត្រីញ ខ្ញុំញញើតលែងហ៊ានទៅរៀត ព្រោះកន្លែងនោះឥណាចង់ធ្វើអីក៏បានស្រេចនឹងចិត្ត ហើយបើទុកជាខ្ញុំទៅ ក៏គេមិនស្វះរាក់ទាក់រកខ្ញុំប៉ុន្មានដែរ។ បើឥណាមួយចង់ឲ្យម្ចាស់ក្បត្រីជួយ ទាល់តែហ៊ានឲ្យលោកចំណេញ ដូចជាព្រមឲ្យលោកកាត់យកប្រាក់ខែមួយចំណែក ឬ ប្រគល់របស់អ្វីដែលហួងប្រទានមក ឲ្យទៅលោក។

ពេលនោះមានស្រីម្នាក់ដែលពីមុនមកខ្ញុំពុំធ្លាប់យកចិត្តទុកដាក់សោះ បែរមករកាប់អានខ្ញុំយ៉ាងស្មោះត្រង់បំផុត។ វាឈ្មោះ ម្លឿង មិនចេះរាំរ៉ែកអ្វីទេ មួយថ្ងៃៗឃើញតែដើរត្រេតត្រតពេញភឹង ចាំក្រែងលោមានឥណាគេប្រើឲ្យធ្វើអ្វីបន្តិចបន្តួចប៉ុណ្ណោះ។ វា គ្មានបង្គោលទីពឹង និង គ្មានសង្ឃឹមថា បានក្លាយខ្លួនទៅជាអស់អ្នក-អស់នាង អ្វីនឹងគេឡើយ។ ម្លឿង មានចរិតស្លូតបូត មិនចេះលោភលន់ ហើយមានមារធ៌មាំ ទំនងជាអាយុវាច្រើនជាងខ្ញុំទៅទៀតក៏មិនដឹង។ ពេលហាត់ភំរាល់ព្រឹក ម្លឿង តែងមកអង្គុយស្ងៀមស្ងាត់តែម្នាក់ឯង នៅកៀនជញ្ជាំងឆ្ងាយពីទស្សនិកជនដទៃទៀត សម្លឹងមើលខ្ញុំឥតព្រិចភ្នែក ឥតរវល់យកចិត្តទុកដាក់នឹងឥណាផ្សេងទៀតទេ...។

បន្ទាប់មក វាតែងដើរយឺរក្បែរបន្ទប់ខ្ញុំដេក ឧស្សាហ៍ភក់ខាក់ជាមួយខ្ញុំ និង ទិញនំចំណីផ្គាប់ផ្គុនហ៊ុនខ្លាំងណាស់ ហើយយើងក៏ចាប់ស្គាល់គ្នាតាំងពីពេលនោះមក។ វាតួញញែរប្រាប់ខ្ញុំថា វានៅដេកក្នុងថែវជាប់នឹងរបងវត្តព្រះកែវនោះពិបាកណាស់ វាសុំមកនៅជាមួយខ្ញុំផង។ ខ្ញុំក៏យល់ព្រមឲ្យវាមកនៅដោយសុទ្ធចិត្ត ព្រោះបន្ទប់ខ្ញុំទូលាយតួរសមដែរ ណាមួយបានវាគ្រាន់ជាគ្នាជួយកំដរកុំឲ្យស្ងាត់ពេក។ វាជញ្ជូន មុង កន្ទេល និង បង្វិចទោអាវ មកដាក់នៅក្នុងបន្ទប់ ដែលជាហេតុធ្វើឲ្យអ្នកឯទៀតគេធ្លើលមកមើលគ្រប់គ្នា ខ្លះថែមទាំងនិយាយចំអែចំអន់រៀបផ្តេសផ្តាសទៀតផង។ មិនដឹងជាចង្រៃអ្វី ខ្ញុំចេះតែនឹករង្កៀសចិត្ត ចំពោះការទទួលឲ្យម្លឿងមកនៅជាមួយ ខ្ញុំហាក់ដូចជាដឹងថា ពាក្យចំអែចំអន់របស់មិត្តភក្តិទាំងនេះ ពិតជាមានសំអាងទៅលើអ្វីមួយជាក់លាក់។

ល្ងាចនេះមិនត្រូវដល់ខ្ញុំគាស់បំរើហួងនៅឯប្រាសាទបាញ់យ៉ុងទេ។ ហ៊ុនក៏ទៅយកបាយពីផ្ទះមកឲ្យខ្ញុំបរិភោគ ហើយម្លឿងក៏ចុះទៅទិញបង្អែមមកទុកឲ្យខ្ញុំលាងមាត់ទៀតផង បន្ទាប់មកវាចេញទៅអង្គុយត្រង់មាត់ទ្វារបន្ទប់ដូចឆ្កែចាំផ្ទះ ទុកឲ្យខ្ញុំបរិភោគបាយតែម្នាក់ឯង។

ភ្លើងអគ្គីសនីឆេះឡើង... ខ្ញុំដើរទៅអង្គុយនៅមាត់បង្អួច អុជបារីមួយជក់ ភ្នែកគយគន់មើលទៅបរិយាកាសខាងក្រៅដែលប្រែជាងងឹតស្លុង ក្រោមស្បៃខ្មៅនៃរាត្រីកាល។ ខ្ញុំងុយដេក ក៏ពិបាកដេក ពីព្រោះខើសទាល់តែឯ ម្លឿង ណាមួយខ្ញុំធ្លាប់រស់នៅតែម្នាក់ឯងតាំងពីយូរមកហើយ ដល់មកដេកជាមួយអ្នកដទៃអញ្ចឹង ដូចជាអផ្សុកណាស់។

ពួកម៉ាកដេកនៅក្នុងបន្ទប់ក្បែរខ្ញុំ គេនិយាយគ្នារសិបរសៀវ ហើយឮស្នូរជើងច្បាស់ ទំនងជាពួកវាដើរមកបន្ទប់ខ្ញុំតែម្តង ខ្ញុំស្ទុះទៅបិទភ្លើងភ្លាម ដើម្បីកុំឲ្យវាចូលមករំខាន។ ប៉ុន្តែហួសពេលទៅហើយ មិសំអាងមារធ៌តម្រាំងដូចប្រុស ដើរចូលមកធ្វើជាសុំភ្លើងអុជបារី ជក់ប៊ីតបង្គុយផ្សែងទ្រលោម ហើយនិយាយធ្វើហ៊ីថា:

~ មីម្លឿង វាអង្គុយធ្វើអីនៅមាត់ទ្វារ?

~ អញមិនដឹងវាអង្គុយធ្វើអីទេ (ខ្ញុំធ្លើយ តាមទិស្ស័យ ឬ ជាមនុស្សត្រង់)។

~ ម៉េចក៏ឯងមិនហៅវាមក? ឯងមិនដឹងទេឬអី ឯងមានឫកពារដូចជាប្រុស បើឯងធ្វើ (ប្អូន) វាមិនសមទេ កុំឲ្យអ្នកក្រៅគេដែល... ដោះស្រាយចាប់ឡើង ឲ្យគេដឹងថា ឥណាធ្វើ (បង) ឥណាធ្វើ (ប្អូន)។

ខ្ញុំឮស្បាហ៍ឮស្រីៗគេហៅគ្នាថា (បង) ថា (ប្អូន) អញ្ចឹងជាញឹកញាប់ ប៉ុន្តែខ្ញុំយល់ន័យពាក្យនេះបានតែពាក់កណ្តាល ក៏ធ្វើជាភ្លើមិនដឹងសោះតែម្តង ដើម្បីស្រួលឈ្លេចសួរវាឲ្យអស់សេចក្តី:

~ គ្មានឥណា បង គ្មានឥណា ប្អូនអីទេ, ម៉េចក៏ឯងសួរអញ្ចឹង?

~ អ្ហ! ឯងមិនដឹងថា មីម្លឿង វាចង់អីទេ? (សំអាង និយាយតិចៗ)។

~ ទេ! អញមិនដឹងអីទេ!

~ វានិយាយប្រាប់គេឯងដឹងគ្រប់គ្នា... ឯងចង់ឲ្យអញបង្រៀនឬ?

~ អើ!, និយាយទៅមើល... អញស្បថចុះថា អញមិនដឹងមែនណា... (ខ្ញុំនិយាយទាំងរំជើបរំជួលក្នុងចិត្ត)។

ក្នុងក្រសែភ្នែក សំអាង ខ្ញុំអាចស្មានបានខ្លះៗសេចក្តីពិតមួយចំណែកតាំងពីមុន ហើយស្តាប់សេចក្តីពន្យល់របស់វាទៅទៀត។ ប៉ុន្តែខ្ញុំស្តាប់ពាក្យពន្យល់របស់ សំអាង យ៉ាងយកចិត្តទុកដាក់ជាទីបំផុត ទោះបើម្លឿងនេះវាធ្វើឲ្យខ្ញុំអៀនឡើងក្រហមមុខយ៉ាងណាក៏ដោយ។ ខ្ញុំដូចជា ខឹងបន្តិច ចង់ដឹងបន្តិច... ខ្ញុំមិនចង់ធ្វើជាប្អូនឥណាទាំងអស់។ សំអាង វានិយាយរៀបរាប់ប្រាប់ខ្ញុំសព្វគ្រប់អស់ពេលយ៉ាងយូរ ហើយវាបញ្ជាក់ថា ការនេះជាការចាំបាច់ ដែលគ្មានឥណាអាចជៀសវាងបានឡើយ។

វាបង្គាប់ឲ្យខ្ញុំកាត់ក្រចកដៃឆ្វេងរិលអស់រលីង រួចលាចេញទៅវិញដោយឆ្លៀតទូន្មានជាចុងក្រោយបំផុតថា:

~ អាណិតវាផង ហៅវាមក!

ខ្ញុំដើបឈរឡើង បេះដូងលោតឱប... ខាក់ៗ... ស្ទើរវេរយះដើមទ្រូង ហើយញ័រជង្គង់ស្ទើរឈរមិនឡើង។ កាហ៊ីនកំពុងជជែកគ្នាអ៊ូសៗជាមួយ ម្លឿង នៅខាងក្រៅ, ខ្ញុំស្រែកប្រាប់ឲ្យ កាហ៊ីនវានៅរកកន្លែងដេកឯណាឯណឹងឲ្យបាត់ទៅ ខ្ញុំប្រឹងស្រែកទាំងសម្លេងញ័រ:

~ ម្លឿង ហ៊ាំ!

វាដើបដើរចូលមកក្នុងបន្ទប់ ព្រមទាំងនិយាយតិចៗសួរថា តើខ្ញុំហៅវាមានការអ្វី?។

ខ្ញុំច្រានទ្វារបិទ, អុជបារីមួយជក់បង្គុយ ដើម្បីបន្ទប់ចិត្តកុំឲ្យញាប់ញ័រខ្លាំងពេក។ បើកុំតែមានពន្លឺភ្លើងនៅក្នុងសួនច្បារចាំងចូលមកព្រលឹតាមបង្អួច ម្ល៉ោះសមបន្ទប់ខ្ញុំងងឹតចាក់ភ្នែកមិនយល់ទេ។

~ តស់, យើងរកដេក! (ខ្ញុំនិយាយរៀបម៉ឺងម៉ាត់ ហើយដើម្បីឲ្យចំណេញពេលបន្តិច ខ្ញុំធ្វើជាឈរផ្លៀងផ្លង លាបទឹកអប់ លាបម្សៅ មួយសន្ទុះធំ)។

វាឈរចាំខ្ញុំស្ទាក់ស្ទើរមិនព្រមបើកមុងចូលសោះ ទាល់តែខ្ញុំបើកច្រានវាចូលទៅ។

~ នែ ល្មើនឡើង!

ខ្ញុំហុចផ្ទៃតឲ្យវា ហើយឡើងទៅដេកដោយរៀបដាក់ជើងមុងក្រោមឲ្យកន្ទុយវាងងឹតផង។

ម្លឿង ដេកប្រកៀកទៅកៀន បែរខ្នងមករកខ្ញុំ។ ខ្ញុំអង្គុយច្រត់ដៃសម្លឹងមើលវាយ៉ាងយកចិត្តទុកដាក់។ ម្លឿង ស្បែកសំពត់ លែងខ្លួនទេ មានតែជាហ៊ីស្ទូត្រពណ៌ល្មើងមួយប៉ុណ្ណោះ។ ខ្ញុំប្រះដេកពីក្រោយខ្នងវា

ល្អកដៃស្តាំទៅដាក់ពីក្រោមក្បាលវា និង ល្អកដង្គង់ទៅសិកខ្ចាស់យកស្មានភាពប្រយុទ្ធ ។ វាស្រមុកតិចៗ ធ្វើឫកជាផេកលក់... ខ្ញុំថើបវាសើរៗត្រង់កញ្ឆឹងក៏វានៅតែមិនកម្រើក ខ្ញុំក៏ចាប់ខាញឲ្យវាផេកផ្ងារ រួចឡើងជិះជាប់ពីលើ ។ វាធ្វើជាភ្ញាក់ រអ៊ិតចៗថា :

~ ធ្វើអីហ្នឹង ?

ខ្ញុំឈ្លោកដាក់មុខថ្ពាល់ទៅលើស្មាវា... វាល្អកដៃមកអង្អែលដោះខ្ញុំ ប៉ុន្តែខ្ញុំក្តិចម៉ាត់ ដែលជាហេតុធ្វើឲ្យវាភ្ញាក់ព្រើត ។ ខ្ញុំនិយាយរអ៊ិបដាក់ត្រចៀកវាថា :

~ នៅឲ្យស្ងៀម អញមិនចូលចិត្តឲ្យ ល្អកលាន់អញទេ ។

វាមិនឱយាយតបថាផ្លូចម្តេចឡើយ... ខ្ញុំដើរតូធ្វើប្រុស ល្អកដៃកៀសដាហ៊ីចេញ ស្ទាបអង្អែលដោះវាដែលប្រែជាក្តៅនុណ្ឌ... ខ្ញុំអាចស្តាប់ឮចង្វាក់បេះផ្លូងយើងទាំងពីរលោតញាប់រន្ធែន ។ ហាក់ផ្លូចជាមានភ្លើងផុតឥលទ្រូងខ្ញុំឲ្យក្រហល់ក្រហាយ ញាំងចិត្តខ្ញុំឲ្យរីតតែក្លាហានថែមឡើងទៀត ។ ខ្ញុំ ឆុបរីត ថើបញាក់ញី ប៉ុន្តែ ប្អូង ចេះតែលាក់មុខ ច្រានខ្ញុំចេញ ព្រមទាំងនិយាយថា :

~ បងឯងធ្វើអីអញ្ចឹង ?

ខ្ញុំមិនឆ្លើយ គិតតែពីរវាស្រាតសំពត់វាអស់រលីងពីខ្លួន ។ ប្អូង យំអណ្តឹតអណ្តក់ ជាហេតុធ្វើឲ្យខ្ញុំរីតតែក្រពុលមុខខ្លាំងឡើង ។ ខ្ញុំលូចដៃដែលទើបនឹងកាត់ក្រចកហើយថ្មីៗ ទៅអង្អែលយោនីវា ចាប់ច្បូតហាមទន់ល្មើយផ្លូចសរសៃសូត្រ ដោយកាយិការញ្ជើរទន្ទើក តាមកម្លាំងតណ្ហាដែលកំពុងឆេះហេលរាលពេញបន្ទុកក្នុងទ្រូង ។

ត្របកភ្នែកខ្ញុំបិទបើកយ៉ាងញាប់ ចិត្តអន្ទះអន្ទែង ហាក់ផ្លូចជាកំពុងរង់ចាំព្រឹត្តិការណ៍មួយដ៏ចម្លែក ដែលនឹងកើតមានឡើងក្នុងពេលបន្តិចទៀតនេះ... តើ សំអាងវានិយាយពិតមែនឬ ?

ស្ងរសម្លេងចាប៉ីរសាត់មកពីឆ្ងាយ លាយឡំនឹងសម្លេងពួកក្មេងស្រីជំទង់នៅក្នុងសួនច្បារ ដែលស្រែកច្រៀងបន្ទរតាមហ្វូង ពិរោះគួរចាប់ចិត្ត ។ ខ្យល់ជំទោរបក់តាំក្លិនផ្កាដែលទើបនឹងរីកដោយសារទឹកសន្សើមមកផ្សព្វផ្សាយគន្ធពិភោរ ឲ្យក្រអូបឈ្ងុយពេញបន្ទប់ខ្ញុំ... ។

ចាប់តាំងពីរាត្រីដ៏ឆ្ពិតលីលោនោះ ប្អូងរីតតែស្រឡាញ់ និង គោរពខ្ញុំថែមឡើងទៀត ។ វាប៉ើខ្ញុំយ៉ាងស្មោះត្រង់បំផុត ខ្ញុំទៅណាមួយជំហាន ក៏វាទៅតាមជាប់ជានិច្ច គឺវាប្រចណ្ឌខ្ញុំណាស់ ហាក់ផ្លូចវានេះជាប្រពន្ធខ្ញុំមែនទែនអញ្ចឹង ។ មិនយូរប៉ុន្មាន ប្អូងនេះក៏ល្បីសុះសាយពេញភឹង ថែមទាំងលេចធ្លទៅដល់ ម៉ែ និង យាយកែម ទៀតផង ។ គាត់រលេះរលាំងធ្វើដំណើរមកភឹងដើម្បីខ្ចូនខ្ញុំ ហើយគាត់ព្រមានថា បើខ្ញុំនៅតែធ្វើផ្តេសផ្តាសអញ្ចឹងទៀត គាត់នឹងយកខ្ញុំទៅផ្ទះវិញ ឈប់ឲ្យនៅភឹងរហូត ។

ឥឡូវខ្ញុំអាចមើលឃើញច្បាស់ថា ស្ត្រីនៅក្នុងភឹងសុទ្ធតែលេងល្បែងស្នេហាភ្លូនដឹងនេះទាំងអស់គ្នា កម្រមានរណាជៀសវាងផុតណាស់ ។ ពួកអ្នកលេងភ្លូនដឹងនេះ គ្រាន់តែក្រឡេកភ្លាម ក៏អាចស្គាល់ភ្លាម ពីព្រោះម្នាក់ៗតែងមានឫកពារទៅតាមការដែលគេប្រកាន់ធ្វើ ជាប្រុស ឬ ជាស្រី ។

ស្រីណាដែលដើរតួជោរធ្វើជាស្រី មានឫកពារទន់ភ្លន់ ចេះផ្តាប់ផ្តួនតក់ច្របាច់ ឯស្រីដែលធ្វើជាប្រុសវិញ គេធ្វើឫកសង្ហាផ្លូចប្រុសមែនទែន ប្រើអំណាចទៅលើប្រពន្ធ គេចង់ទៅដេកនៅជាមួយប្រពន្ធណាមួយក៏បានមានស្រីមួយជំពូកទៀតដែលដើរតួចម្រុះ ចង់ធ្វើជាស្រីក៏បាន ជាប្រុសក៏បាន ។ ម្ចាស់ក្សត្រីស្ថិតនៅក្នុងចំពូកនេះឯង លោកចង់ធ្វើបងឬធ្វើប្អូន ស្រេចតែចិត្តលោកនឹកឃើញ គឺថាខ្លួនលោកនេះតែម្តង ដែលជាអ្នកផ្តល់នុទាហរណ៍អាក្រក់ឲ្យយើងយកតម្រាប់តាម ។ ហេតុនេះហើយបានជាពួកអ្នករបាំក្មេងៗ ដែលនៅ

ហាត់រាំជាមួយលោក ឆាប់ត្រប់ការណាស់ ។ ដូចយ៉ាង មីចៅជាដើម វានៅក្មេងល្អក់ ហើយស្អាតផ្លូចវេតា, រាល់យប់តែងដើរក្រឡឹងមកជិតកន្លែងខ្ញុំដេក ដើម្បីបង្ហាញឲ្យឃើញថាវាអាច .. បានហើយ ។ ប្រសិនបើខ្ញុំចង់ ខ្ញុំអាចហៅប្រពន្ធប៉ុន្មានឆាក់ឲ្យមកដេកកំដរក៏បានដែរ ហាក់ផ្លូចខ្ញុំនេះជាឥស្សរធំ មានប្រពន្ធច្រើនរាប់មិនអស់អញ្ចឹង ។

ប្អូងក៏វាមិនល្អភ្ញាក្តើតសាយភាយពេញភឹងទាំងមូល ស្តេចស្រីអាយុដប់ពីរឆ្នាំ ក៏ផ្លូចអាយុសែសិបឆ្នាំ អ្នករបាំ អ្នកចម្រៀង រហូតដល់ស្នំហ្លួង សុទ្ធតែលេងភ្លូនដឹងទាំងអស់គ្នា ពីព្រោះទំនៀមទម្លាប់នេះ តាំពីស្រុកសៀម មកដល់ភឹងស្តេចខ្មែរតាំងពីច្រើនឆ្នាំមកហើយ ។ ពួកកម្លោះៗនៅក្នុងទីក្រុង ដែលបានដឹងចរិយាមារយាទស្រីក្នុងភឹង គេពេបជ្រាយខ្លាំងណាស់ ។

ហ្លួងក៏មានការសង្ស័យក្នុងប្អូងនេះបន្តិចបន្តួចដែរ ប៉ុន្តែលោកមិនសូវរីរវល់ ព្រោះលោកចាស់ជ្រុលទៅហើយ បើនិយាយដោយខ្លី យើងគ្មានភ័យខ្លាចនរណាមកឆាឆៅទេ ម្ចាស់ក្សត្រីជាអ្នកឲ្យនុទាហរណ៍យើងគ្រាន់តែជាអ្នកយកតម្រាប់តាមប៉ុណ្ណោះ ។

ប៉ុន្តែ មានមីឆ្លូតម្នាក់ឈ្មោះ ចាន់ជ្រៀប វាធ្វើឲ្យបែកការណ៍ប្អូងនេះ បណ្តាលឲ្យចលាចល ផ្តើលណាផ្តើលណី ។ ចាន់ជ្រៀបនេះ ជាអ្នកបំរើសាសន៍ភ្លូង វាឆ្លូតមែន ប៉ុន្តែមិនដែលបង្កើតឲ្យមានគ្រោះថ្នាក់អ្វីជាធំពុំ ទើបគេចេះតែទុកឲ្យវានៅក្នុងភឹងរហូតមក ។ ថ្ងៃមួយ វានៅឃើញចាន់ ម្ចាស់ក្សត្រី និង សំអាង ជាអ្នកដើមគំនិតបង្រៀនខ្ញុំ ស្រាតនេលទាំងពីរនាក់ កំពុងនុបរីតគ្នានៅក្នុងមុង វាក៏តាំយកប្អូងនេះទៅរ៉ាយរ៉ាប់ប្រាប់ក្រុមភឹង និងអ្នកបំរើគ្រប់គ្នា ។ ខ្លួលពេលនោះ លោកមហាមន្ត្រីដើរត្រួតត្រាមើលតាហានយោមល្បាតមកដល់ឮមីឆ្លូតវាកំពុងបរិហារប្អូងយ៉ាងនេះ គាត់ក៏ប្រើតាហានឲ្យចាប់យកទៅថ្វាយម្ចាស់ក្សត្រី ។

តាមពិត ក្នុងចិត្តលោកមហាមន្ត្រី គាពីរកយណាស់ដែលនុកាសហុចឲ្យគាត់មានពេលនឹងយកប្អូងអាក្រក់ទៅទូលហ្លួង ក្នុងបំណងកាច់ផ្តួលម្ចាស់ក្សត្រី ដើម្បីទៅសល់តែគាត់ម្នាក់ឯងជាធំ ត្រួតត្រាភឹងទាំងមូល ។ ម្ចាស់ក្សត្រីខ្លាច លោកមហាមន្ត្រី និង ប្រពន្ធគាត់ ជាងហ្លួងទៅទៀត ពីព្រោះសព្វថ្ងៃនេះ គឺអ្នកទាំងពីរនេះហើយ ដែលមានអំណាចត្រួតត្រាលើអស់ស្រីក្នុងភឹង ។ លោកនឹងនឹងគេ ប៉ុន្តែធ្វើអីគេមិនកើត ក៏បែរជាស្រាចកំហឹងមកលើមនុស្សឆ្លូត ប្រើពួកខ្ញុំបំរើលោក ឲ្យវាយធ្វើបាបគ្នាស្ទើរស្លាប់ស្ទើររស់ ។

គេវាយធ្វើបាបស្រីអកុព្ទនៅជាន់ខាងក្រោមបន្តប់ខ្ញុំ ពួកស្រីពេជ្ឈឃាតធ្វើការុណកម្មយ៉ាងឃោរឃៅ ឥតមានចិត្តត្រាប្រណីបន្តិចបន្តួចសោះ គឺប្រាកដជាគេចង់វាយសម្លាប់គ្នាតែម្តង លុះវាសន្លប់បាត់ស្មារតី គេនាំគ្នាចេញអស់ទៅវិញ ទុកចោលស្រីរងគ្រោះឲ្យនៅដេកស្តូកស្តឹងម្នាក់ឯងលើក្តារ ។ ខ្ញុំរង់ចាំមើលរហូតដល់ថ្ងៃត្រង់ មិនឃើញមាននរណាត្រឡប់មកវិញ ក៏ឆ្លួសបាយមួយចានកាន់ចុះយកទៅឲ្យវាបរិភោគ ។ វាញញឹមទទួលខ្ញុំធ្វើមុខស្លី ហើយបរិភោគបាយឃ្មុមៗ ហាក់ផ្លូចជាគ្មានដឹងរឿងហេតុអ្វីទាំងអស់ ។ មួយសន្ទុះក្រោយមក ម្ចាស់ក្សត្រីត្រឡប់មកវិញ ឃើញមនុស្សទោសនៅរស់នៅឡើយ លោកក៏ស្រែកឡូឡាសួរថា នរណាហ៊ានយកបាយមកឲ្យវាស៊ី ស្រាប់តែមានមីមួយនោះលបមើលឃើញ វាទូលម្ចាស់ក្សត្រីថា ខ្ញុំជាអ្នកយកបាយឲ្យអ្នកទោសស៊ី ។

~ អីយ៉ា ! មីសាវ៉ាម៉ានីវាហ៊ានដល់ម្លឹង ? (ម្ចាស់ក្សត្រីច្រឡោតភ្លូង ប៉ុន្តែលោកម្ចាប់កំហឹងបាន ដើរចេញទៅវិញធ្វើមុខក្រញូវ) ។

ពេលនោះ បងប្រុសម្ចាស់ក្សត្រី គឺម្ចាស់ដួងមធុរ៉ា ត្រូវស្លាប់បាត់បង់ជីវិតទាំងវ័យក្មេងល្អក់ ។ នេះគឺជាការបាត់បង់បង្គោលទីពឹងមួយទៀតសម្រាប់ប្អូនខ្ញុំ ពីព្រោះម្ចាស់មធុរ៉ា តែងស្រឡាញ់រាប់អានខ្ញុំដូចភ្លូនលោក

បង្កើត ហើយលោកថែមទាំងបានទទួលទ្ធានម្ហាស់ក្សត្រីជាច្រើនលើកច្រើនគ្រា ឲ្យលើកខ្ញុំធ្វើជាតួឯងផង ។ លោកស្ទាប់ដោយជំទឹចម្លែកមួយដែលទើបនឹងឆ្លងចូលមកដល់ស្រុកខ្មែរក្នុងពេលថ្មីៗនេះ ហើយដែលបាទាំងហៅថា ជម្ងឺប៉េស្ត៍ ។ លោកវ៉ាស៊ីដង់បាទាំង បង្គាប់ឲ្យពេទ្យបាទាំងវះកាត់សាកសពពិនិត្យមើល ទោះបីម្ហាស់ក្សត្រីតវ៉ាយ៉ាងណា ក៏គេពុំព្រមស្តាប់ ។ ពេលនោះ ម្ហាស់ក្សត្រី និង បក្សពួក ទាំងាទៅនិយាយបញ្ចុះបញ្ចូលខ្មែរនៅម្តុំខាងត្បូងភ្នំង ឲ្យលើកគ្នាមកជួយតវ៉ាថែមទៀត ។ ខ្ញុំរត់ឡើងទៅលើវាទហាលជាមួយមិត្តភក្តិជាងដប់នាក់ ដើម្បីមើលវ៉ាស៊ីដង់បាទាំង អញ្ជើញមកសម្រុះសម្រួលបាតុករ ។ ម្នាក់នោះហៅខ្ញុំឲ្យចូលទៅជិតវា ហើយចង្អុលប្រាប់ថា :

~ សាវ៉ាម៉ាទី ! មើលទំបាទាំងនោះនៅក្មេងសោះ ប៉ុន្តែខ្ពស់ចង្រ្កោង គាត់ហ្នឹងអាយុយ៉ាងច្រើនណាស់ត្រឹមដប់ប្រាំឆ្នាំប៉ុណ្ណឹង ។

ខ្ញុំអើតមើលទៅខាងក្រោមតាមដៃគេចង្អុល ហើយនេះជាលើកទីមួយដែលខ្ញុំបានឃើញ លោក[11] ពេលដែលលោកឈរើនៅមុខប្រាសាទជំកល់ព្រះទ័ពរាជ[12] ។ ត្រាន់តែឃើញលោកភ្លាម ទ្រូងខ្ញុំប្រែជាញាប់ញ័រ ខ្លួនប្រាណប្រែជាស្លាំង ដូចគ្មានឈាមមួយដំណក់នៅក្នុងខ្លួន ។ ខ្ញុំប្រញាប់គេចថយមកក្រោយវិញ និយាយរឿងនេះប្រាប់ សំអាង ស្រាប់តែវាផ្ទុះសំណើច ព្រមទាំងនិយាយខ្លាំងៗថា :

~ អើ ! អានេះគេហៅថាប្រផ្នូល ! សាវ៉ាម៉ាទីឯង ប្រាកដជាបាទប្តីបាទាំងហ្នឹងហើយ ។

ពួកគេបានពាក្យនេះ ទាំងាចំអន់បង្អាប់ខ្ញុំ ពីរ-បីថ្ងៃ បន្តាប់មកគ្មានទណាគឺកឃើញដល់រឿងនេះទៀតឡើយ ។

♥ ♥

នាដ្យូតាវីក្នុងៗ



(11) សូមមិត្តអ្នកអានកុំភ្លេចថា ជំណើរឡើងតាំងពីដើមរហូតមកដល់នេះ គឺជារឿងដែល សាវ៉ាម៉ាទី និយាយប្រាប់ប្តីងាងជាជាតិបាទាំងឈ្មោះ កម្លោះ ។

(12) សូមមិត្តអ្នកអានកុំភ្លេចថា ជំណើរឡើងតាំងពីដើមរហូតមកដល់នេះ គឺជារឿងដែល សាវ៉ាម៉ាទី និយាយប្រាប់ប្តីងាងជាជាតិបាទាំងឈ្មោះ កម្លោះ ។

ពេល ជំលាចេះតែកន្លងទៅមុខឥតអាក់ ដោយគ្មានកើតព្រឹត្តិការណ៍អ្វីជាសំខាន់ឡើយ.. រដូវភ្លៀង នៃ ឆ្នាំវក ក៏កន្លងផុតទៅ ។

ចាប់តាំងពីថ្ងៃមួយកើត នៃ ខែកក្តិក ខ្យល់បក់មកពីខាងជើងរហើយត្រសៀក ក្រោមផ្ទៃមេឃស្រឡះល្ហល្ហៅ ទឹកទន្លេធំក៏ចាប់ផ្តើមហូរត្រឡប់ទៅកាន់សមុទ្រវិញ ។

រៀងរាល់ឆ្នាំ តែដល់ពេលនេះ យើងទាំងាចុះទៅក្នុងទីទាំងផែ ដើម្បីប្រារព្ធធ្វើពិធីបុណ្យអុំទូក និង សំពះព្រះខែ ។ ពួកអស់អ្នក-អស់ទាង ដើរជាក្រុមតូចៗ មានយាយចាស់ទុំ និង ក្រុមក៏ង តាមអមជួនដំណើរជាប់ជាទិច្ច ។ ផ្លូវពីមាត់ទ្វារភ៉ាងទៅកំពង់ផែ ប្រជើងមួយចំអាមសោះ ប៉ុន្តែមនុស្សម្នាភាគច្រើនសុទ្ធតែប្រុសៗ ទាំងាប្រជ្រៀតឈរអមសង្កាងផ្លូវ ដើម្បីមើលស្រីក្នុងភ៉ាងឲ្យឃើញច្បាស់ទឹងហ្នឹកម្តង ព្រោះម្នាក់ៗសុទ្ធតែឆ្លាប់ឮគេនិយាយ ថាអញ្ជេះ ថាអញ្ជុះ ប៉ុន្តែកម្រមានទណាបានឃើញណាស់ ។ ទណាគេមាក់ទងមានតួសង្ហារនៅក្រៅភ៉ាង គេឆ្លៀតទុកាសនេះដើរទៅដើរមក ថែមទាំងកាច់ឫកកាច់រាង ដើម្បីទាក់ទាញចិត្តតួសង្ហារគេ ។ ចំណែកស្រីត្រឹមត្រូវដូចយ៉ាង និង ខ្ញុំ ជាដើម យើងមករស់នៅក្នុងភ៉ាង ព្រោះស្រឡាញ់ចង់បានកិត្តិយស ពុំមែនដើម្បីមកដើរបង្ហូតសាហាយទេ ។ កាលពីរាជ្យហ្លួង សុវណ្ណកោដ្ឋ គេយកកំណាត់មកពាសបាំងសង្កាងផ្លូវ តាំងពីទ្វារភ៉ាងរហូតដល់មាត់ទន្លេ ហើយមានជាក់ទាហានឲ្យឈរយាមទៀតផង ។ ប្រសាទៅពីក្រោយ ផ្តាំងកំណាត់ ត្រូវអង្គុយលុតជង្គង់ទុនមុខចុះ មិនឲ្យងើបមុខមើលពួកយើងជាដាច់ខាត ។ ប៉ុន្តែក្នុងរាជ្យថ្មីនេះ ប្រសច្រឡឺមឈរដង្ហែលើចិញ្ចើមថ្នល់ វាគយគន់មើលយើងឥតកោតញញើត មើលទាល់តែយើងអៀនមិនហ៊ានងើបមុខ ។

យើងដើរចុះតាមច្រាំងទន្លេ ដែលទឹកស្រកចុះអស់ច្រើនណាស់ទៅហើយ... មើលទៅម្តាង ឃើញដំបូលផ្ទះខ្ញុំលេចលើមៗ បន្តិនឹងស្ទឹករុក្ខជាតិ ។ សសរដងកើរខ្ចេតខ្ចោត ហាក់រកកលនឹងរលំធ្លាក់ទៅក្នុងទន្លេ... យើងដើរឆ្លងស្ពានទៅដល់លើទីទាំងផែ ដែលជាកន្លែងពិសេស គេរក្សាទុកសម្រាប់តែពួកយើង ។

បន្ទប់ហ្លួងស្ថិតនៅចំកណ្តាលផែ ពាសជញ្ជាំងធ្វើពីឈើបេងរលោងស្រិល មានទុកចន្លោះធំល្មមអាចដើរក្រឡឹងជុំវិញបាន ។ សាឡុងធំស្ថិតនៅចំពីមុខបន្ទប់ បែរមុខទៅខាងកើតឆ្ពោះទៅរកផ្ទៃទន្លេ ដែលប្រកបទៅដោយទឹករលកបោកបាចឥតឈប់ឈរ ។

បុណ្យអុំទូក ប្រព្រឹត្តទៅបីថ្ងៃបីយប់ជាប់គ្នា ហើយត្រូវបញ្ចប់ក្នុងថ្ងៃពេញបូណ៌មី នៃ ខែកក្តិក ។ ជំលារសៀល នៃ ថ្ងៃនោះ ការប្រណាំងទូកង បានទាក់ទាញរាស្ត្រនៅក្នុងខេត្តជិតខាងរាជធានី ឲ្យមកប្រជ្រៀតគ្នាពេញមាត់ទន្លេ ដើម្បីមើលទស្សនីយភាពប្រចាំឆ្នាំដ៏ត្រកាលនេះ ។ ពួកបាទាំងអង្គុយលើទីទាំងរបាគ ចត

ក្បែរទីតាំងផែ ដែលនៅលើនោះ មានក្រុមតន្ត្រីប្រគុំជាប់ហូត ដល់ពេលព្រលប់ធំទើបឈប់ ។

ទូកចែវបញ្ជាសទឹក កាត់តាមមុខទីតាំងផែឡើងទៅកាន់ដើមទីប្រណាំង, មួយសន្ទុះក្រោយមក ឃើញត្រឡប់មកវិញម្តងមួយឆ្ងាយ ចែវលឿនស្ទើរដោយមនុស្សប្រុសមានធំមាំ ។ អ្នកខ្លះប្រើត្រចៀងឈរចែវ, ខ្លះអង្គុយអុំ, ទូកនីមួយៗផ្ទុកមនុស្សហាសិបនាក់ឬច្រើនជាងនេះផងក៏មាន បណ្តាលឲ្យទូកធ្ងន់ធៀបសឹងនឹងលិច ។ ក្បាលទូកងស្ទើត មានមេក្រុមអង្គុយលើនោះ លើកដៃលើកជើងជាចង្វាក់ និង នៅកណ្តាលទូកមានតួកម្នាក់លោតចាក់ក្បាច់ក្រមាច់ក្រមើម ញាក់មុខញាក់មាត់ ដាក់ហួង ដាក់ពួកទាម៉ឺន និង ដាក់ពួកយើង ។ ពេលធម្មតា គេមិនអនុញ្ញាតឲ្យនរណាចាក់តួកធ្វើឫកច្រឡឹមបែបនេះជាមួយហួងជាដាច់ខាត ប៉ុន្តែពេលនេះជាពេលបុណ្យមាន ទើបហួងលើកលែងទោសមិនប្រកែកប្រកាន់ ។ ខ្ញុំឃើញឮប៉ុលអង្គុយទំលើក្បាលទូកវត្តកោះអន្ធង់ចិន កំពុងចាក់ក្បាច់ខ្លាំងដៃសម្បើមណាស់ ។ ស្នូរច្រវៀគោះទឹកលាន់ឮស្ទូរព្រឺបៗ ធ្វើចង្វាក់លាយឡំនឹងចម្រៀងស្រែកបន្លរ ហៃអើ! ហៃអើ!... ។

ចុងក្រោយគេបង្អស់ គឺទូកមួយធំដាក់មនុស្សពេញព្រៀប ស្រែកហ៊ោកញ្ជ្រៀវលាន់ខ្ទរមកដល់ច្រាំងចែវទៅមុខឡើងរង្គើទឹក ដួចត្រូវព្យុះបក់ចោក ។

បន្ទាប់មក ទូកទាំងអស់តម្រៀបបន្តកន្ទុយគ្នា តាមបណ្តោយទីតាំងរូបនាគ ចាំទទួលយកអំណោយហួងដែលទាម៉ឺនភឹងគេនាំយកទៅចែកឲ្យគ្រប់ៗគ្នា ។ ទស្សនិកជនបំបែកគ្នាវិលទៅកាន់គេហដ្ឋានរៀងៗខ្លួន ឯពួកបាភាំងក៏ត្រឡប់ទៅផ្ទះគ្រើញដែរ ។ កប៉ាល់ហួងដែលចតនៅពីមុខទីតាំងផែ និង កប៉ាល់ជាច្រើនទៀតរបស់ពួកទាម៉ឺនសព្វមុខមន្ត្រី ចាប់អុជប្រទីបថ្វាលាភ្លឺព្រោងព្រាត មានតាក់តែងលំអជារូបផ្សេងៗ រហូតដល់សសរផងកើ ក៏មានអុជភ្លើងបំភ្លឺតាំងពីក្រោមរហូតដល់ចុងកំពូល ។ កាំជ្រួចភ្លឺទៀផ្ទុះក្អូម! ភ្លាំង! ភ្លឺខ្ចោលអស់មួយចំហៀងមេឃ ហើយកប៉ាល់ប្រទីបក៏ចាប់ផ្តើមធ្វើដំណើរទៅមុខយឺតៗ ប្រកបដោយភ្លើងតាក់តែងលំអយ៉ាងត្រកាល កណ្តាលស្បៃងងឹតនៃរាត្រីកាល ។ អស់អ្នក-អស់ទាង ជាច្រើនរូប រួមទាំងខ្ញុំផង យើងនាំគ្នាឆ្លងទៅកាន់ ទីតាំងរូបនាគ និង ទូកដទៃទៀត ដែលចតនៅជាប់គ្នា ។ គេចែកជាវចែកកាំជ្រួច ឲ្យយើងអុជលេងយ៉ាងសប្បាយរីករាយ ប៉ុន្តែដោយជិតដល់ពេលចូលវេនគាល់បំរើហួងទៅហើយ ខ្ញុំក៏ត្រឡប់មកកាន់ទីតាំងផែវិញ ។ អង្គុយជជែកគ្នាលេងនៅត្រង់សាឡុង ដែលហួងគង់ឧតមើលការប្រណាំងទូកកាលពីថ្ងៃ ។

នៅទិសខាងកើតឆ្ងាយឯណោះ ព្រះចន្ទពេញវង់នៃខែកត្តិក រះឡើងមួលក្រឡង់ ចោលកំទេចស្មើស្រទន់ត្រជាក់ពណ៌ប្រាក់ ចាំងធ្លុះលើផ្ទៃទន្លេ... ។

ហួងចេញមកមើលកប៉ាល់លយប្រទីបតែមួយភ្លែត ក៏ត្រឡប់ចូលទៅក្នុងបន្ទប់វិញ ហើយបង្គាប់ឲ្យគេរៀបក្រយាពេលល្ងាចថ្វាយ ។ ក្រុមហួងពិណពាទ្យចាប់ប្រគុំបទបើកឆាក ហើយស្រីៗដែលតែងខ្លួនស្រស់បំព្រង អង្គុយត្រៀបត្រាទៅក្នុងសាឡុងធំនោះ ក៏ស្រែកច្រៀងបទសក្រវាឌី យ៉ាងពិរោះលន្ឋង់លន្ឋោចកណ្តាលសកាពស្ងប់ស្ងាត់ នៃ រាត្រីកាល ។

ហួងផ្ទំសោយអាភៀនទៅក្នុងបន្ទប់ មានស្រីស្អាតៗចាំបំរើ មានសម្លេងទិព្វច្រៀងបទសក្រវាឌីបំពេ ផ្សំនឹងទីតាំងផ្លៀងទៅផ្លៀងមកតាមកម្លាំងទឹករលកផ្ទួចគេយោលអង្រឹងទោះផង លោកប្រែជាងោកងុយធ្វើភ្នែកមមីរ ។

បទសក្រវាឌីចប់ទៅ ដោយអ្នកចម្រៀងត្រូវសំរាក បរិភោគនំចំណី និង ផឹកស្រាកំដៅពោះបន្តិចសិនពីព្រោះពេលនេះខ្យល់ជំនោរត្រជាក់បក់ចោកមកឥតឈប់ បណ្តាលឲ្យរងាព្រឺសម្បុរតឹងតក់ ។

នៅលើទូកមួយផ្សេងទៀត ប្រុសៗសម្លេងត្រលរស្រែកច្រៀងជាទំនុកធ្វើយឆ្លងនឹងយើង ហើយបន្ទាប់

មក សម្លេងប្រុសស្រីស្រែកច្រៀងចម្រុះគ្នាលាន់ឮចេញពីគ្រប់ទូកពួកទាម៉ឺនហួង ។

ហួងចេញមកត្រង់សាឡុងជាថ្មីម្តងទៀត សម្លឹង មើលព្រះចន្ទ មើលទឹក មើលដី មើលស្រីក្មេងៗដែលនៅតាល់ត្រៀបត្រា ។ លោកសម្លឹងមើលពួកយើងមួយត្រួស ឃើញខ្ញុំអង្គុយលាយឡំជាមួយអ្នកចម្រៀងដទៃទៀត ក៏សួរថា :

~ យី, ឯងច្រៀងដែរឬ ? អញឮថាប់តែឮគេថា ឯងខ្វិលច្រអូសណាស់, រួចម៉េចក៏ឯងចេះធ្វើការដែរ ?

ថាហើយលោកដើរក្រឡឹងមួយជុំ ទើបបង្គាប់ឲ្យគេលើកយកអំបុកមកថ្វាយ ។ គេយកអំបុកច្រើនណាស់មកឲ្យយើងបរិភោគ យើងខំតែរតាល់តែដោយឆ្គាមតាំងរង់ញាក់ទន្ទ្រើក ទោះបីយើងមានជាហ៊ឺដណ្តប់គ្រប់គ្នាយ៉ាងណាក៏ដោយ ។ អំបុកសម្រាប់ហួង ធ្វើឡើងដោយស្រូវពិសេស ធុំក្លិនឈ្ងុយឆ្ងល់ឲ្យស្រក់ទឹកមាត់ ។ យើងបរិភោគអំបុកហើយ ផឹកស្រាបាភាំងកំដៅពោះ និង ជក់ចាវីស៊ីហ្គារ៍ផង ។

ខ្ញុំអង្គុយច្រៀងមួយយប់ទល់ភ្លឺ ដើម្បីបំពេរឲ្យហួងផ្ទំលក់ស្រួល ។ អស់លោកជំទាវ លោកស្រីប្រពន្ធទាម៉ឺន នាំគ្នាឡើងមកលើទីតាំងផែដើម្បីកំសាន្តយើង ទាំងដែកពីនេះពីនោះពេលយើងឈប់ច្រៀងម្តងៗ ។ ប៉ុន្តែតាមសម្លឹងមើលខ្ញុំដាប់ជាទិច្ច ទំនងដួចជាប្រចំណូ ពេលឃើញខ្ញុំនិយាយព្រោកប្រាជ្ញជាមួយស្រីៗដទៃទៀត ។ វាយកស្ករគ្រាប់មកឲ្យខ្ញុំបរិភោគ ហើយបង្ខំឲ្យខ្ញុំទទួលយកតាល់តែបាន ដែលជាការឲ្យរង្គៀសចិត្តពេកណាស់ ។

ទូកនីមួយៗ ច្រៀងជាបន្តបន្ទាប់គ្នា ដល់ទីបញ្ចប់ក៏បានមកដល់វេនពួកខ្ញុំច្រៀងម្តងទៀត ។ ព្រះចន្ទយាងជ្រេហួសទៅទិសខាងលិច កប់បាត់ឯជើងមេឃ... កាំភ្លើងពេលព្រឹកបាញ់ ភ្លាំង! ភ្លាំង! ឮសម្លេងយ៉ាងច្បាស់សោត់មកដល់យើង ។ ផ្កាយរលត់បាត់ស្ទើម្តងមួយៗ ផ្ទៃមេឃក៏ប្រែជាភ្លឺស្រឡះប្តឹចឡើងវិញដែរ ។

អ្នកចម្រៀង ប្រុស-ស្រី ដែលមកច្រៀងលេងជាមួយយើងពេញបីយប់ជាប់គ្នាខោះ ក៏លាត្រឡប់ទៅវិញ តាំយកទាំងក្តីស្តាយស្រណោះមិនអាចគណនាបាន ទៅជាមួយផង ។

ការសប្បាយីករាយត្រូវចប់ត្រឹមនេះហើយ ប៉ុន្តែហួងដួចជាពេញចិត្តនឹងរស់នៅលើទីតាំងផែ ទើបលោកសម្រេចថា នឹងបន្តស្នាក់នៅទីនេះបន្តិចទៅទៀត ។ នរណាអស់កម្លាំងដោយមិនបានផេកពេញបីយប់នោះ គេឡើងមកភឹងផេកសម្រាកយកកម្លាំងបន្តិចសិន ។ ខ្ញុំក៏ឡើងមកជាមួយគេឯងដែរ គ្រាន់តែមកដល់បន្តប់ប្រុះផេកភ្លាមក៏លក់ភ្លាម ទាល់តែព្រលប់ធំ កាហ៊ុនវាជាស់ឲ្យងើបបរិភោគបាយ ទើបភ្ញាក់ដឹងខ្លួន ។ ខ្ញុំឥតឃ្លានសោះ ប៉ុន្តែចេះតែទំលេបបង្ការកុំឲ្យឃ្លានយប់ព្រលប់ ហើយមុនទឹងចុះទៅចូលវេនគាល់បម្រើហួងឯទីតាំងផែវិញ ខ្ញុំឆ្លៀតបោសច្រាសបន្តប់ និង ត្រែព្វកផេកបន្តិចផង ។ កំពុងតែរៀបចំបន្តប់ ខ្ញុំស្រាប់តែទឹកភ្នកឃើញរឿងអ្វីមួយ ញ៉ាំងចិត្តឲ្យតិតភ័យញាប់ញ័រដោយមិនសមហេតុសមផល ។ ឃើញអញ្ចឹង កាហ៊ុនវាចូលបើកភ្នែកធំៗ... តើខ្ញុំភ័យពីរឿងអ្វី ? ខ្ញុំគិតមិនយល់តាល់តែសោះ... តាមបង្ហួច ខ្ញុំមើលឃើញព្រះអាទិត្យលិចបាត់ឯជើងមេឃទិសខាងលិចទៅហើយ សល់កំទេចស្មើដែលចាំងធ្លុះលើដំបូលផ្ទះប្រាសាទពណ៌មាស ។ ខ្យល់ជំនោរបក់បោកហើយត្រសៀក ទាំសម្លេងខ្លែងឯកពីទីធ្លាយឮលើយៗ ញ៉ាំងចិត្តខ្ញុំឲ្យស្រងេះស្រងោចក្រៃលែង ។ ក្អែកមួយហ្វូងហើរស្រែកកោកកាកមកទំលើដើមគគីរ ស្រែកបួលឆ្ងងឆ្លើយគ្នាទ្រហឹងអឺងអាប់ កណ្តាលបរិយាកាសស្ងប់ស្ងាត់នៅក្នុងវាំង ។

សម្លេងយាយកែម ដាស់ខ្ញុំឲ្យភ្ញាក់ពីក្តីស្រមៃ ខ្ញុំងាកទៅក្រោយឃើញយាយស្ងៀកពាក់ស ឈរនៅត្រង់មាត់ទ្វារ មានទឹកមុខស្រពាប់ស្រពោន ។ គាត់និយាយមកកាន់ខ្ញុំថា :

~ ចៅ! ងុពុកឯងមិនស្រួលខ្លាំងហើយ វាចង់ឃើញមុខចៅឯងណាស់ ។ ចៅឯងសុំច្បាប់ហួងទៅផ្ទះ

ដើម្បីមើលថែទាំវាពីរ-បីថ្ងៃ បានទេ ?

ខ្ញុំដើរតាមយាយហួតដល់ផ្ទះ ទាំងចិត្តភ្ញាក់ផ្អើលស្ទើរទប់ទឹកភ្នែកមិនឲ្យស្រក់ចុះមកមិនបាន ។ ខ្ញុំឡើងទៅលើផ្ទះឃើញ ញាតិមិត្តអ្នកជិតខាងខ្លះ និង ម៉ែ អង្គុយព័ទ្ធជុំវិញពុក ដែលគេដាក់ឲ្យសំរាន្ត ភ្នែកបិទជិត ដកដង្ហើមញាប់ជង្ហក់ ដៃលើកដាក់ប្រណម្យលើដើមទ្រូង ។ គាត់បើកភ្នែកឡើងឃើញខ្ញុំ ក៏ញ្រ្ជឹងញញឹម ហើយពោលខ្សាវៗ :

~ ក្មួយមកដល់ហើយឬអី ? ពុកដឹងខ្លួនថាមិនស្រួលខ្លាំងហើយ, ក្មួយឯងទៅសុំច្បាប់ហួងលមើល បើលោកឲ្យឈប់ក៏ឈប់ បើលោកមិនឲ្យទេក៏ហីទៅ ប៉ុន្តែ... ពុកចង់បានក្មួយឯងមកទៅជិតឲ្យបានទាន់ដង្ហើមពីព្រោះពុកមិនដឹងជាស្លាប់ពេលណាទេ... ។

ខ្ញុំវាចូលទៅជិតពុក ច្របាច់ជើងគាត់ថ្នមៗ... មេឃងងឹតបន្តិចហើយ ម៉ែអុជចង្កៀងតូចមួយ យកមកដាក់ជិតពុក រួចលុតដង្គង់ លើកដៃសំពះធ្វើមាត់ដិបអួចៗ ។ ខ្ញុំចេញក្រៅដាយយ៉ាងល្បើសសំដៅផែ ទាន់ឃើញហួងកំពុងស្ទៀកពាក់ខោអាវ។ ខ្ញុំអង្វរមីវ៉ែន ឲ្យវាជួយសុំហួងឲ្យខ្ញុំបានទៅផ្ទះផង ពីព្រោះវាឲ្យកែសំដីលែបខាយជាងខ្ញុំ វាក៏យល់ព្រមជួយដោយសុទ្ធចិត្ត ។ វាថ្វាយបង្គំរៀបរាប់ទូលហួងបន្តែមបន្តួយតាមដែលទឹកឃើញ ហួងក៏ឆ្លើយតបវិញថា :

~ អើ ! បើនុំពុក សាំ៉ាម៉ាឌី ឈឺ ឲ្យវាទៅផ្ទះមើលនុំពុកវាចុះ !

ខ្ញុំប្រញាប់ត្រឡប់មកផ្ទះវិញយ៉ាងរួសរាន់ ។ ពុកបម្រាស់នទៀលលើកន្ទេល ក្តួតធ្លាក់ឈាមទាំងដុំៗ ពួកប្រុសៗគេទំនួយទប់គាត់ណាស់ដែរ ប៉ុន្តែគាត់ចេះតែធើបំរះ ព្រមទាំងពោលពាក្យមិនសមរម្យផ្សេងគ្រប់ចាស់ម្នាក់, ដែលថាមកព្យាបាលគាត់ឲ្យជាសះស្បើយ តែកាលពីល្ងាច បែរជាឲ្យគាត់លេបថ្នាំអ្វីម្យ៉ាង ដែលធ្វើទុក្ខក្តៅអន្ទះអន្ទែងត្រាំមិនបាន ។ ទោះបីឃើញគាត់ឈឺធ្ងន់យ៉ាងនេះក៏ដោយ ក៏ខ្ញុំពុំបានគិតថា ពុកនឹងស្លាប់ក្នុងពេលខាងមុខនេះសោះ ។

ដល់ពេលពាក់កណ្តាលអាធ្រាត្រ គាត់ផ្ទុចជាបានសម្ងំខ្លះ ។ យាយ ម៉ែ ព្រមទាំងញាតិខ្លះទៀត គេស្ទើរគ្រចិត្តទៅជួយកំដរហួតដល់ភ្លឺ ។ ចំណែកខ្ញុំ អត់ងងុយកាលបុណ្យអុំទូកនោះ មិនទាន់មានកម្លាំងស្រួលបួលឡើងវិញផង ក៏ទៅប្រុងដេកលក់យ៉ាងស្រួលទៅលើគ្រែ ។ ខ្ញុំភ្ញាក់ពីដេក ថ្ងៃមិនទាន់រះពេញទៅឡើយ ។ ពុកច្រត់ដៃប្រឹងងើបដើម្បីពិសារទឹកថ្នាំក្តៅហុយ ហើយទៅពេល ឃើញចង្កៀង ឃើញព្រះអាទិត្យរះ គាត់ដកដង្ហើមធំនិយាយថា :

~ យ៉ាងយូរណាស់ពីរម៉ោងទៀត ខ្ញុំនឹងស្លាប់ហើយ ម៉ែវ៉ា, ក្មួយ និង បងប្អូនទាំងអស់ សូមឲ្យបងប្អូនជួយមើលខុសត្រូវប្រពន្ធក្មួយខ្ញុំផង ។ ខ្ញុំស្តាយណាស់មិនត្រូវស្លាប់ ទាំងពេញកម្លាំង ទាំងមិនទាន់បានរៀបចំអនាគតក្មួយស្រីឲ្យបានស្រួលបួល ស្លាប់ចោលប្រពន្ធឲ្យនៅរស់លំបាកវេទនា... ។

ឮគាត់និយាយអញ្ចឹង យើងទាំងអស់គ្នាក្តុកក្តួលក្នុងចិត្ត ស្រក់ទឹកភ្នែកច្រោកៗ ។ ម៉ែទ្រហោយំគក់ទ្រូង រួចស្រែកអោបដង្គង់ពុក អង្វរឲ្យគាត់ឈប់និយាយ ប៉ុន្តែពុកមិនព្រមឈប់សោះ ។ បន្តិចក្រោយមក គាត់ប្រឹងត្រដងើបអង្គុយ ប្រាប់ឲ្យយើងជួយងូតទឹកសំអាតខ្លួនគាត់បន្តិច ។ ពួកប្រុសៗជួយលើកវំកិលដាក់គាត់មកលើក្តារ ស្រោចទឹក ជុសសាប៊ូ ជុះក្លែសព្វមុខមាត់ដៃជើង រួចហើយគេផ្លាស់ឲ្យគាត់ស្លៀកសំពត់ថ្មីមួយទៀត ។ ប៉ុន្តែមុនទឹងសំរាន្តទៅវិញ គាត់ ឲ្យគេសិតសក់ ឲ្យយកទឹកមកខ្ចូលមាត់ ។ លុះស្អាតស្រួលបួលហើយ គាត់ញញឹមបន្តិចសំដែងការពេញចិត្ត រួចឲ្យគេផ្តេកគាត់ទៅកន្ទេលវិញ ។

យាយកែម អង្គុយធ្វើទឹកមុខមាំ ផ្លែកខ្នងទឹងសសរ ។ ក្នុងចំណោមយើងទាំងអស់គ្នា មានតែគាត់

ម្នាក់ឯងគត់ដែលមិនយំ ពីព្រោះកាលពីខ្មោចតាស្លាប់ គាត់បានចំណាយទឹកភ្នែកយំស្តាយស្រណោះអស់ច្រើនណាស់ ឥតមានសល់ទឹកភ្នែកសម្រាប់យំចំពោះមរណភាព នៃ ក្មួនប្រុសានេះទៀតទេ ។ គាត់បោយដៃហៅគេម្នាក់ឲ្យចូលទៅជិត ហើយប្រាប់ថា ឲ្យទៅនិមន្តលោកវត្តខ្ពស់ណាលោម មកសូត្រធម៌កំដរអ្នកជម្ងឺ កុំឲ្យស្ងាត់ផ្ទះពេក ។

ពុកស្ងាមម្តងទៀត រញាក់រញ៉ីត្រដរខ្យល់ គាត់ទំប្រឹងលេចសរសៃវាមជុំវិញចំពង់ក ដើម្បីហាមាត់និយាយ ប៉ុន្តែ យាយកែមយកដៃសង្កត់ដើមទ្រូងក្តៅផ្ទួចរងើកភ្លឺង ច្រានពុកឲ្យសម្រាន្តទៅវិញ ។ ន្រណាម្នាក់និយាយសួរពុកថា :

~ បងហាំ ! កាលពីក្មេង បងឯងមានធ្លាប់មកលេងដល់មាន់ទេ ?

ពុកងក់ក្បាលសំដែងការយល់ស្រប និង និយាយបន្តែមថា :

~ ខ្ញុំដឹងថា ខ្ញុំបានប្រព្រឹត្តអំពើអបាយមុខច្រើនណាស់ ខ្ញុំបានចាប់សត្វឲ្យដល់ខ្លា ខ្ញុំបានសម្លាប់មនុស្សជាពិសេសសម្លាប់ឃួនអស់ច្រើនណាស់ ។ សូមអ្នកដែលខ្ញុំធ្លាប់បានធ្វើអំពើល្អទៅលើគេ គេជួយស្រោចស្រង់ឲ្យខ្ញុំបានជួបប្រទះតែនឹងសេចក្តីសុខក្នុងសុគតិភព ។

យាយកែម ឈ្លោកសម្លឹងមើលមុខក្មួនប្រសារដោយក្រសែភ្នែកស្រទន់ ពោរពេញទៅដោយសប្បុរសធម៌ ។ គាត់កាន់ជង្គង់ពុកជាប់ ហើយពោលមួយៗថា :

~ យិន ! ក្មួនឯងកុំគិតពីរឿងខុសត្រូវព្រួយធ្វើអ្វី គិតតែតាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះធម៌ឡើង ។ កុំគិតពីអ្នករស់នៅ មានម៉ែ មានញាតិមិត្តបងប្អូនទៅជួយមើលថែរក្សា ជាភ្នែក ជាច្រមុះ ជំនួសឯងហើយ ។ ឯងទន្លេញធម៌ឲ្យចាំជាប់ក្នុងចិត្តជានិច្ច ដើម្បីសំអាតចិត្តឲ្យស្អាត ពីព្រោះមានតែព្រះធម៌នេះហើយ ដែលអាចជួយយិតយោងឯងឲ្យបានស្គាល់ សេចក្តីសុខ សុភមង្គល ក្នុងលោកខាងមុខ ។

~ ខ្ញុំទន្លេញចាំហើយម៉ែ (ពុកទំធ្លើយតបទាំងហត់ជង្ហក់) ។

ព្រះសង្ឃបីអង្គនិមន្តមកដល់មាត់ទ្វារបង, យាយលេះរលាំងងើបទៅថ្វាយបង្គំនិមន្តលោកឡើងលើផ្ទះ ។ ពុកសម្រាន្តស្ងាកស្តើង បាត់មាត់បាត់ក ភាត់ឥតស្តាប់ឮជាលោកសូត្រធម៌ពីអ្វីខ្លះទេ ។ ស្រាប់តែគាត់ចាប់ផ្តើមត្រដរខ្យល់ម្តងទៀត ប្រកាច់រមួរខប ន្ទទៀលខ្ទេចខ្ទីអស់កន្ទេល គាត់ស្រវាវាយ ព្រមទាំងស្រែកខ្លាំងៗថា :

~ យាយ ! យាយ ! ម៉ែ កុំទៅណាចោលខ្ញុំ ! កុំទៅណាចោលខ្ញុំ ! កុំទៅណាចោលខ្ញុំ ! ។

គេចាប់ជួតភឹងនយ៉ាងរហ័ស ដើម្បីចាំងកុំឲ្យព្រះសង្ឃដែលកំពុងគង់សូត្រធម៌នៅខាងម្ខាងនោះ មើលឃើញអ្នកជម្ងឺ ។

ខ្ញុំចាប់ផ្តើមយល់ថា ក្នុងពេលបន្តិចទៀតខាងមុខនេះ ពុកនឹងបែកចេញពីយើងទៅអស់កាលជានិច្ច ឥតត្រឡប់មកវិញឡើយ ។ ខ្ញុំពុំធ្លាប់ឃើញសេចក្តីស្លាប់ជាក់ច្បាស់ទឹងភ្នែកផ្ទួចម្តងនេះទេ ។ មុខពុកប្រែជាស្លេកស្លាំងគួរខ្លោច, ខ្លាចទាល់តែខ្ញុំមិនហ៊ានទៅជិត មិនហ៊ានទាំងមើលគាត់ទៀតផង ។

សម្លេងព្រះសង្ឃសូត្រធម៌ មានសភាពលន្លង់លន្លោចស្រងេះស្រងោចពេកណាស់ ញ៉ាំងចិត្តយើងឲ្យរីតតែអស់សង្ឃឹមខ្លាំងឡើងថែមទៀត ។ ពុកផ្ទួចជាបានធ្លះបន្តិច គាត់សម្លឹងមើលមុខយើងដែលអង្គុយព័ទ្ធជុំវិញ ដំណេកគាត់ម្តងមួយរំហើយទាំងរកភួយដណ្តប់ ពីព្រោះខ្យល់ជំនោះព្រឹកព្រហាមត្រជាក់ណាស់ ។

~ ឯមហ្ន៎ ! (ពុកស្រែកហៅម៉ែដោយសម្លេងខ្សាវៗ) ឯង, ឯងកុំគិតដល់អញធ្វើអ្វី គិតតែខ្លួនឯង និងក្មួនស្រីទៅ បានហើយ ។ ឯងមិនចាំបាច់លក់មាសប្រាក់ក្មួន ដើម្បីធ្វើបុណ្យខ្មោចអញឲ្យអធិកអធម្មទេ

ពីព្រោះបើទុកជាធ្វើបុណ្យធំដុំ ក៏វាគ្មានបានប្រយោជន៍អ្វី ក្រៅតែពីនាំឲ្យខាតលុយឥតប្រយោជន៍នោះឡើយ។ ឯងកុំលក់ផ្ទះណា យ៉ាងម៉េចៗក៏នៅសល់ដំបូលគ្រាន់ជ្រកនឹងគេដែរ... ឯណាកូនយើង? កូនមកជិតពុកបន្តិចមើល...

ខ្ញុំដើរចូលទៅជិតទាំងរាងកាយញ័រចំប្រប់ដោយក្តីភ័យខ្លាច លុះប៉ះនឹងដៃគាត់ត្រជាក់ស្រឹតដូចទឹកកក ខ្ញុំក៏ស្ទុះថយក្រោយវិញភ្លាម។

~ កូន... (ពុកនិយាយ ព្រមទាំងដកដង្ហើមធំ)។

យាយច្រានខ្ញុំចូលមកវិញ ហើយបន្ទោសថា:

~ ចៅឯង អីក៏ចិត្តអាក្រក់ម្ល៉េះ ទុំពុកមិនទាន់ស្លាប់ផង ឯងខ្លាចប៉ុណ្ណឹងទៅហើយ ធ្វើយ៉ាងនេះគេហៅថាកូនកតញ្ញូកើតដែរឬទេ?

ខ្ញុំអង្គុយឆ្ងាយល្មមតែពុកឈោងដៃចាប់មិនដល់ ទុនមុខជ្រុបយំអណ្តឹតអណ្តក់ទាំងមិនយល់ថា ខ្លួនឯងយំពីរឿងអ្វីផង។

~ កូន! (ពុកនិយាយម្តងទៀតដោយលើកដៃដាក់ប្រណាម្យលើដើមទ្រូង) កូនស្តាប់សំដីពុកឲ្យច្បាស់ណា ពីព្រោះនៅលើដីនេះមានតែទុំពុកទេដែលស្រឡាញ់កូន... ថ្ងៃណាមួយកូនគង់តែយល់ជម្រៅចិត្តពុកមិនខាត...។ អត់ពីទុំពុកទៅ កូនកុំទុកចិត្តនរណាឲ្យសោះ ក្រៅតែពីខ្លួនឯងនិងម្តាយឯង ពីព្រោះមានតែបងប្អូនក៏ដោយ ក៏គ្មាននរណាគេស្រឡាញ់ឯងដូចម្តាយទុំពុកដែរ។ កូនរៀនតាំងចិត្តឲ្យចេះ ចង់មានចង់បាន ហើយនៅប៉ិនហ្នឹងយកចិត្តទុកដាក់ធ្វើការខ្នាប់ខ្នួន កុំឈប់ទៅភ័ងឲ្យសោះ ពីព្រោះក្នុងភ័ងកូនមានដំបូលជ្រក និង មិនភ័យព្រួយពីរឿងអត់ឃ្លានមានស៊ី...

ម្យ៉ាងទៀតបើឯងមកនៅក្រៅ ខ្លាចក្រែងប្រុសឈ្មោលវាមើលងាយ ដោយឯងគ្មានទុំពុកនៅជាបង្គោលសម្រាប់ការពារមើលខុសត្រូវ។ ...កូនចង់ចាំដំបូន្មានពុកចុះ មិនខុសទេ។ ពិសេស កូនត្រូវនឹងគុណម្តាយកុំធ្វើបាបម្តាយមេម៉ាយឲ្យពិបាកចិត្ត ឯងធំហើយត្រូវចេះកែតំនិតមាយាទឲ្យសមតាមអាយុ ឯងមិនមែនក្មេងទៀតទេ... ពុកមានតែពាក្យប៉ុណ្ណោះជាបណ្តាំចុងក្រោយបំផុតទុកឲ្យកូន មុនឯងលាកូនស្លាប់ បើកូនធ្វើតាមបណ្តាំទុំពុក ពុកសប្បាយចិត្តណាស់ស្លាប់បិទភ្នែកជិតហើយ!។

គាត់សម្រាន្តស្ងាត់ឈឹង បើកភ្នែកប្រឹងសម្លឹងមើលខ្ញុំ ហាក់ដូចជាគាត់ប្រុងនឹងស្ទុះមកស្រែកអោបខ្ញុំ។

~ ហ៊ឺ! យីតាស្រឡាញ់កូនណាស់, យាយកែមរឿងតិចៗ ហើយច្រានខ្ញុំឲ្យទិតចូលទៅជិតពុកបន្តិចទៀត ប៉ុន្តែពុកមើលឃើញយាយបង្ហើបខ្លួន ស្មានថាគាត់ប្រឹងដើរទៅណា ក៏ស្រែកអង្វរ:

~ ម៉ែ,កុំទៅណាចោលខ្ញុំ! កុំទៅណាចោលខ្ញុំ! ម៉ែ, កុំទៅណាចោលខ្ញុំ!

~ អរហំ! (យាយស្រែកខ្លាំងៗ ព្រមទាំងចាប់ដៃពុកឲ្យលើកប្រណាម្យដាក់លើដើមទ្រូង)...

~ អរហំ! យិនឯង ទន្ទេញឲ្យចាំជាប់ក្នុងចិត្តទៅកូន!

~ អរហំ... (ពុកទន្ទេញតាមយាយ)។

យើងទាំងអស់គ្នាស្រែករកពុទ្ធោ ដោយលើកដៃសំពះខ្ពស់ហួសក្បាល។

ពុកថ្ងាររក្សាលទៅក្រោយប្រុងត្រដរខ្យល់ម្តងទៀត... ប៉ុន្តែបង្ហើមផុតត្រឹមនេះទាំងភ្នែកបើកក្រឡែតនៅឡើយ។ ដៃដាក់ប្រណាម្យជាប់លើដើមទ្រូង ម្រាមដៃប្រឹងក្តាប់លេចសរសៃវាំម។ ម៉ែយំបោកខ្លួនលើទ្រូងពុក, យាយយកដៃទាញបិទភ្នែកសព, ចំណែកខ្ញុំទំរជ្រៀតទៅកៀនក្រែ ដោយមិនដឹងពីទំហឹ នៃ ក្តីទុក្ខវេទាដែលនឹងត្របសង្កត់មកលើខ្ញុំឡើយ។

ពុកសម្រាន្តនៅកន្លែងដដែល ប៉ុន្តែគេនិយាយថាគាត់ស្លាប់ទៅហើយ... ប្រហែលជាបន្តិចទៀតគាត់នឹងភ្ញាក់ឡើងវិញ... គាត់នឹងក្អក... គាត់នឹងនិយាយ... គាត់នឹងស្រែកហៅខ្ញុំក៏មិនដឹង។ អ្!! ប្រសិនបើយ៉ាងនេះមែន ខ្ញុំនឹងស្នុះទៅអោបគាត់ដូចកាលខ្ញុំនៅក្មេង ដែលគាត់ធ្លាប់តែលើកបីបំពេរដាក់លើភ្លៅយ៉ាងនោះដែរ! ពុក, ពុក, ខ្ញុំយំអណ្តឹតអណ្តក់នៅកៀនជញ្ជាំងតែម្នាក់ឯងឥតមាននរណាឃើញឡើយ ប៉ុន្តែពុកនៅស្ងៀមដដែល។ នេះជាលើកទីមួយ ដែលគាត់មិនឆ្លើយតបនឹងសម្លេងខ្ញុំហៅគាត់ ដែលជាហេតុធ្វើឲ្យខ្ញុំចាប់ផ្តើមយល់ថា ពុកឃ្លាតពីខ្ញុំទៅហើយ ឃ្លាតឥតមានពេលត្រឡប់មកវិញឡើយ។

ក្រោយដែលព្រះសង្ឃសូត្រធម៌ខ្មោចចប់ស្រួលបួល ម៉ែរៀបចំចង្ហាន់ប្រគេនលោកឆាន់ មានទាំងប្រអប់មួ-ស្លា សម្រាប់លោកឆាន់លាងព្រះឧស្ណៀតផង។ ឆាន់រួចហើយ លោកនិមន្តត្រឡប់ទៅវត្តវិញ ទើបយើងចាប់ផ្តើមរៀបចំសំអាតបុគ្គល។ សពពុកស្អាតចែសដោយទើបនឹងមុជទឹកហើយ សាច់សស្តាំង។ អ្នកភូមិជាច្រើនគាក់ តាំត្នាជួយជ្រោមជ្រែងម្នាក់មួយដៃមួយជើង... គ្មាននរណាជឿថាពុកស្លាប់សោះ ទាល់តែមកឃើញច្បាស់ទើងភ្នែកទើបជឿ លាន់មាត់ស្តាយ។ អ្នកដែលបានឃើញតាអាចារ្យលាយថ្នាំឲ្យពុកពិសាកាលពីម្សិលមិញ គេនាំគ្នាចោទប្រកាន់ថា គឺគាត់នេះឯងដែលយកថ្នាំផ្តេសផ្តាសមកឲ្យទុំពុកខ្ញុំពិសាទាល់តែស្លាប់។

គេមួរកន្ទេលកណ្តាលផ្ទះចេញ ប្រុសៗជួយលើកខ្មោចដាក់អង្គុយសណ្តកជើងគងទៅលើជង្គង់ម៉ែចំណែកខាងចុងជើងដែលត្រដាក់ស្រេបនោះ គងលើជង្គង់ខ្ញុំ។ នេះជាករណីយកិច្ចចុងក្រោយបំផុតដែលខ្ញុំត្រូវបំពេញ ដើម្បីតបស្នងសងគុណទុំពុក។ យើង ស្រោចទឹក ដុសក្អែលរួចលាបទឹកអប់ ហើយយកកំណាត់ទេសឯកស មកកុំពីទ្វ ក្រោយដែលម៉ែយកប្រាក់កាក់មួយមកបង់ក្នុងមាត់សព។ បន្តិចក្រោយមក ម៉ែទាំខ្ញុំទៅកាន់ដីណាក់ផែ ដើម្បីទូលហ្លួងឲ្យបានជ្រាបពីដំណឹងដ៏ក្រៀមក្រំនេះ។ ពេលនោះស្រាប់តែមិត្តភក្តិទាំងអស់គេបង្ហាញសមានចិត្តចំពោះខ្ញុំគួររំភើបក្រៃលែង។ វ៉ៃវាទទួលការៈនៅទូលហ្លួងជំនួសខ្ញុំម្តងទៀត។ ហ្លួងកំពុងថ្ពិសោយអាហារ លោកប្រធានប្រាក់ឲ្យខ្ញុំ ហុកសិបរៀល ព្រមទាំងបង្គាប់ទៅក្រុមវាំងម្នាក់ ឲ្យចំណាយព្រះរាជទ្រព្យ ធ្វើម្បាស យកហ្លួង ទិញកំណាត់ទេសឯក និង ដេរគម្របម្បាស សម្រាប់ប្រើក្នុងពេលបុណ្យខ្មោចផង។ ហ្លួងបង្គាប់មិន ឲ្យខ្ញុំកោរសក់ និង ឲ្យខ្ញុំស្ងៀកពាក់ សក្នុងរយៈពេលមួយខែឬពីរខែ។

ខ្ញុំទាំម៉ែត្រឡប់មកផ្ទះវិញ ដោយហ្លួងសន្យាថា ស្នែកនេះម្បាសនឹងធ្វើរួចស្រេច ហើយគេនឹងដឹកយកមកឲ្យដល់ផ្ទះតែម្តង។ ផ្ទះខ្ញុំមានមនុស្សអ្វីអារឡើងចុះតាំងពីព្រលឹមទល់ព្រលប់ ពីព្រោះម៉ែសំរេចថា នឹងតំកល់សពទុកពីរថ្ងៃទៀត។ ទោះបីពុកបានផ្តាំផ្ញើម៉ឺងម៉ាត់យ៉ាងណាក៏ដោយ ក៏ខ្ញុំមិនចង់ទុកគ្រឿងមាសប្រាក់មានតម្លៃធ្វើអ្វីដែរ។ ខ្ញុំលក់ប្រអប់ប្រាក់ពីរ យកលុយមកបង្គ្រប់ជាមួយលុយហុកសិបរៀល ដើម្បីទុកសម្រាប់ចំណាយផ្សេងៗក្នុងពិធីបុណ្យ។ គ្រឿងប្រើប្រាស់របស់ពុកទាំងប៉ុន្មាន ខ្ញុំចែកចាយឲ្យបងប្អូនអស់លើង មានតាំងពី ខ្សៀវបារី ឈើច្រត់ប្រាក់ សម្លៀកបំពាក់ រហូតដល់តុ ទូ ទៀតផង។ រាល់ព្រឹកយើងនិមន្តលោកមកសូត្រធម៌ ទាល់តែឆាន់ព្រឹកឆុច ទើបលោកនិមន្តត្រឡប់ទៅវិញ។ អស់អ្នក-អស់នាង ក្នុងភ័ង និង កូនស្តេចខ្លះយក អង្ករ លុយ ទៀន ធូប មកចូលកុសល ហើយមានពួកកន្លោះខ្លះដែលខ្ញុំមិនធ្លាប់ស្គាល់ទាល់តែសោះក៏យករបស់ផ្សេងៗមកចូលនឹងគេដែរ។

ថ្ងៃទីបី ជាថ្ងៃដង្ហែសពពុកទៅបូជានៅក្នុងវត្តបុទុមក្បែរស្រះស្រង់។

ចាប់តាំងពីពេលពុកស្លាប់ដោយពិសាថ្នាំគាត់ទោះមក អាចារ្យត្រូវផ្សំថ្នាំគាត់ពួនសម្ងំបាត់មុខ ភ្លាចក្រែងម៉ែរកប្តឹងប្តិ្តងផ្តល់ ប៉ុន្តែ យាយ ព្យាយាមពន្យល់ខ្ញុំកុំឲ្យចងពៀរនឹងតាទោះធ្វើអ្វី ធ្វើម៉េចពុកបានជាស្លាប់ទៅហើយ បើទុកជាប្តឹងរកខុសត្រូវទាល់តែគាត់ជាប់គុកច្រវាក់ ក៏ពុកមិនអាចរស់មកវិញដែរ។ ខ្ញុំប្រើគេឲ្យទៅ

ហៅគាត់មក ហើយនិយាយប្រាប់ថា :

~ តាឯង យកថ្នាំផ្តៃសង្គ្រាសមកឲ្យឪពុកខ្ញុំពិសាទាល់តែស្លាប់ ជាការត្រឹមត្រូវតែខ្ញុំប្តឹងផ្តល់រកឲ្យឃើញសខ្មៅ ប៉ុន្តែខ្ញុំចាត់ទុករឿងនេះថាជាសំណាងអាក្រក់របស់ឪពុកខ្ញុំទៅចុះ ប្រហែលពីជាតិមុនឪពុកខ្ញុំធ្លាប់បានសម្លាប់តាឯងហើយមើលទៅ បានជាជាតិនេះតាឯងតាមសងសឹកសម្លាប់គាត់វិញ ។ ណ្ហើយចុះ តាកុំភ័យអី ខ្ញុំមិនប្តឹងទេ ប៉ុន្តែតាឯងធ្វើជាអាចារ្យស្រាប់ ជួយមើលចាត់ចែងបុណ្យខ្មោចឪពុកខ្ញុំផង ឬទេ ?

តាអាចារ្យទទួលយល់ព្រមដោយចិត្តរីករាយ ។ គាត់រៀបចំក្បួនដង្ហែ ប៉ុន្តែពួកភ្ញាំងភ្ញាសមកយឺតពេលពេក យើងមិនអាចចាំយូរតទៅទៀតបាន ក៏ដាច់ចិត្តហែរចេញទៅតាំងអត់ភ្លេង ។ អាចារ្យដើរពីមុខក្បួន ខ្ញុំដើរជាប់ពីក្រោយ គាត់ស្ទៀកពាក់ស ទទូរសំពត់ស ដៃឆ្វេងកាន់ផ្តិលដាក់លាជលាយជាមួយប្រាក់កាក់ ដៃស្តាំលូកចាប់បាចឲ្យរហែតាមផ្លូវ ដោយមានក្មេងមួយហ្វូងដើរតាមចាំដណ្តើមជើរសយកលុយ ។ ខាងក្រោយខ្នងខ្ញុំ ពួកអ្នកងារសែងព្រែស្នែង ដែលនៅលើនោះ មានដាក់ម្សៅស និង មានព្រះសង្ឃពីរអង្គគង់អមសង្កាង ។ មិត្តភក្តិក្នុងភ្ញាំងខ្លះដូចជា សំអាង ឬឿង ឯម ប្ញ កុំ ជាដើម ក៏បានមកជួយហែដែរ វាដើរខាងក្រោយជាមួយម៉ែ ។ ពួ ទង ប្ញទបង្កើតរបស់ពុក ជាអ្នកបួសមុខភ្លើង ។

នៅទីបញ្ចប់ យើងក៏បានមកដល់វត្តបុទុម ឃើញមានគេរៀបគន្លុសទុកហើយស្រេច ។ យើងដើរប្រទក្សិណបីជុំ លើកម្ល្អសដាក់ទៅលើគំនរគ្នុស បន្ទាប់មក តាអាចារ្យ និង អ្នកភ្លុក ចាប់ផុតភ្លើង ហុយផ្សែងខ្មៅទ្រលោមទៅក្នុងលំហអាកាស ។ ខ្ញុំបែរខ្នងចេញ មិនអាចត្រាំមើលទស្សនីយភាពដ៏ខ្មោចផ្សានេះបានឡើយ... ម៉ែអង្គុយលើស្មៅស្រែកយំក្តែងៗ... ។

លុះផុតសុះអស់ ខ្ញុំបែរមកមើលឃើញនៅសល់តែ កំទេចឆ្អឹងលាយឡំជាមួយផែះ និង រងើកភ្លើងប៉ុណ្ណោះ ។ ព្រះសង្ឃនិមន្តត្រឡប់ទៅវត្តវិញ ចំណែក ញាតិមិត្តទាំងអស់ និងខ្ញុំ ទាំងាជីសច្ចឹងប្រមូលដាក់ក្នុងកោដ្ឋមួយ ដើម្បីយកទៅដាំកល់ទុកក្នុងចេតិយឯព្រែកថ្មី ។

ល្ងុ ធ្វើបុណ្យខ្មោចពុកចប់ស្រួលបួលហើយ ម៉ែអង្វរខ្ញុំថាឲ្យឈប់នៅភ្ញាំង មកនៅជាមួយគាត់វិញ គ្រាន់បានជាគ្នាជួយរកស៊ីចិញ្ចឹមជីវិត ។ ប៉ុន្តែខ្ញុំរំលឹកគាត់ថា ពុកបានផ្តាំផ្តាច់មិនឲ្យខ្ញុំចេញពីភ្ញាំង ម្យ៉ាងទៀតនៅក្នុងភ្ញាំងខ្ញុំមានប្រាក់ខែបន្តិចបន្តួចដែរគ្រាន់នឹងចិញ្ចឹមខ្លួន ដោយមិនបាច់រកស៊ីលក់ដូរនាំឲ្យនឿយខ្លួន ។

ចាប់តាំងពីថ្ងៃនោះមក ហ្វូងហាក់ដូចជាមានសមាធិចិត្តអាណិតខ្ញុំច្រើន ។ លោកបង្គាប់ឲ្យខ្ញុំដណ្តប់ជាហ៊ីសជាសញ្ញាកាន់ទុក្ខឲ្យបានយូរ និង សន្យាថា លោកនឹងឲ្យគេសង់ផ្ទះក្បឿងបីខ្នងមួយសម្រាប់ម្តាយខ្ញុំ ។ ក្រោយមកបន្តិច លោកប្រាន្តប្រាក់ទៅម្ចាស់ក្សត្រី ឲ្យយកទៅចែកអស់អ្នក-អស់តាង ក្នុងភ្ញាំងទាំងអស់ ហើយលោកសួរខ្ញុំថា តើមានបានទទួលប្រាក់ង្វាន់ ប្រាំរៀលដូចគេឯងដែរឬទេ ? ខ្ញុំឆ្លើយថា បានទទួលតែបីរៀលទេ ពីព្រោះខ្ញុំបានតែ បីរៀលមែន ហើយអ្នករបាំងទៀតៗក៏គេឆ្លើយដូចខ្ញុំដែរ ។ តើប្រាក់ទៅសល់ទាំងប៉ុន្មាន ម្ចាស់ក្សត្រីយកទៅចែកចាយឲ្យ ក្មួនចៅលោក ឬ យ៉ាងណា ?... ឬឿងនេះធ្វើឲ្យហ្វូងមិនសប្បាយព្រះទ័យ ក៏ស្រែកឡូឡាថា :

~ ក៉មវាគិតយ៉ាងម៉េចហ្នឹង ? បើសិនជាវាខ្វះខាតលុយមកសុំអញ អញមិនដែលថាមិនឲ្យម្តងណាសោះ ត្រចម៉ែចក៏ចាំមកកេងចំណេញលើប្រាក់បន្តិចបន្តួចរបស់ក្មេងភ្នាងទៀត ? ធ្វើអញឲ្យតាំងមុខមិនដឹងគេយល់ច្រឡំថា អញនេះជាមនុស្សខ្ជិចខ្ជៅវិញ ហើយម្យ៉ាងទៀតវាតាំងឲ្យ ស្រីត្រឹមត្រូវ និង អ្នករបាំណ្ឌ គេមិនសប្បាយចិត្តរត់ចោលអញអស់ ។

និយាយចប់ហើយ លោកប្រាន្តប្រាក់ ប្រាំរៀលថែមទៀតឲ្យខ្ញុំ ដែលជាហេតុធ្វើឲ្យពួកឯទៀតគេច្រណែនត្រប់ត្នា ។

ដល់ពេលដាច់ខែ ប្រាក់ខែខ្ញុំនៅតែត្រូវយាយម៉ែនមេបំណុល កាត់យកអស់ដដែល គាត់ថាខ្ញុំមិនទាន់សងការប្រាក់គាត់ត្រប់ចំនួននៅឡើយ ។ ស្មៀតគាត់ប្រសើរមែន ពីព្រោះគាត់មានភ្នែនប្រុសម្នាក់ធ្វើការនៅកន្លែងបើកលុយស្រាប់ ណាមួយគាត់ជាសាច់ញាតិនឹងម្ចាស់ក្សត្រី ចង់ធ្វើអ្វីក៏បានតាមចិត្ត ឥតមានភោតញញើតនរណាទេ ពីព្រោះម្ចាស់ក្សត្រីបើកដៃឲ្យហើយ ។ ប៉ុន្តែឥឡូវនេះ ខ្ញុំមិនមែនល្ងង់ដប់គត់ដូចពីដើមឯណា, ខ្ញុំមិនព្រមឲ្យនរណាប្រើស្មៀតបន្លំ រកស៊ីបំផ្លែកខ្ញុំជាដាច់ខាត ។ ខ្ញុំទៅសួរមើលថាតើប្រាក់ខែខ្ញុំ មានបានឡើងដល់ម្តៃរៀល ដូចគេឬទេ ? ព្រោះកាលទើបនឹងត្រឡប់មកពីបាត់ដំបងវិញភ្លាម ខ្ញុំឮហ្វូងបង្គាប់ឲ្យតម្លើងប្រាក់ខែយើងទាំងអស់គ្នា ។ អ្នកឯមមេឃ្លាំងប្រាក់ លើកបញ្ជីមើលឃើញថា ប្រាក់ខែខ្ញុំនៅតែដប់រៀលដដែល ។ នេះប្រាកដជាគេភ្លេចសរសេរចុះក្នុងបញ្ជីដោយចេតនាតែម្តង ដើម្បីស្រួល

កេងបន្ដំលើប្រាក់ខែខ្ញុំ ។ ខ្ញុំដល់ចិត្ដ ប្រថុយទៅខ្ចីលហួងម្ដងទៀត លោកក៏ប្រើឲ្យគេទៅហៅឯងមកគាស់ ។ ប៉ុន្ដែសិយណាស់ ថ្ងៃនោះអ្នកឯងមិនទៅនឹងកន្លែង តាមរកមិនឃើញសោះ ។ ដើម្បីជាការលួងចិត្ដ ហួងប្រមានប្រាក់ម្ដែរៀលឲ្យខ្ញុំ ហើយរឿងនេះត្រូវចប់ត្រឹមណេះ គឺប្រាក់ខែខ្ញុំនៅតែត្រឹម ៨ប់រៀលរហូត ។

ខែបន្ទាប់មក ខ្ញុំទៅភ្ញាំនឹងអ្នកឯង ពីរឿងប្រាក់ខែម្ដងទៀត គាត់និយាយថាខ្ញុំច្រឡំហើយ ប្រាក់ខែខ្ញុំឥតត្រូវឡើងទេ ។ ខ្ញុំទៅខ្ចីលម្ចាស់ក្សត្រីឲ្យជួយរកយុត្ដិធម៌ ប៉ុន្ដែលោកធ្វើព្រងើយមិនដឹងមិនឮ ។ ខ្ញុំអាចទៅខ្ចីលហួងក៏បាន ប៉ុន្ដែខ្ញុំមិនមែនចង់យករឿងផ្ទាល់ខ្លួនទៅរំខានលោក សុខចិត្ដឲ្យគេកាត់ប្រាក់ខែមួយខែនេះទៀតចុះ ។

លុយខ្លីតែហាសិបរៀលសោះ គេកាត់ប្រាក់ខែយកអស់រាល់ខែ ។ មួយឆ្នាំកន្លះហើយ ក៏នៅតែមិនទាន់រួចលុយបំណុល ហើយមិត្ដភក្ដិខ្ញុំដំខែទៀត ក៏ត្រូវគេប្រើស្មៀតអារកហុតឈាមផ្ងូចគ្នានេះដែរ ។ ខ្ញុំមិនចាំបាច់ឆ្ងល់ទេ ទោះបីខ្ញុំតវ៉ាយ៉ាងណា ក៏ម្ចាស់ក្សត្រីនៅតែ ធ្វើត ធ្វើថ្ពង់ ជាទិច្ច ពីព្រោះមធ្យោបាយរកស៊ីចង់ការប្រាក់នេះ វាអាចទាំឲ្យសាច់ញាតិលោកឆាប់បានធាត់ធំ ។ ពិចារណាសព្វគ្រប់ទៅ ខ្ញុំផ្ងូចជាចាញ់ប្រាថ្នាគេ ត្បូលចិត្ដពេកណាស់ ។

រាល់ថ្ងៃ ម៉ែរស់នៅដោយសារបានឮខ្ញុំជួយផ្ដល់ប្រាក់កាសបន្ដិចបន្ដួច ដល់ឃ្លួរៗទៅ គាត់ជំពាក់គេច្រើនពេក ក៏លក់ផ្ទះនៅកំពង់ផែដើម្បីយកប្រាក់សងគេ ។ គាត់អង្វរខ្ញុំឲ្យឈប់ទៅភ្ញាំង មកជួយរកស៊ីចិញ្ចឹមគាត់ផង ហើយនៅទីបញ្ចប់ ខ្ញុំក៏យល់ព្រមតាមពាក្យអង្វររបស់គាត់ទាំងបង្គំចិត្ដ ។

ទោះបីខ្ញុំមានការជិនឆ្ងន់ឆ្ងៃនឹងអ្នកធំអ្នកឆ្ងួច ខ្លះនៅក្នុងភ្ញាំងក៏ដោយ ក៏ខ្ញុំលាចាកពីភ្ញាំងទៅទាំងទឹកភ្នែកដោយក្ដីស្ដាយស្រណោះរបាំ ដែលខ្ញុំជាប់ចិត្ដស្រឡាញ់តាំងពីក្មេងមក ។ ពេលនេះហួងហាក់ផ្ងូចជាពេញចិត្ដនឹងខ្ញុំណាស់ ប៉ុន្ដែវាហួសពេលទៅហើយ ពីព្រោះសព្វថ្ងៃ អ្នកប្រកាន់ចិត្ដ ស្អប់ច្រណែនឈ្នានីសខ្ញុំ ក៏មានចំនួនច្រើនណាស់ដែរ ថ្ងៃណាមួយពួកគេអាចនឹងប្រឌិតរឿងទាំឲ្យខ្ញុំមានទុក្ខទោស ត្រូវគេវាយធ្វើបាបនឹងរំពាត់ផ្ដៅ គេចាប់យកទៅឃុំឃាំងក្នុងសាលាតាលិយក្ស មិនខាន ។ ខ្ញុំសំរេចចិត្ដរួចស្រេចហើយថា ជាការល្អត្រូវតែខ្ញុំឈប់ទៅភ្ញាំងឲ្យបានទាន់ពេលវេលា ។

ខ្ញុំរក្សារឿងនេះទុកជាសម្ងាត់រហូតទល់ថ្ងៃចុងក្រោយបំផុត មានតែ យ៉ាន ម្នាក់គត់ដែលខ្ញុំប្រាប់ឲ្យដឹង ។ ប៉ុន្ដែវាមិនព្រមជឿសោះ ចេះតែថាខ្ញុំនិយាយលេង ។ ចំណែក នាងរឿង "ប្អូន" ខ្ញុំនោះវិញ តាំងពីដួងថាខ្ញុំជិតឈប់ទៅក្នុងភ្ញាំងមក វាស្រងូតស្រងាត់លែងរីករាយសោះតែម្ដង ។ ខ្ញុំទំនិយាយលួងលោមវាថា :

~ នែ រឿង, ឯងគិតឲ្យហ្មត់ចត់ទៅមើល តើសេចក្ដីស្នេហារវាងស្រីនឹងស្រីនេះ វាបានន័យថាម៉េច ? យើង ស្រីផ្ងូចគ្នា ប្រដាប់ក៏ផ្ងូចគ្នា តើឯងចង់ឲ្យអញធ្វើម៉េចឯង ? ឯងស្មានថាអញនៅតែធ្វើជាប្ដីឯងអញ្ចឹងរហូតទៅឬ ?

ប៉ុន្ដែ រឿង និយាយពន្យល់ខ្ញុំវិញយ៉ាងច្បាស់លាស់ ពីសេចក្ដីស្នេហារបស់វាចំពោះខ្ញុំ :

~ ទេ ! សាវ៉ាន់នី, អ្នកយល់ខុសហើយ ខ្ញុំមិនមែនស្រឡាញ់អ្នកតាមរបៀបស្នេហាចំកួតនោះទេ ខ្ញុំស្រឡាញ់អ្នកពិតប្រាកដយ៉ាងស្មោះអស់ពីដួងចិត្ដ ស្រឡាញ់ ទាំងខ្ញុំខ្លួនឯងមិនដឹងថា ស្នេហានេះវាបណ្ដាលមកពីអ្វីផង ។ ទោះបីអ្នកត្រូវចេញពីភ្ញាំង ទៅមានប្ដីស្រួលបួលត្រឹមត្រូវក៏ដោយ ក៏ខ្ញុំសុំទៅតាមនៅជាមួយអ្នកជាទិច្ច ក្នុងហេតុ:ជាអ្នកបំរើម្នាក់ស្មោះត្រង់ ។

វានិយាយត្រង់មែន គឺវាសុខចិត្ដឈប់ទៅភ្ញាំងមកតាមខ្ញុំ ហើយ លោក[១៣] ក៏ធ្លាប់ស្គាល់វាដែរ មែនទេ ? ពីព្រោះកាលយើងទើបនឹងរៀបការគ្នាហើយថ្មីៗ វានៅជាមួយខ្ញុំនៅឡើយ ប៉ុន្ដែក្រោយមក វាអស់សង្ឃឹមក្នុងចិត្ដ ដោយឃើញខ្ញុំស្រឡាញ់លោកច្រើនជាងវា ទើបវាឈប់នៅជាមួយខ្ញុំ ។ ទៅបានប្ដីនោះអក៏ឮទៀត ប៉ះលើមនុស្សច្បោរខ្មៀ គេធ្វើបាបវាទាន់ណាស់ ។

ខ្ញុំសំរេចចិត្ដរួចហើយថា ត្រូវតែឈប់នៅភ្ញាំង ។ ខ្ញុំជួលក្រុមភ្ញាំងម្នាក់ ឲ្យលុយគាត់ពីរៀល ដើម្បីឲ្យគាត់ជួយសរសេរសំបុត្រថ្វាយបង្គំហួង ។ ខ្ញុំបត់សំបុត្រជាបួន រួចតែងខ្លួនយ៉ាងស្អាតបាត ចូលទៅក្នុងដំណាក់ហួងទាំងចិត្ដរំភើបញាប់ញ័រក្រៃលែង ។ ពេលឃើញខ្ញុំ ហួងញញឹម ហើយបង្គាប់ខ្ញុំឲ្យអង្គុយជាមួយមិត្ដភក្ដិដទៃទៀតដែលត្រូវគាស់បំរើក្នុងវេនទីបួន នៅចុងជើងក្រែ ដើម្បីរៀបចំខ្សៀអាហារ ។ ខ្ញុំលើកខ្សៀដែលស៊ុនវាជាក់អាហ៊ៀនួចស្រេចថ្វាយលោក ប៉ុន្ដែលោកធ្មៀតលេងកំប្លែងបន្ដិចមុនទទួលយកទៅសោយ ។ ខ្ញុំគិតឃើញថា ពេលនេះមិនគួរនឹងថ្វាយសំបុត្រដល់លោកទេ ទើបសំកវាលាក់ទៅក្រោមកន្ទេលសិន ។

ហួងផ្ដិសោយអាហ៊ៀនដោយធ្មៀតនិយាយចំអន់លេងរឿងប្ដីឲ្យយើងសុទ្ធតែមនុស្ស គម កើតស្រែង ឬ អ្វីទៀតតាមតែលោកនឹកឃើញ ។ លោកនិយាយថា ស៊ុនលបសាហាយនឹងក្រុមភ្ញាំង ចំណែកខ្ញុំមានសាហាយម្នាក់ ជាអ្នកលេងនៅស្ងាថ្មី ។ ស៊ុន យកក្បួយដៃបុកខ្ញុំ ហើយឱ្យបថា :

~ សាវ៉ាន់នីឮទេ ? ហួងនិយាយលេងជាមួយឯងផ្ងូចជាស្នំតាប់ព្រះទ័យដែរ... កុំអាលចេញទៅណាអីទ្រាំនៅភ្ញាំងមួយឆ្នាំទៀតទៅ ។

ខ្ញុំធ្វើជាមិនឮ មិនខ្វីសើចនឹងពាក្យកំប្លែងរបស់ហួងទៀតផង ។

ហួងទំនងជាសង្ស័យអ្វីម្យ៉ាងក៏ឈប់និយាយ បែរទៅសោយអាហ៊ៀនធ្វើមុខមាំ ។ ចាំដល់លោកសោយបានពីរខ្សៀ ទើបខ្ញុំហួតយកសំបុត្រពីក្រោមកន្ទេលថ្វាយទៅលោក ។ លោកជ្រួញចិញ្ចើម ហាក់ផ្ងូចជានឹងសេចក្ដីក្នុងសំបុត្រួចស្រេចអស់ទៅហើយ ។ ខ្ញុំឧទមុខចុះញាប់ញ័រអស់ខ្លួនប្រាណ ។

~ សំបុត្រស្អីហ្នឹង ? (លោកសួរខ្ញុំ ព្រមទាំងលាសំបុត្របញ្ចាំងមើលនឹងពន្លឺភ្លើង) ។

~ ក្រាបទូល ! (ខ្ញុំធ្លើយឥតបទាំងអួលដើមកស្ទើរនិយាយមិនចេញ) ខ្ញុំម្ចាស់សុំច្បាប់ឈប់ ។

~ ថាម៉េច ? (លោកស្រែកខ្លាំងៗព្រមទាំងស្ទុះងើបអង្គុយលើគ្រែ) ឈប់ទៀតហើយ ! បន្ដិចឈប់ៗ, វាមានរឿងអីទៀតហើយហ៎ ?

~ ទេក្រាបទូល ! ខ្ញុំម្ចាស់ សុំឈប់ធ្វើការ សុំឈប់នៅភ្ញាំងរហូតតែម្ដង ។

ខ្ញុំមិនហ៊ានងើបក្បាលទេ ហួងងើប ដើរចុះ ដើរឡើង ដោយចិត្ដអន្ទះអន្ដែង ហើយនិយាយរៀបកាចថា :

~ មានរឿងតែប៉ុណ្ណឹងទេហ្ន៎ ? ប៉ុន្ដែ មិនអីទេមើនាង ចេញទៅចុះ ឲ្យលោកមហាមន្ដ្រីយកសំបុត្រលុបឈ្មោះមក ចាំអញស៊ីញ៉ៅឲ្យ... ហ៊ុះ អញអាណិតឯង ព្រោះដឹងថាឯងកំព្រាឪពុក អញសន្យា ថានឹងសង់ផ្ទះឲ្យ ថាតម្លើងប្រាក់ខែឲ្យ ប៉ុន្ដែឯងបែរជារត់ចោលអញទៅវិញ ។ អញមិនយោគយល់ឯងទេ ពីព្រោះវាជារឿងផ្ទាល់ខ្លួនរបស់ឯង... អម្បាញ់មិញអញនិយាយលេងថាឯងមានសាហាយ មិនស្មានថាឯងលបមានសាហាយនៅខាងក្រៅអញ្ចឹងសោះ ។

លោកត្រឡប់មកផ្ដិលើគ្រែវិញ លែងមាត់លែងកឋើមុខស្រងូត ។ លោកសោយអាហ៊ៀនច្រើនណាស់សោយហើយសោយទៀត ។ វេនខ្ញុំផុតទៅហើយ ប៉ុន្ដែចង់បង្ហាញឲ្យឃើញជាចុងក្រោយបំផុត នូវទឹកចិត្ដស្ងិតស្ងាញក្នុងការងារ ទើបខ្ញុំមិនទាន់ចេញមកភ្លាមជាមួយគេឯង សុខចិត្ដទ្រាំនៅអង្គុយគាស់ឲ្យរួចបន្ដិច ។

អស់អ្នក-អស់នាង ដែលបានទទួលដំណឹងថា ខ្ញុំសុំឈប់នៅភ្ញាំង គេនាំគ្នាមកប្រជុំអ្វីអរនៅមាត់ទ្វារ... អ្នកច្រណែនឈ្នានីសនឹងខ្ញុំ គេហួចសប្បាយចិត្ដ ពីព្រោះគេដឹងច្បាស់ថា ខ្ញុំឈប់នៅភ្ញាំងចំលើពេលដែលហួង

(១៣) គឺ បាក់ឯងជាប្ដីនាង ដែលនាងកំពុងនិយាយរឿងប្រាប់ ។

កំពុងសព្វព្រះទ័យនឹងខ្ញុំ ។ អ្នកខ្លះទៀតនឹកគិតក្នុងចិត្តថា ខ្ញុំឈប់នៅភាំងព្រោះមានគូកំណាន់ចិត្តនៅខាងក្រៅ ។

ស្អែកឡើងខ្ញុំត្រឡប់មកដំណាក់ម្តងទៀត សង្ឃឹមថានឹងបានទទួលសំបុត្រអនុញ្ញាតិឲ្យចេញមិនខាន ។ ហួងមើលឃើញខ្ញុំដែរ ប៉ុន្តែលោកបែរជាហុចបារីស៊ីហ្គារ៍មួយដើមមកឲ្យខ្ញុំ ធ្វើឫកហ៊ឺដូចជាមិនដឹងរឿងអីសោះ ។ ខ្ញុំទំព្រាំអត់ ចាំដល់ស្អែកមួយទៀត នៅតែមិនឮលោកថាម៉េចផងដែល ក៏ប្រថុយទូលលោកថា អ៊ីវ៉ាន់ ពុទ្ធ ទាំងប៉ុន្មាន ខ្ញុំរៀបចំរួចស្រេចអស់ទៅហើយ នៅចាំតែព្រះរាជានុញ្ញាតប៉ុណ្ណោះ ទឹងអាលជញ្ជូនអ៊ីវ៉ាន់យកទៅផ្ទះ ស្រាប់តែលោកធ្វើជាភ្ញាក់ :

~ អើ, ល្អហើយអញ្ចឹង ! ចាំស្អែកមកយកសំបុត្រពីអញទៅណា !

ល្ងាចនៃថ្ងៃនោះ នាយទាហានក្រុមភាំងម្នាក់ដែលជាមនុស្សទំនុកចុកចិត្តរបស់ហួង តាមមកកន្ទុំដល់បន្ទប់ហើយនិយាយថា :

~ អ្នក, ពេលនេះព្រះករុណាកំពុងសព្វព្រះទ័យនឹងអ្នកណាស់ មិនត្រូវអ្នកឈប់នៅភាំងសោះ... លោកប្រើខ្ញុំឲ្យមកប្រាប់ថា បើអ្នកព្រមនៅបំរើលោកតទៅទៀត លោកនឹងតម្លើងប្រាក់ខែជូន ។ ស្តាយណាស់ អ្នកមិនត្រូវបដិសេធសប្បុរសធម៌របស់ព្រះករុណាទេ ។

~ ហួសពេលទៅហើយ, (ខ្ញុំប្រកែកដោយទាញហេតុផលមកជំទាស់ក្បែកយ៉ាងសមរម្យ) ខ្ញុំមិនអាចផ្លាស់ប្តូរគំនិតបានទេពេលនេះ បើខ្ញុំព្រមនៅតទៅទៀត ហួងពិតជាមិនអាចបំភ្លេចរឿងនេះបានទេ ហើយលោកថែមទាំងគុំគួនស្អប់ខ្ញុំទៀតផង ថាខ្ញុំមិនស្មោះត្រង់នឹងលោក ព្រមនៅភាំងព្រោះតែចង់បានប្រាក់ខែច្រើន... ។

មួយម៉ោងក្រោយមក គេនាំយកសំបុត្រដែលហួងស៊ីញ្ជើចស្រេចមកឲ្យខ្ញុំ ហើយខ្ញុំក៏ប្រញាប់រៀបចំអ៊ីវ៉ាន់ដើម្បីស្អែកឲ្យបានចេញដំណើរពីព្រលឹម ។ ខ្ញុំមិនប្រាប់នរណាឲ្យដឹងថា ខ្ញុំនឹងជញ្ជូនអ៊ីវ៉ាន់ចេញនៅម៉ោងប៉ុន្មានជាពិតប្រាកដ ពីព្រោះរឿងអ្នករបាំដែលធ្លាប់រស់នៅក្នុងភាំងតាំងពីក្មេងមក ហើយបែរជាឈប់ទៅវិញយ៉ាងនេះ គឺជារឿងចម្លែកមិនដែលមានតាល់តែសោះ វាអាចធ្វើឲ្យគេភ្ញាក់ផ្អើលខ្លាំងណាស់ ។ ម៉ែ និង បងប្អូនពីរបីនាក់ មកជួយជញ្ជូនក្រែ ឮកកន្ទេល ខ្នូ និង តុតូចតាច ដោយក្រុមភាំងម្នាក់ឈរចាំត្រួតពិនិត្យមើល ក្រែងខ្ញុំមានយកដោយរបស់អ្វីមួយដែលពុំមែនជារបស់ខ្ញុំ ។ អ៊ីវ៉ាន់ខ្ញុំពុំមានបីយកចេញពីបន្ទប់ផងមីស្នេវាជញ្ជូនរបស់វាយកមកជាក់ភ្លាមមួយរំពេច ហើយចាប់តាំងពីថ្ងៃនោះមក វាបានផ្លូវឈ្មោះជាវីឡៃ ឡើងហ៊ាន:ជាស្នំឯក គាប់ព្រះទ័យហួងលើសគេទាំងអស់ ។ ខ្ញុំមិនច្រណែននឹងវាទេ វាសនាមនុស្សម្នាក់ៗសុទ្ធតែខុសគ្នាលោកចារមក្សេចស្រេច គ្មាននរណាអាចប្រកែកប្រណាំងពុំព្រមទទួលបានឡើយ ។

ខ្ញុំចេញពីព្រះរាជភាំងតាមទ្វារព្រលប់ ចេញហួតឥតមានពេលវិលត្រឡប់មកវិញឡើយ.. ក្នុងភាំងនរណាក៏ដឹងដែរ ឬរឿងហួងទទួចអង្វរឲ្យខ្ញុំនៅភាំង ហើយរឿងនេះវាធ្វើឲ្យខ្ញុំនឹកភ័យព្រួយជាប់ក្នុងចិត្តជានិច្ច ទោះបីខ្ញុំឈប់នៅភាំងហើយក្តី ។ រវេះមួយដឹកអ៊ីវ៉ាន់ឆ្ពោះទៅកាន់ផ្ទះថ្មី នៅក្បែរផ្សារដែលម៉ែទើបទិនឹងជួលបាន ក្រោយពេលលក់ផ្ទះឯកំពង់ផែ ។ បន្ទប់ម៉ែជួលស្ថិតនៅជាន់ខាងលើ ចំណែកឯខ្ញុំម្នាក់ឡោះ សីតរកស៊ីធ្វើជាងកាត់សក់ ជួលនៅជាន់ខាងក្រោមជាមួយប្រពន្ធគាត់ ។ គាត់មានកូនស្រីម្នាក់ឡោះឆ្មារ ដែលខ្ញុំអាចប្រើប្រាស់បានតាមចិត្ត ជាជំនួសកាហ៊ីន ព្រោះ កាហ៊ីន ភ្ញាត្រឡប់ទៅនៅព្រែកថ្មីវិញបាត់ទៅហើយ ។

ខ្ញុំខ្លាចចិត្តក្រែងស្តើរមិនហ៊ានអើតមើលទៅក្រៅតាមមាត់បង្អួចផង ជាពិសេសគូ គាត់លាក់បំបាំងខ្ញុំណាស់ ។

ប៉ុន្តែ មិនបានប៉ុន្មានផង ស្រាប់តែលេចឃើញប្រុសកម្លោះដើរទៅមកប្រសេចប្រសាចតាមផ្លូវ អាអាក្រក់ក៏មាន អាល្អក៏មាន ។ គេចេញចូលឈូឆរឥតដាច់មកឲ្យពរខ្ញុំកាត់សក់ ហើយអ្នកដែលធ្លាប់ស្គាល់ម៉ែបន្តិចបន្តួច ក៏ទំខាក់ទងរាប់អាន ធ្វើឫកជាអាណិត ទិញរបស់របរមកជូនម៉ែជាច្រើយៗ ដែលជាហេតុអាចញ៉ាំងស្ថានភាពគ្រួសារយើង ឲ្យធូរស្រាលបានមួយកំរិតធំ ។ ពេលនោះស្រាប់តែលេចឃើញ នុរ ជា "សម្ភាញ់ អាប៉" របស់នុន ត្រឡប់មកពីបាត់ដំបងវិញ ដឹងថាខ្ញុំឈប់នៅភាំង វាសប្បាយចិត្តរីកមុខប៉ុនចង្កេះ ។

វានិយាយប្រាប់ថា នុន មានប្រពន្ធអ្នកបាត់ដំបង រួចវាលួចសរសេរសំបុត្រទៅប្រាប់នុន ថាកុំឲ្យនឹកមកខ្ញុំធ្វើអ្វី ពីព្រោះបានរៀបចំការនឹងខ្ញុំហើយ ។ អានេះចំជាខ្លួចមែន ! ។

ក្នុងពេលជាមួយគ្នានេះ ក៏មានអ្នកផ្សេងទៀតជាច្រើនចូលមកស្តីដណ្តឹងខ្ញុំដែរ ម្ល៉ោះហើយបរិយាកាសក្នុងគ្រួសារ ប្រែជាអាប់អួរកកផ្លូវដោះស្រាយមិនសូចសោះ ។ យើងមិនដែលហ៊ានចេញដើរទៅណាមកណាឡើយ ដោយខ្លាចពួកកម្លោះឈាមរាវអស់នោះព្រួតគ្នាចាប់ធ្វើបាប ។ ម៉ែតាំយកខ្ញុំមកណាក់នៅផ្ទះបងប្អូនម្នាក់ធ្វើជារាជការហួងនៅក្នុងភាំង ។ គាត់នោះចាស់បន្តិចមែន ប៉ុន្តែប្រពន្ធគាត់នៅក្មេងល្អក់ ឈ្មោះមីងចែម ។ បានមកនៅផ្ទះថ្មីនេះ ខ្ញុំដូចជាធ្លាក្រេងច្រើន ។

មេក្រុមភាំងឈ្មោះ ទុយ ទាំងដឹងពីក្នុងភាំងមកប្រាប់ខ្ញុំដល់ផ្ទះមីងចែម ថាហួងឥតភ្លេចខ្ញុំទេ លោកឧស្សាហ៍សាកសួរគេឯងជារឿយៗពីសុខទុក្ខខ្ញុំ ហើយលោកឆ្ងល់ខ្លាំងណាស់នៅពេលឮគេនិយាយថា ខ្ញុំមិនទាន់មានប្តីនៅឡើយ ។ ថ្ងៃមួយចៅហ្វាយខេត្តម្នាក់ទើបនឹងរៀបការប្រពន្ធហើយថ្មីៗ ទាំគ្នាទៅថ្វាយបង្គំហួងស្រាប់តែលោកនិយាយលេងរៀបកំប្លែងថា បើចង់រកប្រពន្ធ ឲ្យមកជណ្តឹងខ្ញុំវិញ ពីព្រោះ "សាវ៉ាម៉ាន៏" វាក្រហើយកំព្រាឪពុកផង ។ លោកចៅហ្វាយខេត្តប្រហោងពោះធ្លុង ប្រកែកញាប់មាត់ថា គាត់មិនអាចលែងប្រពន្ធដែលទើបនឹងរៀបការនេះបានទេ ។

ក្រោយបន្តិចមកទៀត ម្ចាស់ស្តីវ័រង្ស ក្មួនប្រុសច្បងរបស់ហួង ដែលស្មីខាងខ្លួចវិលរកលេខជាក់គ្មានមួយថ្ងៃៗគិតតែញ៉ែជាមួយ ប្រពន្ធស្តេចឪពុក និង ស្រីបាំអាភាត់អាឃាយនោះ ក៏តាមរកទាល់តែឃើញផ្ទះខ្ញុំដែរ ។ លោកសួរខ្ញុំថា សព្វថ្ងៃរកស៊ីធ្វើការអ្វី ហើយថាលោកចង់ទាំខ្ញុំឲ្យទៅនៅផ្ទះជាមួយលោក ខ្ញុំឆ្លើយថាមិនហ៊ានទៅទេ ពីព្រោះថាលោកមិនមែនជាសាច់ញាតិនឹងខ្ញុំ បើធ្វើល្អនឹងខ្ញុំពេកទៅខ្លាចក្រែងអ្នកផងគេសើច ។ លោកមិនចាំឲ្យខ្ញុំនិយាយបានច្រើនទាន់ ប្រញាប់លាចេញទៅវិញភ្លាម ដោយធ្លៀតញាក់ចិញ្ចើមរបៀបខ្លួចបន្តិចផង ។

ទោះបីម៉ែខំបំរើងជានលាក់បំពួនយ៉ាងណា ក៏ពួកកម្លោះៗតាមរកទាល់តែឃើញ ហើយម្នាក់ៗខិតខំយកចិត្តយកថ្លើមម៉ែតែរៀងខ្លួន ។ នរណាធ្វើអីក៏ធ្វើទៅ នរណានិយាយថាម៉េចក៏ម៉ែចេះតែអ៊ីអើ ប៉ុន្តែគាត់មិនហ៊ានសម្រេចថាលើកខ្ញុំឲ្យទៅនរណាឡើយ ពីព្រោះថាបើឲ្យទៅអ្នកមួយ អ្នកឯទៀតច្រណែនតាមព្យាបាទណាឥតសមិនខាន ។ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំនឹងស្រឡាញ់បុរសណាដែលអាចយកឈ្នះលើតួប្រដែងទាំងអស់បាន, តាល់តែអ្នកដែលមានប្រាជ្ញាឈ្លាសវៃលើសគេ ទើបសមធ្វើជាប្តីខ្ញុំ ។ សភាពល្វីងជូរចត់ នៃ ជីវិត បានធ្វើឲ្យខ្ញុំកើតទុក្ខតប់ប្រមល់ស្គមខ្លួន ឥតស្គាយកាលរស់នៅក្នុងភាំង ព្រោះកាលនោះ សើរភាពខ្ញុំហាក់ដូចជាខ្លួលំខ្លួលាយជាងសព្វថ្ងៃបន្តិច ។

ពេលនោះក្រុមភាំងម្នាក់មកជួបនឹងម៉ែជាថ្មីម្តងទៀត ដើម្បីប្រាប់ថា បើខ្ញុំមិនទាន់មានប្តីទេ ហួងឲ្យហៅខ្ញុំទៅនៅភាំងវិញ លោកសន្យាថានឹងមើលថែទាំខ្ញុំដូចពីដើម ហើយលោកនឹងបំភ្លេចចោលរឿងដែលខ្ញុំគេចឈប់នៅភាំងនេះ ។ ខ្ញុំមិនឆ្លើយថាព្រមឬមិនព្រមទេ ប៉ុន្តែខ្ញុំកាន់តែយល់ច្បាស់ហើយថា ទោះបីអត់ហួន

មានស៊ីយ៉ាងណា ក៏ការរស់នៅរបស់ខ្ញុំសព្វថ្ងៃ វាមានឯករាជ្យភាពពេញលេញហិរញ្ញវត្ថុច្រើនជាងនៅក្នុងភឹងដែរ។

យប់មួយ ខ្ញុំដេកយល់សប្តិឃើញពស់មួយសម្បុរសស្គុស ចេញតាមចីកខ្ញុំជាប់។ ខ្ញុំភ័យភ្ញាក់ដឹងខ្លួន និយាយរឿងនេះប្រាប់មីងចែម ស្រាប់តែគាត់សើចញឹមៗហើយតាយទុកថា ខ្ញុំដល់ពេលដួបតូព្រេងហើយ តូព្រេងនោះជាមនុស្សសម្បុរស។


ចាប់តាំងពីពេលយល់សប្តិនោះមកមិនខាន់បានមួយអាទិត្យផង ថ្ងៃមួយម៉ែនាំទៅលេងផ្ទះសម្លាញ់គាត់ ខ្ញុំក៏ប្រទះឃើញលោក ដែលគ្រាន់តែឃើញភ្លាម ខ្ញុំអាចស្គាល់ភ្លាមថា លោកប្រាកដជាតូនចាក់ឌែលខ្ញុំធ្លាប់ជួបនៅក្នុងភឹងម្តងកាលពីឆ្នាំទៅនោះហើយ។ សម្លាញ់ម៉ែនិយាយប្រាប់គាត់ថា លោកស្រឡាញ់ខ្ញុំ ចង់ចូលស្តីដណ្តឹងរៀបការត្រឹមត្រូវតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ម៉ែនាំយករឿងនេះមកពិគ្រោះជាមួយបងប្អូន គេក៏យល់ស្របទាំងអស់គ្នាព្រមលើកខ្ញុំឲ្យមកតូនចាក់ឌែលឈ្មោះ កម្លោះ ពីព្រោះហេតុការណ៍ទាំងប៉ុន្មានដែលកើតមានក្នុងពេលនេះ វាត្រូវតាមពាក្យទំនាយពីមុនមកឥតខ្ចោះ។

ជាសំណាងល្អ ខ្ញុំបានមកតូប្រសព្វនឹងលោក ដែលជាមនុស្សមានធម៌ជួយស្រោចស្រង់ខ្ញុំឲ្យចាកផុតអស់ទុក្ខវេទនាផងទាំងពួង។ លោកជាអ្នកមានអំណាចលើសគេ ជាអ្នកឈ្នះលើតូប្រជែងទាំងអស់ ដែលបានចូលមកស្តីដណ្តឹងខ្ញុំ!...។

♥ ♥

♥

ដំរឿបចំសំរាប់ដំណើរប្រមាញ់



Eléphants harnachés pour la chasse

កម្លោះ ត្រាបខ្លួនទៅជិតចង្កៀងធ្វើក្អែកមមី ហាក់ដូចជាដោកងុយដោយសារស្តាប់រឿងដ៏ហូរហែដឹងអន្ទាយរបស់ភរិយា។ តុកកែពីរនៅជិមួលផ្ទះ វាមួលឆ្លើយឆ្លងគ្នា... ខាងក្រៅផ្ទះ ស្វឹកឈើបក់រាំតាមកម្លាំងខ្យល់ ប៉ះទង្គិចគ្នាលាន់ឮច្រាវ្យ!

ខ្យល់ជំនោរបក់ទាំសម្លេងពិណពាទ្យនិសែនពិធានលន្ធង់លន្ធោច មកបំពេរបំបោសអង្អែលសង្កាត់កំពង់ផែ ឲ្យគេដេកលក់ស្កាត់ជ្រងំ។ សារ៉ាម៉ាទី ស្ទុះងើបឈរបង្ហាញរាងកាយទន់ល្អតល្វែសមឥតខ្ចោះ ប្រៀបបានកិន្នរីក្នុងរឿងព្រេងបុរាណខ្មែរ ហើយនុតានថា:

~ លោក! ស្លៀកពាក់ឆាប់ឡើង, ពេលនេះជិតពាក់កណ្តាលអាធ្រាត្រទៅហើយ... លោកដួនខ្ញុំទៅមើលពួកក្មេងថ្មីៗវាវ៉ាំម្តងណា!

និយាយរួច នាងបោះដំហានញាប់ស្មេតម្រង់ទៅរកបន្ទប់ទឹកបាំងស្វឹកនៅក្បែរចង្ក្រានបាយ។

ពន្លឺចង្កៀងចាំងចូលព្រាលៗ ស្ទើរងងឹត ស្ទើរភ្លឺ ទៅក្នុងបន្ទប់តូចនេះ ហាក់ដូចជាជួយបិទបាំង ពុំចាំបាច់ឲ្យនាងប្រយ័ត្នប្រយែងខ្លួនប៉ុន្មានឡើយ។ ដៃកាន់ផ្តិលប្រាក់ នាងដងទឹកពីក្នុងពាងមកចាក់បង្ហូរស្រោចស្រពលើដងខ្លួន ហៀរស្រក់ទៅលើក្តារកំរាល ហើយដុះសាប៊ូសព្វសព៌ាង្គកាយយ៉ាងញាប់ដៃ ទំនងជាប្រញាប់ប្រញាល់ស្រោចទឹកម្តងទៀត ដើម្បីលាងសំអាតខ្លួនឲ្យជ្រះសាប៊ូ។

ហ៊ឹងមួយទៅក្រោមផ្ទះ ស្រែកបញ្ចេញក្តីសប្បាយរីករាយ ដោយត្រូវទឹកត្រជាក់ធ្លាក់ទៅលើខ្លួន ហើយសម្លេងមួយទៀតផ្ញើចគ្នាបេះបិត បន្ទំធ្លើយឆ្លងគ្នាចេញពីក្រោមផ្ទះអ្នកជិតខាង... ប្រជៀវហើរឆាបទង្គិចនឹងស្វឹកចេកលាន់ឮស្ងរចម្លែកត្បូរព្រឹក្សាល។

សារ៉ាម៉ាទី ជាក់ផ្តិលទៅលើតម្របពាង ទាញយកសារុងស្ងួតមកផ្ងាស់ ដើម្បីទាញយកសំពត់ទទឹកចេញពីខ្លួន បន្ទាប់មកនាងបើកទ្វារបន្ទប់ទឹកដើរកាត់តាមចង្ក្រានបាយចូលមកក្នុងផ្ទះជិទ្បាញបណ្តើរ ផ្លូតខ្លួនទន់ក្រមាស្ងួតបណ្តើរ:

~ អ្ហ៊ឹយ! អ្ហ៊ឹយ! (នាងនិយាយទាំងរងារញ័ររណ្តំឆ្ងាម) ទឹកត្រជាក់ណាស់លោក! ខ្ញុំស្លៀកសំពត់អីហ៎? មីកាហ្វេ ឆាប់ឡើង, បើកហិបយកសំពត់មកឲ្យអញស្លៀក ហើយយកចង្កៀងចូលក្នុងផ្ទះទៅ!..... ។

~ ចប់ ~

រៀបចំបោះពុម្ពឡើងវិញដោយទស្សនាវដ្តី**អង្គរវត្ត**នៅក្រុងប៉ារីសខែសីហា២០០៥